ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



- អ៊ីស៊ីម គង្វី
- ការពិភាក្សារវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ

[illegible]

លេខ០០៦ ខែមិថុនា ឆ្នាំ២០០០

ស្វែងរកការពិត

ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ១៨ ខែមិថុនា ឆ្នាំ២០០១

# មាតិកា

◆ សំបុត្រៈ ដើម្បីអនាគតកម្ពុជាដ៏រុងរឿង............................. ១

**ផ្នែកឯកសារ**

◆ ប្រវត្តិរូបសង្ខេបៈ អ៊ីស៊ូប គន្ធី........................................... ២

◆ សកម្មភាពមុនពេលចាប់ខ្លួន អ៊ីស៊ូប គន្ធី.............................. ៣

◆ សេចក្តីថ្លែងការណ៍របស់បក្សកុម្មុយនិស្តកម្ពុជា..................... ៨

◆ រណ្តៅសាកសពនៅស្រុកចម្ការលើ................................... ១១

◆ កំណត់ហេតុរបស់កម្មាភិបាលខ្មែរក្រហម............................ ១៥

◆ តួនាទីដែលគួរសង្ស័យរបស់ស្ថានទូតចិន............................. ១៧

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ សម្លេងពីមន្ទីរស-២១................................................. ១៨

◆ សភាយុទ្ធជនបដិវត្តន៍ខ្មែរក្រហម...................................... ២២

◆ រង្វាស់បទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ.......................... ២៥

**ផ្នែកច្បាប់**

◆ តម្លៃនៃភ័ស្តុតាង....................................................... ២៨

◆ ការអនុវត្តច្បាប់ចំពោះករណីខ្មែរក្រហម.............................. ៣៣

◆ភាពខុសគ្នារវាងទួលស្លែង និង ស-២១............................. ៣៥

**វេទិកាពិភាក្សាសាធារណៈ**

◆ជនកុម្មុយនិស្តខ្មែរក្រហមនិងវៀតណាម............................ ៣៦

◆ បក្សកម្មករជប៉ុន......................................................... ៣៨

◆ រឿងរ៉ាវនៃការនាំយកមេដឹកនាំខ្មែរក្រហម.......................... ៣៩

◆ ការពិភាក្សារវាងរាជរដ្ឋាភិបាលកម្ពុជា............................. ៤៤

◆ ទីបញ្ចប់នៃបដិវត្តន៍..................................................... ៥៥

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ ឆ្នបសម័យខ្មែរក្រហម.................................................. ៥៨

**រូបថតឯកសារខ្មែរក្រហមៈ**

◆បញ្ជីវត្តនិងក្រុមគ្រួសារថតក្នុងសម័យខ្មែរក្រហម..............ក្របក្រោ


អៀង សារី

**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃរាជរដ្ឋាភិបាលកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ ០២៩១ពម.៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**(រូបថតក្របមុខផ្តល់ឲ្យដោយ ហូលីយ៉ូ ហេលដឹលជ្រេស)**

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

***វាគ្មិនលេខនេះ*** ចន ឆរឆីអារី, អេលីហ្សាប៊ែត វ៉ាន់ស្កាក់, មិទ្រី មូសយ៉ាកូវ, ដេវីត អាស្លូលី, ដេវីត ឆេនដល័រ, ថូម៉ាស់ ហាម៉ាប៊ឺក, ដេង ពង្សរ៉ាស៊ី, ហ៊ុយ វណ្ណៈ, ប៉ែន យៀវនិន ***អ្នកនិពន្ធនិងស្រាវជ្រាវៈ*** សាន់ កល្យាណ, លី សុផល, ដួង សុភារិទ្ធ ***ជំនួយការនិពន្ធនាយកៈ*** អែម សុខឃីម ***និពន្ធនាយករងទី១ៈ*** ផាត កុសល ***និពន្ធនាយករងទី២ៈ*** សឹម សុរិយ៉ា ***អ្នកបកប្រែៈ*** សួ ប៊ុនស៊ូ ***និពន្ធនាយកទូទៅៈ*** ឆាំង យុ ***ក្រាហ្វិកកុំព្យូទ័រៈ*** ស៊ឹម សុភ័ក្រ្ត, ***គ្រប់គ្រងការចែកផ្សាយៈ*** ទ្រី សុភក្តិ

*សំបុត្រៈ*

# ដើម្បីអនាគតកម្ពុជាដ៏រុងរឿង

មន្ត្រីដែលទទួលបន្ទុកលើការចរចារៀបចំបង្កើតតុលាការកម្រិតអន្តរជាតិមួយដើម្បីវិនិច្ឆ័យទោសមេដឹកនាំខ្មែរក្រហមបានទាញហេតុផលអំពីភាពខ្វះខាតនៃការរីកចម្រើនក្នុងបញ្ហានេះដោយលើកឡើងថា អទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជាគឺការអភិវឌ្ឍសេដ្ឋកិច្ច ។ ខ្ញុំយល់ថាការផ្តោតអារម្មណ៍លើចំណុចនេះគឺផ្តល់នូវផលបញ្រ្ចាសមកវិញទេ ហើយធាតុពិតនោះគឺបន្តធ្វើឲ្យអន្តរាយដល់កិច្ចប្រឹងប្រែងរបស់កម្ពុជាក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ។

ផែនការអភិវឌ្ឍសេដ្ឋកិច្ចនឹងត្រូវរាំងស្ទះនៅក្នុងបរិយាកាសដែលខ្វះតម្លាភាព ការដាក់ឲ្យទទួលខុសត្រូវនិងមូលដ្ឋានច្បាប់ដ៏រឹងមាំ ។ ប្រទេសកម្ពុជាសព្វថ្ងៃនៅកំពុងទទួលរងនូវបរិយាកាសបែបនេះ ។ បញ្ហាទាំងអស់អាចនិយាយដោយខ្លីក្រោមបរិបទ «វប្បធម៌នៃការរួចទោស» ។ គណៈកម្មាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សបានបញ្ជាក់ម្តងហើយ ម្តងទៀតថា ការរំលោភដ៏ធ្ងន់ធ្ងរបំផុតនៅក្នុងប្រវត្តិសាស្រ្តកម្ពុជា គឺជាអំពើរបស់ខ្មែរក្រហម ។ ខ្មែរក្រហមក៏បានបង្កើតឲ្យមានគំរូរួចទោសយ៉ាងអាក្រក់បំផុតនៅក្នុងប្រទេសកម្ពុជា ។ ប្រសិនបើកម្ពុជាខ្វះសុឆន្ទៈក្នុងការដោះស្រាយវប្បធម៌នៃការរួចទោសដែលមិនអាចទទួលយកបាននេះកម្ពុជាអាចនឹងគ្មានការជឿទុកចិត្តពីសំណាក់សហគមន៍អន្តរជាតិនិងក្នុងចំណោមប្រជាជនកម្ពុជារបស់ខ្លួន ។




អនាគតរបស់កម្ពុជាចេះតែបន្តធ្វើជាចំណាប់ខ្មាំងរបស់ខ្មែរក្រហមតទៅទៀត ។ ទោះបីជាខ្មែរក្រហមត្រូវបានវាយសន្ធប់ឲ្យបរាជ័យតាមផ្លូវយោធា និងមិនអាចបង្កការគំរាមកំហែងដល់ប្រជាជនកម្ពុជាថានឹងមានសង្រ្គាមនិងការសម្លាប់ឲ្យផុតពូជយ៉ាងណាក៏ដោយ ក៏ខ្មែរក្រហមនៅតែបន្តជះឥទ្ធិពលនយោបាយប្រែះស៊ីដែកមកលើសង្គមនិងរាជរដ្ឋាភិបាលកម្ពុជា ។ ខ្មែរក្រហមមិនស្ថិតនៅក្នុងអតីតកាលទេ ។ ផ្ទុយមកវិញ សព្វថ្ងៃនេះខ្មែរក្រហមនៅជាប់ជាមួយយើងគ្រប់ៗគ្នា ផ្ទាល់តែម្តង ។

ដរាបណាខ្មែរក្រហមមិនត្រូវបានជម្រះទោសតាមផ្លូវច្បាប់ល្អិកនោះគឺនៅតែមានន័យថាខ្មែរក្រហមមិនត្រូវបានដាក់ឲ្យនៅក្នុងអតីតកាលឡើយ ។ ដំណើរការវិនិច្ឆ័យទោសមេដឹកនាំខ្មែរក្រហមគឺត្រូវតែចាប់ផ្តើមឡើងមុនពេលបោះឆ្នោតឃុំ ដែលហៀបនឹងមកដល់ ។ អ្នកដែលយល់ដល់ទឹកចិត្តប្រជាជនកម្ពុជាអាចនឹងមើលឃើញធាតុពិតនៃឥទ្ធិពលនយោបាយរបស់ខ្មែរក្រហម ថាបានឆក់ប្លន់ឱកាសពីប្រជាជនកម្ពុជាមិនឲ្យកសាងអនាគតភ្លឺស្វាងមួយ ។ ភាពរអាក់រអួលនៃដំណើរការរៀបចំតុលាការគឺបានជួយដល់ខ្មែរក្រហមប៉ុន្តែមិនបានជួយដល់ប្រជាជនកម្ពុជានិងជនរងគ្រោះនៃរបបនេះទេ ។

ប្រសិនបើរាជរដ្ឋាភិបាលកម្ពុជាសង្កត់ធ្ងន់ទៅលើការដាក់ឲ្យមេដឹកនាំខ្មែរក្រហមទទួលខុសត្រូវយ៉ាងម៉ឺងម៉ាត់ ប្រជាជនកម្ពុជានឹងមានជំនឿកាន់តែមុតមាំថា រដ្ឋាភិបាលពិតជាកំពុងធ្វើការដើម្បីការពារផលប្រយោជន៍ឲ្យខ្លួន ដោយយកជ័យជម្នះលើព្រាយបិសាចក្នុងអតីតកាលដ៏ជូរចត់និងកសាងអនាគតដ៏ត្រចះត្រចង់ជាប្រវត្តិសាស្រ្តមួយសម្រាប់ប្រជាជនកម្ពុជា ។ ដោយមានដំហរបែបនេះប្រជាជនកម្ពុជានឹងមានកម្លាំងពេញទំហឹងក្នុងការអភិវឌ្ឍប្រទេសជាតិឲ្យបានរុងរឿង ។ **ឆាំង យុ**



## ប្រវត្តិរូបសង្ខេបៈ អ៊ីស៊ូប គន្ធី

◆ឈ្មោះដើម អ៊ីស៊ូប គន្ធី ឈ្មោះប្រែ(បដិវត្ត) យឹម ។

◆ថ្ងៃខែឆ្នាំកំណើតៈ កើតនៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ១៩២៩ ។

◆ទីលំនៅកំណើតៈ ក្រុងភ្នំពេញ (សង្កាត់លេខ៤) ។

◆ឪពុកឈ្មោះ អាម៉េដ គន្ធី សញ្ជាតិ ឥណ្ឌា ។

◆ម្តាយឈ្មោះៈ ហ្វាទីម៉ា សាដេក សញ្ជាតិកម្ពុជា (ខ្មែរ ឥស្លាម) ។

◆មុខងារនិងតួនាទីៈ ទូតស្រុកបារាំង ។

◆រៀបការឆ្នាំ១៩៤៩ នៅខុដុង្គជាមួយនារីម្នាក់ឈ្មោះ សួន ម៉ាលីស កើតនៅឆ្នាំ១៩៣៤ ។ មុនថ្ងៃទី១៧ ខែមេសា ឆ្នាំ ១៩៧៥ សួន ម៉ាលីស រស់នៅទីក្រុងភ្នំពេញ ។ បន្ទាប់មក អ៊ីស៊ូប គន្ធី បានលែងលះជាមួយ សួន ម៉ាលីសហើយរៀបការ ម្តងទៀតជាមួយ នរោត្តម ស៊ីថារង្សី ក្នុងឆ្នាំ១៩៥៥ នៅ ទីក្រុងភ្នំពេញ (សង្កាត់លេខ៣) ។ នរោត្តម ស៊ីថារង្សី កើតនៅ ឆ្នាំ១៩២៥ ។

### អ៊ីស៊ូប គន្ធី មានកូន៦នាក់ៈ

◆មារីយ៉ែត គន្ធី អាយុ២៦ឆ្នាំ កើតនៅភ្នំពេញ ។ មុនថ្ងៃ ទី១៧ មេសា ឆ្នាំ១៩៧៥ មានទីលំនៅនៅភ្នំពេញ ។ បច្ចុប្បន្ន មិនដឹងនាងស្ថិតនៅទីណាទេ ។

◆ព្យែរ គន្ធី អាយុ២៥ឆ្នាំ កើតនៅភ្នំពេញ(សង្កាត់ លេខ៤) មានទីលំនៅនៅប្រទេសបារាំង ជានិស្សិត ។

◆មារីយ៉ាន គន្ធី អាយុ២១ឆ្នាំ កើតនៅភ្នំពេញ (សង្កាត់ លេខ៤) មានទីលំនៅនៅភ្នំពេញ កាលពីមុនថ្ងៃ១៧ ខែមេសា ១៩៧៥ ។ បច្ចុប្បន្នមិនដឹងនាងស្ថិតនៅទីណាទេ ។

◆ចន្ទ្រា គន្ធី អាយុ២០ឆ្នាំ កើតនៅភ្នំពេញ (សង្កាត់ លេខ៤) ជានិស្សិត មានទីលំនៅនៅប្រទេសបារាំង ។

◆ភក្ត្រម៉ូរ៉ូ គន្ធី អាយុ១៧ឆ្នាំ កើតនៅក្រុងភ្នំពេញ (សង្កាត់លេខ៤) ជានិស្សិតមានទីលំនៅនៅប្រទេសបារាំង ។

◆ធិសារី គន្ធី អាយុ១៦ឆ្នាំ កើតនៅក្រុងភ្នំពេញ (សង្កាត់ លេខ៣) ជានិស្សិតមានទីលំនៅនៅប្រទេសបារាំង ។

អ៊ីស៊ូប គន្ធី ត្រូវបានអង្គការឃាត់ខ្លួននៅថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៦ ។

### ឈ្មោះអ្នកដែលពាក់ព័ន្ធ និងអ្នករួមការងារ

◆ចាន់ថា ៈ លេខាស្ថានទូតកម្ពុជាប្រចាំទីក្រុងដាអេសសាឡាម ។

◆ឡុង បូរ៉េតៈ ប្រធានទីភ្នាក់ងារសារពត៌មាន អាកាប៉េ ។

◆សុង សាក់ៈ ភ្នាក់ងារ សេ.អ៊ី.អា និងជាឈ្មួញរូបិយវត្ថុ ។

◆នារី សរ សៅរ័ត្នៈ លេខាផ្ទាល់ខ្លួនរបស់អគ្គមហេសី សម្តេចសីហនុ ។

◆ងួន ឆាយគ្រីៈ អគ្គលេខាធិការក្រសួងការបទេស ។

◆យ៉ែម សារ៉ុង ឯកអគ្គរដ្ឋទូតរបស់ លន់ ណុល ប្រចាំ នៅប្រទេសស៊ីស ។

◆ស៊ុម វឌ្ឍនយ៉ាៈ ជាទន្តពេទ្យនិងជាមិត្តរបស់ លន់ ណុល ។

◆ហួត សម្បត្តិៈ ទូតប្រចាំប្រទេសយូហ្គោស្លាវី ។

◆បែម ស្ងួនៈ សមាជិកមន្ទីរក-១៧ បឹងត្របែក ។

◆ប៉ែន ញ៉ាចៈ សមាជិកមន្ទីរក-១៧ បឹងត្របែក ។

◆អ៊ុង មាងៈ អ្នកបើករថយន្តឲ្យសម្តេច សីហនុ ។

◆សួង ស៊ីគឿនៈ បម្រើការនៅក្រសួងការបរទេស ។

◆នុត ឈឿមៈ ការិយាល័យនៅប៉េកាំង, ហោ ណាំហុង, ឡុង ណូរិន, ជួន មុម្ម, ជួន ប្រាសិទ្ធ, ឌិក សាគុន, អ៊ិន សូកាន, អ៊ិន សុភាព (បងប្អូន អ៊ិន សូកាន) ប៉ិច ប៊ុនរ៉េត, ឡាយនី, នូ ប៉ិច, គាត ឈន់, អ៊ិត សួង, អៀង សារី, ខៀវ សំផន, ចៅ សេង,អៀង គុនសាគី, សឺន សាន, កែ មាស, និន និរ៉ុម, សួស ម៉ារីន,គីម ស្រ៊ុន និង ពុង ប៉េងចេង ។

**(ឯកសារលេខ TSL Y146)**

# សកម្មភាពការងារមុនពេលចាប់ខ្លួន អ៊ីស៊ូប គន្ធី

**(ឯកសារលេខ TSL Y146)**

មុនការកើតឡើងនៃរបបខ្មែរក្រហម អ៊ីស៊ូប គន្ធី ធ្វើជានាយកទីភ្នាក់ងារព័ត៌មានខ្មែរ នៅក្រសួងឃោសនាការភ្នំពេញ ។ ក្រោយមកត្រូវបានចាត់តាំងឲ្យធ្វើជាឯកអគ្គរដ្ឋទូតប្រចាំប្រទេសស៊ុយអែដ (Sweden) ។ នៅពេលដែលប្រទេសជាតិធ្លាក់ក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម(កម្ពុជាប្រជាធិបតេយ្យ) អ៊ីស៊ូប គន្ធី ត្រូវបានអង្គការខ្មែរក្រហមចាប់ខ្លួនដោយចោទថា ជាភ្នាក់ងារ កា.ហ្សេ.បេរបស់សូវៀត ដែលមានបំណងផ្តួលរំលំរបបកម្ពុជាប្រជាធិបតេយ្យ ។ ឯកសារចម្លើយសារភាពរបស់ អ៊ីស៊ូប គន្ធី មានចំនួន១៨៥ទំព័រ សរសេរជាភាសាបារាំង ក្នុងនោះមានវាយអង្គុលីលេខជាអក្សរខ្មែរមួយច្បាប់និងអក្សរខ្មែរសរសេរដោយដៃផ្ទាល់របស់អ្នកទោសមានចំនួន៤ទំព័រដែរ ។ ឯកសារបានឲ្យដឹងថា៖

### ១) សកម្មភាពការងារ

កាលពីឆ្នាំ១៩៤៧ អ៊ីស៊ូប គន្ធី ធ្លាប់បានចូលព្រះរាជដំណាក់របស់សម្តេច សីហនុ ដើម្បីរៀនជិះសេះ ។ ការចូលរាជវាំងជាញឹកញាប់បែបនេះធ្វើឲ្យ អ៊ីស៊ូប គន្ធី បានទទួលតំណែងជានាយប៉ូលិសជាតិក្រោមបង្គាប់ លន់ ណុល ហើយក្រោយមកក៏ក្លាយជាអ្នកប្រឆាំងកុម្មុយនិស្តម្នាក់ ។ ចាប់តាំងពីពេលនោះ អ៊ីស៊ូប គន្ធី ចូលរួមប្រតិបត្តិការជាមួយភ្នាក់ងារសន្តិសុខសហព័ន្ធ (គិញ) ដើម្បីស្វែងរកពួកឥស្សរៈ ។ ក្រៅពីនោះបានចូលរួមធ្វើសកម្មភាពផ្សេងៗក្រោមការចាត់តាំងរបស់ ឈុំ ឈាត និង ឯក មូល ដើម្បីប្រឆាំងនឹងក្រុមរបស់ ភោគ ឆាយ នៅភូមិផ្សេងៗរួមមានភូមិស្ទឹងមានជ័យ ខដុង្គ និងកំពង់កន្ទួត ហើយនិងដើរស៊ើបរកជនជាតិវៀតណាមដែលជាប់ពិរុទ្ធ ។

ឆ្នាំ១៩៥១ អ៊ីស៊ូប គន្ធី បានអមដំណើរ លន់ ណុល នៅក្នុងបេសកកម្មតាមបឹងទន្លេសាបនិងកំពង់ចាម ជាមួយនឹងប៉ូលិសជាច្រើននាក់ទៀត ដើម្បីធ្វើការត្រួតពិនិត្យជាទូទៅមួយ ។ លន់ ណុល បាននិយាយថា “ពួកវៀតមិញធ្វើសហប្រតិបត្តិការនៅក្នុងតំបន់នេះ” ហើយ លន់ ណុល បានចាត់ទុកពួកខ្មែរឥស្សរៈក៏ដូចពួកវៀតមិញដែរ ។ ក្រៅពីការបំពេញបេសកកម្មដឹកម្រមាននេះ អ៊ីស៊ូប គន្ធី បានទទួលរ៉ាប់រងការងារខាងដើរល្បាតនៅពេលយប់និងកិច្ចការអចិន្ត្រៃយ៍ នៅក្នុងអគារផ្នែកសន្តិសុខ ។

ប្រហែលជានៅខែសីហា ឆ្នាំ១៩៥១រហូតដល់ដើមឆ្នាំ១៩៥៣ អ៊ីស៊ូប គន្ធី បានទៅធ្វើកម្មសិក្សាមួយខាងការជិះសេះ (ទ័ពសេះ) នៅស្រុកបារាំង ។ នៅពេលត្រឡប់មកវិញត្រូវបានតែងតាំងជាអធិការប៉ូលិសនៅខេត្តតាកែវ (ក្រោមបង្គាប់របស់ ជិនបូរ ដែលមានឋានៈជាស្នងការខេត្ត) ទទួលមុខងារផ្នែកប្រមូលព័ត៌មាន ។ ខណៈនោះ ព្រះអង្គម្ចាស់ នរោត្តម វិរិយ៉ា ដែលត្រូវជាបងប្អូនជីដូនមួយសម្តេច សីហនុ គឺជាអគ្គនាយកប៉ូលិសជាតិ ។ ខែកក្កដា ឆ្នាំ១៩៥៣ អ៊ីស៊ូប គន្ធី បានទទួលតំណែងជាអនុប្រធានស្នងការផ្នែកសន្តិសុខខេត្តកំពត ដែលមានឈ្មោះ គួច ឡង់ ជាចៅហ្វាយ ។ អ៊ីស៊ូប គន្ធី បានសរសេរចុះផ្សាយក្នុងព្រឹត្តិប័ត្រប៉ូលិសនូវព័ត៌មានស្តីពីវត្តមានចលនាពួកខ្មែរឥស្សរៈនៅក្នុងតំបន់នោះ ។

នៅក្នុងសន្និសីទទីក្រុងហ្សឺណែវដែលរៀបចំឡើងតាមសំណើរបស់សម្តេច សីហនុ នៅឆ្នាំ១៩៥៤ អ៊ីស៊ូប គន្ធី បានចូលរួមការពារទីក្រុងភ្នំពេញ រារាំងមិនឲ្យខ្មែរក្រហមវាយដណ្តើមយកអំណាចបានដោយជោគជ័យ ។ គាត់បានត្រឡប់មកភ្នំពេញវិញនៅខែកក្កដា ហើយមកធ្វើការនៅនរគបាលជាតិទទួលភារកិច្ចជាអ្នកសរសេររបាយការណ៍ផ្សេងៗអំពីការចុះចូលរបស់ខ្មែរក្រហមដែលគ្មានអាវុធ (អ្នកទាំងនេះត្រូវអាជ្ញាធរយោធារបស់ លន់ ណុល សម្លាប់យ៉ាងរង្គាល) ។ ក្រោយមក អ៊ីស៊ូប គន្ធី បានមកធ្វើអ្នកត្រួតពិនិត្យលិខិតឆ្លងដែននៅអាកាសយានដ្ឋានពោធិចិនតុងអស់រយៈពេល៧ខែ ។

ដើម្បីបញ្ចៀសកុំឲ្យបក្សកុម្មុយនិស្តកម្ពុជាទទួលជ័យជម្នះក្នុងពេលបោះឆ្នោតឆ្នាំ១៩៥៥ ដែលរៀបចំឡើងស្របពេលជាមួយគ្នានឹងការបើកប្រជុំសន្និសីទក្រុងហ្សឺណែវឆ្នាំ១៩៥៤ អ៊ីស៊ូប គន្ធី បានជំរុញឲ្យសម្តេច សីហនុ ដាក់រាជ្យ ដើម្បីបង្កើតគណបក្សនយោបាយមួយគឺសង្គមរាស្ត្រនិយម ។ គាត់បានចោទប្រកាន់ខ្មែរក្រហមថាមិនធ្វើខ្លួនឲ្យឯករាជ្យពីពួកវៀតមិញ ហើយ

ចង់ដាក់ប្រទេសកម្ពុជាឲ្យស្ថិតនៅក្រោមអំណាចរបស់ហូជីមិញ ដោយសារតែមានអត្ថិភាពនៃបក្សកុម្មុយនិស្តឥណ្ឌូចិន ។ នៅពេលដែលសម្តេច សីហនុ និងគណបក្សរបស់ព្រះអង្គទទួលបានជោគជ័យក្នុងការបោះឆ្នោតបំបាក់មុខគណបក្សកុម្មុយនិស្តដែលជាគណបក្សមួយមានឧត្តមគតិបរិសុទ្ធជាងគេនោះ អ៊ីស៊ូប គន្ធី ក៏បានផ្ញើលិខិតអបអរសាទរសើរមួយច្បាប់ថ្វាយសម្តេច សីហនុ ដើម្បីសម្តែងនូវការសប្បាយរីករាយចំពោះជ័យជម្នះនេះដែរ ។

ឆ្នាំ១៩៥៥-១៩៥៨ អ៊ីស៊ូប គន្ធី បានទៅសិក្សានៅសាលាជាតិរដ្ឋបាលអស់រយៈពេល៣ឆ្នាំនៅប្រទេសបារាំង ដែលជាសាលាក្របខ័ណ្ឌ បណ្តុះបណ្តាលវណ្ណៈគហបតីនិងពួកបច្ចេកាធិបតេយ្យឲ្យចេះកេងប្រវ័ញ្ចនិងជិះជាន់ប្រជាជនតូចតាច ។ ខែតុលា ឆ្នាំ១៩៥៨ អ៊ីស៊ូប គន្ធី បានវិលត្រឡប់មកភ្នំពេញវិញ បម្រើការនៅប៉ូលិសយុត្តិធម៌មួយរយៈ ហើយក៏បានចាកចេញពីអាជីពនេះស្វែងរកការងារផ្សេងទៀត ។ អ៊ីស៊ូប គន្ធី ចាប់ផ្តើមទាក់ទង ឡុង បូរ៉េត ដែលជាម្ចាស់រោងពុម្ពកាសែតមួយឈ្មោះ អេកូនៅក្រុងភ្នំពេញ ។ កាសែតនេះបានទទួលជំនួយពីស្ថានទូតអាមេរិកាំង ។ ឡុង បូរ៉េត ជាមនុស្សប្រឆាំងនឹងខ្មែរក្រហម ។ អ៊ីស៊ូប គន្ធី បានសរសេរអត្ថបទជាច្រើនបរិហារក្រុមខ្មែរក្រហមថា មានបំណងបំផ្លាញឯករាជ្យអព្យាក្រឹតភាពរបស់កម្ពុជា ។ ជារង្វាន់លួងចិត្ត អ៊ីស៊ូប គន្ធី បានឡើងតំណែងជាប្រធានទីភ្នាក់ងារព័ត៌មានខ្មែរអា.កា.ប៉េ ក្រោមចំណុះក្រសួងឃោសនាការ ។ ក្នុងតួនាទីជាប្រធានអា.កា.ប៉េ អ៊ីស៊ូប គន្ធី បានទាក់ទងជាមួយតំណាងនៃទីភ្នាក់ងារព័ត៌មានផ្សេងៗរបស់អាមេរិកាំង ជាអាទិ៍មាន យូ.ភី.អាយ និង អេ.ភី ហើយបានបម្រើផលប្រយោជន៍លោក វ៉ាតាណូវ ទទួលបន្ទុកផ្នែកព័ត៌មាននៅស្ថានទូតសូវៀតទៀតផង ។ វ៉ាតាណូវ ដែលជាលេខាធិការទី១របស់ស្ថានទូតសូវៀតប្រចាំនៅកម្ពុជាបានមកទាក់ទង អ៊ីស៊ូប គន្ធី ឲ្យចុះផ្សាយព័ត៌មានស្តីអំពីការលូតលាស់ផ្នែកឧស្សាហកម្មសូវៀត ។

នៅខែសីហា ឆ្នាំ១៩៦០ អ៊ីស៊ូប គន្ធី បានត្រឡប់ទៅប្រទេសបារាំងវិញ ត្រៀមរៀបចំប្រឡងយកសញ្ញាប័ត្រនៅវិទ្យាស្ថានស្រាវជ្រាវផ្នែកនយោបាយនៅទីក្រុងហ្ក្រឺណូប(ប្រទេសបារាំង) ជាមួយអាហារូបករណ៍មួយរបស់គណៈបក្សសង្គមរាស្ត្រនិយម ។ ដូច្នេះការទាក់ទងគ្នាជាមួយ វ៉ាតាណូវ ត្រូវផ្អាកមួយរយៈ ។ នៅវិទ្យាស្ថាននេះ អ៊ីស៊ូប គន្ធី បានសិក្សាស្រាវជ្រាវដោយមានរួមបញ្ចូលគ្នានូវទស្សនៈរបស់ពួកអាណានិគមបារាំងនិងពួកចក្រពត្តិអាមេរិកាំងស្តីពីខ្មែរក្រហម ដោយចោទថា ខ្មែរក្រហមចាត់ទុកហូជីមិញជាបិតារបស់ខ្លួន ។

ខែសីហា ឆ្នាំ១៩៦២ អ៊ីស៊ូប គន្ធី បានមកដល់ភ្នំពេញ ចាប់ផ្តើមពង្រីកការទាក់ទងជាមួយ ចន្ទរង្សី (ជាមនុស្សស្និទ្ធរបស់អាមេរិកាំង) ដែលជាបងថ្លៃរបស់ខ្លួន ។ ចន្ទរង្សី បានខំប្រឹងធ្វើការបំផ្លិចបំផ្លាញនយោបាយរបស់សម្តេច សីហនុ ដោយរៀបចំបង្កើតបនល្បែងស៊ីសងជាច្រើន ដើម្បីឲ្យមន្ត្រីរាជការភ្នាក់ងារប៉ូលិសទាំងអស់ក្លាយទៅជាមនុស្សចេះស៊ីសំណូក ។ ចន្ទរង្សី គឺជាអ្នកប្រឆាំងខ្មែរក្រហម ពីព្រោះពួកខ្មែរក្រហមជាឧបសគ្គមួយចំពោះនយោបាយធ្វើឲ្យសង្គមពុករលួយរបស់គាត់រាំងស្ទះ ។ ប៉ុន្តែគាត់ជាមនុស្សរបស់ លន់ ណុល ដោយហេតុថាប្រពន្ធគាត់ជាសាច់ញាតិខាងគ្រួសារ លន់ ណុល ។ លន់ ណុល នេះហើយដែលជាអ្នកស្នើសុំសម្តេច សីហនុ ឲ្យដោះលែង ចន្ទរង្សី ។ ចន្ទរង្សី ជា អ្នកផ្តើមគំនិតឲ្យ អ៊ីស៊ូប គន្ធី ទៅធ្វើការនៅស្ថានទូតសហរដ្ឋអាមេរិកក្នុងឋានៈជាភ្នាក់ងារសេ.អ៊ី.អា ហើយត្រូវបានឈ្មោះ អានជីសុន បណ្តុះបណ្តាលឲ្យទៅជាភ្នាក់ងារនៅឆ្នាំ១៩៦៣ ។

នៅឆ្នាំ១៩៦៣ អ៊ីស៊ូប គន្ធី សរសេរអត្ថបទមួយចុះផ្សាយក្នុងកាសែត les réalités cambodgiennes ស្តីពីវិបត្តិសេដ្ឋកិច្ចនៅប្រទេសកម្ពុជា បណ្តាលមកពីនយោបាយរបស់សម្តេច សីហនុ ដែលចង់ធ្វើការសម្របសម្រួលជាមួយពួកខ្មែរក្រហមនិងស្តីពីការធ្វើជាតូបនីយកម្ម(ការធ្វើជាតូបនីយកម្មគឺរាំងមិនឲ្យមានសេរីភាពក្នុងការធ្វើពាណិជ្ជកម្មនិងបំផ្លាញរបបសេដ្ឋកិច្ចសេរី) ធនាគារនានា និងក្រុមហ៊ុនអាហារ័ណ-នីហារ័ណ ។ អ៊ីស៊ូប គន្ធី បានជំរុញភ្នាក់ងារប៉ូលិសសេដ្ឋកិច្ចឈ្មោះ សួស ម៉ារីន (ធ្វើការផ្នែកពាណិជ្ជកម្មក្រៅប្រទេស) ឲ្យធ្វើរបាយការណ៍មិនពិត ដោយចោទ ខៀវ សំផន ថាបានបោកបញ្ឆោតប្រជាជនតាមរយៈសេចក្តីទៀងត្រង់របស់គាត់ ។ ការចោទប្រកាន់នេះគឺដើម្បីឲ្យសម្តេច សីហនុ មានមូលហេតុមួយបញ្ឈប់ ខៀវ សំផន ចេញពីមុខតំណែងជារដ្ឋមន្ត្រី ។

នៅខែតុលា ឆ្នាំ១៩៦៣ អ៊ីស៊ូប គន្ធី បានត្រូវតែងតាំងជាលេខាធិការផ្នែកកិច្ចការបរទេសនៅក្រសួងការបរទេស និងទទួលតំណែងជាប្រធានការិយាល័យផ្នែករៀបចំសន្និសីទថែមទៀត ។ អ្នកការទូតខ្មែរដែលនៅក្រសួងនោះភាគច្រើនសុទ្ធតែជាមនុស្សស្និទ្ធអាមេរិកាំង ហើយប្រឆាំងនឹងខ្មែរក្រហម ។ រាល់បាតុកម្មប្រឆាំងអាមេរិកាំងមន្ត្រីបុគ្គលិកនៅក្រសួងការបរទេសទាំងអស់ធ្វើសកម្មភាពតែរូបភាពប៉ុណ្ណោះ ។ អ៊ីស៊ូប គន្ធី បានភ្ជាប់ចំណងមិត្តភាពជាមួយជនជាតិកូរ៉េខាងត្បូងម្នាក់ឈ្មោះ ហុង ដែលជាអគ្គកុងស៊ុលប្រទេសនេះ ។ បន្ទាប់មកបានចងសម្ព័ន្ធភាពជាមួយឯកអគ្គរដ្ឋទូតឥណ្ឌូនេស៊ីដែលជាមនុស្សរបស់ ស៊ូហាតូ ហើយក៏ជាអ្នកដែលប្រឆាំងកុម្មុយនិស្តម្នាក់ដែរ ។ នៅឆ្នាំ១៩៦៥ អ៊ីស៊ូប គន្ធី បានចងសម្ព័ន្ធភាពជាមួយ ដឹឡារ៉ូហ្សា ជាឯកអគ្គរដ្ឋទូតហ្វីលីពីន ហើយធ្វើសកម្មភាពប្រឆាំងកុម្មុយនិស្តជាមួយគ្នាឡើងវិញ ។ ចំពោះអាមេរិកាំង អ៊ីស៊ូប គន្ធី ធ្លាប់បានជួយសម្រួលក្នុងការរៀបចំសន្និសីទមួយនៃក្រុម *Quakers* នៅសៀមរាបដោយសម្រេចបានជោគជ័យ ។ សឺន សាន (ទីប្រឹក្សារបស់សម្តេចសីហនុ) ក៏ជាមនុស្សប្រឆាំងខ្មែរក្រហមម្នាក់ដែរ ។ ហេតុនេះបានជា អ៊ីស៊ូប គន្ធី សម្រេចចិត្តទាក់ទង សឺន សាន រួមគ្នាតស៊ូប្រឆាំងនឹង ហ៊ូ នឹម, ហ៊ូ យន់, ខៀវ សំផន(តំណាងរាស្ត្រ) ព្រោះអ្នកទាំងបីនាក់បានជំទាស់នឹងការសុំចូលជាសមាជិកធនាគារអភិវឌ្ឍអាស៊ី (ដើម្បីទទួលជំនួយពីធនាគារនេះយកមកកសាងទំនប់ទឹកព្រែកត្នោត) ដោយលើកហេតុផលថាជាធនាគាររបស់អាមេរិកាំងឥណទានរបស់ធនាគារគឺដូចជាផ្តល់ទៅឲ្យពួក សេ.អ៊ី.អា អ៊ីចឹង ។

នៅឆ្នាំ១៩៦៣ អ៊ីស៊ូប គន្ធី បានទៅបង្ហាញខ្លួននៅស្ថានទូតសហរដ្ឋអាមេរិកប្រចាំទីក្រុងភ្នំពេញ សុំអាហារូបករណ៍មួយទៅសិក្សាសហរដ្ឋអាមេរិកដើម្បីយកសញ្ញាប័ត្រ«បរិញ្ញាទោផ្នែកមនុស្សសាស្ត្រ» ។ អាន់ដឺសុន ប្រធានផ្នែកវប្បធម៌ជាអ្នកទទួល អ៊ីស៊ូប គន្ធី ។ អាន់ដឺសុន បានបង្រៀន អ៊ីស៊ូប គន្ធី នូវមេរៀនជាច្រើនស្តីពីរបៀបយកការណ៍របស់ក្រុមសេ.អ៊ី.អា សម្រាប់ធ្វើការឲ្យស្ថានទូតអាមេរិកប្រចាំនៅក្រុងភ្នំពេញ ។ មេរៀនទាំងអស់មានចំនួន ១០ និយាយពីរបៀបជ្រើសរើសពត៌មាន នយោបាយអាមេរិកាំងនៅអាស៊ី-អគ្នេយ៍ របៀបប្រើចិត្តសាស្ត្រជាមួយអ្នកនៅជុំវិញខ្លួនការសិក្សាស្រាវជ្រាវអំពីនយោបាយរបស់ប្រទេសនិងវិច្ឆេទកម្មនយោបាយ ។ អ៊ីស៊ូប គន្ធី ចាប់ផ្តើមបំពេញការងារនៅក្រសួងការបរទេសនៅដើមឆ្នាំ១៩៦៤ ដោយបានទទួលប្រាប់ឧបត្ថម្ភ ៥ពាន់រៀលក្នុងមួយខែពី អាន់ដឺសុន ។ ដោយសារនយោបាយប្រឆាំងចក្រពត្តិអាមេរិករបស់សម្តេច សីហនុ ធ្វើឲ្យទំនាក់ទំនងរវាងសហរដ្ឋអាមេរិកនិងកម្ពុជាធ្លាក់ចុះជាបន្តបន្ទាប់ ។ អ៊ីស៊ូប គន្ធី ក៏បានចូលរួមធ្វើបាតុកម្មប្រឆាំងអាមេរិកាំងជាមួយបុគ្គលិកទាំងអស់របស់ក្រសួងការបទេស ។

ឆ្នាំ១៩៦៥ អ៊ីស៊ូប គន្ធី និង វ៉ាតាណូវ ចាប់ផ្តើមទាក់ទងគ្នាឡើងវិញ ។ នៅខែ៧ អ៊ីស៊ូប គន្ធី ត្រូវបាន វ៉ាតាណូវ ចាប់ផ្តើមអប់រំឲ្យធ្វើជាភ្នាក់ងារកា.ហ្សេ.បេបម្រើនយោបាយសូវៀត ។ មុនពេលចូលធ្វើជាភ្នាក់ងារកា.ហ្សេ.បេ អ៊ីស៊ូប គន្ធី ត្រូវទៅរៀនទ្រឹស្តីនយោបាយនិងរបៀបយកពត៌មានរយៈពេលបីខែ (មួយសប្តាហ៍ម្តង) នៅស្ថានទូតសូវៀត ។ ក្នុងរយៈពេលនោះ អ៊ីស៊ូប គន្ធី បានរាយការណ៍ឲ្យវ៉ាតាណូវ អំពីទស្សនកិច្ចរបស់ ម៉ែម៉ាន់ ហៀល នៅកម្ពុជាអំពីជំហររាជរដ្ឋាភិបាលកម្ពុជាចំពោះបញ្ហាទំនាស់ចិន-សូវៀត ។ ក្នុងនាមជាអ្នកទទួលខុសត្រូវផ្នែកកិច្ចការអន្តរជាតិ អ៊ីស៊ូប គន្ធី ក៏បានឡើងជួយតវ៉ាឲ្យសូវៀតបានចូលរួមក្នុងសន្និសីទអាហ្វ្រិក-អាស៊ី ។ វ៉ាតាណូវ បានចាត់លេខាធិការទី១ម្នាក់សម្រាប់ទំនាក់ទំនងជាមួយ អ៊ីស៊ូប គន្ធី ហើយថែមទាំងផ្តល់ជាវត្ថុវ៉ាន់លើការងារផ្សេងៗតាមតែ អ៊ីស៊ូប គន្ធី ត្រូវការ ។ ចំនួនទឹកប្រាក់ដែល អ៊ីស៊ូប គន្ធី បានទទួលជាបន្តបន្ទាប់ សរុបទាំងអស់ ២ពាន់ដុល្លារសហរដ្ឋអាមេរិក ។ ក្រោយមក អ៊ីស៊ូប គន្ធី ត្រូវបានតែងតាំងជានាយករងទទួលបន្ទុកចូលរួមសន្និសីទអន្តរជាតិនានាមហាសន្និបាតអង្គការសហប្រជាជាតិនិងស្ថាប័នឯកទេសផ្សេងៗ ។ ដោយសារភាពធំដុំនៃមុខងារ អ៊ីស៊ូប គន្ធី បានផ្តើមទំនាក់ទំនងការងារជាមួយឯកអគ្គរដ្ឋទូតហ្វីលីពីន គឺ ដឹឡា រ៉ូហ្សា ។ អ៊ីស៊ូប គន្ធី បានប្រាប់លោក ដឹឡារ៉ូហ្សា ឲ្យដឹងអំពីការតម្រង់នយោបាយបរទេសរបស់សម្តេច សីហនុ ដែលមានលក្ខណៈស្និទ្ធវៀតណាមប្រឆាំងនឹងចក្រពត្តិអាមេរិក ។ សម្តេច សីហនុ ទ្រង់ជាអ្នកដឹកនាំនយោបាយបរទេសដោយផ្ទាល់ព្រះអង្គ ។

ខែធ្នូ ឆ្នាំ១៩៦៦ អ៊ីស៊ូប គន្ធី បានត្រូវចាត់តាំងជាសមាជិក

គណៈប្រតិភូកម្ពុជាទៅចូលរួមសន្និសីទស្តីពីរដ្ឋបាលសាធារណៈនៅទីក្រុងតេអេរ៉ង់ ។ សន្និសីទនេះឧបត្ថម្ភដោយរដ្ឋាភិបាលហ្វីលីពីន ។ សម្រាប់ការចេញដំណើរនេះ អ៊ីស៊ូប គន្ធី បានទទួលប្រាក់៥០០ ដុល្លារពី ជីឡារ៉ូហ្សា ។ គឹម សុន ដែលជាមនុស្សរបស់ទ្រង់សិរិមតៈទៅចូលរួមដែរ ។

អ៊ីស៊ូប គន្ធី ធ្លាប់បានទៅលេងផ្ទះទ្រង់សិរិមតៈជាញឹកញាប់ ដើម្បីបង្ហាញឲ្យឃើញនូវការគោរពរបស់ខ្លួនចំពោះព្រះអង្គ ហើយក៏ជាឥរិយាបថស្តែងចេញពីគំនិតប្រឆាំងកុម្មុយនិស្តនិងប្រឆាំងខ្មែរក្រហមដែរ ។ អ៊ីស៊ូប គន្ធី បានផ្ញើសារទូរលេខមួយច្បាប់គាំទ្រជ័យជម្នះរបស់ លន់ ណុល និងពួកក្បត់ផ្សេងទៀត បន្ទាប់ពីរដ្ឋប្រហារនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ។ ការដែល អ៊ីស៊ូប គន្ធី ជឿទៅលើការឃោសនារបស់ លន់ ណុល និងចក្រពត្តិនិយមអាមេរិកាំង គឺនៅត្រង់ចំណុចថា វៀតណាមខាងជើងបានប្រព្រឹត្តការឈ្លានពានមួយប្រឆាំងនឹងប្រជាជននិងប្រទេសកម្ពុជា ។ អ៊ីស៊ូប គន្ធី បានធ្វើសកម្មភាពយ៉ាងច្រើនជាមួយលោកឯកអគ្គរដ្ឋទូត កែម មីរ៉ុម ដែលប្រឆាំងនឹងសម្តេចសីហនុ ហើយដែលចោទប្រកាន់ព្រះអង្គថាបានលក់ផ្នែកមួយនៃទឹកដីទៅឲ្យវៀតកុង មិនតែប៉ុណ្ណោះ បានវាយប្រហារនៅក្នុងសន្និសីទកាសែតមួយថា សម្តេច សីហនុ ជាជនក្បត់ជាតិ ។

នៅឆ្នាំ១៩៦៧ អ៊ីស៊ូប គន្ធី បានចូលខ្លួនធ្វើជាអ្នកសម្រួលសុំឲ្យប្រទេសកម្ពុជាចូលជាសមាជិកធនាគារអភិវឌ្ឍអាស៊ី ដែលមានទីស្នាក់ការនៅទីក្រុងម៉ានីល ។

ចាប់ពីខែមីនា ឆ្នាំ១៩៦៧ ដល់ខែសីហា ឆ្នាំ១៩៦៩ អ៊ីស៊ូប គន្ធី បានចាកចេញពីក្រុងភ្នំពេញ ទៅចូលរួមសន្និសីទនៅទីក្រុងតូក្យូ ប្រទេសជប៉ុន កូរ៉េខាងជើង បន្ទាប់មកទៅប្រទេសបារាំង ហើយទីបញ្ចប់នៅទីក្រុងវីយែន ប្រទេសអូទ្រីស ។

នៅខែតុលា ឆ្នាំ១៩៦៧ រដ្ឋាភិបាលកម្ពុជាបានចាត់តាំង អ៊ីស៊ូប គន្ធី ធ្វើជាតំណាងសមាជិកគណៈប្រតិភូកម្ពុជាទៅទស្សនកិច្ចនៅទីក្រុងវីយែន ។ នៅទីនោះប្រធានគណៈប្រតិភូសូវៀតបានមកទាក់ទងសុំឲ្យ អ៊ីស៊ូប គន្ធី ជួយធ្វើអន្តរាគមន៍ទៅគណៈប្រតិភូអាហ្វហ្កានីស្ថាន នៅក្នុងសន្និសីទអំពីបញ្ហាព្រំដែនចិន-សូវៀតដើម្បី«កុំឲ្យធ្វើការកែប្រែព្រំប្រទល់ជាមួយប្រទេសប៉ាគីស្ថាន ប្រយោជន៍កុំឲ្យមានការកែប្រែព្រំប្រទល់សូវៀតជាមួយនឹងប្រទេសដទៃ» ។ កិច្ចការដែលបានធ្វើក្នុងសន្និសីទទាំងពីរលើក(ឆ្នាំ១៩៦៨ និង១៩៦៩) អ៊ីស៊ូប គន្ធី បានទទួលប្រាក់ពីគណៈប្រតិភូសូវៀត២ពាន់ដុល្លារសហរដ្ឋអាមេរិក ។

ឆ្នាំ១៩៦៩ នៅទីក្រុងប្រាក ប្រទេសឆេកូស្លូវ៉ាគី អ៊ីស៊ូប គន្ធី ត្រូវបានតែងតាំងជាលេខាទី១ នៅស្ថានទូតខ្មែរប្រចាំក្រុងប្រាក ។ អ៊ីស៊ូប គន្ធី បានទៅទាក់ទងលេខាធិការទី១ស្ថានទូតសូវៀតប្រចាំប្រទេសនេះឈ្មោះ ហ្សាកូវ ជាភ្នាក់ងារកា.ហ្សេ.បេ ហើយដែលបានសន្យាថានឹងទាក់ទងនៅពេលក្រោយកាលណាខ្លួនត្រូវការ ។




នៅខែកក្កដា ឆ្នាំ១៩៧០ បន្ទាប់ពីរដ្ឋប្រហារ អ៊ីស៊ូប គន្ធី និង ឡុង ណូរិន នៅទីក្រុងប្រាក បានពិភាក្សាគ្នា២ដងអំពីស្ថានការណ៍សង្គ្រាមនៅប្រទេសកម្ពុជាយ៉ាងល្អិតល្អន់រួមទាំងផលវិបាកផ្សេងៗរបស់សង្គ្រាមមកលើប្រទេសជាតិនិងប្រជាជន ដើម្បីនឹងស្វែងរកកម្លាំងទី៣ទប់ទល់នឹងកម្លាំង២ផ្សេងទៀត (រណសិរ្សរួបរួមជាតិកម្ពុជាដែលមានវៀតកុងជាសម្ព័ន្ធមិត្ត និងពួកក្បត់ លន់ ណុល មានអាមេរិកាំងជាសម្ព័ន្ធមិត្ត) ដោយផ្តោតអារម្មណ៍ថា មានតែសហភាពសូវៀតទេ ដែលអាចជួយបាន ។ ប៉ុន្តែ ឡុង ណូរិន បានបង្ហាញពីការលំបាកពីរ៖ ទី១ សហភាពសូវៀតគឺ ជាសម្ព័ន្ធមិត្តរបស់វៀតកុងនិងសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម ។ ដូច្នេះសហភាពសូវៀតមិនមានយោបល់អំពីការឈ្លានពានរបស់ពួកវៀតកុងមកលើប្រទេសកម្ពុជានិងជំនួយដែលសូវៀតយល់ព្រមផ្តល់ឲ្យរណសិរ្សរួបរួមជាតិកម្ពុជានោះទេ ប៉ុន្តែក៏មិនអាចបដិសេធថាសហភាពសូវៀតយល់ព្រមផ្តល់ជំនួយជាសម្ភារសឹកទៅឲ្យវៀតកុងនិងសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាមដែរ ។ ក្រសួងការបរទេសនៃប្រទេសឆេកូស្លូវ៉ាគីបានស្នើឲ្យឯកអគ្គរដ្ឋទូតរបស់ លន់ ណុល បញ្ឈប់ការធ្វើអន្តរាគមន៍ទាំងអស់ជាមួយក្រសួងការបរទេសប្រឆាំងនឹងសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាមនិងពួកវៀតកុង ពីព្រោះរដ្ឋាភិបាលទាំងពីរនេះសុទ្ធតែជាមិត្ត

របស់ខ្លួន ។ ទី២គឺថាសង្គ្រាមប្រហែលជាប្រព្រឹត្តធ្វើទៅនៅក្នុងប្រទេសផ្ទាល់ ។ គិតដល់ការលំបាកនេះទើប ឡុង ណូរិន និង អ៊ីស៊ូប គន្នី លះបង់ផែនការនេះចោល ។ នៅក្នុងចន្លោះនៃការពិភាក្សានេះ អ៊ីស៊ូប គន្នី បានលួចទៅទាក់ទងនឹង ហូរ៉ាកូវ ជាលេខានៃស្ថានទូតសូវៀត ដើម្បីស្វែងយល់ពីមតិគាត់អំពីជំហររបស់សហភាពសូវៀត ។ ហូរ៉ាកូវ បានប្រាប់ថា រដ្ឋាភិបាលរបស់គាត់ពុំទាន់បានសម្រេចចិត្តពីបញ្ហានេះទេ ចំណែកខ្លួនគាត់សម្រេចចិត្តនៅខាង លន់ ណុល តទៅទៀតចំពោះស្ថានការណ៍នេះ ។ ឯកម្រោងក្នុងការបង្កើតកម្លាំងទី៣នោះ ហូរ៉ាកូវ បានផ្ដល់យោបល់ថា ការបង្កើតកម្លាំងទី៣មិនអាចធ្វើបានទេ មានតែបម្រើរដ្ឋាភិបាលសូវៀតទើបអាចចូលក្នុងរណសិរ្សរួបរួមជាតិកម្ពុជា ។ អ៊ីស៊ូប គន្នី បានផ្ដល់ដំណឹងទៅ ហូរ៉ាដនី ជាអ្នកទទួលខុសត្រូវនៅក្រសួងការបរទេសប្រទេសឆេកូស្លូវ៉ាគី អំពីការចូលរួមក្នុង "រណសិរ្សរួបរួមជាតិកម្ពុជាដើម្បីកាន់កាប់ស្ថានទូតជាមួយនិស្សិតមួយចំនួន" នៅក្នុងប្រទេសនោះ ។ ហូរ៉ាកូវ ណែនាំ អ៊ីស៊ូប គន្នី ឲ្យយកការណ៍និងធ្វើវិច្ឆេទកម្មបំបែកបំបាក់រណសិរ្ស ។ នៅឯស្ថានទូតរបស់ លន់ ណុល នាទីក្រុងប្រាគមានសេចក្ដីជូនដំណឹងមួយឲ្យក្រសួងការបរទេសនៅក្រុងភ្នំពេញថា ជួន មុម្ម រដ្ឋមន្ត្រីរបស់សម្ដេច សីហនុ បានធ្វើទស្សនកិច្ចនៅទីក្រុងប្រាគ និងជួបអ្នកទទួលខុសត្រូវម្នាក់នៅក្រសួងការបរទេសឆេកូស្លូវ៉ាគីដើម្បីធ្វើអន្តរាគមន៍ក្នុងការទទួលស្គាល់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាដោយប្រទេសឆេកូស្លូវ៉ាគី ។ ប៉ុន្តែការសម្រេចចិត្តរបស់ប្រទេសឆេកូស្លូវ៉ាគីយឺតពេលទៅហើយ បន្ទាប់ពីការធ្លាក់ចុះនៃប្រទេសកម្ពុជា ។ ឡុង ណូរិន បានប្រាប់ឲ្យដឹងថា គាត់បានជួបធ្វើការសន្ទនាជាមួយ ជួន មុម្ម ។ ជួន មុម្ម បានអះអាងថា "អ៊ីស៊ូប គន្នី នឹងត្រូវបានទទួលស្វាគមន៍នៅក្នុងជួររណសិរ្សរួបរួមជាតិកម្ពុជា ប្រសិនបើគាត់សម្រេចចិត្តផ្ដើមធ្វើសកម្មភាពមួយប្រឆាំងនឹងស្ថានទូតរបស់ លន់ ណុល ពោលគឺត្រូវដាក់ស្ថានទូតនេះឲ្យស្ថិតនៅក្រោមការគាំពាររបស់រណសិរ្សរួបរួមជាតិកម្ពុជាវិញ" ។ ម្យ៉ាងទៀត ជួន មុម្ម ថាការដាក់ស្ថានទូតនេះឲ្យស្ថិតនៅក្រោមការគាំពាររបស់រណសិរ្សរួបរួមជាតិកម្ពុជាអាចនឹងជំរុញឲ្យប្រទេសឆេកូស្លូវ៉ាគីទទួលស្គាល់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ។

នៅថ្ងៃទី៨ ខែ៨ ឆ្នាំ១៩៧០ ជារយៈពេលដែល អ៊ីស៊ូប គន្នី ស្ថិតនៅប្រទេសបារាំងជាមួយក្រុមគ្រួសារ ។ ខណៈនោះ ឡុង ណូរិន បានទូរស័ព្ទមកពីទីក្រុងប្រាគបង្ខំឲ្យ អ៊ីស៊ូប គន្នី ត្រឡប់ទៅទីក្រុងប្រាគជាបន្ទាន់ដើម្បីនឹងធ្វើកិច្ចការមួយ ព្រោះខ្លួនគាត់បានផ្ដើមទាក់ទងជាមួយស្ថានទូតសាធារណរដ្ឋចិនប្រជាមានិតអំពីរឿងការសុំស្នាក់អាស្រ័យហើយ ។ អ៊ីស៊ូប គន្នី បានត្រឡប់ទៅទីក្រុងប្រាគវិញ ហើយប្រមូលផ្ដុំនិស្សិតកម្ពុជាឲ្យអស់ចូលរួមធ្វើសកម្មភាពប្រឆាំងនឹងស្ថានទូតរបស់ លន់ ណុល ។ ព្រឹកថ្ងៃទី១០ អ៊ីស៊ូប គន្នី និងក្រុមនិស្សិតបានដាក់ស្ថានទូតកម្ពុជាឲ្យស្ថិតនៅក្រោមការគាំពាររបស់រណសិរ្សរួបរួមជាតិកម្ពុជា ។ រយៈពេល ២១ថ្ងៃនៃការកាន់កាប់ស្ថានទូតនេះតាមរយៈ ហូរ៉ាដនី ជាអន្តរការីនិងជាអ្នកទទួលខុសត្រូវបញ្ហារបស់កម្ពុជានៅក្រសួងការបរទេសឆេក អាជ្ញាធរប្រទេសឆេកបានដាក់ការគាបសង្កត់ បង្ខំឲ្យ អ៊ីស៊ូប គន្នី ព្រមទាំងនិស្សិតចាកចេញឲ្យអស់ពីស្ថានទូត ។ ហូរ៉ាដនី បញ្ជាក់ប្រាប់ថា រដ្ឋាភិបាលរបស់ខ្លួនមិនព្រមចុះចាញ់នូវសកម្មភាពដែលផ្ទុយនឹងច្បាប់អន្តរជាតិឡើយ ។ ឯកអគ្គរដ្ឋទូតឆេកបានទាក់ទងជាមួយតំណាងរណសិរ្សរួបរួមជាតិកម្ពុជានៅទីក្រុងប៉េកាំងហើយសិក្សាអំពីលទ្ធភាពអនុគ្រោះក្នុងការបើកការិយាល័យពត៌មានរបស់រណសិរ្សរួបរួមជាតិកម្ពុជាមួយ នៅទីក្រុងប្រាគដែលមាន អ៊ីស៊ូប គន្នី ជាតំណាងផ្ទាល់ ។ ដើម្បីសុវត្ថិភាព អ៊ីស៊ូប គន្នី និងពួកនិស្សិត បានភៀសខ្លួនទៅជ្រកកោននៅក្នុងស្ថានទូតសាធារណរដ្ឋប្រជាមានិតចិនតាមសេចក្ដីសម្រេចចិត្តរបស់នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលចិន ។ នៅទីក្រុងប៉េកាំង ជួន ប្រាសិទ្ធ បានធ្វើដំណើរទៅទីក្រុងម៉ូស្គូដើម្បីជួបចរចាជាមួយឯកអគ្គរដ្ឋទូតឆេកូស្លូវ៉ាគីនៅទីក្រុងមូស្គូ សុំឲ្យមានភាពអនុគ្រោះជាបន្តបន្ទាប់មួយនូវសកម្មភាពត្រៀមបម្រុងរបស់ អ៊ីស៊ូប គន្នី ។ ការចរចានេះពុំត្រូវបានយល់ព្រមទេ ។ ជួន មុម្ម ពេញចិត្តចំពោះការចរចាសុំឲ្យបើកការិយាល័យពត៌មានមួយរបស់រណសិរ្សរួបរួមជាតិនៅទីក្រុងប្រាគ ។ ចំណែក សារិន ឆាក បែរជាគាំទ្ររដ្ឋាភិបាលឆេកទៅវិញ ។ អ៊ីស៊ូប គន្នី ត្រូវបាន ជួន ប្រាសិទ្ធ ណែនាំឲ្យទូលស្នើសម្ដេច សីហនុ អំពីការគ្រោងគិតការបើកការិយាល័យពត៌មានមួយ នៅទីក្រុងប្រាគ ។ **(នៅមានត)**

**លី សុផល**

# សេចក្តីថ្លែងការណ៍របស់បក្សកុម្មុយនិស្តកម្ពុជាចំពោះបក្សពលករដាណឺម៉ាក

## នួន ជា អនុលេខាបក្សកុម្មុយនិស្តកម្ពុជា

### *ខែកក្កដា ឆ្នាំ១៩៧៨*

តាងនាមឲ្យបក្សកុម្មុយនិស្តកម្ពុជា ខ្ញុំសូមសម្តែងនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះដំណើរទស្សនកិច្ចរបស់លោកមកកាន់ប្រទេសកម្ពុជា ។ នេះជាមហាកិត្តិយសនិងជាប្រភពនៃការលើកទឹកចិត្តដ៏ប្រពៃចំពោះយើងទាំងអស់គ្នាដែលលោកបានមកដល់ទីនេះ ។

### ១) អំពីការកសាងបក្ស ឆ្នាំ១៩៦០-៦៧

តាំងពីដើមមកយើងជឿជាក់ថា ការមានបក្សដែលដឹកនាំដោយវណ្ណៈកម្មករនិងផ្អែកខ្លួនយើងទៅលើទំនាស់នៅក្នុងសង្គមកម្ពុជា ជាការចាំបាច់បំផុតនៅសម័យនោះ ពោលគឺឆ្នាំ១៩៦០ សង្គមកម្ពុជាស្ថិតនៅក្នុងអាណានិគមបែបថ្មីនិងពាក់កណ្តាលសក្តិភូមិ ។ ទំនាស់រវាងជាតិកម្ពុជានិងចក្រពត្តិអាមេរិកមានភាពមុតស្រួចណាស់ ដែលនោះហើយគឺជាទំនាស់ខាងក្រៅ ។ ចំពោះទំនាស់ផ្ទៃក្នុងវិញគឺកើតឡើងរវាងវណ្ណៈកម្មករនិងនាយទុនហើយនិងរវាងប្រជាជនក្រីក្រនិងវណ្ណៈសក្តិភូមិ ។ នៅពេលនោះ ពួកមូលធននិងប្រតិកិរិយានាំគ្នាជិះជាន់ប្រជាជនយើង ។

ផ្អែកលើមូលដ្ឋានទំនាស់នេះ បក្សបានកំណត់ភារកិច្ចបដិវត្តន៍របស់ខ្លួនថាៈ ធ្វើបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យវាយចក្រពត្តិអាមេរិកនិងវណ្ណៈសក្តិភូមិ រំដោះជាតិកម្ពុជានិងវណ្ណៈក្រីក្រ ។ បក្សបានដាក់ចុះនូវមាគ៌ាយុទ្ធសាស្ត្រសម្រាប់បដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យដូចខាងក្រោម÷

១) បក្សដឹកនាំបដិវត្តន៍ត្រូវតែជាបក្សរបស់វណ្ណៈកម្មករ ។ បក្សត្រូវដឹកនាំបដិវត្តន៍ដោយផ្ទាល់ ហើយមិនត្រូវអនុញ្ញាតឲ្យវណ្ណៈដទៃទៀតដឹកនាំបដិវត្តន៍ឬបក្សទេ ។ ជាបឋម បក្សត្រូវកំណត់កម្លាំងបដិវត្តទីមួយកម្លាំងយុទ្ធសាស្ត្រនៅក្នុងជួរបដិវត្តន៍ទីពីរកម្លាំងកលយុទ្ធនៅក្នុងជួរបដិវត្តន៍ ។ ២) កម្លាំងយុទ្ធសាស្ត្រគឺមានកម្មករ កសិករ និងអនុធនផ្សេងៗទៀត ។ ក្នុងចំណោមធាតុទាំងនេះយើងឃើញថា វណ្ណៈកម្មករជាវណ្ណៈមូលដ្ឋាន ហើយវណ្ណៈអនុធនជាកម្លាំងរបៀបសម្ព័ន្ធ ។ មូលធនជាតិជាកម្លាំងបន្ទាប់បន្សំ ។ មិនតែប៉ុណ្ណោះ យើងចាត់ទុកបុគ្គលថ្នាក់លើមួយចំនួននៅក្នុងជួរថ្នាក់ដឹកនាំដែលខ្លះជាមូលធននិងមន្ត្រីរដ្ឋការនិងរដ្ឋាភិបាល ហើយខ្លះទៀតជាព្រះសង្ឃថាជាកម្លាំងបន្ទាប់បន្សំ ។ អ្នកទាំងនោះត្រូវតែមានទស្សនៈជាតិចម្រើននិងស្នេហាជាតិ


នួន ជា

ពោលគឺចម្រើនទាក់ទងនឹងពួកប្រតិកិរិយា ។

ផ្អែកលើចំណាត់ថ្នាក់កម្លាំងនេះ យើងបានព្យាយាមកសាងរណសិរ្សជាតិប្រជាធិបតេយ្យក្នុងគោលបំណងតស៊ូប្រឆាំងនឹងចក្រពត្តិអាមេរិកនិងបរិវារ ។ យើងចង់បញ្ជាក់ប្រាប់ទៅលោកថាកម្លាំងទាំងអស់នេះផ្អែកលើការដឹកនាំរបស់វណ្ណៈកម្មករនិងបក្ស ។ ៣) បក្សរបស់យើងបានជ្រើសរើសការតស៊ូពីរយ៉ាងៈ ទី១គឺតស៊ូផ្នែកនយោបាយ ទី២គឺតស៊ូផ្នែកប្រដាប់អាវុធ ។ ទម្រង់ទាំងពីរយ៉ាងនេះមានការទាក់ទងគ្នាទៅវិញទៅមក ។ ការតស៊ូ

នយោបាយត្រូវបានពង្រីកតាមរយៈការតស៊ូស្របច្បាប់និងមិនស្របច្បាប់ដែលជាមូលដ្ឋាននៃការតស៊ូ ។ ផ្លូវយើងតស៊ូទាំងបើកចំហនិងសម្ងាត់ ហើយការតស៊ូសម្ងាត់គឺជាមូលដ្ឋានរបស់យើង ។ យើងកំណត់ទម្រង់តស៊ូក្នុងវិធីនេះតាមបទពិសោធន៍របស់យើងកន្លងមក ។ ការការពារ ពង្រីក និងកសាងកម្លាំងរបស់យើងតម្រូវឲ្យធ្វើតាមរបៀបនេះ ៤) យើងតស៊ូទាំងនៅក្នុងទីក្រុងនិងនៅតាមជនបទ ៥) ការតស៊ូនៅតាមជនបទគឺជាការតស៊ូជាមូលដ្ឋាន ជាពិសេសតស៊ូកន្លែងដែលមិនសូវមានការលូតលាស់និងនៅតាមជនបទដាច់ស្រយាលឆ្ងាយៗ ។ ទីនោះហើយដែលជាមូលដ្ឋានរបស់យើង ៦) យើងទទួលស្គាល់ថាយើងត្រូវតែធ្វើសង្គ្រាមប្រជាជនពុះពារគ្រប់ឧបសគ្គ បូជាគ្រប់បែបយ៉ាងដើម្បីយកជ័យជម្នះឲ្យខាងតែបាន និងធ្វើការវាយសម្រុកជាលើកចុងក្រោយ ។ យើងប្តេជ្ញាចិត្តថាមិនឲ្យគេវាយយើងទេ មានតែយើងវាយគេ ៧) មាគ៌ាយុទ្ធសាស្ត្ររបស់យើងគឺៈ ឯករាជ្យ អធិបតេយ្យភាព និងស្វ័យម្ចាស់ការ ។ យើងជាអ្នកសម្រេចលើជោគវាសនាលើខ្លួនឯងដោយសេចក្តីថ្លៃថ្នូរ ។ ៨) ការតស៊ូរបស់យើងគឺពឹងផ្អែកលើសាមគ្គីភាពអន្តរជាតិជាមួយបក្សជាបងប្អូនទាំងអស់នៅលើពិភពលោកនិងប្រជាជាជនទាំងអស់នៅប្រទេសនានា នៅលើពិភពលោកដែលប្រឆាំងនឹងសេរីនិយមចក្រពត្តិនិយមអាណានិគមបែបថ្មីនិងអាណានិគមគ្រប់ប្រភេទ ។

គោលការណ៍និងការអនុវត្តជាក់ស្តែងទាំងនេះមិនមែនទើបតែមានទេ ។ វាត្រូវបានទទួលស្គាល់ទូទាំងសកលលោក ប៉ុន្តែយើងរំពុកឡើងវិញជាមួយអស់លោក ដោយសារវាបានបង្ហាញពីបទពិសោធន៍របស់យើង ។ យើងបានដើមតាមគោលការណ៍នេះនៅក្នុងការតស៊ូ ហើយយើងរៀនពីបទពិសោធន៍ទាំងនេះ ។ មាគ៌ានេះត្រូវបានសម្រេចដោយមហាសន្និបាតបក្សលើកទី១ ដែលប្រារព្ធឡើងនៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៦០ ។

ខ្ញុំសូមបញ្ជាក់ថាការយកមាគ៌ានេះមកអនុវត្តមិនមែនជាការងាយស្រួលឡើយ ជាពិសេសនៅមុនឆ្នាំ១៩៧០ ។ នៅឆ្នាំ១៩៦០ យើងបានទទួលឥទ្ធិពលយ៉ាងធ្ងន់ធ្ងរពីមហាសន្និបាតលើកទី២០របស់បក្សនៅសហភាពសូវៀត ។ វៀតណាមក៏ប្រឆាំងនឹងមាគ៌ាបក្សយើងដែរ ជាពិសេសការតស៊ូប្រដាប់អាវុធក៏ដូចជាមាគ៌ាឯករាជ្យ អធិបតេយ្យភាព និងស្វ័យម្ចាស់ការរបស់យើង ។ វៀតណាមនិយាយថា យើងត្រូវតែធ្វើបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យយោងតាមឯកសាររបស់មហាសន្និបាតលើកទី២០នៅសហភាពសូវៀត ។ គេនិយាយថាការបែកវណ្ណៈនៅក្នុងប្រទេសកម្ពុជាមិនមានលក្ខណៈច្បាស់លាស់ទេ ។ វៀតណាមជឿថា វណ្ណៈសក្តិភូមិបេះតែវិវឌ្ឍទៅមុខនៅក្នុងប្រទេសកម្ពុជាហើយនឹងអាចធ្វើបដិវត្តន៍ជាមួយយើងទៀត ។ មិនតែប៉ុណ្ណោះ វៀតណាមគិតថា បដិវត្តន៍អាចសម្រេចទៅបានតាមរយៈសភានិងផ្អែកលើមូលដ្ឋានកិច្ចសហប្រតិបត្តិការក្នុងចំណោមវណ្ណៈផ្សេងៗ ។ ពីពេលមួយទៅពេលមួយ វៀតណាមបានឃើញនិងនៅតែយល់ឃើញថាមាគ៌ារបស់យើងឆ្វេងជ្រុលពេក ។ ប៉ុន្តែយើងបានការពារមាគ៌ាបក្សរបស់យើង ។ ដោយបានកំណត់ត្រឹមត្រូវនូវមាគ៌ាបក្ស និងសកម្មភាពរបស់បក្ស យើងបានបញ្ជូនកម្មាភិបាលរបស់យើងឲ្យទៅធ្វើការនៅតាមជនបទ ។ យើងទុកតែមួយចំនួនតែប៉ុណ្ណោះនៅក្នុងទីក្រុង ។

កងទ័ពរបស់យើងកសាងឡើងតាំងពីបាតដៃទទេ ពីកងទ័ពតូចមកកងទ័ពធំ ។ ពីដំបូងយើងបានបង្កើតកងឈ្លបសម្ងាត់ស្វ័យម្ចាស់ការ ។ យើងបានជ្រើសរើសយុវជនដែលល្អបំផុត ។ នៅពេលនោះកម្មាភិបាលទាំងអស់ត្រូវធ្វើការងារមិនស្របច្បាប់ ហើយមានតែមួយចំនួចតូចប៉ុណ្ណោះ ដែលបានធ្វើការងារស្របច្បាប់ ដូចជាកម្មាភិបាលខ្លះធ្វើការនៅក្នុងសភា ខ្លះផ្នែករដ្ឋបាល ខ្លះនៅសារពត៌មាន ។ ការងារស្របច្បាប់គឺធ្វើឡើងដើម្បីកៀងគរកម្លាំងមហាជន ប៉ុន្តែការងារស្នូលគឺធ្វើនៅជនបទនិងក្នុងចំណោមកម្មករ ។ ភាពធ្វើការមិនស្របច្បាប់និងសម្ងាត់ជាការងារមួយពិបាកណាស់ ។ នេះមានន័យថាខ្មាំងរបស់យើង ដែលមានចក្រពត្តិអាមេរិកបរិវារ និងវណ្ណៈប្រតិកិរិយាមិនអាចរកឃើញទេថា នរណាជាអ្នកដឹកនាំបដិវត្តន៍ ។ គេស្គាល់ឈ្មោះកម្មាភិបាលមួយចំនួនដូចជា ខៀវ សំផន ជាដើម ។ គេគិតថា កម្មាភិបាលទាំងនោះគឺជាមេដឹកនាំពិតប្រាកដរបស់បដិវត្តន៍ ។ ប៉ុន្តែគេមិនដឹងថា អ្នកណាជាមេដឹកនាំពិតប្រាកដឡើយ ។ ដោយសារតែគេអាចចាត់ការចំពោះអ្នកដែលគេស្គាល់ ដូច្នេះភាគច្រើននៃ

មេដឹកនាំរបស់យើងមានលទ្ធភាពអាចធ្វើការយ៉ាងមានសុវត្ថិភាព ។

នៅក្នុងអំឡុងឆ្នាំ១៩៦០-៦៧ យើងបានបង្កើតនិងពង្រឹងមូលដ្ឋានជាច្រើននៅតាមជនបទ ។ ចលនាគាំទ្រការបង្កបង្កើនផលនិងប្រឆាំងនឹងពួកម្ចាស់ដី មានសភាពខ្លាំងក្លាណាស់ ។ កសិករប្រយុទ្ធប្រឆាំងនឹងវណ្ណៈកាន់អំណាច ។ ប្រជាជនទាំងនោះគ្មានអ្វីប្រើទេ គឺមានតែដុំថ្ម កាំបិត ដំបង និងពូថៅជាដើម ។ មានប្រពន្ធកសិករក្រីក្រមួយចំនួនបានចូលរួមដែរ ដោយយកកូនឲ្យមកធ្វើបាតុកម្មនៅមុខរដ្ឋសភា ។ កម្លាំងបដិវត្តន៍នៅតាមជនបទខ្លាំងក្លាណាស់នាពេលនោះ ។ យើងបានឲ្យសមាជិកបក្សយើងដែលមកពីវណ្ណៈកម្មករ ឲ្យទៅធ្វើការងារជាមួយកសិករក្រីក្រនិងកសិករកណ្តាល ។

នៅទីក្រុងមានសកម្មភាពប្រហាក់ប្រហែលគ្នានេះដែរ ។ នៅក្នុងស្រទាប់កម្មករ សិស្ស និងនិស្សិត ។ អ្នកទាំងនោះទាមទារឲ្យរដ្ឋាភិបាលកាត់ជំនួយមកពីសហរដ្ឋអាមេរិក និងបណ្តេញឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកចេញពីប្រទេស ។ បាតុករបានដុតទង់ជាតិសហរដ្ឋអាមេរិកនិងស្ថានទូតដុតចោល ។

នៅជនបទចលនាប្រជាជនមានការផុសផុល ។ ប្រជាជនដែលមានការអត់ឃ្លានបានងើបឈរឡើងប្រឆាំងនឹងជនក្បត់ប្រតិកិរិយានិងភ្នាក់ងារនៃរបបនោះ ។ ពាក្យស្លោកគឺ «ធ្វើបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ» ពោលគឺវាយចក្រពត្តិអាមេរិក ។ ស្មារតីស្នេហាជាតិមានខ្ពស់ណាស់ ។ ម្នាក់ៗមានអារម្មណ៍ថាត្រូវតែវាយចក្រពត្តិអាមេរិក ។ ប៉ុន្តែយើងចែកការតស៊ូនេះជាពីរផ្នែក គឺការតស៊ូប្រជាជាតិនិងតស៊ូប្រជាធិបតេយ្យ ។ ចំពោះការតស៊ូប្រជាជាតិយើងបានលើកពាក្យស្លោកទាមទារសិទ្ធិសម្រាប់សិស្ស និស្សិត កម្មករ និងកសិករ ទាមទារប្រាក់ខែខ្ពស់ ដីចម្ការសម្រាប់កសិករ តម្លៃអង្ករ សណ្តែក ត្រឡាច ល្ពៅ សាច់ ឲ្យខ្ពស់ និងឲ្យប្រជាជនបានរស់នៅក្នុងជីវភាពប្រសើរជាងនេះ ។

ការតស៊ូក្តោបបញ្ហាធំៗ និងបញ្ហាតូចៗ ហើយពាក់ព័ន្ធនឹងតំបន់នានា និងមធ្យោបាយផ្សេងៗ ។ ខ្មាំងបានព្យាយាមសង្កត់សង្កិនយើង ប៉ុន្តែត្រូវបរាជ័យដោយសារយើងវាយតាមផ្លូវច្បាប់និងសម្ងាត់នៅលើសមរភូមិតូចនិងធំនៅពេលតែមួយ ។ តាមវិធីនេះ យើងអាចការពារនិងពង្រឹងកម្លាំងបដិវត្តន៍ជាជំហានៗ ។

តាមរយៈការតស៊ូ យើងបានកសាងជួរដឹកនាំរបស់បក្សដោយជ្រើសរើសបានកម្មាភិបាលល្អៗក្នុងចំណោមកម្មករកសិករ បុគ្គលិករដ្ឋការ ព្រះសង្ឃ និងស្ត្រី ។ នៅក្នុងការតស៊ូ យើងបានលត់ដំកម្មាភិបាលនៅគ្រប់ជាន់ថ្នាក់ ។ ដូចនេះទំនាស់នៅក្នុងសង្គមយើងមានកាន់តែជ្រៅឡើងៗដូចជាទំនាស់រវាងកម្មករនិងមូលធនរវាងកសិករនិងម្ចាស់ដី រវាងបុគ្គលិក និងមន្ត្រីរដ្ឋការ ។ ខ្មាំងបានព្យាយាមបង្ក្រាបចលនាយើងយ៉ាងខ្លាំង ។ ស្ថិតនៅក្នុងស្ថានភាពនេះដោយប្រឈមមុខជាមួយនឹងទំនាស់ដ៏មុតស្រួច យើងបានធ្វើកិច្ចប្រជុំគណៈកម្មាធិការមជ្ឈិមមួយ ។ យើងសម្រេចថាយើងមិនអាចបន្តការតស៊ូតាមផ្លូវច្បាប់បានទៀតទេ ហើយថាយើងត្រូវតែចាប់ផ្តើមងើបបះបោរឡើង ។ ការបះបោរនេះបានកើតឡើងនៅក្នុងខែមករា ឆ្នាំ១៩៦៨ ។

ឯកអគ្គរដ្ឋទូតសហភាពសូវៀតប្រចាំនៅទីក្រុងភ្នំពេញបានប្រឆាំងនឹងយើង ។ សូវៀតនិយាយថា បក្សយើងធ្វើការតស៊ូប្រដាប់អាវុធរបៀបនេះគេមិនពេញចិត្តទេ ។ គេចាប់ផ្តើមកសាងបក្សថ្មីមួយក្នុងគោលបំណងប្រឆាំងនឹងយើង ប្រមូលកៀងគរប្រជាជនដែលចុះចាញ់ខាងខ្មាំងនិងពួកក្បត់ អ្នកឆ្វេងឱកាសនិយម និងជនអនាថាសាត់អណ្តែតដូចចក ។ វៀតណាមក៏ប្រឆាំងនឹងការតស៊ូប្រដាប់អាវុធរបស់យើងដែរ ។ កម្មាភិបាលវៀតណាមបានចាត់វិធានការប្រឆាំងនឹងយើងដោយក្រឡឹងលបលួចផ្តល់លិខិតខ្ទីៗឲ្យដល់កម្មាភិបាលរបស់យើងដូចជាលទ្ធិកុម្មុយនិស្តឆ្វេងនិយមដែលជាចលាចលរបៀបកូនក្មេង ។ វៀតណាមនិយាយថា យើងឆ្វេងជ្រុល ។

យើងប្រាប់អស់លោកអំពីបញ្ហានេះដើម្បីបញ្ជាក់ថាវៀតណាមមិនជួយយើងទេ! មនុស្សជាច្រើនយល់ច្រឡំអំពីរឿងនេះ ។ គឺពេលនោះហើយដែលបក្សរបស់យើងពង្រឹងជំហរឯករាជ្យនិងអធិបតេយ្យ ។ យើងដឹងថាបញ្ហារបស់យើងមានលក្ខណៈផ្សេង ។ យើងត្រូវតែគិតអំពីសភាពជាក់ស្តែងដើម្បីដោះស្រាយទំនាស់សង្គមរបស់យើង ។ ប្រហែលជាមានការលំបាកមែននៅតាមកន្លែងដទៃទៀត ប៉ុន្តែនេះជាអ្វីដែលកើតឡើងនៅទីនេះ ។

**(នៅមានត)**

# រណ្តៅសាកសពនៅស្រុកចម្ការលើ និងស្រុកព្រៃឈរ ខេត្តកំពង់ចាម

**ទីតាំងសម្លាប់ឡូអឹម១៨** (M-១៨) លេខកូដៈ ០៣០២០៩ ។

នៅរសៀលថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០០ ក្រុមស្រាវជ្រាវមជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើដំណើរទៅដល់ ឡូ អឹម-១៨ ដែលមានទីតាំងនៅចម្ការកៅស៊ូស្ថិតក្នុងភូមិ៣២ មូលដ្ឋានស្វាយមាស ស្រុកចម្ការលើ ខេត្តកំពង់ចាម ។ ប្រជាជនតែងតែហៅឡូ អឹម-១៨ តាំងពីដើមរហូតមកដល់បច្ចុប្បន្ននេះ ។ ថ្វីដ្បិតដើមកៅស៊ូចាស់ៗត្រូវបានកាប់រំលំ ហើយត្រូវបានជំនួសដោយកូនកៅស៊ូថ្មីរាប់ពាន់ដើមយ៉ាងណាក៏ដោយ ក៏ឈ្មោះឡូ អឹម-១៨ មិនត្រូវបានផ្លាស់ប្តូរឡើយ ។ ការកំណត់តាមម៉ាស៊ីនកត់ត្រាទីតាំងភូមិសាស្ត្រតាមផ្កាយរណប ឡូ អឹម-១៨ នេះស្ថិតនៅខ្សែស្រប១២°១៣' ០៦:៤៣ និងខ្សែបណ្តោយ១០៥°១៨'៥០:៥៤ ។ ឡូ អឹម-១៨ ជាទីតាំងសម្លាប់ដ៏ធំមួយរបស់ខ្មែរក្រហមរវាងឆ្នាំ១៩៧៥-១៩៧៩ ។

លោក យ៉ាន់ យ៉ុម អាយុ៤៨ឆ្នាំ ស្រុកកំណើតនៅខេត្តតាកែវ បច្ចុប្បន្នរស់នៅភូមិ៣២ មូលដ្ឋានស្វាយមាស ស្រុកចម្ការលើ បានឲ្យដឹងថាកាលពីជំនាន់ ប៉ុលពត (មិនចាំឆ្នាំ) នៅពេលដែលគាត់កំពុងចៀរជ័រកៅស៊ូ ស្រាប់តែឃើញក្បួនរថយន្តធំៗដឹកមនុស្សយ៉ាងច្រើនចូលមកកាន់ឡូអឹម-១៨នេះ ។ លោក យ៉ុម បញ្ជាក់ថាក្បួនរថយន្តទាំងនោះច្រើនចូលមកចម្ការកៅស៊ូប្រហែលជាម៉ោង៧ឬ៨យប់ ។ ក្នុងពេលនោះលោក យ៉ុម មិនហ៊ានលេចមុខឲ្យហ្វូងមនុស្សលើរថយន្តនិងអ្នកបើករថយន្តឃើញទេ ។ នៅពេលប្រជាជនទាំងនោះត្រូវបានសម្លាប់រួចហើយក្បួនរថយន្តធំៗនោះចេញអស់ ទើបលោក យ៉ុម ហ៊ានចេញមុខទៅអើតមើលកន្លែងសម្លាប់ ។ លោក យ៉ុម បានឃើញនូវរបស់របរប្រើប្រាស់ជាច្រើនដូចជា កាបូប ក្រមា ប្រហុក ខ្សៀដក់បារីជាដើម ។ លោកយ៉ុម បានប្រាប់ថា


យ៉ាន់ យ៉ុម

"មនុស្សដែលស្លាប់នេះគឺមិនមែនយកមកពីមូលដ្ឋានស្វាយទាបទាំងអស់ទេ គឺមានរួមបញ្ចូលទាំងប្រជាជនថ្មីមកពីគ្រប់ឃុំក្នុងស្រុកចម្ការលើ និងមកពីស្រុកមួយចំនួនទៀតក្នុងខេត្តកំពង់ចាម" ។ លោក យ៉ុម បានឃើញរណ្តៅសាកសពដែលទំនងទើបតែជីកថ្មីៗចំនួនជិត២០រណ្តៅ ដែលរណ្តៅមួយៗមានទទឹង៥ម៉ែត្របណ្តោយ១០ម៉ែត្រ ជម្រៅ២ម៉ែត្រ ។

លោក ស៊ីម លី ជាប្រជាជនរស់នៅភូមិ៣២ មូលដ្ឋានស្វាយមាស ស្រុកចម្ការលើបាននិយាយថា ប្រជាជនដែលយកមកសម្លាប់នៅឡូ អឹម-១៨ នេះមិនត្រូវបានឃុំឃាំងទុកសូម្បីតែ១យប់ឡើយ គឺត្រូវសម្លាប់ភ្លាមៗនៅពេលទម្លាក់ចេញពីឡាន ។ លោក ស៊ីម លី បានអះអាងប្រាប់ដូច្នេះ ព្រោះគាត់បានឃើញស្ទើរតែគ្រប់សកម្មភាពសម្លាប់មនុស្សរបស់ពួកខ្មែរក្រហមនៅឡូអឹម-១៨ នេះ ។ លោក ស៊ីម លី បានបន្តថា ការសម្លាប់មនុស្សនៅពេលនោះគឺមានវិធីសម្លាប់ជាច្រើន ប៉ុន្តែវិធីសម្លាប់មានតែមួយគត់ដែលសម្លាប់បានលឿនបំផុត គឺគាបកនឹងធាងត្នោតទម្លាក់ចូលក្នុងរណ្តៅ ។


ស៊ីម លី

លោក ស៊ីម លី បានរៀបរាប់ពីឧបករណ៍សម្លាប់របស់ខ្មែរក្រហមថានៅលើរណ្តៅមានដាក់ស្ពានមួយគងពីលើមាត់រណ្តៅម្ខាងទៅម្ខាងទៀត ហើយនៅចំកណ្តាលស្ពាននោះមានបោះបង្គោលគ្រង់មួយដើមប្រវែងជាង១ម៉ែត្រ ដែលផ្នែកខាងលើបង្គោលមានចងភ្ជាប់នូវឃ្នាបធ្វើពីធាងត្នោតប្រវែងជាងមួយហត្ថសម្រាប់គាបបំបែកបំពង់កជនរងគ្រោះ ។ ចំណែកទីតាំងសម្លាប់ជាច្រើនទៀតក្នុងបរិវេណឡូ អឹម-១៨នេះ ក៏មានការសម្លាប់តាមលក្ខណៈផ្សេងៗពីគ្នា ដូចជាចាក់មេក្រូបន្ទប់ដើម្បីវាយសម្លាប់មនុស្សនឹងគល់ឫស្សីនិងត្បូងចប ។ ចំណែកក្មេងតូចៗត្រូវពួកខ្មែរក្រហមសម្លាប់ដោយចាប់កជើងគ្រវែងបោកនឹងដើមកៅស៊ូ

ដោយគ្មានញញើតដៃ ។ លោក ស៊ីម លី និយាយបន្តថា អ្នកដែលបានមកស្លាប់នៅទួល អឹម-១៨ នេះសុទ្ធតែចាញ់បោកពាក្យឃោសនារបស់ខ្មែរក្រហមថាត្រូវឲ្យមានការផ្លាស់ប្តូរទីលំនៅ ។ កាបូប វ៉ាលិស ខោអាវ របស់ជនរងគ្រោះ ត្រូវបានដុតបំផ្លាញចោល បន្ទាប់ពីម្ចាស់ត្រូវបានសម្លាប់រួចមក ។ ស៊ីម លី បញ្ជាក់បន្ថែមថា គំនរផេះក្រោយពីដុតមានកម្រាស់ស្មើនឹងទ្រូងមនុស្សចាស់(ប្រហែលកម្ពស់១ម៉ែត្រ) ។ លោក ស៊ីម លី បានប្រាប់ថាក្នុងចន្លោះឆ្នាំ១៩៧៥និងឆ្នាំ១៩៧៧ មានប្រជាជនឃុំស្វាយទាបចំនួន៥០០គ្រួសារត្រូវបានសម្លាប់នៅទួល អឹម-១៨ ទាំងអស់ ។ ចំនួនសាកសពរួមនៅទួល អឹម-១៨ លោក ស៊ីម លី មិនអាចប៉ាន់ស្មានចំនួនជនរងគ្រោះដែលស្លាប់បានទេ ប៉ុន្តែគាត់និយាយថា «រាប់មិនអស់ទេ ច្រើនណាស់!» ។

## ស្រុកព្រៃឈរ

**១) មន្ទីរសន្តិសុខមិត្តសុប** លេខកូដភូមិសាស្ត្រ ០៣១៣០៦ ។

មន្ទីរសន្តិសុខមិត្តសុបស្ថិតនៅក្នុងភូមិតាកែវ ឃុំគរ ។ មន្ទីរនេះគឺជាមន្ទីរសន្តិសុខតំបន់៤១ ភូមិភាគកណ្តាល ។ មន្ទីរនេះមានអគារ៤ខ្នងសង់ជាលក្ខណៈសាលារៀន ដំបូលប្រក់ក្បឿងជញ្ជាំងក្តារ ក្នុងមួយខ្នងៗប្រវែង១២ម៉ែត្រនិងទទឹង៦ម៉ែត្រ ។ មន្ទីរនេះគ្រប់គ្រងដោយមិត្តសុប ។ មិត្ត សុប មានស្រុកកំណើតនៅឃុំសំរោង ស្រុកព្រៃឈរ ខេត្តកំពង់ចាម ។

មន្ទីរសន្តិសុខមិត្តសុបដែលមានផ្ទៃដីទទឹង៦០ម៉ែត្រនិងបណ្តោយ១០០ម៉ែត្រ បច្ចុប្បន្ននេះគឺជាដីកម្មសិទ្ធិរបស់លោកតាហ៊ុល និង យាយសៀប ។ បរិវេណមន្ទីរសន្តិសុខមិត្តសុបមានស្រះទឹកចំនួនបីដែលជីកដោយកម្លាំងអ្នកទោសក្នុងរបបខ្មែរក្រហម បច្ចុប្បន្នបរិវេណមន្ទីរនេះមានម៉ុងខ្មោចចិនជាច្រើន ។ កំណត់តាមម៉ាស៊ីនកត់ត្រាភូមិសាស្ត្រតាមផ្កាយរណបទីតាំងនេះស្ថិតនៅចំណុចខ្សែស្រប១២°០៦'៥៨:២០ និងខ្សែបណ្តោយ១០៥° ១២' ២២:៤៣ ។

យើងបានជួបជាមួយលោក ណៃ គឹមសាន់ ដែលជាជំទប់លេខ២(អនុប្រធានទី២)ឃុំគរ ។ លោក គឹម សាន់ មានអាយុ៥៣ឆ្នាំ ស្រុកកំណើតនៅភូមិតាមាស ឃុំគរ ស្រុកព្រៃឈរ ខេត្តកំពង់ចាម ។ នៅជំនាន់ ប៉ុល ពត បច្ចុប្បន្នគាត់រស់នៅភូមិដដែល ។ លោក គឹម សាន់ បានប្រាប់ថា កាលពីជំនាន់ ប៉ុល ពត មន្ទីរសន្តិសុខមិត្តសុបនេះដាក់អ្នកទោសភាគច្រើនជាអ្នកជាប់និន្នាការទាហាន លន់ ណុល ។ អ្នកទោសទាំងនោះត្រូវបានធ្វើទារុណកម្មរហូតដល់ស្លាប់ដោយប្រើដំបងឈើនិងដែកជាឧបករណ៍សម្លាប់ ។ ចំណែកការហូបចុកវិញ លោក គឹម សាន់ ប្រាប់ថាគ្មានចាននិងស្លាបព្រាសម្រាប់បរិភោគទេ ។ អ្នកទោសទាំងអស់តម្រូវឲ្យដាក់ខ្នោះជាប់ជារៀងរាល់ថ្ងៃ ។ ខ្នោះដែលដាក់នេះមិនមែនខ្នោះដែកទេ គឺជាខ្នោះឈើដែលមានទំហំមុខកាត់៥ហ៊ុនកម្ពស់១៥ហ៊ុន ចោះប្រហោងសម្រាប់ដាក់កជើង ហើយមានបន្ទះក្តារមួយទៀតដែលមានទំហំល្មមគ្របពីលើរួចចាក់សោ ។ ពេលបាយ ពេលបន្ទោរបង់លាមក និងពេលដេកអ្នកទោសទាំងអស់គឺមិនត្រូវបានដោះខ្នោះចេញពីជើងឡើយ ។ អ្នកទោសទាំងអស់គ្មានគ្រែសម្រាប់ដេកទេ (ដេកផ្ទាល់ដី) ពេលបន្ទោរបង់លាមកម្តងៗគឺមានពាងតូចមួយសម្រាប់ដាក់លាមកខ្លួន ដោយគ្រាន់តែរំកិលគូថដាក់ឲ្យចំមាត់ពាងដែលស្ថិតនៅក្បែរខ្លួនទៅជាការស្រេច ។ ក្នុងមន្ទីរសន្តិសុខមិត្តសុបនេះមិនដែលមានការប្រជុំបំពាក់បំប៉នអ្វីដល់អ្នកទោសឡើយ ក្រៅពីឲ្យចេញទៅធ្វើការនៅម៉ោង៧ព្រឹក និងត្រឡប់មកវិញនៅម៉ោង១១:៣០នាទី ។ បន្ទាប់មកអ្នកទោសទាំងអស់ត្រូវដេកជាប់ខ្នោះនៅមួយកន្លែង ។ លោក គឹម សាន់ បន្តថា អ្នកទោសដែលជាប់ក្នុងមន្ទីរនេះគ្មាននរណាម្នាក់អាចរួចខ្លួនបានទេ គឺត្រូវសម្លាប់ទាំងអស់ រួចហើយសែងសាកសពយកទៅកប់នៅកន្លែងមួយដែលស្ថិតនៅមិនឆ្ងាយប៉ុន្មានពីបរិវេណមន្ទីរសន្តិសុខនេះដូចជាទីតាំងទួលក្រសាំង ត្នោតជួរ អូរតាគង់ និងទួលដើមអំពិល ។

**២) ទីតាំងសម្លាប់**

**ក) អូរតាគង់** លេខកូដភូមិសាស្ត្រ ០៣១៣០៣ ។

អូរតាគង់គឺជាអូរទឹកមួយ (បច្ចុប្បន្នអូរស្តុកទឹកសម្រាប់ធ្វើស្រែ) ដែលលាតសន្ធឹងពីភូមិតាមាសដល់ស្ទឹងទឹកឆាមាន ប្រវែងប្រហែល១០០០ម៉ែត្រ ។ អូរនេះជាប់ព្រំប្រទល់ភូមិតាមាស និងភូមិតាកែវ ឃុំគរ ហើយក្លាយទៅជាកន្លែងដាក់សាកសពតាំងពីឆ្នាំ១៩៧៥មកម្ល៉េះ ។ លោក គឹម សាន់ បានប្រាប់ថាមានសាកសពប្រហែល១០០០នាក់ត្រូវបានពួកខ្មែរ

ក្រហមសម្លាប់ រួចយកមកគម្រៀបនៅក្នុងអូរដែលមានជម្រៅ ១ម៉ែត្រនិងទទឹងពី២ទៅ ២,៥ម៉ែត្រ ដើម្បីឲ្យទឹកហូរច្រោះពីលើសាកសព ។ សាកសពទាំងនេះច្រើនតែជាអ្នកជាប់និន្នាការនិងកម្មាភិបាលខ្មែរក្រហមដែលបានខុសសីលធម៌ ។ ទីតាំងនេះស្ថិតនៅចន្លោះខ្សែស្រប១២°០៧'០៥:៩៨ និងខ្សែបណ្តោយ ១០៥°១២' ១៩:០២ ។

**ខ) ទួលក្រសាំង** *លេខកូដភូមិសាស្ត្រៈ ០៣១៣០៤ ។*

ទួលក្រសាំងស្ថិតនៅក្នុងទឹកដីភូមិតាកែវ ឃុំគរ ។ ទួលនេះមានទទឹង៥០ម៉ែត្រ និងបណ្តោយ១០០ម៉ែត្រ បច្ចុប្បន្នមានដើមក្រសាំងជាសញ្ញាសម្គាល់ ។ លោក គឹម សាន់ បានប្រាប់ថា កាលពីជំនាន់ ប៉ុល ពត ទួលនេះជាទួលសម្លាប់និងកប់មនុស្ស ។ តាមការប៉ាន់ស្មានរបស់លោក គឹម សាន់ នៅលើទួលនេះមានដល់ទៅរាប់រយរណ្តៅនិងសាកសពជិត១០០០នាក់ ។ រណ្តៅនីមួយៗមានសាកសពពី៣-៥នាក់ ។ ទីតាំងនេះស្ថិតនៅខាងលិចមន្ទីរសន្តិសុខមិត្តសុបប្រហែល៥០០ម៉ែត្រ និងស្ថិតនៅខាងលិចឆៀងខាងជើងទីតាំងអូរតាគង់ ។ ទីតាំងនេះស្ថិតនៅចំណុចខ្សែស្រប១២° ០៧'០០:៨១ និងខ្សែបណ្តោយ ១០៥° ១២'០៨:២០ ។



ទីតាំងប្រឡាយអូរតាគង់

សាកសពត្រូវបានគម្រៀបនៅតាមបាតប្រឡាយនេះកាលពីជំនាន់ខ្មែរក្រហម ។

**គ) ត្នោតជួរៈ** *លេខកូដភូមិសាស្ត្រៈ០៣១៣០៥ ។*

ត្នោតជួរ ស្ថិតនៅភូមិតាកែវ ឃុំគរដែរ ប៉ុន្តែស្ថិតនៅខាងត្បូងអូរតាគង់ប្រហែលជា៥០០ម៉ែត្រនិងមានចម្ងាយប្រហែល២០០ម៉ែត្រពីមន្ទីរសន្តិសុខមិត្តសុប ។ ទួលត្នោតជួរមានទំហំដីប្រមាណ២០០ម៉ែត្របួនជ្រុងដែលមានពី៧០-៨០រណ្តៅ ហើយក្នុងមួយរណ្តៅៗមានជម្រៅពី២-៣ម៉ែត្រ និងមានទំហំ២ម៉ែត្របួនជ្រុង ។ លោក គឹម សាន់ បញ្ជាក់ថា សាកសពដែលបានស្លាប់នៅទីនោះមានប្រហែលពី២៤០ទៅ ៣០០នាក់ ។ កំណត់តាមម៉ាស៊ីនកត់ត្រាទីតាំងភូមិសាស្ត្រតាមផ្កាយរណប ទីតាំងនេះស្ថិតនៅខ្សែស្រប១២°០៦'៥១:៤៩ និងខ្សែបណ្តោយ១០៥°១២'១៨:៤៦ ។

**ឃ) ទួលដើមអំពិល**

ទួលដើមអំពិលស្ថិតនៅក្នុងភូមិតាកែវ ឃុំគរជាប់នឹងព្រំប្រទល់ភូមិតាមាសនិងនៅជាប់ជាមួយទីតាំងអូរតាគង់តែម្តង ។ បច្ចុប្បន្នមានដើមអំពិលជូរមួយដើមជាសម្គាល់ ។ លោក គឹម សាន់ និយាយថា ទួលនេះមានប្រហែល២០រណ្តៅសាកសព ។ រណ្តៅមួយៗមានទទឹង២ម៉ែត្រនិងបណ្តោយ៣ម៉ែត្រ ដែលមានផ្ទុកសាកសព ៣-៤នាក់ក្នុងមួយរណ្តៅ ។ តាមការសន្និដ្ឋានថារណ្តៅទាំង២០នេះមានសាកសពសរុបប្រហែល៨០នាក់ ។

**ង) ទីតាំងសម្លាប់នៅក្នុងសាលាបឋមសិក្សា ប៊ុនរ៉ានី ហ៊ុនសែន ឃុំគរ**

*លេខកូដភូមិសាស្ត្រៈ ០៣១៣០៧ ។*

ទីតាំងនេះស្ថិតនៅក្នុងភូមិតាម៉ូត ឃុំគរ ស្រុកព្រៃឈរ ។ នៅរវាងឆ្នាំ ១៩៧៥ដល់ឆ្នាំ១៩៧៩ អគារសិក្សានេះក្លាយទៅជាកន្លែងផ្ទុកនិងសម្លាប់មនុស្ស ។ ក្រោយឆ្នាំ១៩៧៩ អគារមួយខ្នងនេះនៅមានស្នាមឈាមប្រឡាក់ជញ្ជាំងនិងបន្សល់ទុកនូវវត្ថុតាងសម្លាប់មនុស្សដូចជាដំបងជាដើម ។ លោក គឹម សាន់បាននិយាយថា នៅក្រោយឆ្នាំ១៩៧៥ប្រជាជនត្រូវពួកខ្មែរក្រហមជម្លៀសចេញទៅភូមិផ្សេងទៀត ហើយយកប្រជាជនថ្មី (ប្រជាជន១៧មេសា) មកដាក់ជំនួសវិញ ពិសេសនៅភូមិតាកែវនិងភូមិតាមាស ។

ការស្លាក់នៅនៃប្រជាជនថ្មីមិនបានយូរទេ គឺពួកខ្មែរក្រហមដឹកយកទៅទាំងកណ្ដាលអធ្រាត្រ មកដាក់សាលាបឋមសិក្សានេះរួចហើយក៏សម្លាប់ចោលតែម្ដង ។ ប្រជាជនដែលបានដឹកមកសាលានេះសុទ្ធតែត្រូវចាញ់ពាក្យឃោសនារបស់ខ្មែរក្រហមថាឲ្យមកប្រជុំ ។ សាកសពទាំងនោះត្រូវពួកខ្មែរក្រហមអូសយកមកដាក់ក្នុងបន្ទប់មួយដែលស្ថិតនៅខាងជើងអគារទន្ទឹមគ្នាបីខ្នងប្រហែល១០០ម៉ែត្រ ។ ជនដៃដល់ក្នុងការសម្លាប់ប្រជាជនកាលណោះឈ្មោះ តែម និងឈ្មោះ ដន ។ លោក គឹម សាន់ បញ្ជាក់ថាមានសាកសពចំនួនជិត២០០នាក់ បូករួមទាំងក្នុងបន្ទប់និងលូបន្ទន់នេះផង ។ ចំណែកបរិវេណជិតបន្ទន់ប៉ែកខាងលិចក៏មានរណ្ដៅច្រើនទៀត គឺមានរណ្ដៅចំនួន៦០ក្នុងទំហំដីជាង១០០ម៉ែត្រ ។ រណ្ដៅនីមួយៗមានទទឹង១ម៉ែត្រនិងបណ្ដោយ២ម៉ែត្រ ជីកជាបីជួរក្នុងមួយជួរមាន២០រណ្ដៅ ។ សាកសពសរុបទាំងអស់មានប្រហែល២៥០នាក់ ។ **ផេង ពង្សរ៉ាស៊ី**



ប៉ុល ពត
អៀង សារី

# កំណត់ហេតុរបស់កម្មាភិបាលខ្មែរក្រហម

**(តចប់) III) ទស្សនៈនិងគោលជំហរយើង**

១) ត្រូវឃើញថាយើងឈ្នះ ទំរាយសម្រុកទាំងសមរភូមិមុខ ទាំងសមរភូមិក្រោយ ។ ទំបំពេញភារកិច្ចទោះតូចធំក៏ដោយ ។ ក្នុងស្មារតីវាយសម្រុកដែរ កុំដាច់ពីសមរភូមិ ។

២) ត្រូវពុះពារកសាងពង្រឹងគោលជំហរឯករាជ្យម្ចាស់ការ ទ្រាំទ្រការលំបាកគ្រប់យ៉ាងទាំងអស់ ។ លំបាកវេទនាខាងផ្លូវចិត្ត ខាងសម្ភារ កិច្ចការថែជន្យត្រូវទ្រាំទ្រការលំបាក ។ ឯករាជ្យម្ចាស់ការ ទ្រាំទ្រការលំបាក គោងទៅជាមួយគ្នា ។ បញ្ហាធំមិនមែនបញ្ហាបុណ្យសក្តិទេ គឺបញ្ហាភារកិច្ច ។ តើបំពេញភារកិច្ចបានល្អឬមិនបានល្អ? ចង់គិតខ្លួនឯងបុណ្យសក្តិ ប៉ះពាល់គេឯង ហើយវាអឺចេះអឺចុះ ។ ប្រុងកសាងខ្លួនឲ្យទៅជាជនក...១ល្អ ។

៣) លើកកម្ពស់ស្មារតីប្រុងប្រយ័ត្នវាយគ្រប់ឧបាយកលខ្មាំងទាំងអស់ សម្រួចស្មារតីតស៊ូលុះត្រាយកបានជ័យជំនះទាំងស្រុង ។

៤) សាមគ្គីធំទូលាយរឹងប៉ឹង ប្តូរប្រេជ្ញាគោរពអង្គការវិន័យឲ្យបាន ទោះយើងឃើញការនឹងលំបាកយ៉ាងម៉េចគោងពុះពារ ។ កុំឃើញតែខ្លួនត្រូវឬឃើញតែគេខុស ។ សាមគ្គីបានលុះត្រាតែគោរពវិន័យ ឬមួយយើងមិនតស៊ូហោប្រជុំ សាមគ្គីមិនមែនប្របូកប្របល់មិត្តភក្តិទេ គឺសាមគ្គីលើ ក.ដ.ប ។ សាមគ្គីតស៊ូតស៊ូសាមគ្គី ។

៥) ពុះពារកម្ចាត់កម្មសិទ្ធិឯកជន កម្មសិទ្ធិបុគ្គលស្ងួនតួ ។ គ្មានអ្វីជាឯកជន ជាស្ងួនតួទៀតទេ គោងគិតជាសមូហភាពជាស្ងួនរួម ។ ទោះយើងនិយាយ សិល្បករលេងល្អ គោងថាជាលទ្ធផលរបស់សមូហភាព បើពិនិត្យមិនល្អត្រូវហ៊ានទទួលខុស ។ សព្វថ្ងៃរដ្ឋយើងមានធាតុផ្តាច់ការប្រជាជនបដិវត្តន៍ ។

- ឯកជន
- ពាក់កណ្តាលរដ្ឋ ពាក់កណ្តាលឯកជន
- សមូហភាព សហករណ៍
- សង្គមនិយម រដ្ឋកាន់កាប់

**ថ្ងៃទី ២៦-៣-៧៥**

ប្រជុំចាត់តាំងគណៈវគ្គអប់រំ ២៧.៣.៧៥-២.៤.៧៥

ពត៌មានៈ ខុទ្ទេសនាមៈ បងថុង ។ ត្រៀមរៀបចំឲ្យបានល្អ ។ អប់រំទាំងអស់គ្នា ទាំងបក្ខជន យុវកក មហាជន ។ សល់ពេលប្រមូលកម្លាំងជួយ...ដោយទុកភារកិច្ចស្នួល... ។ អាចមាន មី គុងនប់ (បើមិនជាប់គណនេយ្យ) ។

ទិសដៅៈ ១) កសាងគោលជំហរនិងទស្សនៈឲ្យបានត្រឹមត្រូវតាមមាគ៌ានយោបាយនិងគោលជំហររបស់បក្សកុម្មុយនិស្តកម្ពុជាចំពោះបញ្ហាដូចតទៅៈ

- សភាពការណ៍សកលលោក
- សភាពការណ៍ប្រទេសកម្ពុជាយើងបច្ចុប្បន្ន
- ជំហរវណ្ណៈកម្មកររបស់បក្ស

កម្ចាត់គោលជំហរសន្តិភាពនិយម កម្មសិទ្ធិបុគ្គល ឲ្យអស់ពីក្រសួង ។

២) បំពាក់នូវទ្រឹស្តីនិងការដឹងយល់សម្រាប់វិភាគនិងបែងចែក ។

- វណ្ណៈនៅក្នុងសង្គមកម្ពុជា
- សភាពការណ៍បច្ចុប្បន្នទាំងនៅលើសកលលោកនិងនៅក្នុងប្រទេស
- កម្ចាត់អត្តនោម័តិនិយមក្នុងការវិភាគនិងគិតគូរពិចារណា ។

៣) លើកកម្ពស់ស្មារតីគោរពអង្គការវិន័យក្នុងបញ្ហា ។

- សាមគ្គីភាពក្នុងការចាត់តាំងនិងបំពេញភារកិច្ច
- ប្រជាធិបតេយ្យប្រមូលផ្តុំ សមូហភាពដឹកនាំ បុគ្គលទទួលខុសត្រូវ

កម្មវិធីនិងឯកសារៈ

១) សម្ភារនិយមបដិច្ចសមុប្បាទ ២៧-៣-៧៥ ។

២) សម្ភារនិយមប្រវត្តិសាស្ត្រ ២៨-៣-៧៥ ។

៣) ការបែងចែកវណ្ណៈ ទំនាស់វណ្ណៈ និងការតស៊ូវណ្ណៈក្នុងសង្គមកម្ពុជា (២៩-៣-៧៥) ។

៤) ទស្សនៈសភាពការណ៍សកលលោកនិងក្នុងស្រុក (៣០-៣-៧៥) ។

៥) កសាងនិងពង្រឹងគោលជំហរសតិអារម្មណ៍ឲ្យកាន់តែរឹងមាំតាមគោលជំហរវណ្ណៈកម្មកររបស់បក្ស (៣១.៣.៧៥) ។

៦) ពង្រឹងគោលជំហរខាងចាត់តាំងឲ្យបានល្អត្រឹមត្រូវនិងរឹងមាំ (១.៤.៧៥) ។

៧) ពុះពារកម្ចាត់ជំងឺអត្តនោម័តិ ជំងឺបុគ្គលសួនតួ លើកស្ទួយស្មារតីទទួលខុសត្រូវឲ្យខ្ពស់ ដើម្បីអនុវត្តនិងដឹកនាំអនុវត្តមាគ៌ានយោបាយរបស់អង្គការឲ្យបានល្អ សាមគ្គីធំទូលាយកម្ចាត់កម្មសិទ្ធិបុគ្គល លើកស្ទួយលក្ខការណ៍ប្រជាធិបតេយ្យប្រមូលផ្តុំ សមូហភាពដឹកនាំ បុគ្គលទទួលខុសត្រូវ (២.៤.៧៥) ។

**ចំពោះស្ថានការណ៍នេះ ការងារជាក់ស្តែង**

១) ឃើញច្បាស់ជ័យជម្នះចេញពីញើសឈាមពលិកម្មប្រជាជនយើង យុទ្ធជនយើង កុលបុត្រ កុលធីតា ក្រោមការដឹកនាំរបស់ប.ក.ក ។ ឲ្យឃើញច្បាស់គ្មានអ្នកណាមកស្រោចស្រង់យើងទេ ។ ជាភារកិច្ច ជាសតិ ឲ្យឃើញ ឲ្យច្បាស់ ។

២) ពុះពារធ្វើយ៉ាងដូចម្តេច ផ្សព្វផ្សាយជ័យជម្នះនេះឲ្យបានប្រមូលកម្លាំងជាតិទាំងមូល ហើយកម្លាំងលើអន្តរជាតិទៀត ។ ពេលយើងមានប្រៀបខាងយោធាយ៉ាងដូច្នេះការងារឯទៀតស្រួលយល់ បើយើងចេះដំណើរការ ។

ដូច្នេះវិទ្យុយើងនៅទីនេះគោងក្តាប់មាគ៌ាវណសិរ្សរបស់បក្សឲ្យជាប់ គឺអត្តន័យវាពីរម៉ាត់ៈ ធំទូលាយ-រឹងប៉ឹង ។ ត្រូវពុះពារទំមែនទែនត្រូវប្រមូលកម្លាំងធំទូលាយផងនិងរឹងប៉ឹងផង ។ ធំទូលាយគឺប្រមូលកម្លាំងប្រជាជាតិទាំងមូល ព្រោះបក្សយើងទទួលខុសត្រូវទាំងអស់ ។ ជាដំបូង ភ្លេងក្តីកុំឲ្យប៉ះសញ្ចេតនាមនុស្ស ។ ប៉ុន្តែរឹងប៉ឹងធាតុពិតកងទ័ពបដិវត្តឈ្មោះវាច្បាប់គឺ FHPLNK ។ រឹងប៉ឹងគឺផ្អែកលើកម្មករ កសិករក្រកណ្តាលក្រោម ។ វណ្ណៈនេះមានចំណុចខ្សោយ តែប្រៀបធៀបនឹងវណ្ណៈឯទៀតវណ្ណៈនេះល្អជាងគេដាច់ខាត ។ វាល្អជាមូលដ្ឋានចំរើនជាមូលដ្ឋាន ក.ជ យើងគោងដាច់ខាត ។ ដាច់ខាតឲ្យទៅជាជំហរ ហើយធ្វើការងារត្រូវឈរលើ... ។

បើមិនកែប្រែទស្សនៈនេះទៅប្រឆាំងបដិវត្តន៍យើងនៅរក្សាធាតុដើម ឪពុកម្តាយយើង ហើយអនុធនថ្នាក់លើ ។ សុំកម្ចាត់វាមែនទែន មុខជាជ្រុះតាមផ្លូវ តែហ៊ានមើលឆាយវណ្ណៈក្រីក្រ ហើយអានេះជាទស្សនៈមួយ ។ ធ្វើការនៅវិទ្យុត្រូវក្តាប់អាហ្នឹង ធ្វើការឆោកអន្តជាតិគោងក្តាប់អានេះ ។

៣) នៅនេះទាក់ទងបរទេស ។

ភារកិច្ចគឺទាក់ទងបរទេសឲ្យបានល្អ ធ្វើម៉េចឲ្យគេថាជ័យជម្នះនេះជារបស់យើង តែថាអរគុណ សរសើរមិនខ្វាចលើកទឹកចិត្តគេ ។ ព្រោះទេសកាលនឹងគេថាយើងលឿនជាងគេ ។ តែគ្មានស្មារតីខ្ញុំគេទេ គ្មានស្មារតីរណបអ្នកណាទាំងអស់ ។ ជាភារកិច្ចមួយមមាញឹក ហើយធ្វើមែនទែន ។

◆ ពិធីការ ការចាយលុយ ក្តាប់ដំណឹង=ក្តាប់ដំណឹងឲ្យបានល្អរាយការណ៍ឲ្យសត្យានុម័តិមែនទែន ដើម្បីអ្នកដឹកនាំមាន..គិតធ្វើដូម្តេចបំពេញភារកិច្ចនេះបានល្អអនាគតស្រេចលើបច្ចុប្បន្នសុំគិតអនាគតតាមបុគ្គលសួនតួ ។

**ក.ជ សតិរបស់យើងក្នុងរយៈកាលថ្មី**

១) បញ្ហាសព្វថ្ងៃគឺលើកកម្ពស់ស្មារតីតស៊ូវណ្ណៈដាច់ខាត ។

◆ លើកកម្ពស់ស្មារតីប្រុងប្រយ័ត្នបដិវត្ត

◆ លើកម្ពស់ស្មារតីចូលរួមសមូហភាព ។ ត្រូវកសាងត្រូវឈានទៅមុខទៀត យើងកុំគិតបុគ្គល ត្រូវហ៊ានឈានទៅមុខកម្ចាត់កម្មសិទ្ធិបុគ្គល ។

២) សតិអង្គការវិន័យៈ បើអ្នកស្រែកមកពីណាកុំជឿឲ្យសោះ កិច្ចការនៅទីនេះ មានអង្គការត្រូវធ្វើតាមអង្គការ ។ ផ្តាច់ការសហជីពមិនទាន់ទេ តែផ្តាច់ការប្រជាជនបដិវត្ត ។ ពេលហ្នឹងមើលមនុស្សមែនទែន រឿងអង្គការវិន័យ ។ លើសតិភ្លើតភ្លើន ។

៣) ប្រឆាំងដាច់ខាត សន្តិភាពនិយម សេរីនិយម ។ កសាងជំហរសុភាពរាបសារបដិវត្ត ជាជំហរអធន គឺជំហរវណ្ណៈកម្មកររបស់បក្ស ។

**ខ្ញុំចេញទៅជាការសម្ងាត់ដាច់ខាត ។**

បងរ៉ាៈ ទទួលខុសត្រូវរួម ត្រូវគោរពដាច់ខាតត្រូវរក្សាការសម្ងាត់ដាច់ខាត អ្នកណាចង់ខឹង១ទៅកុំខ្វាចគេវិនិច្ឆ័យយើងបានឲ្យសោះ ។

គង់ៈ ផ្សាយតាមដំណឹងច្បាស់មែនទែន កុំទៅនិយាយប្រាប់អ្នកណាឲ្យសោះ ។

ខុនៈ គិតគូរខាងពិធីការផង ហើយជួយតាមដានដំណឹង...ចាំបងរ៉ាបញ្ញាក់ ។

បញ្ញាក់ៈ ការតស៊ូវណ្ណៈវាស្រួចស្រាល់ណាស់ពេលនេះ ។

# តួនាទីដែលគួរឱ្យសង្ស័យរបស់ស្ថានទូតចិននៅទីក្រុងហាណូយ ១៩៧៨

**(តចប់)** ខាងក្រោមនេះគឺជាចម្លើយសារភាពរបស់ឆ្នាំក្រហមវ័យក្មេងម្នាក់ឈ្មោះ លឿង ធានកុ ។ (លឿង ធានកុ កើតនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៦០ មានដើមកំណើតជាជនជាតិចិនមកពីកុងទុង សព្វថ្ងៃរស់នៅផ្ទះលេខ៤៤-អា វិថីហាងប ស្រុកហ័ន កៀម ទីក្រុងហាណូយ)៖ «វង់ មែន ហា ធ្លាប់បបួលខ្ញុំទៅលេងផ្ទះគាត់លេខ៣៨ វិថី ហាង ហ្សៀក ទៅស្តាប់ចម្រៀងល្បីៗមកពីបស្ចិមប្រទេស និងអានប្រលោមលោកចិននិងរូបភាពអាសអាភាសដែលគាត់យកមកពីសៃហ្គន ។ មិនតែប៉ុណ្ណោះនៅមានសៀវភៅ កាសែត និងទស្សនាវដ្តីរូបភាពជាច្រើនក្បាលទៀតដែលគាត់បានមកពីស្ថានទូតចិន ។»

«ឪពុករបស់ខ្ញុំប្រាប់ថាប្រពន្ធរបស់ ហា ឈ្មោះ ផាន អាយធៀន គឺជាក្មួយស្រីរបស់គាត់ ហើយថា ម្តាយក្មេករបស់ ហា បានផ្លាស់លំនៅដ្ឋានមកពីវៀតណាមនៅឆ្នាំ១៩៥៤ ហើយបានបើកតៀមលក់ភេសជ្ជៈនៅផ្ទះលេខ៣៧ វិថី លី ធឿង គាតនៅឆ្នេរសមុទ្រ វង់ តៅ ។ ក្រោយពីមានជ័យជម្នះឆ្នាំ១៩៧៥ គាត់ក៏ភៀសខ្លួនទៅរដ្ឋហាវ៉ៃ ហើយរៀបការជាមួយបុរសម្នាក់ជាជនជាតិអាមេរិកាំង ។ ជាញឹកញយ គាត់តែងតែផ្ញើរបស់របរមកឲ្យ ហា និងប្រពន្ធ។ ហា តែងតែដំណាលប្រាប់ខ្ញុំ ដោយរីករាយអំពីជីវភាពរស់នៅធូរធារនៅក្នុងប្រទេសទាំងឡាយដែលអាណិកជនចិនរស់នៅរកស៊ី ។ នៅចុងបញ្ចប់គាត់និយាយថាគាត់នឹងមិនឲ្យឱកាសរបស់មាតុភូមិដែលបើកចំហឲ្យអាណិកជនចិនរស់នៅវៀតណាមកន្លងផុតទៅឡើយ ពីព្រោះគ្មានអ្នកណាហាមឃាត់យើងមិនឲ្យទៅប្រទេសផ្សេងៗទៀតក្រោយពីវិលត្រឡប់មកពីប្រទេសចិនទេ ។ គាត់បន្ថែមទៀតថា ចំពោះរឿងខ្ញុំអាជ្ញាធរចិននឹងរៀបចំការចេញដំណើររបស់ខ្ញុំយ៉ាងឆាប់រហ័ស ពីព្រោះខ្ញុំមានសាច់ញាតិបងប្អូនរស់នៅសហរដ្ឋអាមេរិកនិងកាណាដា ពោលគឺមានការធានាយ៉ាងពិតប្រាកដនៅក្នុងការធ្វើអន្តោប្រវេសន៍នេះ ។»

«វង់ មែន ហា អាចនិយាយភាសាចិនកុំងតុង និងចិនកុកងឺបានយ៉ាងរអិល ។ យូរៗម្តងគាត់បាននាំខ្ញុំទៅស្ថានទូតចិនដោយនិយាយថា៖ ឯងត្រូវមកទីនេះមកជួយធ្វើការនៅស្ថានទូត ។ ឯងត្រូវធ្វើឲ្យអស់ពីកម្លាំងកាយចិត្តដើម្បីមាតុភូមិ ។ ឥឡូវនេះមាតុភូមិកំពុងតែអំពាវនាវដល់ជនជាតិហ៊័ររស់នៅក្នុងប្រទេសវៀតណាមត្រឡប់មកវិញ និងចូលរួមការកសាងជាតិដើម្បីឲ្យយើងទាំងអស់គ្នាអាចចេញទៅបានឆាប់រហ័ស ។ ទៅកាន់តែឆាប់កាន់តែល្អ ។ យុវជនវ័យក្មេងដូចជាឯងគួរតែទៅមុន ។ បើឯងនៅ មិនយូរមិនឆាប់ឯងនឹងត្រូវបង្ខំឲ្យចូលជាពលរដ្ឋវៀតណាមមិនខាន ។ មិនដឹងជាអន់យ៉ាងណាទេដែលជាតិធំត្រូវចូលសញ្ជាតិវៀតណាមនោះ ។»

«ខ្ញុំនៅចាំបានថានៅដើមសប្តាហ៍ទីពីរនៃខែឧសភា ឆ្នាំ១៩៧៨ ហា បាននាំខ្ញុំទៅស្ថានទូតចិន ដើម្បីយកសំណុំបែបបទទៅបំពេញសុំទិដ្ឋាការ ។ មើលទៅគាត់និងមិត្តភក្តិយ៉ាងច្រើននៅស្ថានទូតអាចឲ្យដឹងថា គាត់មកស្ថានទូតជាញឹកញយណាស់ ។ ហា បានយកសំណុំបែបបទមួយដុំមាន២០ច្បាប់ ហើយឲ្យខ្ញុំមួយច្បាប់ ក្រៅពីនោះគាត់យកទៅ ហៃហ្វុង យកទៅលក់ឲ្យជនជាតិហ៊័រដែលត្រូវទទួលរងនូវការបំភ័យថាមានសង្គ្រាមនិងត្រូវបំបែកឲ្យចាកចេញពីប្រទេសវៀតណាមក្នុងពេលឆាប់ៗនេះ ។»

«ពីរបីថ្ងៃក្រោយមក ហា បាននាំខ្ញុំទៅស្ថានទូតម្តងទៀត ប៉ុន្តែមិនត្រឹមតែសុំទិដ្ឋាការទេ ថែមទាំងយកសំណុំបែបបទទិដ្ឋាការទៅលក់ទៀតផង ។ ហា ត្រូវបានទទួលដោយអគ្គរដ្ឋទូតចិនឈ្មោះ ជី ហ្វាង ដែលប្រាប់គាត់យ៉ាងលម្អិតនិងហ្មត់ចត់ថា តែហ៊ាន ក្លាត់តែបន្តិចនឹងគ្រោះថ្នាក់ដល់ផែនការយើងជាមិនខាន ។ ឯកអគ្គរដ្ឋទូតបន្ថែមទៀតថាប្រសិនបើមានអ្វីកើតឡើងនៅពេលយើងដើរ ល្បិចនេះយើងត្រូវរាយការណ៍ជាបន្ទាន់មកគណៈកម្មាធិការដឹកនាំដើម្បីសុំជំនួយ ។»

«ខ្ញុំបានវាយឯកសារឃោសនាដល់សិស្សនិងជនជាតិហ៊័រដោយម៉ាស៊ីនអង្គុលីលេខដែលប៉ាខ្ញុំបានខ្ចីពីមន្ទីរ ។ វង់ មែន ហា បានប្រាប់ខ្ញុំឲ្យគោរពរាល់សេចក្តីណែនាំទាំងឡាយមកពីឯកអគ្គរដ្ឋទូតវិសាមញ្ញនិងពេញសមត្ថភាព ជិន ជី ហ្វាង ដាច់ខាតទោះបីជាមានការលំបាក គ្រោះថ្នាក់ និងការលះបង់អ្វីក៏ដោយចុះ ។

## (តពីលេខមុន) ការបោសសម្អាតចុងក្រោយបង្អស់

ខែកញ្ញា ឆ្នាំ១៩៧៨ ភូមិភាគបូព៌ាត្រូវបាន"បោសសម្អាត" ។

ខែចុងក្រោយរបស់កម្ពុជាប្រជាធិបតេយ្យគឺនៅពេលដែលមានការប៉ុនប៉ងពោរពេញដោយក្តីអស់សង្ឃឹមពីសំណាក់របបនេះក្នុងការស្វែងរកការគាំទ្រផ្នែកយោធាពីប្រទេសចិននិងបផ្អែកផ្អែកនយោបាយពីប្រទេសមិនមែនកុម្មុយនិស្តនានា នៅក្នុងខណៈដែលរបបនេះកាត់បន្ថយទិដ្ឋភាពឃោរឃៅរបស់ខ្លួន ។ ការបោសសម្អាតចេះតែបន្ត ប៉ុន្តែមិនសូវជាខ្លាំងក្លាប៉ុន្មានទេ ។ នៅក្នុងដំណើរការបោសសម្អាតនេះកន្លងមក មុខសញ្ញាដែលត្រូវបោសសម្អាតគឺបុគ្គលដែលមិនគួរឲ្យទុកចិត្ត ។ អ្នកទោសត្រូវបានយកមកដាក់មន្ទីរស-២១ដោយចាប់មកពីផ្លូវរថភ្លើង រោងចក្រ និងសូម្បីតែអ្នកមកពីភូមិភាគនិរតីដែលមានភក្តីភាពក៏ចាប់ដែរ ។ ភូមិភាគនិរតីជាកន្លែងរបស់ "បញ្ញវន្ត" ឈ្មោះ តាម៉ុក ដែលមានការផ្តោតយ៉ាងហ្មត់ចត់និងស្អប់ជនបរទេសធ្វើជាមេបញ្ជាការអស់រយៈពេលជាច្រើនឆ្នាំ ។ មកដល់ឆ្នាំ១៩៧៨ កម្មកររោងចក្រត្រូវបានចាប់បញ្ជូនមកមន្ទីរស-២១ ជាមួយនឹងឈ្លើយសឹកវៀតណាមជាច្រើនរយនាក់ ។ វន វ៉េត ដែលជាឧបនាយករដ្ឋមន្ត្រីនិងជាអ្នកធ្វើការជាមួយនឹង តាម៉ុក យូរណាស់មក ហើយនិង ចេង អន ដែលជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកផ្នែកឧស្សាហកម្ម ក៏ត្រូវបានបោសសម្អាតដែរ គឺនៅក្នុងខែវិច្ឆិកា ដោយត្រូវបានចោទប្រកាន់ពីបទរៀបចំគម្រោងផែនការក្បត់ធ្វើរដ្ឋប្រហារ និងប្រមែប្រមូលកម្មកររោងចក្រដែលជាអតីតពលទាហាន ។ ក្រុមយុវជនក្មេងៗដែលមានការរៀបចំត្រឹមត្រូវ ឥឡូវក្លាយទៅជាសំបុកជនក្បត់យ៉ាងធំ ។

នៅខែធ្នូ ការសង្ស័យបានធ្លាក់មកលើ សុន សេន ដែលត្រូវបានឲ្យធ្វើជាលេខាភូមិភាគបូព៌ា បន្ថែមពីលើភារកិច្ចមួយចំនួនទៀតក្រោយពី សោ ភឹម ធ្វើអត្តឃាត ។ សុន សេន ប្រហែលជាត្រួតពិនិត្យគ្រប់គ្រងប្រតិបត្តិការនៅមន្ទីរស-២១មិនសូវបានមាំទាំនិងដិតដល់ដូចសព្វមួយដងទេ ដោយសារតែការទទួលខុសត្រូវថ្មីៗទាំងនេះ ព្រមទាំងទទួលបន្ទុកវាយជាមួយវៀតណាមផង ។ សុន សេន ធ្លាប់បានធ្វើការយ៉ាងជិតដិតជាមួយនឹង វន វ៉េត ចាប់តាំងពីមានសង្គ្រាមស៊ីវិលមកម្ល៉េះ ហើយភ័ស្តុតាងវាយប៉ាយនានាបានបង្ហាញថាអ្នកទាំងពីរនេះអាចនឹងកំពុងគិតធ្វើរដ្ឋប្រហារការពារខ្លួនឯងប្រឆាំងនឹងមជ្ឈិមបក្ស ។ ការឈ្លានពានរបស់វៀតណាមនិងការដួលរលំនៃកម្ពុជាប្រជាធិបតេយ្យប្រហែលជាបានជួយសង្គ្រោះជីវិត សុន សេន ។



សម្លេងពីមន្ទីរ ស-២១
ខគ្គទី៤: បង្កើតសំណួរសម្រាប់ទម្លាក់កំហុស
ដោយសាស្ត្រាចារ្យ ដេវីដ ឆេនដល័រ

បើគ្មានអន្តរាគមន៍វិសាមញ្ញរបៀបនេះទេ ម្ល៉េះគ្មានយន្តការណាមួយនៅមន្ទីរស-២១ ឬនៅក្នុងមជ្ឈិមបក្សអាចបញ្ឈប់ឬរារាំងដំណើរការ "បោសសម្អាត" ឡើយ ។ រាល់បទបញ្ជាឲ្យធ្វើរបៀបនេះគឺសុទ្ធតែចេញមកពី "បងថ្នាក់លើ"ទាំងអស់ ។ មកដល់ប៉ុន្មានខែចុងក្រោយនៃឆ្នាំ១៩៧៨ គ្មានឃើញបទបញ្ជាធ្លាក់ចុះមកទៀតទេ ។ នៅពេលដែលអ្នកទោសជាមុខសញ្ញាទូទៅកាន់តែមានចំនួនថយចុះ មនុស្សដែលជាមុខសញ្ញាបន្ទាប់គឺកម្មាភិបាលជាន់ខ្ពស់ ។ នៅពេលស្ថានការណ៍នៅទូទាំងប្រទេសកាន់តែដុនដាបទៅៗ ការសង្ស័យបានកើតមានកាន់តែខ្លាំងនៅក្នុងជួរថ្នាក់លើរបស់បក្ស ហើយនៅពេលដែលការវាយប្រហារជាមួយវៀតណាមមានលទ្ធផលមិនល្អ គឺត្រូវតែមានអ្នកទទួលថ្មបាក់ជាពុំខាន ។ ជាក់ស្តែងនៅពេលមនុស្សថ្នាក់ក្រោមនៃបក្សកុម្មុយនិស្តកម្ពុជាត្រូវបានកម្ចាត់ចោល ការសង្ស័យមកលើឥស្សរជនជាន់ខ្ពស់ចេះតែកើនជាលំដាប់ ។ សូម្បីតែ តាម៉ុក និងកម្មាភិបាលមកពីភូមិភាគនិរតីស្ថិតនៅក្រោមបញ្ជារបស់ តាម៉ុក ក៏ស្ថិតនៅក្រោមការតាមដានដែរនៅក្នុងអំឡុងសប្តាហ៍ចុងក្រោយនៃការបញ្ចប់របបនេះ ។ តើអ្នកណានឹងចូលខ្លួន

មកទៀត? តើការធ្វើទុក្ខបុកម្នេញនឹងត្រូវបញ្ចប់នៅកន្លែងណា? ការបោសសម្អាតទាំងអស់បង្កើតបានជាគំនិតមួយគួរឲ្យញាក់សាច់ៈ តើធ្វើយ៉ាងដូចម្តេចទើបអាចដឹងឲ្យប្រាកដថាខ្មាំងលាក់មុខត្រូវបានរកឃើញនោះ? បក្សកុម្មុយនិស្តដែលមានទ្រង់ទ្រាយធំ មានបទពិសោធន៍ច្រើន និងមានការទុកចិត្តលើខ្លួនឯងថាអាចមានលទ្ធភាពចាត់ចែងការបោសសម្អាតនៅពេលដែលការបោសសម្អាតនេះពិបាកគ្រប់គ្រង ។ កិច្ចខិតខំប្រឹងប្រែងដែលមានការយឺតយ៉ាវទាក់ទងនឹងបញ្ហានេះ ត្រូវបានធ្វើឡើងនៅប៉ុន្មានខែចុងក្រោយក្នុងឆ្នាំ១៩៧៨ នៅពេលដែលចំនួនអ្នកទោសដែលត្រូវនាំចូលមកមន្ទីរស-២១ធ្លាក់ចុះយ៉ាងខ្លាំង ។ ក៏ប៉ុន្តែមជ្ឈិមបក្សនៅតែមានអារម្មណ៍ថាមានខ្មាំងនៅជុំវិញខ្លួន ។ មានភ័ស្តុតាងគ្រប់គ្រាន់មកពីមន្ទីរស-២១បញ្ជាក់ករណីនេះៈ បេសកកម្មរបស់សន្តិបាលគឺបញ្ជាក់ច្បាស់លាស់អំពីការសង្ស័យដ៏អាក្រក់បំផុតរបស់មជ្ឈិមបក្ស ។ ក្រោយពីការលុកលុយរបស់វៀតណាមនៅក្នុងអំឡុងឆ្នាំ១៩៧៧-៧៨ និងការបោសសម្អាតនៅក្នុងភូមិភាគបូព៌ា មជ្ឈិមបក្សត្រូវបានរំខានដោយសារការភ័យខ្លាចនិងការប្រញាប់ប្រញាល់ខ្លាចយឺតពេល ។

របបដែលពោរពេញទៅដោយភេរវកម្មនិងបដិវត្តន៍មិនចេះចប់ (នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ) ត្រូវការខ្មាំងមកធ្វើជាចំណីជាបន្តបន្ទាប់ ។ នៅពេលដែលខ្មាំងទាំងនេះបង្កប់ជាក្រុមតូចមួយនៅក្នុងបក្សនយោបាយដែលគ្មានបទពិសោធន៍និងមិនអាចបែកដាច់ពីប្រជាជនភាគច្រើននៃប្រជាជនទាំងអស់ក្នុងការប៉ុនប៉ង បោសសម្អាតខ្មាំងទាំងអស់របស់ខ្លួន អាចជះឥទ្ធិពលប្រកបដោយគ្រោះថ្នាក់ ។ ដូចជា ឌុច និងបក្ខពួកដែលធ្វើអ្វីតាមការបញ្ជាអ៊ីចឹងដែរ ពោលគឺអ្នកទាំងនេះបានធ្វើឲ្យអន្តរាយដល់ប្រសិទ្ធភាពយោធារបស់កម្ពុជា រំសាយរចនាសម្ព័ន្ធរដ្ឋបាលរបស់ប្រទេសនិងកម្ទេចបក្ស ។ ក្បាលម៉ាស៊ីនឃាតកម្មនៅមន្ទីរស-២១ត្រូវបានធ្វើឲ្យមានតុល្យភាពតាមរយៈការពិតដែលថាឥស្សរជនជាន់ខ្ពស់បំផុតរបស់បដិវត្តន៍ត្រូវបានចាប់ខ្លួន នៅពេលដែលបក្សត្រូវការកម្មាភិបាលដែលមានបទពិសោធន៍ ដើម្បីបង្កើតជារណសិរ្សរួបរួមជាតិមួយក្នុងការទប់ទល់អធិករណ៍ជាមួយនឹងវៀតណាម ។ នៅចុងឆ្នាំ១៩៧៨ ថ្នាក់ដឹកនាំរបស់បក្សនៅតាមភូមិភាគ ភាគច្រើនបានដួលរលំ ហើយ តាម៉ុក ក៏កាន់មុខតំណែងបញ្ជាការនៅក្នុងភូមិភាគជាច្រើនក្នុងពេលតែមួយ ។

នៅពេលដែលវៀតណាមធ្វើការវាយលុកចូលមកនៅចុងខែធ្នូ ឆ្នាំ១៩៧៨ គណៈកម្មាធិការមជ្ឈិមបក្សនៃបក្សកុម្មុយនិស្តកម្ពុជាត្រូវបានកម្ចាត់ ។ លើកលែងតែ តាម៉ុក មួយចេញក្រៅពីនោះ លេខាភូមិភាគដែលធ្វើការតាំងពីមុនមក ព្រមទាំងអ្នកដែលមកជំនួស ភាគច្រើនត្រូវបានបោសសម្អាតទាំងអស់ ហើយចំពោះអ្នកគ្រប់គ្រងស្ទើរតែគ្រប់រោងចក្រនិងមន្ទីរពេទ្យរដ្ឋព្រមទាំងកម្មាភិបាលយោធារាប់រយនាក់ទៀត ក៏ទទួលរងសនាដូចគ្នានេះដែរ ។ នៅចុងឆ្នាំ១៩៧៨ គ្មានបុគ្គលមានបទពិសោធន៍គ្រប់គ្រាន់សម្រាប់ដឹកនាំប្រទេសទេ ហើយក៏គ្មានមេដឹកនាំយោធាសម្រាប់រៀបចំ ឲ្យមានការការពារមាំទាំដែរ ។ នៅឆ្នាំ១៩៩៧ ម៉ៃ ម៉ាន់ ដែលធ្លាប់ធ្វើជាជនកុម្មុយនិស្ត បានរំឭកអំពីរបបនោះប្រាប់លោក ស្ទីវ ហេឌ័រ ថា “ម្នាក់ៗគិតតែពីចោទគ្នាទៅវិញទៅមកថា អ្នកនេះក្បត់ អ្នកនោះក្បត់ ហើយគ្មានអ្នកណាម្នាក់ដឹងថាមានអ្វីកើតឡើងពិតប្រាកដឡើយ” ។

នៅក្នុងខែកក្កដា ឆ្នាំ១៩៩៧ នៅពេលដែល ប៉ុល ពត ត្រូវបានកាត់ទោសនៅឯមូលដ្ឋានអន្លង់វែង (ដែលជាការគួរឲ្យអស់សំណើច ចំពោះទោសឧក្រិដ្ឋរបស់ ប៉ុល ពត គឺការបញ្ជាឲ្យសម្លាប់ សុន សេន) មានអ្នកចោទប្រកាន់ម្នាក់ក្នុងចំណោមអ្នកចោទប្រកាន់មួយចំនួនទៀតបានស្តីបន្ទោស ប៉ុល ពត ថាបានជំរុញឲ្យមានការមិនទុកចិត្តជាទូទៅនៅក្នុងចំណោមអ្នកដើរតាមខ្លួន ។ ទោះបីជាការចោទប្រកាន់បានផ្តោតសំខាន់តែទៅលើទសវត្សរ៍ឆ្នាំ១៩៩០ក៏ដោយ ក៏ប៉ុន្តែការប្រើពាក្យច្បាស់ៗតាមរយៈការយល់ឃើញក្រោយពីមានហេតុការណ៍កើតឡើង បានបង្ហាញចេញនូវឥទ្ធិពលប្រកបដោយហាយនភាពមួយចំនួននៅក្នុងមន្ទីរស-២១ដូចតទៅនេះៈ “ប៉ុល ពត យល់ថា ខ្មាំងសត្រូវគឺជាសាច់ស្អុយរលួយ ជាសាច់ហើមប៉ោង ។ សត្រូវនៅជុំវិញ ។ សត្រូវនៅពីមុខ សត្រូវនៅពីក្រោយ សត្រូវនៅខាងជើង សត្រូវនៅខាងត្បូង សត្រូវនៅខាងលិច សត្រូវនៅខាងកើត សត្រូវនៅគ្រប់ទិសទី សត្រូវមកពីទិសទាំងប្រាំបីប្រាំបួនទិស រុំជុំជិតគ្មានកន្លែងដកដង្ហើម ។ ប៉ុល ពត បានឲ្យយើងពង្រីងស្មារតី ពង្រឹង

*គោលដៅហរ ពង្រឹងហើយពង្រឹងទៀត រួមទាំងវិធានការសម្លាប់មនុស្សក្នុងជួរខ្លួនឯង...សូម្បីតែអ្នកតស៊ូនៅក្នុងជួរតែមួយនៅក្នុងចលនានេះក៏យ៉ាងដូច្នោះដែរ» ។*

*នៅចន្លោះឆ្នាំ១៩៧៥និងការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ «ខ្មាំង» រាប់សែននាក់ត្រូវបានចាប់ខ្លួននិងសម្លាប់ចោលនៅទូទាំងប្រទេស ។ យ៉ាងហោចណាស់មានមនុស្សចំនួនមួយសែនបួនម៉ឺននាក់ត្រូវបានឃុំខ្លួន សួរចម្លើយ ធ្វើទារុណកម្មនិងសម្លាប់ចោលដោយសន្តិបាល ។ ប្រសិនបើការវាយលុករបស់វៀតណាមត្រូវបានពន្យារពេលនោះ ម៉្លេះសមដំណើរការបំផ្លិច*



*រូបថតនៅមន្ទីរស-២១*



**ហេង ណាត ឬ វ៉ាន់ ណាត**
**នាពេលបច្ចុប្បន្ន**

*បំផ្លាញនៅមន្ទីរស-២១មិនអាចទាយទុកបានទេ ។ «កង់ប្រវត្តិសាស្ត្រ» ចេះតែវិលទៅមុខដាន់អ្នករាល់គ្នា ហើយមិនអាចទប់បានឡើយ ។ មិនតែប៉ុណ្ណោះអ្នកសួរចម្លើយនៅគុកទួលស្លែងដែលត្រូវបានចាប់ខ្លួន នៅពេលនោះបានត្អូញត្អែរនៅក្នុងចម្លើយសារភាពរបស់ខ្លួនថា «ប្រសិនបើអង្គការគិតតែពីចាប់ អ្នកណាក៏ចាប់ដូច្នេះ តើបានអ្នកណាធ្វើបដិវត្តន៍?» ។*

## បង្កើតសំណួរសម្រាប់ទម្លាក់កំហុស

*នៅខែមករា ឆ្នាំ១៩៧៨ ហេង ណាត ហៅ វ៉ាន់ ណាត ដែលជាវិចិត្រករអាជីព នៅខេត្តបាត់ដំបងត្រូវចាប់ខ្លួននិងសួរចម្លើយអស់រយៈពេលជាច្រើនថ្ងៃមុននឹងដាក់ឡោះបញ្ជូនមកមន្ទីរស-២១ ។ ក្នុងឆ្នាំ១៩៧៨ វ៉ាន់ ណាត មិនដឹងថា ហេតុអ្វីបានជាគាត់ត្រូវចាប់ខ្លួនឡើយ ។ មកទល់សព្វថ្ងៃនេះក៏គាត់នៅតែមិនទាន់ដឹងនៅឡើយ ។ និយាយទៅកាន់អ្នកស្រាវជ្រាវឈ្មោះសាវ៉ាខូម ក្នុងឆ្នាំ១៩៩៥ វ៉ាន់ ណាត បានរំឭកដល់ការសួរចម្លើយលើកទី១ ដូចតទៅៈ អ្នកសួរចម្លើយបានសួរខ្ញុំថា «តើមានបញ្ហាអ្វីបានជាគេចាប់អ្នកឯងមក?» ។ ខ្ញុំមិនដឹងដែរ ។ «អង្គការមិនមែនមិនដឹងអីទេ ។ អង្គការមិនដែលចាប់មនុស្សដែលគ្មានកំហុសទេ ។ ឥឡូវគិតម្តងទៀត ។ តើអ្នកឯងធ្វើអ្វីខុស?» ខ្ញុំឆ្លើយថា«ខ្ញុំមិនដឹងទេ» ។*

*អ្នកទោសជាច្រើននាក់ផ្សេងទៀតនៅមន្ទីរស-២១ត្រូវបានបង្ខំឲ្យពន្យល់ហេតុផលនៃការចាប់ខ្លួន និងមូលហេតុដែលធ្វើឲ្យខ្លួនមានកំហុស ។ ហ្វូស្កា ខេ និយាយនៅក្នុងសំណេររបស់ខ្លួនថា អ្នកទាំងនោះមិនមែនត្រូវចោទប្រកាន់ដោយសារខ្លួនមានកំហុសទេ ប៉ុន្តែមានកំហុសដោយសារការចោទប្រកាន់ ។ សំណួរគឺធ្វើឡើងដើម្បីដាក់ឲ្យអ្នកទោសស្ថិតនៅក្នុងគ្រោះថ្នាក់និងភាពមិននឹងនប៉ុន្តែអ្នកសួរចម្លើយខ្លួនឯងជាញឹកញាប់ពិតជាចង់ដឹងមែននិងមានចិត្តស្មោះត្រង់ ។ អ្នកសួរចម្លើយជឿជាក់ថាអ្នកទោសមានកំហុស ប៉ុន្តែមិនដឹងថា បទល្មើសអ្វីដែលខ្លួនត្រូវរកឲ្យឃើញទេ ។ សំណួរទី១ដែលលំបាកសម្រាប់អ្នកសួរចម្លើយ និងអ្នកឆ្លើយ*

ដូចរៀបរាប់ខាងលើគឺទាក់ទងនឹងបច្ចេកទេសក្នុងការសួរចម្លើយ ដែលប្រើដោយមន្ត្រីនគរបាលនៅគ្រប់ទីកន្លែង ហើយសូម្បីតែរបបកុម្មុយនិស្តមួយចំនួនក៏យកវិធីសាស្ត្រនេះមកប្រើប្រាស់ដែរ ។ ដូចជា នៅក្នុងសហភាពសូវៀតនិងប្រទេសចិនដែលប្រកាន់យកលទ្ធិកុម្មុយនិស្ត "ទោស" ដែលថា អ្នកទោសបានលាក់បាំង គឺកើតចេញពីគំនិតរបស់អ្នកចោទប្រកាន់តែប៉ុណ្ណោះ ។ ភារកិច្ចរបស់អ្នកសួរចម្លើយគឺធ្វើឲ្យស្របតាមសាលក្រមរបស់បក្ស ដោយដកស្រង់នូវចម្លើយសារភាពមានលក្ខណៈពេញលេញ ។ ឯកសារទាំងនេះដែលត្រូវបានរៀបចំសព្វគ្រប់ហើយបានក្លាយជាអត្ថបទប្រវត្តិសាស្ត្រដែលប្រហែលជាបង្ហាញពីទំនាក់ទំនងនៃ "គោលបំណង" របស់អ្នកទោសទៅនឹងកំហុសធ្ងន់ធ្ងរផ្សេងៗ ការយកចិត្តទុកដាក់របស់បុគ្គលិកនៅមន្ទីរស-២១ និងអ្នកប្រាជ្ញទ្រង់ញាណនៃបក្ស ។

ក្រៅពីគំរូកុម្មុយនិស្តទាំងនេះ ក៏មានបច្ចេកទេសប្រហាក់ប្រហែលគ្នាមួយចំនួនទៀតរវាងបច្ចេកទេស ដែលប្រើប្រាស់នៅមន្ទីរស-២១ និងបច្ចេកទេសប្រើនៅក្នុងការជម្រះក្តីនាសតវត្សរ៍ទី១៧នៅប្រទេសអេស្ប៉ាញ របបកាន់កាប់នៅប្រទេសបារាំងដែលពោរពេញទៅដោយភេរវកម្មនៅក្នុងទសវត្សរ៍ឆ្នាំ១៧៩០ និងកាន់តែប្រហាក់ប្រហែលជាងនេះទៀតគឺនៅក្នុងដំណាក់កាល "បុរាណវត្ថុវិទ្យា" នៃចិត្តវិភាគរបស់ ហ្វ្រើដ ។ ហ្វ្រើដ បានកត់សម្គាល់ទៅលើចំណុចមួយក្នុងចំណោមចំណុចដែលមានលក្ខណៈដូចគ្នាទាំងប៉ុន្មាននេះ ។ សរសេរទៅកាន់មិត្តភក្តិរបស់គាត់ ឈ្មោះ វីល ហេមវ្លេស នៅក្នុងខែមករា ឆ្នាំ១៨៩៧ ហ្វ្រើដ បានសួរថា "ហេតុអ្វីបានជាចម្លើយសារភាព (ក្រោមការធ្វើទារុណកម្ម) ក្រោមការសួរចម្លើយមានលក្ខណៈដូចគ្នាម្ល៉េះ ទៅនឹងការប្រាស្រ័យទាក់ទងគ្នារបស់អ្នកជំងឺដែលខ្ញុំព្យាបាលជំងឺផ្លូវចិត្ត" ។

ចម្លើយទៅនឹងសំណួររបស់ ហ្វ្រើដ អាចស្ថិតនៅក្នុងទំនាក់ទំនងដែលមានភាពទុកចិត្តនិងលម្អៀងតែម្ខាងរបស់ចៅក្រមអ្នកសួរចម្លើយនិងអ្នកវិភាគជាច្រើននាក់ចំពោះអ្នកទោសនិងអ្នកជំងឺ ។ ជាងនេះទៅទៀត ជាញឹកញយអ្នកវិភាគនិងអ្នកសួរចម្លើយអះអាងថាបានដឹងនូវអ្វីដែលខ្លួនកំពុងតែស្វែងរក ចំណែកឯអ្នកជំងឺនិងអ្នកទោសវិញមិនដឹងថាអ្វីទៅដែលត្រូវ"លាក់បាំង" ទេ ។ វីរបុរសមួយរូបក្នុងចំណោមវីរបុរសនានារបស់ ហ្វ្រើដ គឺបុរាណវិទូឈ្មោះ ហេន រិកឆ្លីមែន ដែល"ដឹង" អំពីទីតាំងរបស់ទីក្រុងត្រូយ (Troie) ហើយនៅពេលដែលជីកទៅឃើញថាត្រឹមត្រូវដូចគាត់ថាមែន ។ គួបផ្សំជាមួយនឹងការគាបសង្កត់ផ្សេងៗទៀត រួមទាំងការសួរចម្លើយផង អ្នកសួរចម្លើយយ៉ាងស្ទាត់ជំនាញនៅមន្ទីរស-២១អាចអន្ទោកអន្ទងការចងចាំដែលមានទំនាក់ទំនងបន្តិចបន្តួច ឬក៏គ្មាន ទៅនឹង "ការពិតជាប្រវត្តិសាស្ត្រ" ។ នៅក្នុងករណីខ្លះ អ្នកទោសចេះតែផ្សំផ្គុំបង្កើតការចងចាំឡើងដើម្បីតម្រូវចិត្តអ្នកសួរចម្លើយ និងដើម្បីបញ្ជាក់ថាអ្វីដែលនិយាយចេញនេះគឺពិតជាត្រឹមត្រូវឥតក្លែងបន្លំ ។ បញ្ហាស្មុគស្មាញផ្សេងៗការចងចាំ "ដែលត្រូវបានទឹកឃើញឡើងវិញ" និងការផ្ទេរពេលនោះ ក៏លេចចេញជារូបរាងឡើង ។

នៅមន្ទីរស-២១ មានអ្នកទោសមួយចំនួនមានជំនឿថាខ្លួនឯងពិតជាមានកំហុសពីបទប្រឆាំងនឹងបដិវត្តន៍ ។ នេះគ្មានអ្វីគួរឲ្យភ្ញាក់ផ្អើលទេ ពីព្រោះនៅក្រោមសភាពតឹងតែងដូចដែល រីឆាត អហ្ស៊ី និង អ៊ី ថាន វ៉ែតធ័រ បានសរសេរនៅក្នុងបរិបទផ្សេងទៀតគឺ "យើងមានបំណងចង់បង្កើតរឿង "ហេតុនិងផល" ចេញពីជីវិតយើង ហើយ...នៅពេលដែលយើងគ្មានលទ្ធភាពធ្វើបែបនេះ យើងនឹងងាយទទួលរងបំផុតនូវការឲ្យយោបល់ពីអ្នកដទៃ" ។ នៅពេលជាមួយគ្នានេះដែរ ដូចដែលមានជំនឿសុសសាយនៅក្នុងសហភាពសូវៀតនាទសវត្សរ៍ឆ្នាំ ១៩៣០ ការប្រឆាំងនឹងបដិវត្តន៍នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យមិនមែនជាសកម្មភាព ប៉ុន្តែជា"សភាពនៃចិត្តដែលចេញមកពីគំនិតរបស់រដ្ឋ" ។ និយាយម្យ៉ាងវិញទៀត ការពិតទោះបីជាអ្នកទោសធ្វើអ្វីក៏ដោយ ក៏ខ្លួនត្រូវតែបង្ខំចិត្តយល់ព្រមជាមួយនឹងការទាញសន្និដ្ឋានរបស់បក្សដែលថាខ្លួនមានកំហុសដោយសារត្រូវបានចាប់ខ្លួន ។ ដូចដែល ស៊ុយ ឆេងហួត ជាអតីតកម្មករអគ្គិសនីនិយាយដោយស្មោះត្រង់នៅចុងបញ្ចប់នៃចម្លើយសារភាពរបស់គាត់ថា "ខ្ញុំមិនមែនជាសេ.អ៊ី.អាទេ ។ ខ្ញុំឆ្លើយថាសេ.អ៊ី.អានៅពេលប្រឈមមុខនឹងទោសកំហុសរបស់ខ្ញុំ ។"

(នៅមានត)

# សភាយុទ្ធជនបដិវត្តន៍ខ្មែរក្រហម



សភាយុទ្ធជនបដិវត្តន៍ជាផ្នែកមួយនៃកងទ័ពកម្ពុជាប្រជាធិបតេយ្យ ដែលស្ថិតនៅក្រោមការចាត់តាំងរបស់កងអនុសេនាធំ ដើម្បីជាជំនួយដល់គណៈបញ្ជាការក្នុងការអនុវត្តប្រជាធិបតេយ្យ ៣យ៉ាងនៅក្នុង "កងកម្លាំងប្រដាប់អាវុធប្រជាជន" សំដៅបង្កើនកម្លាំងប្រយុទ្ធនិងកសាងអង្គភាពខ្លួនឲ្យបានរឹងមាំខាងនយោបាយ សតិអារម្មណ៍ បច្ចេកទេស យោធា ព្រមទាំងអង្គការវិន័យ ។

ទាក់ទិនទៅនឹងភាពចាំបាច់និងភារកិច្ចនៃសភាយុទ្ធជនក្នុងកងអនុសេនាធំនេះ នៅក្នុងឯកសារទ្រឹស្តីកងទ័ពរបស់ ជ័យ លឹម បានសរសេររៀបរាប់ថា "សភាយុទ្ធជនបដិវត្តន៍ជាកម្លាំងមួយក្រុមដែលស្ថិតនៅក្រោមការដឹកនាំដោយផ្ទាល់របស់បញ្ជាការនិងគណៈកម្មការលេខាបក្សនៅក្នុងកងអនុសេនាធំ ។ សភាយុទ្ធជនមានភារកិច្ចជំនួយគណៈបញ្ជាការអនុសេនាធំក្នុងការអនុវត្តនិងបើកទូលាយនូវប្រជាធិបតេយ្យក្នុងជីវភាពនយោបាយ យោធា និងសេដ្ឋកិច្ចនៅក្នុងកងអនុសេនាធំ" ។

អង្គភាពនៃសភាយុទ្ធជនបដិវត្តន៍ត្រូវបានចាត់តាំង និងបង្កើតឡើងដោយកងអនុសេនាធំ ដើម្បីធ្វើសកម្មភាពទំនាក់ទំនងជាមួយក្រសួងនិងអង្គភាពមូលដ្ឋាន ។ ចំពោះចំនួនមនុស្សដែលជ្រើសរើសបញ្ចូលទៅក្នុងសភាយុទ្ធជនត្រូវបានពិនិត្យនិងអាស្រ័យលើចំនួនមនុស្សនៅក្នុងអង្គភាពតិចឬច្រើន ដើម្បីកំណត់ចំនួនសមាជិកដែលត្រូវរួមប្រាស្រ័យក្នុងគណៈកម្មការសភាយុទ្ធជន ។ ជាធម្មតាសភាយុទ្ធជនបដិវត្តន៍ត្រូវមានសមាជិកចាប់ពី៩ ទៅ ១១រូប ។ សមាសភាពទាំងអស់នៃសភាយុទ្ធជនរួមមាន ប្រធានមួយរូបទទួលភារកិច្ចរួមចំពោះរាល់សកម្មភាពរបស់សភាយុទ្ធជន អនុប្រធានមួយរូប និងសមាជិកមានពី៥ ទៅ៩រូប ។

ដើម្បីទទួលបាននូវលទ្ធផលជាផ្លែផ្កាទាំងការងារនយោបាយ សតិអារម្មណ៍ បច្ចេកទេសប្រយុទ្ធ និងអង្គការវិន័យក្រុមនៃសភាយុទ្ធជនបដិវត្តន៍នេះត្រូវបានបែងចែកជាបីពួកធំៗរួមមានៈ ១)ពួកនយោបាយ ត្រូវមានប្រធានពួក១រូប និងសមាជិកចាប់ពី២ ទៅ៣រូប ។ ពួកនយោបាយមានតួនាទីធានារ៉ាប់រងក្នុងការអនុវត្តប្រជាធិបតេយ្យនយោបាយ និងអនុវត្តរាល់ការផ្តើមគំនិត ទាំងគោលនយោបាយរបស់បក្ស និងវិន័យកងកម្លាំងប្រដាប់អាវុធប្រជាជននៅក្នុងកងអនុសេនាធំរបស់ខ្លួន ។ ពួកយោធា រួមមានប្រធានពួកមួយរូប និងសមាជិកចាប់ពី២ទៅ៣រូប ។ ពួកយោធាមានភារកិច្ចធានារ៉ាប់រងក្នុងការអនុវត្តប្រជាធិបតេយ្យ

យោធា យុទ្ធវិធី បច្ចេកទេស រក្សាសម្ងាត់ និងកីឡាកម្សាន្ត នៅក្នុងអនុសេនាធំ ។ ពួកសេដ្ឋកិច្ច រួមមានប្រធានពួក១រូប និងសមាជិកចាប់ពី២ទៅ៣រូប ។ ពួកសេដ្ឋកិច្ចមានភារកិច្ចធានារ៉ាប់រងក្នុងការអនុវត្តប្រជាធិបតេយ្យខាងសេដកិច្ច អនាម័យ នៅក្នុងអង្គភាព និងពិនិត្យរាល់សម្ភារផ្សេងៗនៅក្នុងអង្គភាព ។

សមាសភាពនៃគណៈកម្មាធិការសភាយុទ្ធជននៅតាមបណ្តាខេត្តនិងផ្នែកនីមួយៗ ត្រូវបានជ្រើសរើសដោយការបោះឆ្នោតជ្រើសតាំងឡើងទៅតាមលក្ខការណ៍សំខាន់ៗបីចំណុចរួមមាន ១) បោះឆ្នោតដោយសម្ងាត់ ២) សមាជិកពេញសិទ្ធិបោះឆ្នោតមុន (បើមានសមាជិកបម្រុងបោះឆ្នោតក្រោយ) និង៣) គណៈកម្មការសភាយុទ្ធជនជ្រើសតាំងប្រធាននិងអនុប្រធាន ។ ចំពោះបេក្ខភាពដែលត្រូវឈរឈ្មោះបោះឆ្នោតចូលជាគណៈកម្មាធិការសភាយុទ្ធជនត្រូវមានលក្ខណៈសម្បត្តិ៥យ៉ាងៈ ១) វណ្ណៈភាពជាគោលចារីក ២) មានជំហរសតិអារម្មណ៍ចម្រើន ៣) ប្រយុទ្ធអង់អាចក្លាហាន ៤) ខ្នះខ្នែងក្នុងការងារនិងមានគំរូល្អ និង ៥) ត្រូវបានមហាជនជឿជាក់ ។ ចំណែកឯសមាសភាពកម្មាភិបាលកងអនុសេនាធំ និងកងអនុសេនាតូចដែលចូលប្រាស្រ័យក្នុងការបោះឆ្នោតមិនត្រូវឲ្យលើសពីចំនួន២ភាគ៥ឡើយ ហើយអ្នកទាំងនោះត្រូវបោះឆ្នោតឲ្យអនុប្រធាននយោបាយនៃកងអនុសេនាធំធ្វើបេក្ខភាពក្នុងគណៈកម្មាធិការសភាយុទ្ធជន ។

បន្ទាប់ពីការបោះឆ្នោតចាត់តាំងគណៈកម្មាធិការដឹកនាំសភាយុទ្ធជនបដិវត្តន៍រួចហើយ ប្រធាននយោបាយនៃសភាយុទ្ធជនត្រូវធ្វើការដឹកនាំការងារជាមួយសមាជិកទាំងអស់ឲ្យអនុវត្តនូវប្រជាធិបតេយ្យ៣យ៉ាងនៅក្នុងកងអនុសេនាធំរបស់ខ្លួន ។ ប្រជាធិបតេយ្យទាំងបីយ៉ាងនោះរួមមានៈ ១) ប្រជាធិបតេយ្យខាងនយោបាយមានគោលបំណងសំខាន់នៃប្រជាធិបតេយ្យខាងនយោបាយគឺដើម្បីពង្រឹងនូវស្មារតីទទួលខុសត្រូវសិទ្ធិស្មើភាពអំពីនយោបាយសាមគ្គីឯកភាពនៅក្នុងកងអនុសេនាធំ ដើម្បីធ្វើឲ្យកងអនុសេនាធំមានកម្លាំងរឹងមាំនៅក្នុងការប្រយុទ្ធកសាងអង្គភាព ។ មិនតែប៉ុណ្ណោះត្រូវខិតខំធ្វើយ៉ាងណាឲ្យមហាជនយុទ្ធជនចូលរួមប្រាស្រ័យដើម្បីរួមវិភាគទានក្នុងការងារអនុវត្តសេចក្តីផ្តើមគំនិតគោលនយោបាយរបស់បក្ស និងអនុវត្តការងារអប់រំនយោបាយដឹកនាំសតិអារម្មណ៍ដល់អង្គភាព ។ ជាមួយគ្នានោះត្រូវធ្វើការផ្លាស់ប្តូរយោបល់គ្នា ដើម្បីឲ្យជ្រួតជ្រាបនូវសារាចរ បទបញ្ជារបស់ថ្នាក់លើ និងសេចក្តីសម្រេចចិត្តរបស់សាខាបក្ស ។ ត្រូវធ្វើការទិតៀននិងស្វ័យទិតៀនសំដៅបង្កើននិងពង្រឹងនូវសាមគ្គីភាពឯកភាពផ្ទៃក្នុងអង្គភាព ទាំងការងារទាក់ទងរវាងថ្នាក់ដឹកនាំនិងសមាជិកនៅក្នុងអង្គភាព ។ លើសពីនេះទៅទៀត ត្រូវជួយជាយោបល់ក្នុងការសរសើរចំពោះអ្នកដែលបានទទួលនូវស្នាដៃឬគុណសម្បត្តិនិងអនុវត្តនូវទោសឲ្យបានសមស្របចំពោះអ្នកដែលមានគុណវិបត្តិថាគួរត្រូវមានទោស ឬពិន័យទោស ។ ធានានូវសិទ្ធិតវ៉ាអំពីបញ្ហាអ្វីមួយរបស់កម្មាភិបាលនិងយុទ្ធជនដែលមិនទាន់អស់ចិត្តឬមិនឯកភាព ដើម្បីរកគ្រប់វិធីជួយសម្រេចនិងដោះស្រាយ ។ ២) ប្រជាធិបតេយ្យយោធាគឺសំដៅពង្រឹងនូវស្មារតីទទួលខុសត្រូវនិងស្មារតីប្រឌិតភ្លឺស្វាងដើម្បីចូលរួមវិភាគទានក្នុងផែនការប្រយុទ្ធ ព្រមទាំងកសាង ហ្វឹកហ្វឺនកងទ័ពនៅក្នុងកងអនុសេនាធំ ។ នៅមុនពេលប្រយុទ្ធត្រូវចំណាយពេលធ្វើការពិគ្រោះពិភាក្សាឲ្យបានជ្រួតជ្រាបនូវគោលគំនិតអាជ្ញាបទបញ្ជារបស់ថ្នាក់លើ ។ ជួយជាយោបល់ក្នុងការរៀបចំផែនការប្រយុទ្ធទាំងកងអនុសេនាធំនិងកងអនុសេនាតូច ។ នៅក្នុងពេលប្រយុទ្ធម្តងៗត្រូវតាមដានរាល់សភាពការណ៍ផ្លាស់ប្តូរក្នុងការប្រយុទ្ធជាក់ស្តែង ដើម្បីជំរុញបំផុសស្មារតីគ្នាទៅវិញទៅមក ។ រក្សាឲ្យបានខ្ជាប់នូវការប្តេជ្ញាចិត្តប្រយុទ្ធនិងអនុវត្តឲ្យបានម៉ឺងម៉ាត់នូវវិន័យប្រយុទ្ធ ។ នៅក្រោយពេលប្រយុទ្ធ ដោយផ្អែកតាមសភាពការណ៍ជាក់ស្តែង និងតាមសេចក្តីណែនាំរបស់ប្រធាននយោបាយ ត្រូវធ្វើសន្និបាតសភាយុទ្ធជន ដើម្បីត្រួតពិនិត្យរកគុណសម្បត្តិ គុណវិបត្តិ តាំងពីបុគ្គលរហូតដល់អង្គភាពក្នុងកងអនុសេនាធំទាំងមូល ចំពោះការប្រយុទ្ធកន្លងមក ។ ធ្វើរបៀបនេះក្នុងគោលបំណងបង្ហាញនូវបទពិសោធន៍ចំពោះការប្រយុទ្ធនៅពេលខាងមុខទៀត ។ ក្រៅពីការអនុវត្តទ្រឹស្តីនៅតាមបណ្តាសមរភូមិមុខនិងសមរភូមិក្រោយគណៈកម្មាធិការសភាយុទ្ធជនត្រូវហាត់ហ្វឹកហ្វឺនលើបញ្ហាផ្សេងៗជាច្រើនដែលបានកំណត់ដោយថ្នាក់លើ ។ ការហ្វឹកហ្វឺននេះត្រូវបានបែងចែកជាពាដំណាក់កាល÷ ១) នៅមុនពេលហ្វឹកហ្វឺនៈ គណៈកម្មាធិការសភាយុទ្ធជន

ត្រូវធ្វើការពិគ្រោះពិភាក្សាឲ្យបានជ្រួតជ្រាបនូវសារាចរព្រមទាំងបទបញ្ជារបស់ថ្នាក់លើ ។ ទន្ទឹមគ្នានោះ ត្រូវជួយជាយោបល់ក្នុងការអនុវត្តសារាចរ និងបទបបញ្ជាទាំងនេះឲ្យមានប្រសិទ្ធភាព ព្រមទាំងការច្នៃប្រឌិតភ្នំស្វាងចំពោះការហ្វឹកហ្វឺនដោយឆ្លងកាត់រាល់ការលំបាកដើម្បីត្រៀមរៀបចំសម្ភារសម្រាប់ការហ្វឹកហ្វឺននៅពេលខាងមុខ ។ ២) នៅក្នុងពេលហ្វឹកហ្វឺនគឺត្រូវបើកទូលាយប្រជាធិបតេយ្យ រួមយោបល់ដល់អ្នកបង្ហាត់បង្រៀននិងអ្នករៀនក្នុងគោលបំណងកែប្រែវិធីសាស្ត្ររៀនសូត្រ ។ ៣) ក្រោយពេលហ្វឹកហ្វឺនគឺត្រូវបើកសន្និបាតសភាយុទ្ធជនដើម្បីត្រួតពិនិត្យចំពោះការហ្វឹកហ្វឺន រកគុណសម្បត្តិ គុណវិបត្តិ សម្រាប់ជាបទពិសោធន៍បម្រើឲ្យការហ្វឹកហ្វឺននៅពេលខាងមុខថែមទៀត ។ រាល់ការសិក្សារៀនសូត្រទាំងអម្បាលម៉ាននេះត្រូវធានាអនុវត្តឲ្យបានតាមការកំណត់អំពីខ្លឹមសាររបស់អង្គការដែលបានដាក់ចេញ ។ ៤) ប្រជាធិបតេយ្យសេដ្ឋកិច្ច គឺមានគោលបំណងសំដៅលើកកម្ពស់នូវស្មារតីទទួលខុសត្រូវរបស់កម្មាភិបាលយុទ្ធជនក្នុងការអនុវត្តនិងប្រើប្រាស់មូលដ្ឋានសម្ភារឲ្យបានល្អព្រមទាំងកែប្រែស្ថានភាពរស់នៅដល់អង្គភាពទាំងមូល ។ ត្រូវជ្រួតជ្រាបនិងពិភាក្សានូវរាល់របបគោលនយោបាយរបស់បក្សជាមួយនិងថវិកាដែលបក្សបានផ្តល់ឲ្យគ្រប់គ្រងរួមទាំងការចំណាយផង ។ ត្រូវថែរក្សាឲ្យបានល្អនូវសម្ភារសស្ត្រាវុធ សម្ភារសឹកផ្សេងៗ ព្រមទាំងសម្ភារមូលដ្ឋានដទៃទៀតដូចជាបាយ អង្ករ ខោអាវ ប្រាក់កាសជាដើម ។ នៅក្នុងការប្រើប្រាស់ជយភណ្ឌត្រូវអនុវត្តការសន្សំសំចៃប្រឆាំងនឹងការលោភលន់ការខ្ជះខ្ជាយ ដើម្បីចូលរួមប្រាស្រ័យកែប្រែជីវភាពខាងសម្ភាររស់នៅរបស់អង្គភាព ។

ដើម្បីធ្វើឲ្យសភាយុទ្ធជនបដិវត្តន៍អាចធានានិងទទួលបាននូវប្រសិទ្ធភាពការងារប្រធាននយោបាយ ត្រូវក្តាប់ឲ្យជាប់ក្នុងការណែនាំសម្រួលការងារ ចាត់តាំងរាល់សកម្មភាពរបស់សភាយុទ្ធជន ដោយពិនិត្យឲ្យបានច្បាស់នូវៈ ១) ការសំណូមពរ ២) អំពីការកែសម្រួលខាងចាត់តាំង ៣) ត្រូវធានាឲ្យសភាយុទ្ធជនមាន“ធាតុពិតជាអង្គការចាត់តាំងមហាជន” ។ ជានិច្ចកាលត្រូវពង្រឹងប្រជាធិបតេយ្យប្រមូលផ្តុំទាំងកម្លាំងប្រដាប់អាវុធនិងមហាជន ៤) ធានាឲ្យយុទ្ធជនមានលក្ខណៈគ្រប់គ្រាន់ទាំងខាងបរិមាណនិងសម្ភារដើម្បីបន្តសកម្មភាពបដិវត្តន៍ ៥) នៅពេលដែលមានការផ្លាស់ប្តូរដូចជាសមាជិកគណៈកម្មាធិការទៅកន្លែងផ្សេងៗ ឬត្រូវរបួសពិការ ត្រូវបំពេញសមាជិកជាបន្ទាន់ដើម្បីបន្តសកម្មភាព ៦) បើខ្វះសមាជិកនៅក្នុងក្រុមណាមួយ ត្រូវជ្រើសរើសបន្ថែមជាបន្ទាន់ដើម្បីធានាសកម្មភាពបានជាបន្តបន្ទាប់ ។ ៧) ក្នុងលក្ខណៈបោះឆ្នោតជ្រើសរើសប្រធានមិនបាន ត្រូវត្រៀមមនុស្ស និងគួបផ្សំបើកប្រជាធិបតេយ្យចង្អុលកំណត់ រួចរាយការណ៍ឡើងទៅគណៈកម្មាធិការសាខាបក្សអនុម័ត ហើយត្រូវប្រកាសឲ្យសន្និបាតសភាយុទ្ធជនបដិវត្តន៍ធ្វើការអនុម័តបន្ថែមទៀត ។ ៨) ករណីសភាយុទ្ធជនផុតកំណត់កាលបរិច្ឆេទចំនួន៣ខែ ប្រធាននយោបាយត្រូវណែនាំឲ្យធ្វើសេចក្តីរាយការណ៍ដល់សន្និបាតនៃសភាយុទ្ធជន រួចធ្វើការបោះឆ្នោតជ្រើសរើសសមាជិកសភាថ្មីនិងបន្ទាប់មករាយការណ៍ឡើងទៅគណៈកម្មាធិការសាខាបក្សដើម្បីពិនិត្យនិងអនុម័ត ដោយផ្អែកទៅលើសេចក្តីណែនាំរបស់គណៈកម្មាធិការសាខាបក្ស ប្រធាននយោបាយ ត្រូវធ្វើយ៉ាងណាឲ្យសភាយុទ្ធជនមានសកម្មភាពជួយដល់គណៈបញ្ជាការក្នុងសកម្មភាពអនុវត្តប្រជាធិតេយ្យ៣យ៉ាងខាងលើនេះ នៅក្នុងកងកម្លាំងប្រដាប់អាវុធឲ្យមានប្រសិទ្ធភាព ។

ជាមួយគ្នានេះដែរ ត្រូវទទួលប្រមែប្រមូលយោបល់និងគោលបំណងសំណូមពររបស់កម្មាភិបាលយុទ្ធជន ដើម្បីធ្វើសេចក្តីរាយការណ៍ឡើងទៅគណៈបញ្ជាការ ព្រមទាំងសុំទិសដៅនិងវិធីសម្រេចដោះស្រាយ ។ ណែនាំសភាចាត់តាំងរាល់ជីវភាពប្រជាធិបតេយ្យនិងរៀបចំផែនការឲ្យសភាយុទ្ធជនធ្វើសកម្មភាពជាក់ស្តែង ចៀសវាងនូវសកម្មភាពច្របូកច្របល់ពាសវាលពាសកាល ។

នៅក្នុងរចនាសម្ព័ន្ធកងទ័ពនៃរបបកម្ពុជាប្រជាធិបតេយ្យបានធ្វើការបែងចែកនូវលំដាប់ថ្នាក់ពីថ្នាក់លើមកថ្នាក់ក្រោមយ៉ាងច្បាស់លាស់បំផុត ។ នៅតាមបណ្តាផ្នែកនីមួយៗ រួមមានកងពល កងវរសេនាធំ កងវរសេនាតូច កងអនុសេនាធំ កងអនុសេនាតូច ក្រុម និងពួក ហើយនៅក្នុង១កងអនុសេនាធំមានចំនួនកងទ័ពសរុបប្រមាណ១០០នាក់ ។

**ហ៊ុយ វណ្ណៈ**

# រង្វាស់បទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅក្នុងប្រទេសកម្ពុជា

**(តចប់)** មានទីតាំងមួយចំនួនត្រូវបានរាយការណ៍មកថា មានទំហំធំណាស់ ។ ទីតាំងអស់នេះស្ថិតនៅតំបន់ដាច់ស្រយាលនិងពិបាកចូលទៅដល់ ហើយជាទីតាំងដែលប្រកបទៅដោយគ្រោះថ្នាក់ទៀតផង ។ គ្រោះថ្នាក់នោះមានដូចជា ព្រៃក្រាស់ គ្រុនចាញ់ តំបន់មីន (ដែលមិនទាន់មានសញ្ញាបង្ហាញច្បាស់លាស់) ចោរព្រៃ អតីតកម្លាំងប្រដាប់អាវុធខ្មែរក្រហម (តំបន់អន្លង់វែង និងទួលប្រាសាទ) ហើយនិងអតីតកម្មាភិបាលខ្មែរក្រហមដែលនៅមានជីវិត និងមេដឹកនាំខ្មែរក្រហមទាំងឡាយ ដែលជាញឹកញាប់បង្ហាញឲ្យឃើញដោយផ្ទាល់ឬប្រយោលថាមិនពេញចិត្តចំពោះកិច្ចការស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។

ជាងនេះទៅទៀត នៅពេលដែលទិន្នន័យចុះផ្ទើផែនទីត្រូវបានបញ្ចប់សព្វគ្រប់ មជ្ឈមណ្ឌលឯកសារកម្ពុជានឹងជួបការងារ



មួយទៀតដែលប្រហែលជាមានការពិបាកខ្លាំងជាងនេះ គឺការពិនិត្យរបៀបកោសល្យវិច័យទៅលើទីតាំងរណ្ដៅសាកសពដែលត្រូវបានរកឃើញរួចហើយ ។ កិច្ចការនេះនឹងមានសារសំខាន់ចាំបាច់ក្នុងការបន្ថែមការបញ្ជាក់ច្បាស់របៀបវិទ្យាសាស្ត្រ ដោយផ្តោតទៅលើអត្តសញ្ញាណនិងមូលហេតុនៃការស្លាប់របស់ជនរងគ្រោះនៅក្នុងរណ្ដៅសាកសពដែលត្រូវបានរកឃើញ ដើម្បីទាញហេតុផលឲ្យបានច្បាស់លាស់ទៅលើភ័ស្តុតាងដែលទទួលបានតាមរយៈការចុះពិនិត្យផ្ទាល់របស់ក្រុមធ្វើផែនទីទៅតាមទីតាំងដែលសាក្សីបានប្រាប់និងពត៌មានសន្និកសន្ទាប់នៅក្នុងបណ្ណសាររបស់នគរបាលសម្ងាត់របស់ខ្មែរក្រហមហៅថា “សន្តិបាល” ។

បុគ្គលិកមានការតាំងចិត្តខ្ពស់ ដែលចូលរួមធ្វើកិច្ចការនៅក្នុងគម្រោងធ្វើផែនទីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានជួយជ្រោមជ្រែងដើម្បីធានាថា ការពិតស្តីអំពីទំហំនៃអំពើដ៏អមនុស្សធម៌របស់ខ្មែរក្រហមអាចត្រូវបានផ្សព្វផ្សាយឲ្យដឹងពេញដល់ប្រជាជនកម្ពុជា និងពិភពលោកទាំងមូល ។ បុគ្គលិកទាំងនេះថែមទាំងជួយធានាទៀតថា អ្នកដែលប៉ុនប៉ងបដិសេធការពិតនៃអំពើប្រល័យពូជសាសន៍នឹងមិនអាចមានមុខនៅក្នុងការពិភាក្សាក្នុងលក្ខណៈទាន់សម័យឡើយ ។ យើងបានចាប់ផ្តើមដំណើរការតាំងពីថ្ងៃដែលប្រជាជនកម្ពុជាមានការភ័យខ្លាចចំពោះខ្មែរក្រហមរហូតដល់ពេលដែលខ្មែរក្រហមមានហេតុផលច្បាស់លាស់ក្នុងការភិតភ័យថាប្រសិនបើខ្លួនត្រូវបាននាំយកមកកាន់តុលាការដើម្បីវិនិច្ឆ័យទោសចំពោះបទឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរនឹងមានភ័ស្តុតាងគ្រប់គ្រាន់ក្នុងការចោទប្រកាន់ដល់ខ្លួន ។ ចំពោះអ្នកដែលបដិសេធថាខ្មែរក្រហមមិនបានសម្លាប់ជនរងគ្រោះកម្ពុជាដោយឥតត្រាប្រណីជាទ្រង់ទ្រាយធំ ភ័ស្តុតាងដែលរកឃើញដោយមជ្ឈមណ្ឌលឯកសាកម្ពុជាតាមរយៈការជីកគាស់នៅតាមទីវាលដែលបានចុះទៅដល់ពិតជាផ្តល់នូវចម្លើយយ៉ាងច្បាស់ដោយមិនអាចប្រកែកបានឡើយ ។ **របាយការណ៍មជ្ឈមណ្ឌលឯកសារកម្ពុជា**


ប្រជាជនកំពុងគាស់រណ្ដៅសាកសពជនរងគ្រោះ


ប្រជាជនកំពុងប្រមែប្រមូលអដ្ឋិធាតុជនរងគ្រោះ

# អដ្ឋិធាតុជនរងគ្រោះ


បូជនីយដ្ឋានតម្កល់អដ្ឋិធាតុនៅវត្តថ្មី ខេត្តសៀមរាប


ពិធីបង្សុកូលនៅឃុំឈើទាល ស្រុកស្វាយរៀង

# តម្លៃនៃភ័ស្តុតាង

**(តពីលេខមុន)** ២) បំណងឧក្រិដ្ឋ

តម្រូវការនៃបំណងឧក្រិដ្ឋឬសភាពផ្លូវចិត្តគឺជាការដឹងព្ និងចេតនាដែលជនសង្ស័យមាន ចំពោះការចូលរួម និងធ្វើការសម្រេចចិត្តមួយដោយដាក់ផែនការ ជំរុញ បញ្ជា ប្រព្រឹត្ត ឬបើពុំនោះទេគឺជួយគាំទ្រនិងជ្រោមជ្រែងអំពើឧក្រិដ្ឋ ។ ទាំងការដឹងព្និងមានចេតនាអាចទាញបានតាមកាលៈទេសៈ ហើយមិនចាំបាច់មានផែនការរៀបចំទុកជាមុនក្នុងការភូតកុហកការទទួលខុសត្រូវចំពោះមុខច្បាប់ទេ ។

### ក) ការការពារខ្លួនចំពោះឧក្រិដ្ឋកម្មអន្តរជាតិ

១) ការបង្ខិតបង្ខំ ភាពចាំបាច់ និងប្រធានសក្តិ (ហេតុហួសនិស្ស័យមិនអាចទប់ទល់និងចៀសវាងបាន) ។

ការបង្ខិតបង្ខំអាចកើតឡើងប្រសិនបើចុងចោទអាចបង្ហាញឃើញនូវការគំរាមកំហែងភ្លាមៗដល់អាយុជីវិតឬសុខុមាលភាពផ្នែករាងកាយ ក្នុងករណីចុងចោទមិនបានប្រព្រឹត្តឧក្រិដ្ឋទេនោះ ។ ភាពចាំបាច់ឬប្រធានសក្តិអនុវត្តបាន ប្រសិនបើចុងចោទត្រូវបានដាក់ឲ្យស្ថិតនៅក្នុងបញ្ហាដែលមិនអាចចៀសផុតមិនមែនធ្វើដោយខ្លួនឯង ហើយចុងចោទត្រូវជ្រើសរើសវាងឧក្រិដ្ឋកម្មឬក៏ផលប្រយោជន៍ផ្ទាល់ខ្លួនដ៏លើសលប់ (ឧទាហរណ៍ៈ ត្រូវបានទុកចោលនៅលើទូកសង្គ្រោះដែលហៀបនឹងលិចដោយសារមានចំនួនមនុស្សជិះលើសចំណុះ) ។

២) ការការពារខ្លួនផ្សេងៗទៀត

ការការពារអំពើរបស់រដ្ឋ ឬអភ័យឯកសិទ្ធិបូរណភាពមិនត្រូវបានទទួលស្គាល់នៅក្នុងតុលាការឧក្រិដ្ឋកម្មអន្តរជាតិទេ ។ បទបញ្ជាមកពីខាងលើ និងការបញ្ជាតាមផ្លូវច្បាប់ ក៏មានការការពារមិនឲ្យចូលជាឧក្រិដ្ឋកម្មអន្តរជាតិដែរ ។ បទបញ្ជាមកពីខាងលើ និងការបញ្ជាតាមផ្លូវច្បាប់គ្មានការការពារមិនឲ្យចូលជាឧក្រិដ្ឋកម្មអន្តរជាតិទេ ។ នៅក្រោមអនុសញ្ញាឆ្នាំ១៩៦៨ ស្តីអំពីអាជ្ញាយុកាលច្បាប់ដែលមិនអាចអនុវត្តចំពោះឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ការការពារដោយអាជ្ញាយុកាលច្បាប់មិនត្រូវបានទទួលស្គាល់ ក៏ប៉ុន្តែទាំងប្រទេសកម្ពុជានិងរដ្ឋរបស់សមាគមប្រជាជាតិអាស៊ីភាគអគ្នេយ៍មិនមែនជាភាគីនៃអនុសញ្ញានេះទេ ហើយលក្ខណៈនៃគោលការណ៍ដែលជាច្បាប់ទម្លាប់នៅក្នុងនៅក្នុងឆ្នាំ១៩៧៥ នៅមានលក្ខណៈគួរឲ្យសង្ស័យនៅឡើយ ។

### ឃ) គោលការណ៍នៃការទទួលខុសត្រូវលើការបញ្ជា

គោលការណ៍ច្បាប់មួយទៀតដែលមានការទាក់ទងគ្នាយ៉ាងសំខាន់ទៅនឹងការកាត់ក្តីអតីតមេដឹកនាំនៃបក្សកុម្មុយនិស្តកម្ពុជាគឺ គោលការណ៍នៃការទទួលខុសត្រូវលើការបញ្ជាដែលនៅក្នុងនោះ ការបញ្ជាមេដឹកនាំ យោធា និងស៊ីវិលអាចត្រូវបានចាត់ចូលជាការទទួលខុសត្រូវចំពោះអំពើឧក្រិដ្ឋរបស់អ្នកដែលនៅក្រោមបង្គាប់នៅក្នុងកាលៈទេសៈជាក់ច្បាស់ណាមួយ ។ ផ្នែកខាងក្រោមនេះបង្ហាញពីការយល់ឃើញរបស់ខ្ញុំចំពោះធាតុផ្សំរបស់គោលការណ៍នេះ និងការពិភាក្សាជាសង្ខេបទៅលើការប្រើប្រាស់គំរូភ័ស្តុតាងឯកសារដ៏សំខាន់ក្នុងការបង្កើតបានជាធាតុផ្សំនីមួយៗ ។

១) ធាតុផ្សំនៃការទទួលខុសត្រូវលើការបញ្ជា

នៅក្នុងទម្រង់ដ៏មានសារសំខាន់ គោលការណ៍នៃការទទួលខុសត្រូវលើការបញ្ជាដាក់មន្ត្រីថ្នាក់បញ្ជាការយោធាឬមេដឹកនាំស៊ីវិលឲ្យទទួលខុសត្រូវចំពោះអំពើឧក្រិដ្ឋរបស់កូនចៅដែលនៅក្រោមបង្គាប់នៅពេលដែលអំពើទាំងនោះចូលទៅក្នុងចំណុចដូចខាងក្រោម÷

### ក) ទំនាក់ទំនងបញ្ជា

ទី១ ទំនាក់ទំនងបញ្ជាត្រូវតែមានរវាងជនជាប់ចោទដែលនៅថ្នាក់លើ និងជនជាប់ចោទដែលជាកូនចៅក្រោមបង្គាប់នៅពេលមានការប្រព្រឹត្តអំពើឧក្រិដ្ឋ ។ ទំនាក់ទំនងបញ្ជាអាចជានីតិន័យឬព្រឹត្តន័យ ។ ដើម្បីបង្កើតជាទំនាក់ទំនងបញ្ជាជនជាប់ចោទដែលជាថ្នាក់លើ ត្រូវមានអំណាចបញ្ជាដាក់ស្តែងដើម្បីគ្រប់គ្រងអំពើដែលប្រព្រឹត្តឡើងដោយកូនចៅនៅ

ក្រោមបង្គាប់របស់ខ្លួន ។ អំណាចដាក់ស្តែងត្រូវបានយល់ថា មានប្រាកដមែន ប្រសិនបើថ្នាក់លើមានសមត្ថភាពពិសេសក្នុង ការ ក) ទប់ស្កាត់កូនចៅដែលនៅក្រោមបង្គាប់កុំឲ្យប្រព្រឹត្តអំពើឧក្រិដ្ឋ ឬ ខ) ដាក់ទណ្ឌកម្មកូនចៅក្រោមបង្គាប់ដែលបានប្រព្រឹត្តអំពើនេះនៅក្នុងករណីចាំបាច់ ។

### ១) បំណងឧក្រិដ្ឋ

តម្រូវការទី២ដែលធ្វើឲ្យថ្នាក់លើទទួលខុសត្រូវក្រោមគោលការណ៍នៃការទទួលខុសត្រូវលើការបញ្ជា គឺបំណងឧក្រិដ្ឋ ប្រសិនបើជននោះមានការដឹងឮពិតប្រាកដចន្លុលទៅតាមរយៈភ័ស្តុតាងចំពោះមុខ ឬភ័ស្តុតាងប្រយោល ដែលបង្ហាញថាកូនចៅនៅក្រោមបង្គាប់បានប្រព្រឹត្តឬអាចប្រព្រឹត្តអំពើឧក្រិដ្ឋ ។ តម្រូវការនៃការដឹងឮពិតប្រាកដ មិនអាចត្រូវបានទាញចេញជាសេចក្តីសន្និដ្ឋាន និងត្រូវបានបង្ហាញច្បាស់តាមគំរូភ័ស្តុតាង ។ សញ្ញាបង្ហាញអំពីការដឹងឮ រួមមាន ចំនួន ប្រភេទ និងវិសាលភាពនៃអំពើខុសច្បាប់ ការកំណត់ពេលវេលានិងភ័ស្តុតាងនៃអំពើ ចំនួននិងប្រភេទនៃកងទ័ពដែលពាក់ព័ន្ធ វិសាលភាពនៃភូមិសាស្ត្រ និងទីតាំងដែលមានអំពើកើតឡើង ល្បឿននៃយុទ្ធវិធីក្នុងការធ្វើប្រតិបត្តិការដែលមានលក្ខណៈប្រហាក់ប្រហែលនឹងអំពើឧក្រិដ្ឋ មន្ត្រីនិងបុគ្គលិកដែលពាក់ព័ន្ធនៅក្នុងអំពើនេះ ព្រមទាំងទីតាំងរបស់ថ្នាក់លើនៅពេលមានការប្រព្រឹត្តអំពើនេះកើតឡើង ។

តម្រូវការនៃបំណងឧក្រិដ្ឋក៏កើតមានបានដែរ ប្រសិនបើថ្នាក់លើមានពត៌មានដែលអាចមានហេតុផលគ្រប់គ្រាន់ក្នុងការដឹងឮអំពីគ្រោះថ្នាក់កើតឡើងអំពីបទឧក្រិដ្ឋរបស់កូនចៅនៅក្រោមបង្គាប់ និងក្នុងការបញ្ជាក់ឲ្យខ្លួនមានការចាំបាច់ធ្វើការស៊ើបអង្កេតបន្ថែមទៅលើឧក្រិដ្ឋកម្មកាលពីមុន និងដែលនឹងអាចកើតឡើងនៅពេលខាងមុខ ។ ដោយផ្អែកលើករណីយុទ្ធសាស្ត្រ ការធ្វេសប្រហែសផ្នែកព្រហ្មទណ្ឌជាទូទៅមិនគ្រប់គ្រាន់ដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃបំណងឧក្រិដ្ឋដូចកាលពីឆ្នាំ១៩៧៥ បានទេ ។ លុះត្រាណាតែអ្នកថ្នាក់លើបានទទួលពត៌មានដាក់ស្តែងដែលបង្ហាញពីការចាំបាច់មានហេតុផលត្រឹមត្រូវឲ្យមានការស៊ើបអង្កេតថែមទៀតទើបការធ្វេសប្រហែសនោះមានលក្ខណៈធ្ងន់ធ្ងររហូតដល់ក្លាយជាចេតនាបណ្តែតបណ្តោយឲ្យមានអំពើកើតឡើង ឬចេតនាក្នុងការព្យាបាទ ។

### គ) អំពើពិរុទ្ធ

ដើម្បីឲ្យមានការទទួលខុសត្រូវក្រោមគោលការណ៍នៃការបញ្ជា បុគ្គលថ្នាក់លើម្នាក់ត្រូវបំពេញតាមតម្រូវការនៃអំពើពិរុទ្ធ ឬអំពើខុសច្បាប់ ។ បុគ្គលថ្នាក់លើអាចបំពេញតម្រូវការនេះដោយអំពើវិជ្ជមាន ឬក៏ការខកខានមិនបានទប់ស្កាត់ដែលបណ្តាលឲ្យមានការទទួលខុសត្រូវលើការបញ្ជា "ផ្ទាល់" និង "ប្រយោល" ទៅតាមកម្រិត ។ អាចក្លាយជាការទទួលខុសត្រូវលើការបញ្ជាដោយផ្ទាល់បានគឺនៅពេលដែលបុគ្គលថ្នាក់លើបានបញ្ជា ឬជំរុញឲ្យកូនចៅក្រោមបង្គាប់ប្រព្រឹត្តបទឧក្រិដ្ឋ ។ ចំណែកឯការទទួលខុសត្រូវប្រយោលវិញគឺកើតឡើងនៅពេលដែលបុគ្គលថ្នាក់លើខកខានមិនបានដាក់ទណ្ឌកម្មទៅលើកូនចៅដែលនៅក្រោមបង្គាប់ប្រព្រឹត្តបទឧក្រិដ្ឋ ឬក៏មិនចាត់វិធានការទប់ស្កាត់សមហេតុសមផល និងធ្វើការស៊ើបអង្កេតនៅពេលដែលខ្លួនបានដឹងឮ ឬគួរតែបានដឹងឮចំពោះលទ្ធភាពគ្រោះថ្នាក់កម្រិតខ្ពស់នៃបទឧក្រិដ្ឋដែលបានកើតឡើង ។ បុគ្គលថ្នាក់លើអាចដាក់ឲ្យទទួលខុសត្រូវដោយប្រយោលចំពោះការខកខានរបស់ខ្លួនក្នុងការចាត់វិធានការដែលស្ថិតនៅក្នុងវង្វង់នៃ"ការទទួលខុសត្រូវចាំបាច់បំផុត" ទោះបីខ្លួនមិនបានប្រតិបត្តិឬមិនបានប្រព្រឹត្តអំពើនោះក៏ដោយ ។

## III. ការប្រើប្រាស់ជាទូទៅនូវភ័ស្តុតាងឯកសារ

### ក) ការប្រើប្រាស់ភ័ស្តុតាង

ជាទូទៅភ័ស្តុតាងឯកសារគឺភ័ស្តុតាងគួរឲ្យទទួលយកបានដើម្បីបង្ហាញអំពីធាតុផ្សំនៃការទទួលខុសត្រូវលើការបញ្ជា ដែលបង្ហាញថា ធាតុផ្សំនេះត្រូវបានបញ្ជាក់ថាពិត ឬមានសញ្ញាទទួលខុសត្រូវផ្សេងៗមួយទៀតដែលមានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។ បើគ្មានសញ្ញារបៀបនេះទេ ឯកសារទាំងឡាយនឹងមានទម្ងន់ស្រាល ឬមិនអាចត្រូវបានទទួលយកបានទាំងអស់ទៀតផង ។ បើសិនជាគួរឲ្យទទួលយកបាន ឯកសារទាំងនេះអាចត្រូវបានយកមកប្រើប្រាស់ក្នុងការបង្កើតធាតុផ្សំសំខាន់នីមួយៗក្នុងចំណោមធាតុផ្សំទាំងបីនៃការទទួលខុសត្រូវលើការបញ្ជាដែលមានដូចខាងក្រោមនេះ៖

១) ទោសកម្មជាមូលដ្ឋាន

ឯកសារទាំងឡាយអាចប្រើប្រាស់ជាភស្តុតាងបង្ហាញអំពីបទល្មើសព្រហ្មទណ្ឌតាមហេតុការណ៍ពិត ។ អំពើទាំងនេះអាចត្រូវបានប្រព្រឹត្តឡើងដោយចុងចោទខ្លួនឯង ឬដោយកូនចៅដែលស្ថិតនៅក្រោមបញ្ជាខ្លួន ។

២) ទំនាក់ទំនងនៃការបញ្ជា

ឯកសារទាំងឡាយនេះអាចបង្ហាញអំពីអត្ថិភាពនៃទំនាក់ទំនងនៃការបញ្ជា ដោយបញ្ជាក់ថា បុគ្គលថ្នាក់លើមានការគ្រប់គ្រងតាមហេតុការណ៍ពិតទៅលើកូនចៅក្រោមបញ្ជាដែលបានប្រព្រឹត្តអំពើឧក្រិដ្ឋដែលកំពុងតែពិភាក្សានេះ ។ ឯកសារដែលបង្ហាញផ្លូវទាំងនេះរួមមានៈ ក) ឯកសារបោះពុម្ពផ្សាយជាផ្លូវការនូវច្បាប់ក្នុងស្រុកដែលកំណត់ច្បាស់អំពីអំណាចរបស់បុគ្គលដែលស្ថិតនៅក្នុងជំហរណាមួយនោះ ខ) លិខិតូបករណ៍តែងតាំងបុគ្គលនេះឲ្យកាន់មុខងារនិងបញ្ជាក់ច្បាស់អំពីអំណាចនិងតួនាទីរបស់បុគ្គលម្នាក់នេះ គ) បញ្ជាដែលចុះហត្ថលេខា ឬចេញដោយបុគ្គលថ្នាក់លើដែលបង្ហាញពីទំនាក់ទំនងក្នុងការគ្រប់គ្រងដែលមានបញ្ជាក់ពីតួនាទី ឬសកម្មភាពជាក់ស្តែងដែលបញ្ជាក់ពីការគ្រប់គ្រងតាមហេតុការណ៍ពិត និង ឃ) បញ្ជីបង្ហាញពីតួនាទីរបស់បុគ្គលថ្នាក់លើនៅក្នុងជួរបក្សកាន់កាប់អំណាច ។

៣) បំណងឧក្រិដ្ឋ

ដើម្បីបង្ហាញថាបុគ្គលថ្នាក់លើបានដឹងឮអំពីទោសកម្មដែលត្រូវបានប្រព្រឹត្តឡើង លុះត្រាតែមានភស្តុតាងឯកសារពីរប្រភេទៈ ទី១ របាយការណ៍ដែលទទួលដោយចុងចោទពីកូនចៅក្រោមបញ្ជា ដោយរដ្ឋាភិបាលអង្គការក្រៅរដ្ឋាភិបាល ឬប្រព័ន្ធផ្សព្វផ្សាយ អាចទទួលយកជាទូទៅជាការនាំផ្លូវដល់ការដឹងឮរបស់ចុងចោទ បើទោះជាទម្ងន់របស់ឯកសារទាំងនេះមិនគ្រប់គ្រាន់ឈានដល់ការសម្រេចទោសក៏ដោយ ។ ទី២ ឯកសារទាំងឡាយដែលបង្ហាញថាចុងចោទបានចូលរួមក្នុងកិច្ចប្រជុំជាមួយនឹងមេដឹកនាំដែលមានរៀបចំផែនការឬរបាយការណ៍អំពីអំពើឃោរឃៅ អាចយកមកប្រើប្រាស់ជាភស្តុតាងដើម្បីបង្កើតជា«បំណងឧក្រិដ្ឋ» ។

៤) អំពើពិរុទ្ធ

រាល់ភស្តុតាងឯកសារទាំងឡាយណាដែលបង្ហាញថាចុងចោទបានៈ ក) បញ្ជា ជួយឧបត្ថម្ភ ឬជួយជ្រោមជ្រែង ឬ ខ) មិនបានដាក់ទណ្ឌកម្មដល់កូនចៅស្ថិតនៅក្រោមបញ្ជាដែលប្រព្រឹត្តឧក្រិដ្ឋកម្ម គឺអាចទោរទៅរកភស្តុតាងដែលជាការបញ្ជាក់ថាចុងចោទមិនបានចាត់វិធានការសមហេតុផលក្នុងការទប់ស្កាត់រារាំងសកម្មភាពព្រហ្មទណ្ឌដែលអាចកើតឡើង ។ បទបញ្ជាដែលមានបញ្ជាក់ដោយហត្ថលេខា ឬការទាក់ទងដែលបង្ហាញថាពិតជាមានបញ្ជាឲ្យប្រព្រឹត្តបទឧក្រិដ្ឋ ប្រហែលជាទម្រង់មួយដ៏មាំទាំនៃភស្តុតាងឯកសារ ។ វត្តមាននៅក្នុងកិច្ចប្រជុំនានាដែលមានការរៀបចំផែនការពិភាក្សា ឬអនុម័តឲ្យមានការប្រព្រឹត្តបទឧក្រិដ្ឋ ក៏អាចបង្ហាញផ្លូវទៅរកភស្តុតាងដែរ ។ នៅពេលដែលចុងចោទត្រូវបានចោទប្រកាន់ថាខកខានមិនបានទប់ស្កាត់ ឬដាក់ទណ្ឌកម្មចំពោះកូនចៅដែលស្ថិតនៅក្រោមបញ្ជា អង្គជម្រះក្តីត្រូវតែដាក់ស្នើភស្តុតាងមួយចំនួនដែលបង្ហាញពីការខកខាននេះ ។ ភស្តុតាងរបៀបនេះអាចរួមមានដូចជា កំណត់ហេតុប្រជុំ ឬលិខិតទាក់ទងផ្សេងៗដែលបង្ហាញថាបុគ្គលថ្នាក់លើនេះបានគិត ឬពិភាក្សាអំពីសកម្មភាពឧក្រិដ្ឋ ប៉ុន្តែមិនចាត់វិធានការទប់ស្កាត់ ។

ឯកសារទាំងឡាយអាចមានប្រយោជន៍ក្នុងការបង្ហាញពីការកើតឡើងនៃឧក្រិដ្ឋកម្មមូលដ្ឋានឬឧក្រិដ្ឋកម្មដែលចូលជាការទទួលខុសត្រូវលើការបញ្ជា ។ លិខិតឆ្លងឆ្លើយគ្នា និងរបាយការណ៍ផ្លូវការដែលបញ្ជាក់ពីអំពើឧក្រិដ្ឋដែលត្រូវបានប្រព្រឹត្តឡើងគឺជាផ្លូវនាំទៅដល់ភស្តុតាង ។ របាយការណ៍សរសេរឡើងដោយអ្នកជំនាញការដែលរាយលម្អិតអំពីអត្ថិភាពនៃភស្តុតាងជាក់ស្តែង ក៏អាចជាការបង្ហាញអំពីភស្តុតាងដ៏មានប្រយោជន៍ដែរ ។

## ១) ទម្រង់មានបញ្ហានៃភស្តុតាងឯកសារ

ទោះបីជាភស្តុតាងឯកសារត្រូវបានទទួលស្គាល់ជាទូទៅដែលមានការទាក់ទង និងបង្ហាញផ្លូវទៅដល់ភស្តុតាងពិតប្រាកដក៏ពិតមែន តែមានទម្រង់មួយចំនួននៃភស្តុតាងអាចមានបញ្ហាផ្នែកគតិយុត្តិដោយសារទម្រង់ទាំងនេះមានភាពប្រាកដប្រជាតិចតួចពេក ពោលគឺទម្រង់«ពាក្យចចាមអារ៉ាម»និង«ចម្លើយសារភាព» ។

១) ពាក្យចចាមអារ៉ាម

តុលាការឬអង្គជំនុំជម្រះពិសេសដែលរៀបចំផែនការកាត់

ក្តីអតីតមេដឹកនាំនៃបក្សកុម្មុយនិស្តកម្ពុជានិងវិធាននៃការស្វែងរកនៃភ័ស្តុតាងមកប្រើប្រាស់ដោយផ្អែកទៅលើប្រពៃណីនៃច្បាប់ស៊ីវិល ។ នៅក្រោមវិធាននៃច្បាប់ស៊ីវិល ពាក្យចចាមអារ៉ាមមិនត្រូវបានបដិសេធថាមិនមែនជាភ័ស្តុតាងនោះទេ ប៉ុន្តែចៅក្រមក្នុងអង្គជំនុំជម្រះត្រូវប្រគល់សេចក្តីសម្រេចទៅលើភ័ស្តុតាងដែលកើតចេញពីពាក្យចចាមអារ៉ាមដែលមិនសូវមានទម្ងន់ ។ វិធាននេះមានការពាក់ព័ន្ធក្នុងការវាយតម្លៃប្រតិចារឹកស្រង់ពីកិច្ចសម្ភាសន៍ និងពាក្យចចាមអារ៉ាមផ្សេងៗដែលមានលក្ខណៈជាសេចក្តីប្រកាសមាននៅក្នុងឯកសារទាក់ទងគ្នា ។ ដោយសារតែព្រឹត្តិការណ៍ដែលនឹងត្រូវចោទប្រកាន់នៅក្នុងតុលាការកើតឡើងអស់រយៈពេលជាង២០ឆ្នាំទៅហើយ ឯកសារបានមកពីកិច្ចសម្ភាសន៍និងទម្រង់ផ្សេងៗទៀតនៃពាក្យចចាមអារ៉ាម មានប្រភពសំខាន់ៗនៃភ័ស្តុតាងសម្រាប់ការជម្រះក្តីរឿងខ្មែរក្រហម ។

២) ចម្លើយសារភាព

ឯកសារចម្លើយសារភាពគឺជាប្រភេទទី២នៃភ័ស្តុតាងឯកសារដែលមានភាពប្រាកដប្រជា ។ ទោះបីជាចម្លើយសារភាពមិនត្រូវបានយល់ថាមិនមានភាពប្រាកដប្រជាក៏ដោយ ក៏ទម្ងន់របស់ចម្លើយសារភាពមានសភាពខុសប្លែកពីគ្នាទៅតាមការយល់ឃើញរបស់អង្គតុលាការ ទៅលើវិធីនៃការទទួលបានចម្លើយសារភាពទាំងនេះ ។ ចម្លើយសារភាពបានមកដោយការសួរចម្លើយ គ្មានទីប្រឹក្សាច្បាប់និងភ័ស្តុតាងដែលចុងចោទត្រូវបានប្រាប់ពីសិទ្ធិតាមផ្លូវច្បាប់របស់ខ្លួន មានទម្ងន់ស្រាលណាស់យោងតាមហេតុផលពីរយ៉ាងគឺៈ ទី១ ចម្លើយសារភាពរបៀបនេះមិនមានភាពប្រាកដប្រជា ពីព្រោះការពិតនៃចម្លើយសារភាពទាំងនេះមិនមានលក្ខណៈច្បាស់លាស់ទេ និង ទី២ ការប្រើប្រាស់ចម្លើយសារភាពរបៀបនេះផ្ទុយនឹងសញ្ញាណជាមូលដ្ឋាននៃនីតិវិធីយុត្តិធម៌ ។ ដោយសារឯកសារចម្លើយសារភាពមួយភាគធំជារបស់បក្សកុម្មុយនិស្តកម្ពុជា វិធាននេះមានការពាក់ព័ន្ធច្រើនណាស់សម្រាប់ការកាត់ក្តី ។

## IV. *ប្រើប្រាស់ឯកសារតម្កល់ទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជាជាភ័ស្តុតាង*

មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងឯកសារជាច្រើនសន្ធឹកសន្ធាប់ទាក់ទងនឹងរបបខ្មែរក្រហម ដែលជាផ្នែកមួយដ៏សំខាន់អាចយកមកប្រើប្រាស់ជាភ័ស្តុតាងនៅក្នុងដំណើរការកាត់ក្តីមេដឹកនាំកម្ពុជាប្រជាធិបតេយ្យ ។ ឯកសារដើមត្រូវបានរៀបចំជាសំណុំឯកសារថែរក្សាទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជានិងទុកសម្រាប់អធិការកិច្ចដែលមានលក្ខណៈសមស្រប ។ តាមគំនិតខ្ញុំផ្ទាល់យល់ឃើញថា គ្រោះថ្នាក់ដែលនាំឲ្យខូចភ័ស្តុតាងដែលតម្កល់ទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានតិចណាស់ ។ ទោះបីជាខ្ញុំមិនមែនជាអ្នកជំនាញខាងនីតិវិធីបញ្ជាក់អំពីលក្ខណៈយថាភាពពិតត្រឹមត្រូវយ៉ាងណាក៏ដោយ ក៏ខ្ញុំជឿជាក់ថាឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាអាចត្រូវតាមបទដ្ឋានអន្តរជាតិនៅក្នុង«លក្ខណៈយថាភាពពិតត្រឹមត្រូវ» ។

ខាងក្រោមនេះគឺជាគម្រោងចំណុចនៃមធ្យោបាយជាគោលៗមួយចំនួន ដែលតាមរយៈគម្រោងនេះឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាអាចត្រូវបានយកទៅប្រើប្រាស់នៅក្នុងការកាត់ក្តី ។ ខ្ញុំសូមចាប់ផ្តើមតាមរយៈការពិភាក្សាលើបញ្ហាសំខាន់ជាមុនដំបូងគឺៈ ក) ពាក្យកាត់ដែលត្រូវបានប្រើដោយបក្សកុម្មុយនិស្តកម្ពុជា ។ បន្ទាប់មកខ្ញុំនឹងបន្តវគ្គទី២ ខ) ដើម្បីពិភាក្សាមធ្យោបាយទូទៅដែលនៅក្នុងនោះឯកសារទាំងឡាយអាចយកមកប្រើក្នុងការបង្ហាញថាចុងចោទបានប្រព្រឹត្តបទឧក្រិដ្ឋ ឬទទួលខុសត្រូវចំពោះបទឧក្រិដ្ឋតាមរយៈគោលការណ៍នៃការទទួលខុសត្រូវលើការបញ្ជា គ) និយាយពីបញ្ហាភ័ស្តុតាងជាក់ស្តែងផ្សេងៗ និង ឃ) ទាក់ទងនឹងបញ្ហាសំខាន់មួយនៃការបញ្ជាក់ពីសំណាក់សាក្សី ។

### *ក) ពាក្យកាត់*

ជំហានសំខាន់ដំបូងក្នុងការប្រើប្រាស់ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាជាភ័ស្តុតាងគឺត្រូវបញ្ជាក់ន័យពិតប្រាកដរបស់ពាក្យកាត់មួយចំនួនរបស់បក្សកុម្មុយនិស្តកម្ពុជា ។ ឯកសាររបស់បក្សជាញឹកញយមានប្រើរហស្សនាមនិងឈ្មោះក្លែងក្លាយដែលជាការបិទបាំងដល់អត្តសញ្ញាណរបស់សមាជិកបក្សដែលមានការពាក់ព័ន្ធ និងការឆ្លើយឆ្លងគ្នា ។ ដើម្បីប្រើប្រាស់ឯកសារទាំងនេះជាភ័ស្តុតាងឲ្យមានប្រយោជន៍ ជាការសំខាន់ក្នុងការបង្ហាញថាពាក្យកាត់ទាំងនេះត្រូវបានយោងទៅលើសកម្មភាព

ដាក់លាក់ផ្សេងៗនិងបុគ្គលណាមួយ ។

ទោះបីជាឯកសារទាំងនេះមានការបញ្ជាក់ពីន័យរបស់ពាក្យកាត់យ៉ាងណាក៏ដោយ ក៏ពាក្យទាំងនេះមិនមានន័យពិតប្រាកដច្បាស់លាស់ដែរ ។ ដូចនេះជាការចាំបាច់ណាស់ក្នុងការជ្រើសរើសសាក្សីធម្មតានិងសាក្សីជំនាញច្បាស់លាស់ មកបង្ហាញន័យរបស់ពាក្យនីមួយៗឲ្យបានច្បាស់ ។ ថ្មីៗនេះ លោក ស៊ីវ ហេឌ័រ បានធ្វើវិភាគអត្ថន័យរបស់ពាក្យ "កម្ទេច" និង "បោសសម្អាត" ដែលត្រូវបានប្រើប្រាស់នៅក្នុងការចងក្រងឯកសាររបស់បក្សកុម្មុនិស្តកម្ពុជា ។ លោក ស៊ីវ និងប្រវត្តិវិទូដទៃទៀត បានទាញសេចក្តីសន្និដ្ឋានថា "កម្ទេច"មានន័យថា "សម្លាប់" ហើយចំណែកពាក្យ"សម្រិតសម្រាំង" ទាក់ទងសកម្មភាពជាច្រើនក្នុងការកម្ចាត់បុគ្គលដែលបក្សកុម្មុយនិស្តយល់ថាជាខ្មាំងរបស់ខ្លួន ។ ពាក្យថា "ខ្មាំង" ឬ "សមាសភាពមិនល្អ" ក៏មានជាញឹកញាប់នៅក្នុងការធ្វើឯកសារដែរ ។ ពាក្យនេះត្រូវបាននិយាយយោងទៅដល់អ្នកដែលប្រឆាំងនឹងអង្គការ ។

១) "កម្ទេច" និង "បំផ្លាញ"

នៅក្នុងករណីខ្លះ ការបង្រួញន័យកុំឲ្យទូលំទូលាយឬឲ្យកាន់តែច្បាស់ជាការចាំបាច់ណាស់សម្រាប់ការកាត់ក្តី ។ ឧទាហរណ៍ពាក្យ"កម្ទេច" ។ ពាក្យនេះគួរតែត្រូវបានបញ្ជាក់ឲ្យបានច្បាស់ថាមានន័យពិសេស ពោលគឺ"សម្លាប់" ។ និយមន័យមួយដែលមានលក្ខណៈទូលំទូលាយរួមទាំងទម្រង់នៃការដាក់ទណ្ឌកម្មតាមផ្លូវច្បាប់ផងអាចធ្វើឲ្យមានការដោះទាល់ការពារខ្លួន ដែលអាចទាញជាហេតុផលថារាល់ការ"កម្ទេច"ត្រូវបានរាយការណ៍មក អាចបង្កើតជាអំពើមួយដែលស្របច្បាប់ ។ ដោយសារតែធាតុផ្សំនីមួយៗនៃបទឧក្រិដ្ឋត្រូវតែបង្ហាញឲ្យបានច្បាស់លាស់ បើពុំនោះសោតការការពារក្តីរបស់ចុងចោទអាចឈ្នះបាន ។ ពាក្យថា "បំផ្លាញ" ដែលត្រូវបាននិយាយយោងដល់ការសម្លាប់មនុស្សក្នុងចំនួនច្រើន ក៏គួរតែកំណត់ឲ្យបានច្បាស់លាស់ដែរ ។

២) "ការសម្រិតសម្រាំង" និង "ការបោសសម្អាត"

ពាក្យថា "សម្រិតសម្រាំង" គឺពិបាកយល់បន្តិច ។ ន័យពិតរបស់ពាក្យនេះពុំមានលក្ខណៈច្បាស់ដូចពាក្យថា"កម្ទេច"ទេ ហើយភាពមិនច្បាស់លាស់ស្រពេចស្រពិលនេះអាចធ្វើឲ្យទឡ្ហីករណ៍របស់ចុងចោទកាន់តែមានទម្ងន់ ដែលនាំដល់ការទាញហេតុផលច្បាប់យ៉ាងច្បាស់លាស់គ្រប់គ្រាន់ថា នេះគឺគ្រាន់តែជា "ការសម្រិតសម្រាំង" សមាសភាពរបស់បក្សតែប៉ុណ្ណោះ មិនមែន "កម្ទេចទេ" ។ ដោយសារហេតុផលនេះ ការកាត់សេចក្តីត្រូវតែផ្តោតយ៉ាងសំខាន់ទៅលើនិយមន័យនៃពាក្យនេះ ។ និយមន័យដែលល្អបំផុត គួរតែកម្រិតដល់ការសម្លាប់ ការធ្វើទុកបុកម្នេញ ការជម្លៀស ឬការឃុំឃាំងតាមទំនើងចិត្តជាអំពើដែលចូលទៅក្នុងនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។ ការឲ្យនិយមន័យទូលំទូលាយ ពេកនឹងផ្តល់មធ្យោបាយឲ្យចុងចោទវាយប្រហារមកលើឯកសារយោងទាំងឡាយដែលប្រឆាំងនឹងខ្លួនជាមិនខាន ។

"បោសសម្អាត"គឺជាពាក្យដែលកម្រប្រើ ។ ពាក្យនេះមានន័យប្រហាក់ប្រហែលគ្នាជាមួយនឹងពាក្យ"សម្រិតសម្រាំង" ។ ការកាត់ក្តីគួរតែមានបំណងដាក់ពាក្យ "បោសសម្អាត" ឲ្យចូលក្នុងអំពើផ្សេងៗដូចជាការសម្លាប់និងការជម្លៀសចូលនៅក្នុងបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលអាចផ្តន្ទាទោសបាន ។ សក្ខីកម្មរបស់អ្នកជំនាញការនិងសាក្សីមកពីសមាជិកនៃបក្សកុម្មុយនិស្តកម្ពុជា អាចក្លាយជាមធ្យោបាយដ៏មានប្រសិទ្ធភាពក្នុងការផ្តល់បន្ថែមនូវសញ្ញាប្រាប់ផ្លូវចំពោះឯកសារខ្លួនឯងផ្ទាល់ ។

៣) "ខ្មាំង" និង "សមាសភាពមិនល្អ"

ពាក្យពីរទៀត ជាទូទៅត្រូវបានប្រើនៅក្នុងការចងក្រងឯកសាររបស់បក្សកុម្មុយនិស្តកម្ពុជាគឺ "ខ្មាំង" និង"សមាសភាពមិនល្អ" ។ ពាក្យទាំងពីរនេះនិយាយយោងដល់បុគ្គលដែលត្រូវបានចុះឈ្មោះយកទៅអប់រំកែប្រែ ដាក់ទណ្ឌកម្ម និង"សម្រិតសម្រាំង" ដោយបក្សកុម្មុយនិស្តកម្ពុជា ។ ក៏ប៉ុន្តែនិយមន័យពិតប្រាកដនៃពាក្យថា "ខ្មាំង" និង "សមាសភាពមិនល្អ" អាចមានផលប៉ះពាល់យ៉ាងធ្ងន់ទៅលើកម្លាំង និងការយកមកប្រើប្រាស់នូវភ័ស្តុតាងឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ ដើម្បីទាញថាមេដឹកនាំជាន់ខ្ពស់នៃបក្សកុម្មុយនិស្តកម្ពុជាពិតជាបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍ឬឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ពាក្យថា"ខ្មាំង"ត្រូវតែកំណត់ឲ្យបានច្បាស់លាស់ថាជាសមាជិកនៃក្រុមត្រូវបានការពារដោយច្បាប់ ។ **(នៅមានត)**

**ចន ឆរតីអារី**

# ការអនុវត្តច្បាប់ចំពោះករណីខ្មែរក្រហម

ពាក់ព័ន្ធនឹងទោសកំហុសរបស់មន្ត្រីខ្មែរក្រហមក្រោមច្បាប់កម្ពុជា ទាមទារនូវការវិភាគយ៉ាងល្អិតល្អន់នូវកម្រងទាំងមូលរបស់ក្រមព្រហ្មទណ្ឌកម្ពុជា និងការគិតពិចារណានូវកត្តាសំខាន់នានានិងដែលមានពីមុនមក ដែលមិនអាចបានមកពីការគ្រាន់តែពិនិត្យឡើងវិញនូវច្បាប់ខក្រិដ្ឋប៉ុណ្ណោះទេ ។

ចំពោះបទល្មើសសំខាន់ៗផ្សេងទៀតមានការលេចឡើងថាភាពឃោរឃៅប្រព្រឹត្តដោយខ្មែរក្រហមត្រូវនឹងនិយមន័យទូទៅនៃខក្រិដ្ឋកម្មនានានៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ ។ ភាពឃោរឃៅទាំងអស់នោះរួមមានៈ ឃាតកម្ម ការធ្វើទារុណកម្ម ការចាប់រំលោភ ការឃុំខ្លួនដោយខុសច្បាប់ ការវាយតប់លើរាងកាយ ការវាយប្រហារទៅលើសាសនា និងការរំលោភបំពានផ្សេងៗទៀតរបស់អាជ្ញាធររដ្ឋាភិបាល ។ ដោយសារបទល្មើសទាំងអស់នេះគឺជាខក្រិដ្ឋកម្មក្រោមច្បាប់កម្ពុជា ព្រះរាជអាជ្ញានឹងមិនចាំបាច់បង្ហាញនូវធាតុផ្សំបន្ថែមសម្រាប់ទាញឲ្យចូលជាអំពើប្រល័យពូជសាសន៍ខក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ខក្រិដ្ឋកម្មសង្គ្រាម និងខក្រិដ្ឋកម្មអន្តជាតិផ្សេងៗទៀតនោះទេ ។ ជាពិសេស បំណងបំផ្លាញក្រុមនានា លក្ខណៈជាប្រព័ន្ធ ទំហំនិងមូលហេតុបណ្តាលឲ្យមានការប្រឆាំងនឹងបុគ្គលម្នាក់ ដោយសារតែមានអត្តការក្រុម ហើយនិងសម្ព័ន្ធជម្លោះប្រដាប់អាវុធទាំងអស់នេះគឺមិនជាប់ទាក់ទងឡើយ ។

ការពិនិត្យសើរើឡើងវិញយ៉ាងល្អិតល្អន់នូវច្បាប់ខក្រិដ្ឋកម្ពុជា ប្រាកដណាស់នឹងឆ្លុះបញ្ចាំងឲ្យឃើញនូវអំពើខក្រិដ្ឋកម្មដ៏ច្រើនអនេក រួមមាន ខក្រិដ្ឋកម្មលើទ្រព្យសម្បត្តិជាច្រើននិងការរំលោភបំពានផ្សេងទៀតទៅលើសិទ្ធិពលរដ្ឋនិងសិទ្ធិខាងកម្មសិទ្ធិទ្រព្យសម្បត្តិ ។ ការស្វែងរកមន្ត្រីខ្មែរក្រហមទទួលខុសត្រូវចំពោះខក្រិដ្ឋកម្មកម្ពុជាក្នុងលក្ខណៈតូចតាច នឹងរងនូវគុណវិបត្តិដូចគ្នាទៅនឹងការប៉ុនប៉ងយកអ្នកទាំងនោះមកកាត់ទោសចំពោះការទទួលខុសត្រូវលើបទខក្រិដ្ឋកម្មអន្តរជាតិក្នុងលក្ខណៈតូចតាចដែរពោលគឺមានផលចំណេញតូចទាបណាស់សម្រាប់ពេលវេលាស៊ើបអង្កេតដែលត្រូវទាមទារឲ្យចំណាយនោះ ។ ក៏ប៉ុន្តែចម្លើយរបស់មេធាវីការពារចុងចោទលើកឡើងនូវការពិចារណាដ៏សំខាន់មួយចំនួន ។ ទី១ ជនល្មើសស្ថិតក្នុងយុវភាពប្រហែលជាអាចត្រូវលើកទោស ជាពិសេសដោយសារអ្នកទាំងនោះត្រូវបានផ្តល់នូវការគ្រប់គ្រងជាលក្ខណៈផ្តាច់ការនិងបរិយាកាសដ៏រន្ធត់ញាប់ញ័រព្រៃផ្សៃដែលគ្របដណ្តប់ប្រទេសក្នុងអំឡុងពេលដែលពួកខ្មែរក្រហមបានកាន់អំណាចនោះ ។ ហេតុដូច្នេះ លទ្ធផលនៃការរកឃើញពីទោសកំហុសរបស់ក្មេងជំទង់ដែលមិនអាចយល់ពីអ្វីដែលល្អឬអាក្រក់នោះ ហាក់ដូចជាពិបាកនឹងមាននិរន្តរភាពណាស់ ។ ទី២ ស្ថានការណ៍ពិតប្រាកដពីខាងចុងចោទតម្រូវឲ្យមានការបរិយាយយ៉ាងពិស្តារ ថ្វីបើច្បាប់ហាក់ដូចជាលើកសំណូមពរថាជនល្មើសម្នាក់ត្រូវតែប្រឈមមុខនឹងស្ថានភាព "សម្លាប់ ឬត្រូវសម្លាប់" ដោយពិតប្រាកដ ។ ករណីនេះអាចកម្រិតចំនួនមនុស្សដែលអាស្រ័យលើការការពារខ្លួនបែបនេះឲ្យមានចំនួនកាន់តែតិច ។ស្រដៀងគ្នាដែរ យើងបានលើកជាសំណួរថាតើការទាញហេតុផលឲ្យមានសិទ្ធិស្វ័យការពារនឹងត្រូវអនុវត្តដែរឬក៏អត់នៅក្នុងស្ថានការណ៍ជាច្រើនដែលកើតមានដល់ភាពអស់រំពឹងរបស់ជនរងគ្រោះស្ទើរតែទាំងអស់របស់ខ្មែរក្រហម ។ ទី៣គឺទំហំនៃចុងចោទដែលការពារខ្លួនថា ខ្លួនបានធ្វើតាមបញ្ជានៅក្រោមច្បាប់កម្ពុជានោះ ចាំបាច់ត្រូវតែកំណត់ឲ្យបានច្បាស់ ។ តើបញ្ជារបស់ខ្មែរក្រហមត្រឹមត្រូវតាមច្បាប់ចំពោះបំណងនៃការការពារនេះដែរឬទេ? ប្រសិនបើអត់ទេ តើថ្នាក់ក្រោមត្រូវទទួលខុសត្រូវចំពោះការអនុវត្តនូវបញ្ជាខុសច្បាប់ត្រឹមកម្រិតណាដែរ? ដើម្បីឆ្លើយនឹងសំណួរទាំងអស់នេះ តុលាការនឹងត្រូវក្រឡេកមើលបញ្ហាអតីតកាលដែលកើតឡើងពីសង្គ្រាមលោកលើកទី២ និងស្ថានការណ៍ដទៃទៀត ។ ការពិនិត្យមើលនេះផ្តល់នូវលទ្ធផលយ៉ាងណាក៏ដោយ ក៏គ្មានភាពមន្ទិលសង្ស័យទាល់តែ

សោះថា ជនទាំងឡាយដែលមានឋានៈជាថ្នាក់ដឹកនាំជាតិ ឬក៏ជនដទៃទៀត មានអភ័យឯកសិទ្ធិគ្រប់គ្រាន់ដើម្បីចេញបញ្ហានេះ មិនអាចយកមកការពារបែបនេះមកអនុវត្តបានឡើយ ។

ជាចុងក្រោយហើយសំខាន់បំផុតនោះគឺបញ្ហាខាងដែនអាជ្ញាយុកាល ។ ការបកស្រាយមួយជាធម្មតានឹងផ្តល់ឲ្យត្រឹមតែតម្លៃសំបកខាងក្រៅ ហើយច្រានចោលនូវការនាំយកមន្ត្រីខ្មែរក្រហមមកកាត់ទោសចំពោះអំពើឃោរឃៅរបស់ខ្លួនក្នុងអំឡុងឆ្នាំ ១៩៧៥-១៩៧៩ និងក្រោយខែមករា ឆ្នាំ១៩៨៩ ពេលគឺរយៈពេលដប់ឆ្នាំបន្ទាប់ពីថ្នាក់ដឹកនាំទាំងនោះរត់ចេញពីភ្នំពេញ ។ តាមពិតទៅឧក្រិដ្ឋកម្មប្រព្រឹត្តមុនឆ្នាំ១៩៧៩ គួរតែត្រូវបានធ្វើការស៊ើបអង្កេតឬកាត់សេចក្តីឲ្យបានមុនឆ្នាំ១៩៨៩ ។ ក៏ប៉ុន្តែការបកស្រាយនិងការជ្រើសរើសដទៃទៀតក៏មានអត្ថិភាពសម្រាប់ព្រះរាជអាជ្ញានិងតុលាការដែរ ។ ទី១ តុលាការអាចកំណត់ថា អវត្តមាននៃប្រព័ន្ធតុលាការនៅកម្ពុជាចាប់តាំងពីឆ្នាំ ១៩៧៥ គឺបញ្ជាក់ថាដែនអាជ្ញាយុកាលគ្មានសុពលភាពតាំងពីពេលនោះមក ។ តាមទ្រឹស្តីនេះដែនអាជ្ញាយុកាលគ្មានដំណើរការរហូតដល់មានការិយាល័យព្រះរាជអាជ្ញាដ៏មានប្រសិទ្ធភាពមួយ និងប្រព័ន្ធតុលាការដែលត្រូវបានបង្កើតឡើងវិញ ។ គោលគំនិតដែលថា “គ្មានជនណាម្នាក់អាចធ្វើឲ្យប្រសើរឡើងនូវឋានៈរបស់ខ្លួនដោយសារការធ្វើខុសរបស់ខ្លួនឡើយ” មានន័យថា ពួកខ្មែរក្រហមមិនគួរបានទទួលប្រយោជន៍ពីការបំផ្លិចបំផ្លាញរបស់ខ្លួននូវប្រព័ន្ធតុលាការកម្ពុជាក្នុងអំឡុងចុងទសវត្សរ៍ឆ្នាំ១៩៧០ឡើយ ។

ការទាញហេតុផលនេះក៏ផ្តល់នូវគុណសម្បត្តិដែរ ករណីដែលមានការយល់ឃើញថា ក្រមព្រហ្មទណ្ឌកម្ពុជា “ឬក៏ច្បាប់ក្នុងប្រទេសនានាផ្សេងទៀត” ដូចជាប្រព័ន្ធតុលាការដែលដំណើរការនៅក្នុងរដ្ឋាភិបាលដោយមានការគ្រប់គ្រងទៅលើបូរណភាពរបស់ខ្លួន នៅមិនទាន់មាននៅឡើយទេតាំងពីឆ្នាំ១៩៧៩មក ។ ប្រព័ន្ធតុលាការស្ថិតនៅតែក្នុងសភាពបុរាណនិងគ្មានរបៀបរៀបរយ ដែលនាំឲ្យជនសង្ស័យស្ថិតនៅក្រៅពីការគ្រប់គ្រងនៃអាជ្ញាធរមជ្ឈិម ។ ទោះបីជាតុលាការបដិសេធមិនព្រមពន្យារដែនអាជ្ញាយុកាលសម្រាប់ហេតុផលទាំងអស់នេះក្តី ក៏សភាជាតិប្រហែលជាអនុម័តនូវច្បាប់មួយប្រហែលគ្នានេះហើយ ។ ប្រទេសកម្ពុជាអាចយកច្បាប់បារាំងស្រដៀងគ្នានេះធ្វើជាមូលដ្ឋាន ដែលច្បាប់នោះបានពន្យារដែនអាជ្ញាយុកាលស្តីពីការកាត់សេចក្តីដោយសារតែតុលាការដ៏មានប្រសិទ្ធភាពក្នុងអំឡុងសង្គ្រាមលោកលើកទី២ ។ ទី២ តុលាការអាចកំណត់ថា ការកាត់ទោសកំបាំងមុខមេដឹកនាំខ្មែរក្រហមនៅឆ្នាំ១៩៧៩ ដោយសាធារណរដ្ឋប្រជាមានិតកម្ពុជាជួយធ្វើឲ្យគ្មានដែនអាជ្ញាយុកាលទេ ហើយថា ទាំងរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជានិងរដ្ឋាភិបាលក្រោយៗមកទៀត បាននិងកំពុងស៊ើបអង្កេតនូវឧក្រិដ្ឋកម្មរបស់ពួកខ្មែរក្រហមតាំងពីពេលនោះមក ។ មាត្រា១១២ និងមាត្រា ១១៤នៃក្រមព្រហ្មទណ្ឌបានចែងថា ការស៊ើបអង្កេតណាដែលបញ្ជាដោយអាជ្ញាធរតុលាការគឺធ្វើឲ្យអាក់ខានដល់ដែនអាជ្ញាយុកាល សូម្បីតែការស៊ើបអង្កេតនេះមានន័យថាជាការសំដៅរកឲ្យឃើញនូវអត្តសញ្ញាណនៃជនល្មើសក៏ដោយ ។ ដែនអាជ្ញាយុកាលមិនចាប់ផ្តើមដំណើរការជាថ្មីម្តងទៀតទេ រហូតដល់ដំណាក់កាលចុងក្រោយនៃសកម្មភាព ។ ក៏ប៉ុន្តែការទាញហេតុផលនេះមានគុណវិបត្តិជាក់ស្តែង២គឺ ការកាត់ទោសឆ្នាំ១៩៧៩ខ្លួនឯង គឺគួរឲ្យសង្ស័យថាអាចធ្វើជាគំរូច្បាប់បាន ហើយយើងមិនបានដឹងទាល់តែសោះថាតើមានការស៊ើបអង្កេតរឿងឧក្រិដ្ឋកម្មពិតប្រាកដមែនទែនអំពីរឿងអំពើឃោរឃៅរបស់ខ្មែរក្រហមដោយអាជ្ញាធរកម្ពុជាដែរឬក៏អត់តាំងពីពេលមានការកាត់ក្តីទាំងអស់នេះមក ។ ទី២ដែលជាចំណុចគួររំពឹងដែរនោះគឺថា រាជរដ្ឋាភិបាលកម្ពុជាអាចអនុម័តច្បាប់ថ្មីដែលបន្ទាយពេល ឬក៏លុបចោល “ដែលផុយទៅនឹងការពន្យារ” ដែនអាជ្ញាយុកាលក្នុងករណីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលរួមមានអំពើប្រល័យពូជសាសន៍ជាដើម ។ យុទ្ធសាស្ត្របែបនេះមានគំរូពីមុនមកគ្រប់គ្រាន់ដូចជាក្នុងសកម្មភាពធ្វើដោយរដ្ឋាភិបាលអឺរ៉ុបខាងលិច ជាពិសេសសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ក្នុងទសវត្សរ៍ឆ្នាំ១៩៦០ជាឆ្នាំដែលដែនអាជ្ញាយុកាលធម្មតាចាប់ផ្តើមផុតកំណត់ចំពោះឧក្រិដ្ឋកម្មនានាដែលប្រព្រឹត្តដោយពួកណាហ្ស៊ី ។ ការលុបចោលនូវដែនអាជ្ញាយុកាលអាចនឹងត្រូវស្របគ្នាជាមួយ“កតិកាសញ្ញាឆ្នាំ ១៩៦៨ ស្តីពីការមិនអាចអនុវត្តដែនអាជ្ញាយុកាលចំពោះឧក្រិដ្ឋកម្មសង្គ្រាមនិងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ” **(តទៅទំព័រ៦០)**

# ភាពខុសគ្នារវាងទួលស្លែង និង ស-២១

ខ្ញុំបានចាប់ផ្តើមអានឯកសារនៅសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែងនាដើមទសវត្សរ៍ឆ្នាំ១៩៩០ ។ ចាប់តាំងពីពេលនោះមកខ្ញុំបានអានឯកសាររាប់ពាន់ ហើយខ្ញុំក៏បានរៀបចំជាកិច្ចពិភាក្សានិងសិក្ខាសាលានានាស្តីអំពីសារមន្ទីរនិងគុករបស់កម្ពុជាប្រជាធិបតេយ្យដែលនៅក្នុងជំនាន់នោះ ត្រូវបានហៅថាមន្ទីរ“ស-២១” ។ នៅក្នុងស្នាដៃសៀវភៅរបស់ខ្ញុំដែលមានចំណងជើងថា “សម្លេងពីមន្ទីរស-២១” ខ្ញុំបានសង្ខេបនូវការសិក្សាស្រាវជ្រាវរបស់ខ្ញុំចេញពីឯកសារនិងកិច្ចសម្ភាសន៍ជាមួយអ្នកដែលនៅរស់រានមានជីវិតមកអំពីគុកនេះ ព្រមទាំងអ្នកដែលធ្លាប់ធ្វើការនៅក្នុងគុកនេះទៀតផង ។ សៀវភៅនេះកំពុងតែត្រូវបានបកប្រែមួយវគ្គម្តងៗចុះផ្សាយតាមទស្សនាវដ្តី “ស្វែងរកការពិត” របស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលចេញផ្សាយជារៀងរាល់ខែ ។

ជាញឹកញាប់ ប្រជាជនខ្មែរបានប្រាប់ខ្ញុំថា “ស-២១” ត្រូវបានប្រឌិតឡើងដោយវៀតណាមទាំងស្រុង ដើម្បីធ្វើឲ្យខូចដល់កិត្តិយសប្រជាជនកម្ពុជា និងចោទប្រកាន់ប្រជាជនកម្ពុជាទាំងអស់ថាបានប្រព្រឹត្តខុក្រិដ្ឋកម្មប្រល័យពូជសាសន៍ ។ គ្មាននរណាម្នាក់ដែលនិយាយជាមួយខ្ញុំអំពីបញ្ហានេះអាចត្រូវបានចាត់ទុកថាជាខ្មែរក្រហមទេ ។

ខ្ញុំតែងតែឆ្លើយតបទៅវិញថា ខ្ញុំជឿថាការឲ្យយោបល់របស់ប្រជាជនទាំងនោះគឺពិតជាការយល់ច្រឡំហើយ ។ កិច្ចប្រឹងប្រែងក្នុងការប្រឌិត “ស-២១” តាមខ្ញុំគិតគឺឆ្ងាយពីអ្វីដែលថាជាការប្រឌិតរបស់វៀតណាម និងមានភាពស្មុគស្មាញពេកណាស់ ។ វៀតណាមគ្មានប្រភពឯណានឹងតាក់តែងជាឯកសារឲ្យដូចទៅនឹងឯកសារដែលត្រូវបានរកឃើញនៅក្នុងបណ្ណសាររបស់មន្ទីរស-២១ (ព្រមទាំងឯកសាររាប់ពាន់ទៀតដែលទាក់ទងនឹងស-២១ ហើយដែលត្រូវបានរកឃើញនៅតាមកន្លែងនានានៅក្នុងទីក្រុងភ្នំពេញក្រោយពីវៀតណាមដកទ័ពចេញពីប្រទេសកម្ពុជា) ដើម្បីប្រឌិតជាឈ្មោះនិងប្រវត្តិរបស់អ្នកធ្វើការនៅក្នុងគុកនេះ ធ្វើរូបថតភ័ស្តុតាងក្លែងក្លាយនិងកសាងឯកសារប្រវត្តិរូបរបស់អ្នកដែលនៅរស់រានមានជីវិតព្រមទាំងអតីតអ្នកធ្វើការនៅក្នុងគុកនោះទេ ។ ជាងនេះទៅទៀត ប្រសិនបើវៀតណាមបានធ្វើសកម្មភាពយ៉ាងដូច្នេះមែនម៉្លេះ អ្នកដែលបានចូលរួមក្នុងសកម្មភាពនឹងនិយាយអំពីរឿងនេះ ជាពិសេស ក្រោយពេលវៀតណាមដកទ័ពចេញពីកម្ពុជានៅឆ្នាំ១៩៨៩ ។

បើនិយាយឲ្យប្រាកដ សន្ទុះក្នុងការប្រែក្លាយមន្ទីរស-២១ឲ្យទៅជាសារមន្ទីរទួលស្លែងគឺចេញមកពីវៀតណាម ក្រោមការដឹកនាំរបស់វរសេនីយ៍ឯក ម៉ៃ ឡាំ ដែលសព្វថ្ងៃនេះចូលនិវត្តន៍ ហើយកំពុងរស់នៅទីក្រុងហូជីមិញ ។ ម៉ៃ ឡាំ ត្រូវបានធ្វើសម្ភាសន៍ជាញឹកញាយ ។ ម៉ៃ ឡាំ និយាយថា គាត់មានមោទកភាពណាស់ចំពោះស្នាដៃរបស់គាត់ក្នុងការប្រែក្លាយមន្ទីរស-២១ ឲ្យទៅជាសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ។ ម៉ៃ ឡាំ ក៏រីករាយដែរ ដែលបានប្រែក្លាយវាលពិឃាតជើងឯកដែលអ្នកទោសមន្ទីរស-២១ជាង១ម៉ឺននាក់បានសម្លាប់ឲ្យទៅជាកន្លែងទេសចរណ៍មួយដ៏គួរឲ្យរន្ធត់ ។

វៀតណាមបានបង្កើតជាសារមន្ទីរនៅទួលស្លែងនៅក្នុងរវាងឆ្នាំ១៩៧៩-១៩៨០ គឺដោយសារមានមូលហេតុច្រើនយ៉ាង ។

ទី១ គឺខ្ញុំជឿថាវាជាការសំខាន់សម្រាប់វៀតណាមក្នុងការធ្វើឲ្យវត្តមានរបស់ខ្លួននៅក្នុងប្រទេសកម្ពុជានិងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតកម្ពុជាមានមូលដ្ឋានស្របច្បាប់ ដោយហេតុថាខ្លួនបានរំដោះប្រទេសកម្ពុជាចេញពី “បនប្រល័យពូជសាសន៍” ប៉ុល ពត អៀង សារី ដែលត្រូវបានកាត់ទោសប្រហារជីវិតកំបាំងមុខនៅក្នុងខែសីហាឆ្នាំ១៩៧៩ ។ ទី២ ជាការសំខាន់សម្រាប់វៀតណាមនិងសម្ព័ន្ធមិត្តរបស់ខ្លួននៅក្នុងប្លុកសូវៀត ក្នុងការគម្លាតខ្លួនពីបក្សកុម្មុយនិស្តនិងដៃគូកម្ពុជា ឲ្យចេញឆ្ងាយពីរបបកុម្មុយនិស្តកម្ពុជាប្រជាធិបតេយ្យ ។ ទី៣ វៀតណាមនិងសាធារណរដ្ឋប្រជាមានិតកម្ពុជាចង់ដាក់ឈ្មោះរបបកម្ពុជាប្រជាធិបតេយ្យថាជារបប“ហ្វាស៊ីស” ដូចជាណាហ្ស៊ីអាល្លឺម៉ង់ជាជាងដាក់ថា “របបកុម្មុយនិស្ត” ដូចដែលបានទទួលស្គាល់ដោយប្រទេសកាន់លទ្ធិកុម្មុយនិស្តជាច្រើន ។

មូលហេតុចុងក្រោយមួយទៀតគឺវៀតណាមចង់ទាញហេតុផលថា អ្វីដែលកើតឡើងនៅក្នុងប្រទេសកម្ពុជាក្រោមរបបកម្ពុជាប្រជា-ធិបតេយ្យ ជាពិសេសនៅមន្ទីរស-២១ គឺជាអំពើប្រល័យពូជសាសន៍ដែលមានលក្ខណៈដូចគ្នាទៅនឹងហាយនភាពនៅក្នុងសង្គ្រាមលោកលើកទី២ ហើយថា វាមិនមែនជាការធ្វើឃាតខ្មាំងនយោបាយដែលកើតឡើងក្នុងសម័យផ្សេងៗគ្នានៅក្នុងប្រវត្តិសាស្ត្រសហភាពសូវៀតប្រទេសចិនកុម្មុយនិស្តនិងវៀតណាមនោះឡើយ ។

វៀតណាមបានរៀបចំមន្ទីរស-២១ឲ្យក្លាយទៅជាសារមន្ទីរដោយប្រើប្រាស់ឯកសារយ៉ាងច្រើនសន្ធឹកសន្ធាប់ដែលនៅសេសសល់ក្នុងទីតាំងនេះតែម្តង ។ ដូចគ្នានេះ វៀតណាមបានប្រែក្លាយជើងឯកទៅជាកន្លែងទេសចរណ៍ក្រោយពីបានជីកគាសរណ្តៅខ្មោចជាច្រើននៅទីនោះរួចមក ។ វៀតណាមមិនបានបង្កើតជាស្ថាប័នមន្ទីរស-២១ទេ ។ ផ្ទុយមកវិញ ឯកសារនៅបណ្ណសារមន្ទីរស-២១ រូបថតអ្នកទោសកិច្ចសម្ភាសន៍ជាមួយអ្នកមានវាសនារស់រានមានជីវិតនិងអតីតអ្នកធ្វើការនៅក្នុងគុកនេះបាននាំឲ្យខ្ញុំជឿជាក់ថាមន្ទីរស-២១គឺជាស្ថាប័នរបស់កម្ពុជាដែលបម្រើឲ្យគោលបំណងដ៏គួរឲ្យតក់ស្លុតរបស់មេដឹកនាំព្រៃផ្សៃនៃរបបមួយគួរឲ្យភ័យខ្លាចជាទីបំផុត ។

**ដេវីដ ឆេនដល័រ**

# ជនកុម្មុយនិស្តខ្មែរក្រហម និង វៀតណាមៈ
# ប្រវត្តិទំនាក់ទំនងរវាងខ្មែរក្រហម និង វៀតណាម

**(តពីលេខមុន)** នៅឆ្នាំ១៩៦៦ ស្ថានទូតសូវៀតប្រចាំនៅទីក្រុងភ្នំពេញបានចាប់ផ្ដើមទទួលសារដែលមានសេចក្ដីថា "បក្សកុម្មុយនិស្តកំពុងតែរៀបចំកៀងគរមហាជនធ្វើការបះបោរប្រដាប់អាវុធ" ។ នៅក្នុងខែធ្នូ ឆ្នាំ១៩៦៦ ទិនានុប្បវត្តិ"សម្លេងពលករ" ដែលជិតដិតជាមួយនឹងជនបក្ខពួកកុម្មុយនិស្ត បានបោះពុម្ពផ្សាយអត្ថបទមួយនិយាយថា "បងប្អូនកម្មករ កសិករ ចូររួបរួមគ្នាឡើងដើម្បីរកគ្រប់មធ្យោបាយកម្ទេចពួកដឹកនាំសក្តិភូមិនិងប្រតិកិរិយា និងខ្ញុំបម្រើឲ្យអស់ពីកម្ពុជា" ។

ដោយអនុះសាថា "ប្អូនៗ" កំពុងតែបាត់ម្ចាស់ការ ហើយទុកផលប្រយោជន៍វៀតណាមខាងជើង ដោយឡែកទីក្រុងហាណូយក៏សម្រេចចិត្តអនុវត្តតាមទិសដៅពីរៈ ទី១គឺដាក់វាយនិងដាក់បញ្ចូលមនុស្សសំខាន់ៗ ទៅក្នុងបក្សកុម្មុយនិស្តកម្ពុជា ពោលគឺខ្មែរកុម្មុយនិស្តដែលបានសិក្សានិងរស់នៅវៀតណាម ។ អ្នកទាំងនេះនឹងត្រូវបានដាក់ចូលអង្គការបក្សកម្ពុជាក្នុងគោលបំណងដើម្បីពង្រឹងបុគ្គលិករបស់បក្ស ។ យោងតាមបណ្ណសារចុះកាលបរិច្ឆេទឆ្នាំ១៩៦៥ជាលើកដំបូង ក្រោយពីអស់រយៈកាលជាច្រើនឆ្នាំដែល "ក្រុមកុម្មុយនិស្តកម្ពុជាត្រូវបានផ្លាស់ទៅវៀតណាមខាងត្បូងដើម្បីបង្កភាពប្រទូសរ៉ាយនៅក្នុងប្រទេសកម្ពុជា ។ ទិសដៅទី២ គឺមិនចូលរួមនៅក្នុងជម្លោះជាមួយនឹងក្បាលម៉ាស៊ីនដឹកនាំនៃបក្សកុម្មុយនិស្តថ្មីនៅទីក្រុងភ្នំពេញ ប៉ុន្តែបង្ហាញពីការគាំទ្រណាមួយចំពោះក្រុមដឹកនាំនៅក្នុងបក្សកុម្មុយនិស្តកម្ពុជា ។ មិនដូចជាឆ្នាំមុនៗទេ មកដល់ពេលនេះគ្មានពុស្សូរនិយាយអំពីតួនាទីចម្រើនទៅមុខរបស់សម្ដេច សីហនុ ឡើយ ។ សេចក្ដីថ្លែងការណ៍ថា "ការតស៊ូរបស់ខ្មែរកុម្មុយនិស្តនឹងទទួលជោគជ័យ" ក៏ជាការភ្ញាក់ផ្អើលដែរ ។ ទីក្រុងហាណូយបានជួបប្រទះស្ថានការណ៍លំបាកមួយដែលត្រូវរកផ្លូវដោះស្រាយថាតើត្រូវបង្កើតអង្គការកុម្មុយនិស្តថ្មីមួយនៅក្នុងប្រទេសកម្ពុជាដែលមានបុគ្គលិកហ្វឹកហាត់នៅវៀតណាមខាងជើង ឬដាក់ "មនុស្សសំខាន់ៗ" ឲ្យកាន់មុខតំណែងដឹកនាំធំៗនៅក្នុងបក្សកុម្មុយនិស្តដែលមានស្រាប់ ហើយទទួលស្គាល់ ទោះបីជាបណ្ដោះអាសន្នក្ដី ចំពោះ ប៉ុល ពត ដែលមិនគួរឲ្យទុកចិត្តទាល់តែសោះ ថាជាមេដឹកនាំកុម្មុយនិស្តស្របច្បាប់នៃបក្សជាបងប្អូន ។ អ្នកនយោបាយវៀតណាមបានជ្រើសរើសយកជម្រើសទី២ ពីព្រោះគោលបំណងរបស់ខ្លួនគឺពង្រឹងកម្លាំងកុម្មុយនិស្តនៅក្នុងប្រទេសកម្ពុជា ជាជាងធ្វើឲ្យកម្លាំងទាំងនេះចុះខ្សោយដោយសារតែការបែកបាក់ផ្ទៃក្នុង ។

ជាងនេះទៅទៀត គ្មានការធានាថា អង្គការដែលគាំទ្រវៀតណាមដឹកនាំដោយ ស៊ឺង ង៉ុក មិញ ដែលជាមនុស្សសម្របសម្រួលតាមបង្គាប់របស់ទីក្រុងហាណូយនឹងមានអំណាចនិងមានចំនួនច្រើនជាងបក្សរបស់ ប៉ុល ពត ឡើយ ។ ព្រឹត្តិការណ៍មួយដែលល្បីសុសសាយនោះបង្ហាញថាតើ ស៊ឺង ង៉ុក មិញ មានឈ្មោះបោះសម្លេងត្រឹមកម្រិតណាក្នុងចំណោមខ្មែរកុម្មុយនិស្ត ។ កែវ មាស ជាជើងចាស់មួយរូបបានចោទប្រកាន់ ស៊ឺង ង៉ុក មិញ ជាសាធារណៈថា "សម្ងំសុខ ដេកស៊ីនៅក្នុងខណៈដែលបក្ខជនដែលមានភក្ដីភាពកំពុងតែត្រូវបានវាយកម្ទាត់" ។

ក្រៅពីនេះ និងដូចដែលព្រឹត្តិការណ៍ផ្សេងៗមួយចំនួនទៀតបានបង្ហាញឲ្យឃើញថា នយោបាយរបស់ថ្នាក់ដឹកនាំបក្សថ្មីត្រូវបានគាំទ្រពីសំណាក់ជើងចាស់ដែលមានអំណាចនៅក្នុងបក្សប្រជាជនបដិវត្តន៍កម្ពុជា ។ នៅក្នុងចំណោមជើងចាស់ទាំងនោះមាន សោ ភឹម ដែលជាអនាគតគណៈភូមិភាគបូព៌ានិងជាមនុស្សទីបួននៅក្នុងជួរបក្ស និង តាម៉ុក អនាគតជាគណៈភូមិភាគនិរតី និងជាអ្នកដែលមានភាពដាច់ខាតនិងភក្ដីភាពចំពោះ ប៉ុល ពត ក្នុងចំណោមអ្នកដទៃទៀតដែលគាំទ្រ ប៉ុល ពត ។ ដូច្នេះ

ស្ថានការណ៍បានវិវត្តកាន់តែច្បាស់ថា ទីក្រុងហាណូយមិនមានជម្រើសពិសេសក្រៅពីនេះទៀតទេ (នៅក្នុងកិច្ចសន្ទនាជាមួយឯកអគ្គរដ្ឋទូតសូវៀតនៅក្នុងខែមករា ឆ្នាំ១៩៧៨ ង្វៀន កូ ថាច់ និយាយបានថា សោ ភឹម និង តាម៉ុក គឺជាអតីតសមាជិកនៃបក្សកុម្មុយនិស្តឥណ្ឌូចិន ។ ឯកសារនៃកិច្ចសន្ទនារវាងឯកអគ្គរដ្ឋទូតសូវៀតជាមួយនឹងឧបនាយករដ្ឋមន្ត្រីការបរទេសនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ង្វៀន កូ ថាច់ ថ្ងៃទី២១ ខែមករា ឆ្នាំ១៩៧៨ ទំព័រ២០) ។

តាមការលើកហេតុផលមកខាងលើនេះអាចទាញសន្និដ្ឋានបានថា វៀតណាមបានសម្រេចចិត្តយល់ព្រមនៅពេលនេះដោយសង្ឃឹមថានឹងបានដក ប៉ុល ពត ចេញពីជួរដឹកនាំ ។ មនុស្សសំខាន់ៗផ្សេងៗទៀតក៏យល់ព្រមទៅលើការសម្របសម្រួលនេះដែរ ដោយសារថា មានតែវៀតណាមទេដែលអាចផ្តល់ធនធានសម្រាប់ការតស៊ូប្រដាប់អាវុធ និងតម្រូវការចាំបាច់របស់បក្ស? កាលនោះល្បីថា ប៉ុល ពត កំពុងតែស្វះស្វែងរកការគាំទ្រពីសំណាក់សហភាពសូវៀត និងចិនកុម្មុយនិស្ត ។ យោងតាមប្រភពផ្សេងៗបានឲ្យដឹងថា ប៉ុល ពត បានទៅធ្វើទស្សនកិច្ចនៅទីក្រុងប៉េកាំងនៅក្នុងឆ្នាំ១៩៦៥ ហើយដូចដែលបានបញ្ជាក់


ទាហានវៀតណាម


យោធាខ្មែរក្រហម

តាមរយៈទិន្នន័យបណ្ណសារដោយប្រយោលថា ប៉ុល ពត បានទទួលការគាំទ្រចំពោះផែនការបដិវត្តន៍របស់ខ្លួនពីសំណាក់មេដឹកនាំចិន ។

បើយោងតាមពត៌មានពីស្ថានទូតសូវៀតប្រចាំនៅទីក្រុងហាណូយនៅក្នុងឯកសារចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៦៨ យ៉ាងហោចណាស់មានការកត់សម្គាល់ថា "ដោយប្រើស្ថានការណ៍សេដ្ឋកិច្ចសំខាន់របស់ប្រជាកសិករនៅតាមខេត្តខ្លះ ចិនបានពង្រីកសកម្មភាពមួយចំនួនតាមរយៈអ្វីដែលចិនហៅថាខ្មែរក្រហមនៅតាមខេត្ត នៅភាគឧត្តរ និងពាយ័ព្យប្រទេសកម្ពុជាដោយរត់ពន្ធអាវុធ និងបង្កើតកម្លាំងប្រដាប់អាវុធតូចៗដើម្បីធ្វើវិទ្ធង្សនានៅក្នុងប្រទេសកម្ពុជា ។

អ៊ីង ខុនសាន អនុប្រធានទទួលបន្ទុកកិច្ចការផ្ទៃក្នុងនៅក្រុមប្រឹក្សារដ្ឋមន្ត្រីនៃប្រទេសកម្ពុជា បានប្រាប់តំណាងរបស់សហភាពសូវៀតអំពីការចូលរួមយ៉ាងសកម្មរបស់ទីក្រុងប៉េកាំងនៅក្នុងការពង្រីកសកម្មភាពបះបោរ ។ អ៊ីង ខុនសាន មានប្រសាសន៍ថា "ពួកខ្មាំងប្រដាប់សុទ្ធតែអាវុធទំនើបៗផលិតនៅប្រទេសចិន កាំភ្លើងដៃស្វ័យប្រវត្តិ កាំភ្លើងបាញ់រ៉ុក្កែត និងកាំភ្លើងត្បាល់ ៨១ម.ម... អាវុធទាំងនេះត្រូវបានរកឃើញនៅក្នុងឡាំងផ្ទើទៅ

រោងចក្រវាយនភណ្ឌនៅខេត្តបាត់ដំបងដែលក្រុមអ្នកជំនាញការចិនធ្វើការ (សកម្មភាពវិទ្ធង្សនារបស់ចិននៅក្នុងប្រទេសកម្ពុជា ភ្នំពេញថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៦៨ ទំព័រទី៩-១០) ។

អាចនិយាយថា ក្រៅពីដំណើរទៅកាន់ទីក្រុងប៉េកាំងនៅឆ្នាំ១៩៦៦ ប៉ុល ពត មានបំណងចង់ជួបជាមួយតំណាងរបស់ស្ថានទូតសូវៀតប្រចាំនៅទីក្រុងភ្នំពេញដោយសង្ឃឹមថានឹងបានទទួលការគាំទ្រពីទីក្រុងមូស្គូ ។ កិច្ចប្រជុំត្រូវបានធ្វើឡើង ប៉ុន្តែ ប៉ុល ពត មិនពេញចិត្ត ដោយសារខ្លួនត្រូវបានរៀបចំឲ្យជួបជាមួយមន្ត្រីទូតជាន់ទាបនៃស្ថានទូតសូវៀត។ (តាមដែលអតីតឯកអគ្គរដ្ឋទូតសហភាពសូវៀតប្រចាំនៅកម្ពុជាឈ្មោះ យូរី មីយ៉ាកូនី បានប្រាប់ខ្ញុំថា នៅបារីកា នាថ្ងៃទី១៤ ខែសីហា ឆ្នាំ១៩៩៣ គឺជាកិច្ចសន្ទនាជាមួយនឹងលេខាទីបីនៃស្ថានទូតសហភាពសូវៀតតែប៉ុណ្ណោះ) ។

បំណងរបស់បក្សកុម្មុយនិស្តកម្ពុជាក្នុងការសុំជំនួយពីសហភាពសូវៀតមិនត្រូវបានឆ្លើយតបទេ គឺដោយសារតែតំណាងសហភាពសូវៀតមិនមានពត៌មានជាក់លាក់ស្តីអំពីបក្សកុម្មុយនិស្តកម្ពុជា (កិច្ចសន្ទនាជាមួយនឹង យូរី មីយ៉ាកូនី នៅទីក្រុងបារីកា ថ្ងៃទី១៤ ខែសីហា ឆ្នាំ១៩៩៣) ។ កាលនោះអ្វីដែលស្ថានទូតសូវៀតអាចធ្វើបានច្រើនបំផុតគឺ "បញ្ជូនគ្រូខ្មែរសនាមឲ្យទៅជួបតំណាងរបស់កម្លាំងឆ្វេងនិយមដើម្បីនិយាយប្រាប់អំពីបញ្ហាសេដ្ឋកិច្ចសង្គមរបស់កម្ពុជា" ។

ការខកខានពុំបានបង្កើតចំណងទាក់ទងជាមួយនឹងទីក្រុងមូស្គូ មិនធ្វើឲ្យជំហររបស់ ប៉ុល ពត ចុះខ្សោយនោះទេ ដោយសារថា ប៉ុល ពត មានទីក្រុងប៉េកាំងនិងហាណូយនៅពីក្រោយរួចខ្នងទៅហើយ ។ ដើម្បីពង្រឹងការគាំទ្ររបស់ខ្លួនពីសំណាក់ទីក្រុងហាណូយ ប៉ុល ពត បានបង្ហាញពីភាពប្រុងប្រៀបរួចជាស្រេចក្នុងការរួបរួមជិតដិតនិង "សាមគ្គីភាពពិសេស" ជាមួយនឹងវៀតណាម ។ ប៉ុល ពត បានណែនាំ នួន ជា មនុស្សទុកចិត្តរបស់ទីក្រុងហាណូយ ដែល ឡេ យន់ មេដឹកនាំបក្សកុម្មុយនិស្ត វៀតណាមបានហៅថាជាអ្នកនយោបាយ "គាំទ្រទិសដៅរបស់វៀតណាម" នៅក្នុងកិច្ចសន្ទនាជាមួយនឹងឯកអគ្គរដ្ឋទូតសហភាពសូវៀតថាជាអ្នកកាន់តំណែងសំខាន់ទីពីរនៅក្នុងបក្ស ។ និយាយដល់រឿង នួន ជា, ឡេ យន់ បាននិយាយដោយត្រង់ៗថា នួន ជា "ជាមនុស្សរបស់យើងពិតៗ និងជាមិត្តសម្លាញ់របស់ខ្ញុំទៀតផង" ឯកសារនៃកិច្ចសន្ទនារបស់ឯកអគ្គរដ្ឋទូតសហភាពសូវៀតជាមួយនឹង ឡេ យន់ លេខាទី១នៃគណៈកម្មាធិការមជ្ឈិមបក្សនៃបក្សកុម្មុយនិស្តកម្ពុជា ។ ***(នៅមានត)***

**មិទ្រី មូសយ៉ាកូវ**

# បក្សកម្មករវៀតណាម

កម្មវិធី

<u>សំណូមពរ</u>

១) ចរចាជាមួយសមមិត្ត ប៉ុល ពត លេខាបក្សកុម្មុយនិស្តកម្ពុជានឹងអ្នកដឹកនាំផ្សេងទៀត ។

គណៈប្រតិភូចង់ប្រាប់អំពីសភាពការណ៍បច្ចុប្បន្ននៃការឈ្លានពានរបស់យួនប្រឆាំងកម្ពុជាប្រជាធិបតេយ្យ ។

គណៈប្រតិភូចង់ប្រាប់អំពីសភាពការណ៍អំពីភារកិច្ចសំខាន់ៗនៃការកសាងសង្គមនិយម ។ គណៈប្រតិភូចង់ផ្លាស់ប្តូរអំពីសភាពការណ៍អន្តរជាតិចលនាកុម្មុយនិស្តអន្តរជាតិនិងបញ្ហាផ្សេងៗទៀតដែលជាប្រយោជន៍រួម ។

២) គណៈប្រតិភូចង់ទស្សនារោងចក្រ សាលារៀន សហករណ៍ និងសំណង់ផ្សេងៗ នៅទីក្រុងនិងជនបទ ។

៣) គណៈប្រតិភូចង់មើលភស្តុតាងដែលជាសក្ខីភាពនៃការឈ្លានពានរបស់យួន ។

៤) គណៈប្រតិភូចង់ទស្សនាប្រាសាទបុរាណអង្គរ ។

៥) ចង់ជួបកម្មាភិបាលនារីថ្នាក់មធ្យមដើម្បីស្តាប់អំពីប្រវត្តិតស៊ូរបស់គេនិងការកសាងខ្លួនរបស់គេ ។

៦) ចង់ជួបយុវជននៃអង្គការយុវជនកុម្មុយនិស្តកម្ពុជាដើម្បីស្តាប់អំពីការកកើតនៃអង្គការនិងការដែលអង្គការចូលរួមក្នុងការកសាងនិងការពារប្រទេស ។

**(*ឯកសារលេខៈ* D13958)**

# រឿងរ៉ាវនៃការនាំយកមេដឹកនាំខ្មែរក្រហមមកកាត់ទោស

នៅក្នុងឆ្នាំ១៩៧៤ ខ្ញុំបានចាប់ផ្តើមធ្វើការស្រាវជ្រាវមួយដែលមានរយៈពេល "មួយភាគបួននៃសតវត្សរ៍" ទៅលើចលនារបស់ខ្មែរក្រហម ។ ក្នុងនាមជានិស្សិតថ្នាក់បរិញ្ញាប័ត្រ ខ្ញុំបានសរសេរអត្ថបទសិក្សាស្រាវជ្រាវមួយដែលមានចរិតជាការសង្កេតពិនិត្យហេតុការណ៍ជាក់ស្តែង ស្តីអំពីការបះបោរប្រឆាំងនឹងរបបសម្តេច សីហនុ នៅចុងទសវត្សរ៍ឆ្នាំ១៩៦០ ហើយមិនយូរប៉ុន្មានក៏បោះពុម្ពផ្សាយជាទម្រង់អត្ថបទខ្លីៗ ។ មុនដំបូងខ្ញុំហាក់ដូចជាមានការពេញចិត្តគួរសមដែរចំពោះកំណែទម្រង់ផ្សេងៗនិងជាតិនិយម ប៉ុន្តែនៅពេលដែលខ្ញុំចាប់ផ្តើមការងារស្រាវជ្រាវកម្រិតថ្នាក់បណ្ឌិតនៅឆ្នាំ១៩៧៨ ខ្ញុំក៏ទទួលស្គាល់កំហុស ហើយចាប់ផ្តើមដំណើរការនូវគម្រោងមួយមានរយៈពេល ២ទសវត្សរ៍ក្នុងការធ្វើឯកសារចងក្រងឧក្រិដ្ឋកម្មប្រព្រឹត្តឡើងនៅក្នុងរបបខ្មែរក្រហម ។ មកដល់ឆ្នាំ១៩៨០ ខ្ញុំបានសម្ភាសន៍ជាមួយអ្នកនៅរស់រានមានជីវិតពីរបបខ្មែរក្រហមដែលជាជនជាតិខ្មែរប្រមាណរាប់រយនាក់ហើយក៏ចាប់ផ្តើមផ្សព្វផ្សាយនូវព័ត៌មានរបស់បុគ្គលផ្តល់កិច្ចសម្ភាសន៍ទាំងអស់ ។ នៅឯប្រទេសអូស្ត្រាលីក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៨០ ខ្ញុំបានបកប្រែកិច្ចសម្ភាសន៍របស់ខ្ញុំស្ទើរតែទាំងអស់ព្រមទាំងឯកសារខ្មែរក្រហមសំខាន់ៗមួយចំនួនទៀត ហើយបានសរសេរព័ត៌មានលម្អិតទៅលើចំណុចពិសេសមួយៗនៃអំពើប្រល័យពូជសាសន៍ ។ មិនតែប៉ុណ្ណោះ ខ្ញុំថែមទាំងចេញផ្សាយនូវអត្ថបទវិភាគផ្នែកប្រវត្តិសាស្ត្រទៅលើការឡើងកាន់អំណាចរបស់ខ្មែរក្រហមទៀតផង ។

នៅឯសាកលវិទ្យាល័យយែល ក្នុងឆ្នាំ១៩៩៤ ខ្ញុំបានបង្កើតឡើងនូវកម្មវិធីសិក្សាស្រាវជ្រាវអំពើប្រល័យពូជសាសន៍នៅកម្ពុជាក្រោមការឧបត្ថម្ភពីសំណាក់ក្រសួងការបរទេសសហរដ្ឋអាមេរិក ។ នៅខែមករា ឆ្នាំ១៩៩៥ យើងបានបើកមជ្ឈមណ្ឌលឯកសារកម្ពុជានៅទីក្រុងភ្នំពេញ ។ អស់រយៈពេលបួនឆ្នាំក្រោយមកក្រុមអ្នកជំនាញការរបស់អង្គការសហប្រជាជាតិបានបំពេញរបាយការណ៍របស់ខ្លួនដាក់ជូនលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ កូហ្វី អាណាន់ ។ របាយការណ៍នេះនិយាយអំពីលទ្ធផលដែលគួរឲ្យភ្ញាក់ផ្អើលនិងនឹកស្មានមិនដល់ ស្តីពីអំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជា ។ នៅក្នុងខែមីនា ឆ្នាំ១៩៩៩ របាយការណ៍នេះត្រូវបានពុម្ពបោះផ្សាយ ដោយលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ។ របាយការណ៍បញ្ជាក់ថា÷

"ជាង២០ឆ្នាំចុងក្រោយនេះ មានការប្រាថ្នាចង់ប្រមែប្រមូលភស្តុតាងនៃអំពើឃោរឃៅរបស់ខ្មែរក្រហមក្នុងគោលបំណងបង្កើតជាឯកសារប្រវត្តិសាស្ត្រទាក់ទងនឹងអំពើទាំងនេះ ។ អស់ជាង២០ឆ្នាំហើយដែលអ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់ខិតខំប្រមែប្រមូលភស្តុតាង ដោយចុះជួបនិយាយផ្ទាល់ជាមួយអ្នករស់រានមានជីវិត និងអ្នកដែលបានចូលរួមនៅក្នុងអំពើភេរវកម្មព្រមទាំងថតជាឯកសារ រូបថតនិងរណ្តៅសាកសព ។ កិច្ចខិតខំប្រឹងប្រែងដែលគួរឲ្យចាប់អារម្មណ៍និងមានការរៀបចំហ្មត់ចត់បំផុតទាក់ទងនឹងផ្នែកឯកសារគឺត្រូវបានធ្វើឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជាដែលបច្ចុប្បន្នស្ថិតនៅក្នុងទីក្រុងភ្នំពេញ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាដែលកកើតដំបូងនៅសាកលវិទ្យាល័យយែលក្រោមការឧបត្ថម្ភរបស់រដ្ឋាភិបាលសហរដ្ឋអាមេរិកបានដើរតួជាវិទ្យាស្ថានស្រាវជ្រាវមានចរិតឯករាជ្យមួយក្រោមការជួយជ្រោមជ្រែមផ្នែកថវិកាពីសំណាក់រដ្ឋាភិបាលនិងមូលនិធិនានាជាច្រើន ។ មជ្ឈមណ្ឌលឯកសារកម្ពុជាបានអនុវត្តគម្រោងចងក្រងឯកសារដើម្បីប្រមែប្រមូលរៀបចំនិងតម្កល់ឯកសាររបស់កម្ពុជាប្រជាធិបតេយ្យ ព្រមទាំងអនុវត្តគម្រោងចុះធ្វើផែនទីដើម្បីស្វែងរកទីតាំងមនុស្សឃាតនិងរណ្តៅសាកសព" ។

របាយការណ៍បានជូនជាយោបល់ឲ្យមានការបង្កើតតុលាការកម្រិតអន្តរជាតិមួយដើម្បីវិនិច្ឆ័យទោសមេដឹកនាំខ្មែរក្រហម ។ ប្រទេសកម្ពុជាបច្ចុប្បន្ននេះកំពុងសិក្សាអំពីការបង្កើតឡើងនូវតុលាការចម្រុះជាតិនិងអន្តរជាតិមួយ ។ ជោគជ័យនេះ

ត្រូវបានសម្រេចដោយមានការវាយប្រហារមិនត្រឹមតែពីសំណាក់ខ្មែរក្រហមទេ ថែមទាំងពីសំណាក់សារពត៌មានរបស់មហាអំណាចខាងលិចទៀតផង ។

## កម្មវិធីសិក្សាស្រាវជ្រាវអំពើប្រល័យពូជសាសន៍នៅកម្ពុជា (ស៊ី.ជី.ភី) ១៩៩៤-១៩៩៩

"ជាប្រតិបត្តិការសិក្សាស្រាវជ្រាវតែមួយគត់លើពិភពលោកដែលផ្តោតសំខាន់ទៅលើអំពើឃោរឃៅប្រព្រឹត្តឡើងដោយខ្មែរក្រហម ក្រៅពីកម្មវិធីសិក្សាស្រាវជ្រាវអំពើប្រល័យពូជសាសន៍នៃសាកលវិទ្យាល័យយែល" ។ នេះជាអ្វីដែលលោកនិពន្ធនាយកចាត់ការទូទៅនៃទិនានុប្បវត្តិ *Asian Wall Street Journal* (AWSJ) បានពិពណ៌នាមជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងឆ្នាំ១៩៩៧ ប៉ុន្តែទោះជាយ៉ាងនេះក្តី ទិនានុប្បវត្តិ AWSJ ដឹកនាំធ្វើយុទ្ធនាការមួយប្រឆាំងនឹងកម្មវិធីសិក្សាស្រាវជ្រាវអំពើប្រល័យពូជសាសន៍នៃសាកលវិទ្យាល័យយែល អស់រយៈពេលពេញ ២ឆ្នាំក្នុងអំឡុងពេលនៃការបង្កើតមជ្ឈមណ្ឌលឯកសារកម្ពុជា ។

ថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៩៥ គឺជាថ្ងៃរំឭកខួបលើកទី២០ នៃការកាន់កាប់អំណាចរបស់របបប្រល័យពូជសាសន៍ខ្មែរក្រហម ។ ទិនានុប្បវត្តិនេះបានឆ្លៀតឱកាសចុះផ្សាយនូវអត្ថបទវែងមួយក្នុងទំព័រពិសេសអំពាវនាវឲ្យក្រសួងការបរទេសសហរដ្ឋអាមេរិក និងសភាជាន់ទាបលុបចោលនូវជំនួយឧបត្ថម្ភលើកដំបូងរបស់ក្រសួងការបរទេសដល់ ស៊ី.ជី.ភី ដោយបរិហារកេរ្តិ៍នាយកកម្មវិធីនេះ (គឺរូបខ្ញុំ) ថាជា"ជនកុម្មុយនិស្ត" ដែលមានសន្តានចិត្តអាណិតអាសូរចំពោះខ្មែរក្រហម ។ ការអំពាវនាវនេះត្រូវទទួលបរាជ័យ ក្រោយពីទិនានុប្បវត្តិបោះផ្សាយនូវការឆ្លើយតបវិញ ។ ប៉ុន្តែដោយមានការវាយប្រហារផង អត្ថបទនេះបានសំដៅទៅលើប្រភពថវិការបស់ ស៊ី.ជី.ភី ។ ផ្ទុយទៅវិញ អត្ថបទនេះក្លាយជារូបភាពជួយជំរុញឲ្យមានការគាំទ្រដូចជាតាមរយៈសំបុត្រផ្ញើមកពីជំនាញការជាន់ខ្ពស់អន្តរជាតិចំពោះបញ្ហាកម្ពុជាចំនួន២៩រូប ព្រមទាំងអ្នកសិក្សាជាន់ខ្ពស់ជាច្រើនផ្សេងទៀតដែលគាំទ្រខ្ញុំ ។ ទន្ទឹមនឹងពេលនោះដែរ ខ្មែរក្រហមបាន "ចោទប្រកាន់ខ្ញុំ" ថាជា "ជនឧក្រិដ្ឋគួរឲ្យស្អប់ខ្ពើម" និងជា "មេពជ្ឈឃាតរបស់ចក្រពត្តិអាមេរិក" ។ ទោះជាមានការវាយប្រហារយ៉ាងសន្ធប់ពីប្រភពទាំងពីរនេះយ៉ាងណាក៏ដោយ ក៏យើងនៅតែខិតខំបន្តការងាររបស់យើងដើម្បីបង្កើតបណ្ណសារមួយដែលផ្តល់ការយល់ដឹងទូលំទូលាយជាសាធារណៈ និងទិន្នន័យក្នុងប្រព័ន្ធកុំព្យូទ័រស្តីពីអំពើប្រល័យពូជសាសន៍ ហើយម្យ៉ាងទៀតគឺដើម្បីហ្វឹកហ្វឺនអ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់និងបណ្ណសារនិកឲ្យចេះរៀបចំចាត់ចែង និងធ្វើឲ្យមានការរីកចម្រើនឆ្ពោះទៅមុខ ។

នៅឆ្នាំក្រោយមកទៀត ទិនានុប្បវត្តិ AWSJ បានវាយប្រហារម្តងទៀតមកលើ ស៊ី.ជី.ភី ដោយរិះគន់ថាយើងមិនបានផ្តល់អាទិភាពទៅលើការស្រាវជ្រាវរកទាហានអាមេរិកាំងដែលបាត់ខ្លួនក្នុងអំឡុងសង្គ្រាមនៅកម្ពុជាឆ្នាំ១៩៧០-៧៥ ពោលគឺមុនពេលខ្មែរក្រហមមកកាន់អំណាច ។ នៅក្នុងការរារាំងមិនឲ្យមានការផ្តល់ថវិកាដល់ ស៊ី.ជី.ភី អត្ថបទនេះបានហៅខ្ញុំថា "ជាជនមិនសមនឹងទទួលប្រាក់ជំនួយទេ" ។

ទិនានុប្បវត្តិបានបោះផ្សាយអត្ថបទនេះម្តងទៀត ហើយប្រកាសចំពោះអ្នកអានដោយអមជាមួយនឹងបទវិចារណកថាមួយនិយាយថា ស៊ី.ជី.ភីនឹងត្រូវបិទទ្វារនៅខែក្រោយនេះ ។ គ្មានអត្ថបទណាមួយក្នុងចំណោមអត្ថបទដែលត្រូវបានចេញផ្សាយទាំងអស់ មានលក្ខណៈពិតប្រាកដឡើយ ហើយទិនានុប្បវត្តិបានបដិសេធឈប់បោះផ្សាយនូវការឆ្លើយតបនិងការកែតម្រូវ ។ ស៊ី.ជី.ភី បានស្វែងរកជំនួយថវិកាបាន១លាន៥សែនដុល្លារ ដែលកើនឡើងទ្វេភាគប្រៀបទៅនឹងចំនួនដែលទទួលបានដំបូង ។ ស៊ី.ជី.ភី និងមជ្ឈមណ្ឌលឯកសារកម្ពុជា ត្រូវបានធានាផ្តល់ថវិកាគ្រប់គ្រាន់ក្នុងដំណើរការការងាររបស់ខ្លួនក្នុងរយៈពេល៥ឆ្នាំទៀត ដែលជាការខុសឆ្ងាយពីការសង្ឃឹមទុករបស់យើងកាលពីឆ្នាំ១៩៩៥ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាដែលពោរពេញទៅដោយឯកសារផ្ទៃក្នុងខ្មែរក្រហម ដែលយើងប្រមែប្រមូលក្នុងឆ្នាំ១៩៩៥-៩៦ ឥឡូវនេះបានក្លាយជាស្ថាប័នសិក្សាស្រាវជ្រាវឯករាជ្យមួយស្តីអំពីប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមរបស់ ប៉ុល ពត ដែលត្រូវបានស្គាល់ជាទូទៅថា "កម្ពុជាប្រជាធិបតេយ្យ" ដែលបានដឹកនាំនូវការស្លាប់បាត់បង់ជីវិតមនុស្ស ១លាន៧សែននាក់ ។

ហេតុអ្វីបានជាទិនានុប្បវត្តិ AWSJ ធ្វើយុទ្ធនាការរបៀប

នេះទៅវិញក្នុងឆ្នាំ១៩៩៥? ហេតុអ្វីបានជាមានការប៉ុនប៉ងចង់បំផ្លាញដំណើរការស្រាវជ្រាវតែមួយគត់នៅលើពិភពលោកស្តីពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា? ហេតុអ្វីបានជាទិនានុប្បវត្តិនេះជ្រើសរើសមុខសញ្ញាដូចគ្នាទៅនឹងមុខសញ្ញាដែលខ្មែរក្រហមបានជ្រើសរើសដែរ? ហេតុអ្វីបានជាទិនានុប្បវត្តិនេះត្រូវទទួលបរាជ័យទៅវិញ? តើអ្វីទៅជាទំនាក់ទំនងរវាងការបដិសេធថាមិនទទួលស្គាល់អំពើប្រល័យពូជសាសន៍និងការបិទបោលនូវការស៊ើបអង្កេតទៅលើអំពើនេះ? នៅក្នុងករណីនេះ ដូចដែលយើងឃើញស្រាប់មានទំនាក់ទំនងស្មុគស្មាញរវាងការអះអាងនិងការបដិសេធថាមិនមានអំពើប្រល័យពូជសាសន៍កើតឡើង ។

ខ្ញុំនឹងពិភាក្សាទៅលើទម្រង់ពីរនៃការបដិសេធថា មិនមានអំពើប្រល័យពូជសាសន៍នៅកម្ពុជា និងការគាបសង្កត់មួយ ។ មតិទី១អះអាងថា ការប៉ុនប៉ងបដិសេធថាគ្មានរឿងអ្វីធ្ងន់ធ្ងរកើតឡើងទេ។ នៅក្នុងឆ្នាំ១៩៨៤ ផាច់ ប៊ុនរឿន នៅសាកលវិទ្យាល័យ ស៊ីរ៉ាឃ្យូស ផ្នែកវិទ្យាសាស្ត្រនយោបាយ បានប្រកាន់យកនូវជំហរនេះ ។ ប៊ុនរឿន បានសរសើរមេដឹកនាំ "របបកម្ពុជាប្រជាធិបតេយ្យ" ដែលបានកប់ចោលនូវអតីតកាលដោយជោគជ័យ វាយប្រហារអ្វីដែលគាត់ហៅថាយុទ្ធនាការហាណូយ "បន្ខូចឈ្មោះបក្សកុម្មុយនិស្តកម្ពុជា" និងបានទាញហេតុផលឲ្យមានការបញ្ចូលខ្មែរក្រហមចូលទៅក្នុងអនាគតរបស់ប្រទេសកម្ពុជា ។ ប៊ុនរឿន បានទទួលការគាំទ្រពីសំណាក់អ្នកសិក្សាជាន់ខ្ពស់ពីរបីនាក់ប៉ុណ្ណោះ ប៉ុន្តែក៏មានជនជាតិខ្មែរម្នាក់ដែលមានគំនិតប្រហាក់ប្រហែលគ្នានេះ គឺឈ្មោះ ពៅ សំពេង ដែលជាអ្នកជំទាស់ការទទួលខុសត្រូវចំពោះមុខច្បាប់នៃអំពើប្រល័យពូជសាសន៍ខ្មែរក្រហម ។ នៅចុងខែមីនា ឆ្នាំ១៩៩៧ សំពេង បានប្រកាសថា "ការដាក់ទណ្ឌកម្ម ប៉ុល ពត នឹងមិនអាចដោះស្រាយបញ្ហាបានឡើយ" ។ សំពេង បន្ថែមថា "ការជម្រះទោសក្នុងលក្ខណៈអនាធិបតេយ្យជាការស្រមើស្រមៃហើយអាចរាំងស្ទះដល់ការបង្រួបបង្រួមជាតិ" ។ អ្នកកាសែតដែលបានធ្វើសម្ភាសន៍ជាមួយ សំពេង បានរាយការណ៍ថា សំពេង និយាយថាគាត់ចង់អត់ឱនឲ្យខ្មែរក្រហមដើម្បីបំបាត់ចោលនូវភាពវិលវល់មិនចេះចប់នៃការបោកប្រាស់និងអំពើឃោរឃៅដែលកើតឡើងកន្លងមក" ។ អ្នករាយការណ៍បានសរសេរទៀតថា "សំពេង គាំទ្រការផ្សះផ្សាជាមួយខ្មែរក្រហម ជាជាងការដាក់ទណ្ឌកម្មចំពោះឧក្រិដ្ឋកម្មក្នុងអតីតកាល និងគាំទ្រវិធីសាស្ត្រជាក់ស្តែងក្នុងការបញ្ចូលអ្នកចុះចូលខ្មែរក្រហមទៅក្នុងរដ្ឋាភិបាល ក្នុងក្តីសង្ឃឹមមួយថាចលនាខ្មែរក្រហមនឹងសាបសូន្យដោយខ្លួនឯង" ។

ការសុំទោសរបស់ សំពេង ជំនួសខ្មែរក្រហមគឺមានឥទ្ធិពលជាង ប៊ុនរឿន។ កម្មវិធីសិក្សាអំពីហាយនភាព និងអំពើប្រល័យពូជសាសន៍ បានចេញផ្សាយនូវគំនិតវាយតម្លៃទៅរបស់គាត់ចំពោះសៀវភៅ "របប ប៉ុល ពត" របស់ខ្ញុំដែលបោះផ្សាយនៅឆ្នាំ១៩៩៦ ។ នៅក្នុងគំនិតវាយតម្លៃរបស់ សំពេង គាត់បានហៅមេដឹកនាំខ្មែរក្រហមថា "ជនប្រល័យពូជសាសន៍" ។ សំពេង ភ្ជាប់អ្វីដែលគាត់ហៅថាសារជាតិនៃអំពើឃោរឃៅទៅនឹងសមភាពនិយមរបស់ ប៉ុល ពត ការប្រុងប្រយ័ត្នអសន្តិសុខភាពងាយទទួលរងគ្រោះថ្នាក់និងការគាំទ្រមិនទៀងពីសំណាក់ប្រជាជន ។ លើសពីនេះទៀត សំពេង បាននិយាយថា ចាប់ពីឆ្នាំ១៩៧០ដល់១៩៧៥ ជនជាតិចាមមិនត្រូវបានធ្វើទុក្ខបុកម្នេញសោះឡើយ ។ នៅពេលដែលដឹងថាមានការសម្លាប់រង្គាលនូវជនជាតិចាម សំពេង បានបដិសេធថា វាមិនមែនជាការគ្រោងទុកឡើយ ទោះបីជាមានភ័ស្តុតាងយ៉ាងហូរហៀរក៏ដោយ ។ ក្រោយមកទៀត សំពេង អះអាងថា "បក្ខពួក ប៉ុល ពត បានធ្វើការប៉ុនប៉ងជាច្រើនលើក ប៉ុន្តែសុទ្ធតែបរាជ័យក្នុងការទប់ស្កាត់ការកាប់សម្លាប់នេះ ។ ពិតជាមិនធម្មតាឡើយក្នុងការអានអត្ថបទប្រភេទនេះនៅក្នុងទិនានុប្បវត្តិនៅសារមន្ទីរអនុស្សាវរីយ៍ហាយនភាព ។ មានអ្នកនិពន្ធពីរ-បីនាក់បានបង្ហាញនូវភាពជឿជាក់ក្នុងការការពារជនប្រល័យពូជសាសន៍ ប៉ុល ពត ។

កាលពីឆ្នាំ១៩៩១ សហការីរបស់ សំពេង ម្នាក់ឈ្មោះ ស៊ីវ ហេឌ័រ បានហៅបុគ្គលថ្នាក់ដឹកនាំខ្មែរក្រហមថាជា"អ្នកខ្វែងគំនិត" ដែលជាជនសង្ស័យនៅក្នុងក្រសែភ្នែករបស់ ប៉ុល ពត ។ អ្នកខ្វែងគំនិតទាំងអស់រួមទាំង សុន សេន ឧបនាយករដ្ឋមន្ត្រីនិងជាប្រធានសន្តិសុខនៃបក្សកុម្មុយនិស្តកម្ពុជា ឈិត ជឿន ហៅ ម៉ុក មេបញ្ជាការយោធាខ្មែរក្រហម កែ ពក មេបញ្ជាការយោធារង និង ឌុច ប្រធានគុកទួលស្លែង (មន្ទីរស-២១) ។ ស៊ីវ

បានសរសេរថា "អ្នកខ្វងគំនិតដែលនៅរស់ដូចជា សុន សេន និង កែ ពក" ហើយប្រហែលរួមទាំង តាម៉ុក និង ឌុច ផងត្រូវបានយល់ខុសថាជា "អ្នកស្មោះស្ម័គ្រនឹង ប៉ុល ពត" ។ ស៊ីវ បន្តទៀតថាមានតែជនកុម្មុយនិស្តកម្ពុជាសំខាន់ៗពីរនាក់តែប៉ុណ្ណោះ ដែលមិនមែនជាជនសង្ស័យនៅក្នុងក្រសែភ្នែករបស់ ប៉ុល ពត និងនួន ជា ។ អ្នកទាំងពីរនោះគឺ អៀង សារី និងខៀវ សំផន ។ អៀង សារី និង ខៀវ សំផន ត្រូវបានចាត់ទុកយ៉ាងច្បាស់ថាមានភក្តីភាពពិតប្រាកដនិងខ្វះកម្លាំងនយោបាយផ្ទៃក្នុង ។

ក៏ប៉ុន្តែ នៅពេលដែល អៀង សារី និង ខៀវ សំផន ខិតមកជិតផ្លូវច្បាប់ ស៊ីវ បែរជាទាល់តម្រិះទៅវិញ ។ នៅឆ្នាំ១៩៩៦ អៀង សារី បានចូលមកខាងរាជរដ្ឋាភិបាលកម្ពុជា ។ ឥឡូវនេះ ស៊ីវ បានចាត់ទុក អៀង សារី ថាបានបង្ហាញសញ្ញា "ខ្វងគំនិតនិងការងារចេញពីនយោបាយរបស់ ប៉ុល ពត" ។ ស៊ីវ និយាយថា "នៅក្នុងតំបន់កាន់កាប់ដោយ អៀង សារី ក្នុងទសវត្សរ៍ឆ្នាំ១៩៨០ ប្រជាកសិករអាចមានទ្រព្យសម្បត្តិផ្ទាល់ខ្លួនបន្តិចបន្តួច" ។ ស៊ីវ បន្ថែមទៀតថា "មិនអាចយល់ឃើញថា អៀង សារី ធ្វើដូច្នេះពិតជាសមហេតុផលជាង ប៉ុល ពត" មិនតែប៉ុណ្ណោះ ស៊ីវ បន្តទៀតថា "ការខុសប្លែកគ្នាទាំងពីរនេះ អាចកើតមានមែននៅក្នុងរបប ប៉ុល ពត រវាងឆ្នាំ១៩៧៥-១៩៧៩ ដោយមាន អៀង សារី ជាអ្នកមានឥរិយាបថអត់ឱនចំពោះបញ្ញវ័ន្ត និងជាអ្នកទទួលការចោទប្រកាន់ថាការពារវណ្ណៈគហបតី ។ ស៊ីវ បន្តទៀតថា "គ្មានភ័ស្តុតាងណាមួយបញ្ជាក់ថា អៀង សារី ជាបងទីពីរ ឬមានមូលដ្ឋានអំណាចដើម្បីឲ្យខ្លួនអាចធ្វើការសម្រេចតាមឆន្ទៈរបស់ខ្លួនឡើយ ។ អៀង សារី តាមពិតជាបងទី៣ បន្ទាប់ពី ប៉ុល ពតនិង នួន ជា ។ ស៊ីវ បានហៅកម្មវិធីសិក្សាអំពើប្រល័យពូជសាសន៍ថាមានលក្ខណៈស្រាលចំពោះ អៀង សារី ។ អ្នកជំនួយការរបស់ អៀង សារី ថែមទាំងបានដកស្រង់សម្តីរបស់ ស៊ីវ តាមវិទ្យុ ប្រាំងអាំងទែណាស្យូណាល់ថា "តាមឯកសារដែលខ្ញុំបានយមកប្រើប្រាស់ អៀង សារី ជាមេដឹកនាំខ្មែរក្រហមតែមួយគត់ ដែលមកដល់ពេលនេះ ខ្ញុំមិនទាន់រកប្រមូលបានភ័ស្តុតាងជាក់ស្តែងណាមួយបង្ហាញថា អៀង សារី ចាប់ផ្តើមឬអនុវត្តវិស្សុទ្ធកម្មទៅលើបញ្ញវ័ន្តឡើយ ។"

ខៀវ សំផន មិនមែនជាមនុស្សក្នុងលក្ខណៈបែបនេះទេ ។ នៅក្នុងនិក្ខេបបទស្រាវជ្រាវឆ្នាំ១៩៩១ ស៊ីវ ទាញសេចក្តីសន្និដ្ឋានថា "តារាននយោបាយ ខៀវ សំផន បានរះឡើងលើគំនរសាកសព" ។ ការបន្ទរះនេះគឺដោយសារ ខៀវ សំផន បានជួយ ប៉ុល ពត ក្នុងការបោសសម្អាតជនកុម្មុយនិស្ត ។ យោងតាម ស៊ីវ គឺថា ខៀវ សំផន គឺជាអ្នកចូលរួមយ៉ាងសំខាន់ក្នុងក្បាលម៉ាស៊ីនប្រតិបត្តិនយោបាយដែល ប៉ុល ពត បង្កើតឡើង និងជាអ្នកបម្រើ ប៉ុល ពត ហើយប្រហែលជាមនុស្សទី២បន្ទាប់ពី នួន ជា ។

ប៉ុន្តែនៅឆ្នាំ១៩៩៩ ក្រោយពី ខៀវ សំផន បានចុះចូលជាមួយ នួន ជា ស្រាប់តែ ស៊ីវ ក៏ចាប់ផ្តើមនិយាយថាករណីប្រឆាំងនឹង ខៀវ សំផន មិនគ្រប់គ្រាន់ទេ ។ "មានករណីជាច្រើនដែលត្រូវឆ្លើយដោយ ខៀវ សំផន និង អៀង សារី ប៉ុន្តែតាមឯកសារភ័ស្តុតាងដែលមានស្រាប់ យើងមិនត្រូវមានជំនឿពេកទេថា ខៀវ សំផន និង អៀង សារី នឹងត្រូវបានសម្រេចឲ្យមានទោស... ។ មានភ័ស្តុតាងផ្សេងៗទៀតប្រឆាំងនឹង ខៀវ សំផន ដែលបង្ហាញអំពីការពាក់ព័ន្ធក្នុងដំណើរការបោសសម្អាត ប៉ុន្តែមានឯកសារភ័ស្តុតាងតិច ឬអាចគ្មានផង ដើម្បីយកមកស្រាយបំភ្លឺនៅក្នុងតុលាការ ។ ក៏ប៉ុន្តែនោះមិនមានន័យថា យើងនឹងមិនជីកកាស់រកឯកសារដែលមានចរិកបែបនេះនៅថ្ងៃស្អែកនោះទេ ។"

តាមពិតឥឡូវនេះ ស៊ីវ បានជីករកភ័ស្តុតាងដើម្បីធ្វើការចោទទៅលើបុគ្គលដែលខ្លួនបានរៀបរាប់ក្នុងឆ្នាំ១៩៩១ ថាជាអ្នកខ្វងគំនិតនឹង ប៉ុល ពត ។ ម៉ុក និង កែ ពក ព្រមទាំង នួន ជា អាចត្រូវបានចោទប្រកាន់តាមរយៈចំណាររវាងមេដឹកនាំនៅភូមិភាគមជ្ឈិមទាំងនេះជាមួយនឹងមេបញ្ជាការភូមិភាគពាក់ព័ន្ធនឹងការចាប់ខ្លួននិងកាប់សម្លាប់ ។ ប៉ុន្តែនៅក្នុងកិច្ចសម្ភាសន៍មួយជាមួយអ្នកកាសែត ស៊ីវ និយាយថា "ចំណុចខ្សោយនៃករណីប្រឆាំងនឹង ខៀវ សំផន និង អៀង សារី គឺទាក់ទងនឹង(ការទទួលខុសត្រូវចំពោះការបញ្ជាដោយប្រយោល) ដែលជារឿងមួយអាចមានបញ្ហានៅក្រោមច្បាប់អន្តរជាតិ" ។

នេះជារឿងដែលមិនពិត ។ ករណីឧក្រិដ្ឋកម្មសង្គ្រាមត្រូវការណាស់នូវភ័ស្តុតាងអំពី "ការទទួលខុសត្រូវលើការបញ្ជា" ប៉ុន្តែក្នុងករណីផ្សេងទៀតនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ

និងអំពើប្រល័យពូជសាសន៍អ្វីដែលជាការចាំបាច់នោះ គឺភ័ស្តុតាងនៃការសមគំនិត ។ អ្នកច្បាប់អន្តរជាតិលោកបណ្ឌិត ហ្វ្រ៊ី ហ្គូរីស្ទេនសុន បានសរសេរថា ÷

“ស៊ីវ ទាញហេតុផលខុសចំពោះការទទួលខុសត្រូវរបស់ ខៀវ សំផន និង អៀង សារី ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនិងអំពើប្រល័យពូជសាសន៍” ។ អ្វីដែលជាចាំបាច់ក្នុងការបង្ហាញអំពីចរិតនៃបទឧក្រិដ្ឋកម្មទាំងពីរនេះគឺការចូលរួមប្រព្រឹត្ត ។ គ្រាន់តែបញ្ជាក់ច្បាស់អំពីការចូលរួមរបស់ អៀង សារី និង ខៀវ សំផន នៅឯកិច្ចប្រជុំគណៈមជ្ឈិមបក្សដែលជាកន្លែងចេញសេចក្តីសម្រេចក្នុងការកម្ទេចជនជាតិចាមឬអ្នកដែលនៅភូមិភាគបូព៌ា វាជាការគ្រប់គ្រាន់ណាស់ទៅហើយ ។ កំណត់ហេតុរបស់ អៀង សារី ក៏បញ្ជាក់ភ័ស្តុតាងថា អៀង សារី បានដឹងឮយ៉ាងច្បាស់អំពីផែនការកម្ចាត់ខ្មាំងរបស់បក្ស ។ ខៀវ សំផន អាចត្រូវបានបង្ហាញថាបានដឹងឮកម្រិតប្រហាក់ប្រហែលគ្នានេះដែរ ចំពោះនយោបាយរបស់បក្ស” ។

ខៀវ សំផន ពិតជាបានដឹងឮមែន ។ យើងមានឯកសារចម្លងទាំងអស់ស្តីពីកំណត់ហេតុកិច្ចប្រជុំលើកទី១៥របស់អង្គការដ៏មានអំណាចក្នុងរបបកម្ពុជាប្រជាធិបតេយ្យពោល គឺគណៈកម្មាធិការអចិន្ត្រៃយ៍នៃគណៈកម្មាធិការមជ្ឈិមនៃបក្សកុម្មុយនិស្តកម្ពុជាដែលកំពុងតែកាន់អំណាចពេលនោះ ។ កិច្ចប្រជុំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ដ៏សំខាន់នេះឯង ត្រូវបានរៀបចំធ្វើឡើងក្នុងអំឡុងថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៥ ដល់ថ្ងៃ៣០ ខែឧសភា ឆ្នាំ១៩៧៦ ។ ខៀវ សំផន ត្រូវបានកត់ចូលក្នុងកំណត់ហេតុកិច្ចប្រជុំ(ដោយដាក់ឈ្មោះបដិវត្តន៍ថា ហែម) ថាបានចូលរួមចំនួន១២លើកក្នុងចំណោមកិច្ចប្រជុំទាំង១៥លើកនេះ ។ កំណត់ហេតុនៃកិច្ចប្រជុំពីរលើកនេះមិនបានកត់ឈ្មោះអ្នកចូលរួមប្រជុំទេ ប៉ុន្តែវាហាក់ដូចជាថា ខៀវ សំផន ក៏នៅទីនោះដែរដែលជាការបន្ថែមនូវចំនួន១៤លើកក្នុងចំណោមកិច្ចប្រជុំទាំង១៥លើកដែលយើងមានភ័ស្តុតាងស្រាប់ ។ នៅឯកិច្ចប្រជុំធ្វើឡើងនៅថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៥ គណៈកម្មាធិការមជ្ឈិមឲ្យ ខៀវ សំផន ទទួលខុសត្រូវខាងរណសិរ្ស និងរាជរដ្ឋាភិបាល(និង)ផ្នែកគណនេយ្យ និងខាងចាត់ចែងតម្លៃនៅក្នុងផ្នែកពាណិជ្ជកម្ម ។ ខៀវ សំផន ក៏ត្រូវបានឲ្យធ្វើជាប្រធានរដ្ឋ ពោលគឺគណៈប្រធានរដ្ឋនៃកម្ពុជាប្រជាធិបតេយ្យ ដោយមានការសម្រេចចិត្តពីគណៈកម្មាធិការមជ្ឈិមនាថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ ។ ក្នុងឆ្នាំ១៩៧៧-១៩៧៨ ខៀវ សំផន ក៏បានធ្វើជាប្រធានមន្ទីរនៃគណៈកម្មាធិការមជ្ឈិមនៃគណបក្សកុម្មុយនិស្តកម្ពុជាមន្ទីរ(៨៧០) ។ នៅខែមេសា ឆ្នាំ១៩៧៧ ក្រោយពីកាន់មុខតំណែងនេះភ្លាម ខៀវ សំផន បានប្រកាសជាសាធារណៈថា “យើងត្រូវតែបោសសម្អាតខ្មាំងនិងបង្ក្រាបខ្មាំងគ្រប់ប្រភេទគ្រប់ពេលទាំងអស់” ។ សៀវភៅកំណត់ហេតុប្រចាំថ្ងៃរបស់ជំនួយការ អៀង សារី បង្ហាញអំពីគំនិតដូចខាងក្រោមនេះ÷ “នៅក្នុងប្រទេសយើងមានពួកក្បត់ប្រហែលពី១ ទៅ៥ភាគរយដែលបង្កប់....ខ្មាំងគឺនៅក្នុងខ្លួនយើងក្នុងជួរយោធា កម្មករសហករណ៍និងនៅក្នុងជួរយើងក៏មានដែរ... ។ ខ្មាំងទាំងនោះត្រូវតែបោសសម្អាតជាបន្តបន្ទាប់” ។

អ្វីដែលមានលក្ខណៈទូទៅជាងគឺឡាកាយសម្ព័ន្ធផ្នែកគំនិតរបស់ ស៊ីវ គឺទស្សនៈដែលមានលក្ខណៈដូចគ្នាដែលថាអ្វីដែលកើតឡើងក្រោមរបបខ្មែរក្រហម ទោះបីជាពោរពេញដោយឃាតកម្មមែន ប៉ុន្តែមិនមែនជាអំពើប្រល័យពូជសាសន៍ឡើយ ។ ប្រវត្តិវិទូពីររូបដែលជំនាញខាងបញ្ហាកម្ពុជាគឺលោក វីគ ឃ័ររី នៃសាកលវិទ្យាល័យ សេន ម៉ាឡេស្យ៉ា និង ដេវីត ឆេនដល័រ មកពីសកលវិទ្យាល័យ ម៉ូណាស អ្នកទាំងពីរសុទ្ធតែមានជំហរដូចគ្នា ។ ប្រវត្តិវិទូទាំងពីររូបបានប្រឆាំងទៅនឹងខ្មែរក្រហម ប៉ុន្តែបានចាត់ទុកឧក្រិដ្ឋកម្មនៃរបបនេះជាបទឧក្រិដ្ឋក្រៅពីបទឧក្រិដ្ឋប្រល័យពូជសាសន៍ ។ **(នៅមានត)** **ប៉ែន ឃៀវនិន**

សូមសរសេរលិខិត

ឬអត្ថបទពិភាក្សាជុំវិញបញ្ហាខ្មែរក្រហម ផ្ញើមក

**ទស្សនាវដ្តី “ស្វែងរកការពិត”**

ប្រអប់សំបុត្រលេខ ១១១០ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ឬតាមទូរសារលេខៈ (៨៥៥)(២៣)២១០៣៥៨

ឬ Email: dccam@bigpond.com.kh



ថូម៉ាស់ ហាម៉ាប៊ើក

# ◆ការពិភាក្សារវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិៈ តើកិច្ចព្រមព្រៀងទៅលើការបង្កើតតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម កើតឡើងដោយរបៀបណា?





### ភាគ១ៈ ខែមីនា ឆ្នាំ១៩៩៧-ខែមីនា ឆ្នាំ១៩៩៩

នៅក្នុងអំឡុងបេសកកម្មរបស់ខ្ញុំជាលើកដំបូងនៅក្នុងប្រទេសកម្ពុជា (ខែមិថុនា ឆ្នាំ១៩៩៦) ខ្ញុំហាក់ដូចជាយល់យ៉ាងច្បាស់មួយរំពេចថា ឧក្រិដ្ឋកម្មរបស់ខ្មែរក្រហមនៅក្នុងទសវត្សរ៍ឆ្នាំ១៩៧០ នៅតែបង្កើតជាស្រមោលងងឹតគ្របដណ្តប់មកលើសង្គមកម្ពុជា ។ ការសម្លាប់អ្នកមានអាជីពច្បាស់លាស់ដែលបានទទួលការអប់រំត្រឹមត្រូវ បានធ្វើឲ្យមានគម្លាត ហើយនៅតែធ្វើឲ្យទ្រុឌទ្រោមដល់ប្រព័ន្ធតុលាការផ្នែកគ្រប់គ្រងរដ្ឋបាល រួមទាំងផ្នែកសុខាភិបាល និងវចនាសម្ព័ន្ធអប់រំ ។ ចំណែកផ្នែកសីលធម៌វិញ ក៏រឹតតែមានឥទ្ធិពលជ្រាលជ្រៅថែមទៀត ។ ខណៈដែលគ្មានអ្នកណាម្នាក់ត្រូវបានដាក់ឲ្យទទួលខុសត្រូវចំពោះការកាប់សម្លាប់ជាទ្រង់ទ្រាយធំនិងអំពើឃោរឃៅផ្សេងៗទៀត បានរួមចំណែកយ៉ាងច្បាស់ក្រឡែតដល់វប្បធម៌នៃការរួចទោសដែលនៅតែរាលដាលពាសពេញប្រទេសកម្ពុជា ។

គ្រប់ទីកន្លែងនៅក្នុងទីក្រុងភ្នំពេញនិងនៅតាមខេត្តនានាដែលខ្ញុំបានទៅដល់ ខ្ញុំតែងតែលើកឡើងនូវគំនិតពិភាក្សាអំពីមរតកខ្មែរក្រហមនិងអ្វីដែលត្រូវធ្វើ ។ អត្ថន័យមួយបានលេចរូបរាងច្បាស់ថាៈ ឧក្រិដ្ឋកម្មមិនត្រូវបានបំភ្លេចឡើយ ។ មនុស្សស្ទើរគ្រប់រូបដែលខ្ញុំបានជួប សុទ្ធតែមានផលប៉ះពាល់រៀងៗខ្លួនដោយទទួលរងនូវការឈឺចាប់ ឬយ៉ាងហោចណាស់ជាញាតិសន្តានរបស់ខ្លួនដែលបានចាកលោកនេះទៅ ។ សូម្បីតែដល់ពេលនេះ ពោលគឺអស់រយៈពេលជាងពីរទសវត្សរ៍មកហើយ ក៏នៅតែមានមតិភាគច្រើនលើសលប់ចង់ឲ្យមានការកាត់ទោសនិងដាក់ទណ្ឌកម្មចំពោះជនទាំងឡាយណាដែលទទួលខុសត្រូវ ។ អំណះអំណាងមួយលើកឡើងថាការចាប់ខ្លួននិងការជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហមនឹងនាំមកនូវភាពរំជើបរំជួលនិងសង្គ្រាមស៊ីវិល ។ ក៏ប៉ុន្តែខ្ញុំបានឮសំឡេងច្រើនណាស់ដែលនិយាយថាកុំយកហេតុផលនេះដើម្បីជាការគេចវេះក្នុងការស្វែងរកយុត្តិធម៌ឲ្យសោះ ។

បណ្តាអ្នកដឹកនាំ(ស្ទើរតែគ្មានករណីលើកលែងឡើយ) មានការចងចាំនូវមនោសញ្ចេតនា និងការឈឺចាប់ដែលបានទទួលរងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនៅក្នុងទសវត្សរ៍ឆ្នាំ១៩៧០ ។ សម្តេចព្រះ នរោត្តម សីហនុ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាបានព្យាយាមបញ្ចេញហេតុផលជាមួយខ្មែរក្រហម ប៉ុន្តែត្រូវបានធ្វើឲ្យអាម៉ាស់មុខ និងមានសមាជិករាជវង្សានុវង្សមួយចំនួនត្រូវបានសម្លាប់ ។ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន និងសមាជិកបក្សប្រជាជនកម្ពុជាជាច្រើនរូបសុទ្ធតែបានចូលរួមជាមួយចលនាខ្មែរក្រហម ហើយក្រោយមកក៏បានចុះចូលទៅខាងវៀតណាម ។ អ្នកទាំងអស់នេះក៏បាត់បង់សមាជិកគ្រួសារមួយចំនួនដែរ ។ ជាការសំខាន់ណាស់ក្នុងការទទួលស្គាល់នូវទំហំនៃសោកនាដកម្មរបស់កម្ពុជា ដើម្បីអាចយល់បាននូវភាពមិនស៊ីសង្វាក់គ្នានៅក្នុងការពិភាក្សាដែលនឹងលើកយកមកលាតត្រដាងដូចខាងក្រោមនេះ÷

បញ្ហាយុត្តិធម៌លេចរូបរាងកាន់តែក្តៅគគុកនៅឆ្នាំ១៩៩៦ គឺនៅពេលដែលចលនាខ្មែរក្រហមកំពុងតែរំកិលខ្លួនធ្លាក់ចូលទៅក្នុងវិបត្តិ ។ ទោះបីជាសកម្មភាពយោធាមួយចំនួននៅតែបន្តនៅតាមព្រំដែនភាគខាងជើងនិងពាយ័ព្យ ហើយមានការវាយឆ្មក់ញាំញី

ដល់ភូមិស្រុកនិងសហគមន៍នេសាទត្រី(ដែលមានជនជាតិវៀតណាមជាច្រើន) យ៉ាងណាក៏ដោយ ក៏នៅតែមានសញ្ញាបង្ហាញអំពីការបែកបាក់ដែរ ។ ទាំងគណបក្សហ៊្វុនស៊ិនប៉ិចនិងគណបក្សប្រជាជន បានផ្តើមគំនិតធ្វើការសាកល្បងទាក់ទងជាមួយសមាសភាពផ្តាច់ខ្លួននៃចលនាខ្មែរក្រហម ។ គណបក្សទាំងពីរបានផ្តល់នូវលក្ខណៈអនុគ្រោះមួយចំនួនដូចជាការឲ្យបន្តកាន់កាប់ទឹកដីដែលខ្មែរក្រហមកំពុងរស់នៅ ស្វ័យ័តភាព ធនធាន តួនាទីល្អៗ រួមមានទាំងឋានៈយោធានិងការលើកលែងទោសតាមសភាពជាក់ស្តែងទៀតផង ។ លក្ខណៈអនុគ្រោះនេះពិតជាមានឥទ្ធិពលណាស់ ។ នៅខែសីហា ឆ្នាំ១៩៩៦ អៀង សារី អតីតឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យ បានចុះចូលជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា ដោយនាំមកជាមួយនូវកូនទាហានរាប់ពាន់នាក់ និងបំបែកចេញពីចលនាខ្មែរក្រហមទាំងស្រុង ។

ចំណុចនេះនាំមកដល់នូវស្ថានភាពផ្ទុយគ្នាមួយ ។ ទី១ ជាការច្បាស់ណាស់ថា ពេលនេះគឺលែងអាចចៀសផុតពីការពិភាក្សាលើបញ្ហាយុត្តិធម៌ទៀតឡើយ ហើយនិងអំពីតុលាការដែលមានបទដ្ឋានអន្តរជាតិទៀតផង ។ ដំណើរការជម្រះក្តីដែលរៀបចំឡើងនៅឆ្នាំ១៩៧៩ ដោយរដ្ឋាភិបាលដែលគ្រប់គ្រងដោយវៀតណាមគឺមានគុណវិបត្តិច្រើនណាស់ ហើយមានមតិទូទៅមួយថា ការអនុវត្តរបៀបនេះមិនបានផ្តល់ការឆ្លើយតបតាមផ្លូវច្បាប់ឲ្យដល់កម្រិតខ្ពស់ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនោះទេ ។ ទី២គឺការប្រកួតប្រជែងគ្នារវាងគណបក្សធំៗពីរនៅទីក្រុងភ្នំពេញក្នុងការទាក់ទាញអ្នកចុះចូលមកក្នុងគណបក្សរបស់ខ្លួន ។ នៅក្នុងវិស័យយោធា គណបក្សប្រជាជនមានប្រៀបជាងគណបក្សដទៃទៀត ចាប់តាំងពីបេសកកម្មរបស់អង្គការសហប្រជាជាតិដែលត្រូវបានស្គាល់ជាទូទៅថា អ៊ុនតាក់ ត្រូវបញ្ចប់នៅឆ្នាំ១៩៩៣មកម្ល៉េះ ។ ប៉ុន្តែមានលទ្ធភាពដែលអាចទៅរួចដែលថា ការចុះចូលបន្តបន្ទាប់នៃកងទ័ពខ្មែរក្រហមមកក្នុងគណបក្សហ៊្វុនស៊ិនប៉ិច អាចធ្វើឲ្យមានការផ្លាស់ប្តូរ ។ ដូច្នេះការបែកបាក់ក្នុងជួរខ្មែរក្រហមបានធ្វើឲ្យមានភាពតានតឹងកាន់តែខ្លាំងឡើងៗជាមួយនឹងរដ្ឋាភិបាលចម្រុះ ។ ជាការជាក់ស្តែងនៅក្នុងស្ថានភាពបែបនេះសម្តេចនាយករដ្ឋមន្ត្រីទាំងពីរគឺ សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ប្រធានគណបក្សហ៊្វុនស៊ិនប៉ិច និងសម្តេច ហ៊ុន សែន មេដឹកនាំគណបក្សប្រជាជន សុទ្ធតែមានការស្ទាក់ស្ទើរមិនចង់ជំរុញឲ្យមានតុលាការដើម្បីជំនុំជម្រះក្តីខ្មែរក្រហម ។

ក៏ប៉ុន្តែការលើកលែងទោសចំពោះ អៀង សារី នៅខែកញ្ញា ឆ្នាំ១៩៩៦ នៅក្នុងន័យ "បង្រួបបង្រួមផ្សះផ្សាជាតិ" គឺពិតជាមានភាពចម្រូងចម្រាស ។ សម្តេចនាយករដ្ឋមន្ត្រីទាំងពីររូបបានស្នើដល់ព្រះមហាក្សត្រសុំប្រទានការលើកលែងទោស ។ ព្រះករុណាទ្រង់ក៏ប្រទានតាមសំណើ ។ ទោះជាយ៉ាងនេះក្តី ក៏សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ក្រោយមកមានបន្ទូលមកកាន់ខ្ញុំថាព្រះអង្គទ្រង់មិនចង់គាំទ្រដល់សំណើលើកលែងទោសនេះទេ ប៉ុន្តែដោយសារការទទូចហើយទទូចទៀតរបស់សម្តេច ហ៊ុន សែន ។ ជាចុងក្រោយព្រះអង្គទ្រង់ក៏សម្រេចយល់ព្រមតាមការទទូចនេះទៅ ។

សូម្បីតែនៅក្នុងចំណោមគណបក្សប្រជាជន ក៏មិនសូវសប្បាយចិត្តចំពោះការលើកលែងទោសនេះដែរ ។ ចំណែកសម្តេច ហ៊ុន សែន វិញក្រោយមកបានពន្យល់ប្រាប់ខ្ញុំថាគោលបំណងនៃការលើកលែងទោសគឺ ដើម្បីជំរុញលើកទឹកចិត្តឲ្យមានការចុះចូលកាន់តែច្រើនថែមទៀត ។ ក្រឹត្យលើកលែងទោសចំពោះ អៀង សារី ត្រូវបានរៀបចំដោយចេតនាដើម្បីជួយការពារ អៀង សារី មិនឲ្យមានការដាក់ទណ្ឌកម្មដូចដែលបានលើកឡើងនៅក្នុងតុលាការឆ្នាំ១៩៧៩ (ដែលជាទោសប្រហារជីវិត) ហើយនិងការកាត់សេចក្តីដែលអាចកើតឡើងចំពោះការរំលោភរបស់ខ្លួនទៅលើច្បាប់ដាក់ខ្មែរក្រហមឲ្យនៅក្រៅច្បាប់ឆ្នាំ១៩៩៤តែប៉ុណ្ណោះ ។ ទោះបីជាកិច្ចការនេះបាននាំឲ្យមានការចុះចូលជាក់ស្តែងថែមទៀតក៏ដោយ ក៏នៅតែគ្មានគម្លាភាពស្តីអំពីសារជាតិនៃការលើកលែងទោសចំពោះ អៀង សារី ហើយនិងបញ្ហាថាតើ អៀង សារី ត្រូវបានការពារដោយច្បាប់ឬក៏អត់ដើម្បីទប់ទល់នឹងការកាត់ឲ្យជាប់ទោសដោយតុលាការចំពោះអំពើរបស់ អៀង សារី ក្នុងទសវត្សរ៍ឆ្នាំ១៩៧០ ។

**សេចក្តីសម្រេចរបស់គណៈកម្មាធិការ**

តើអង្គការសហប្រជាជាតិមានជំហរយ៉ាងដូចម្តេចចំពោះការជំនុំជម្រះក្តី? ដើម្បីចាប់ផ្តើមដំណើរការស្រាយបំភ្លឺបញ្ហានេះ ខ្ញុំក៏បានស្នើសុំជាផ្លូវការនៅក្នុងអំឡុងនៃបេសកកម្មរបស់អង្គការសហប្រជាជាតិផ្នែកសិទ្ធិមនុស្សនៅក្នុងខែមេសា ឆ្នាំ១៩៩៧ ថាសូមឲ្យដាក់បញ្ចូលកថាខណ្ឌមួយទៀតនៅក្នុងសេចក្តីសម្រេចនេះ ។ កថាខណ្ឌនេះនឹងនិយាយអំពីលទ្ធភាពជំនួយអន្តរជាតិសម្រាប់ជួយឲ្យប្រទេសកម្ពុជាអាចដោះស្រាយការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើវិស័យសិទ្ធិមនុស្ស ។ គណៈកម្មាធិការបានបញ្ចូលចំណុចដូចខាងក្រោមនេះក្នុងសេចក្តីសម្រេចរបស់ខ្លួនលេខ ១៩៩៧/៤៩ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៩៧÷

«ស្នើអគ្គលេខាធិការតាមរយៈតំណាងពិសេសរបស់លោក ទទួលបន្ទុកផ្នែកសិទ្ធិមនុស្សនៅប្រទេសកម្ពុជា ដោយមានកិច្ចសហការជ្រោមជ្រែងជាមួយនឹងមជ្ឈមណ្ឌលសិទ្ធិមនុស្ស សុំពិនិត្យរាល់សំណើសុំជំនួយរបស់កម្ពុជាដែលទាក់ទងនឹងការរំលោភដ៏ធ្ងន់ធ្ងរទៅលើច្បាប់កម្ពុជានិងច្បាប់អន្តរជាតិ ជាមធ្យោបាយសម្រាប់នាំមកនូវការបង្រួបបង្រួមជាតិ ពង្រឹងលទ្ធិប្រជាធិបតេយ្យ និងដោះស្រាយបញ្ហានៃការដាក់ឲ្យទទួលខុសត្រូវជាបុគ្គល» ។

## សំបុត្រខែមិថុនា ឆ្នាំ១៩៩៧

នៅក្នុងខែមិថុនា ឆ្នាំ១៩៩៧ ខ្ញុំបានពិភាក្សាអំពីអ្វីដែលកើតចេញពីសេចក្តីសម្រេចជាមួយនឹងសម្តេចសហនាយករដ្ឋមន្ត្រីទាំងពីរ និងកត់សម្គាល់ថា អង្គការសហប្រជាជាតិអាចឆ្លើយតបក្នុងលក្ខណៈវិជ្ជមានចំពោះសំណើសុំជំនួយ ដើម្បីដោះស្រាយបញ្ហាឧក្រិដ្ឋកម្មខ្មែរក្រហមដែលមានការរំពឹងទុកជាយូរណាស់មកហើយ ។ មុនដំបូងខ្ញុំចាប់ផ្តើមទាក់ទងសម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ នៅពេលដែលព្រះអង្គទ្រង់មានការស្ទាក់ស្ទើរអំពីផលប៉ះពាល់ដែលចេញមកអំពីការពិភាក្សាលើបញ្ហាតុលាការចំពោះលទ្ធភាពរបស់ព្រះអង្គក្នុងការទាក់ទាញអ្នកចុះចូល ។ នេះក៏ជាពេលមួយដែលទំនាក់ទំនងរវាងមេដឹកនាំទាំងពីរកាន់តែធ្លាក់ចុះ ។

សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ទ្រង់បានយល់ព្រមឡាយព្រះហស្ថលេខាទៅលើសំណើ ប៉ុន្តែទ្រង់បានមានបន្ទូលសុំឲ្យខ្ញុំផ្ញើសេចក្តីព្រាងជាសំបុត្រផ្ញើមកព្រះអង្គ ។ ខ្ញុំនិយាយថា ខ្ញុំមានបំណងចង់ផ្តល់ជំនួយផ្នែកបច្ចេកទេសដល់ទ្រង់ ប៉ុន្តែសំបុត្រនឹងត្រូវបានចាត់ទុកជារបស់ទ្រង់ផ្ទាល់និងសម្តេច ហ៊ុន សែន ។ នៅរសៀលថ្ងៃនោះដែរ យើងមានសំណើមួយ ហើយក៏ចុះហត្ថលេខាតែម្តង ។ ខ្ញុំបានរាយការណ៍ដំណើរវិវត្តន៍ទាំងនេះប្រាប់សម្តេច ហ៊ុន សែន នៅក្នុងជំនួបជាមួយសម្តេចជាបន្តបន្ទាប់ ។ សម្តេច ហ៊ុន សែន មានប្រសាសន៍ថា សម្តេចពិតជានឹងចុះហត្ថលេខាដើម្បីផ្តាញ់ខ្មែរក្រហមដែលសម្តេចបានតស៊ូប្រយុទ្ធអស់មួយជីវិតទៅហើយនោះ ។

នៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ១៩៩៧ សំបុត្រមួយបានទៅដល់អគ្គលេខាធិការ «សុំជំនួយពីអង្គការសហប្រជាជាតិ និងសហគមន៍អន្តរជាតិក្នុងការកាត់សេចក្តីបុគ្គលទាំងឡាយណាដែលមានការទទួលខុសត្រូវចំពោះអំពើប្រល័យពូជសាសន៍និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅក្នុងរបបដឹកនាំរបស់ខ្មែរក្រហមចាប់ពីឆ្នាំ១៩៧៥ ដល់ ១៩៧៩» ។

សេចក្តីសំបុត្របន្តទៀតថា «កម្ពុជាមិនមានធនធាន ឬជំនាញការក្នុងការអនុវត្តនូវដំណើរការជម្រះក្តីដ៏សំខាន់នេះឡើយ ។ ហេតុដូចបានជម្រាបមកនេះ យើងជឿជាក់ថាជាការចាំបាច់ក្នុងការសុំជំនួយពីអង្គការសហប្រជាជាតិ ។ យើងជ្រាបអំពីកិច្ចខិតខំប្រឹងប្រែងប្រហាក់ប្រហែលគ្នានេះ ក្នុងការឆ្លើយតបទៅនឹងអំពើប្រល័យពូជសាសន៍និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅប្រទេសរ៉្វាន់ដា និងអតីតយូហ្គោស្លាវី ហើយសុំឲ្យមានជំនួយដូចគ្នានេះមកដល់កម្ពុជាផង» ។

«យើងជឿជាក់ថា ឧក្រិដ្ឋកម្មដ៏ធំធេងរបៀបនេះគឺជាការព្រួយបារម្ភរបស់មនុស្សគ្រប់ៗរូបនៅលើពិភពលោក ដោយសារតែវាធ្វើឲ្យចុះថយផ្នែកការគោរពសិទ្ធិមនុស្សជាមូលដ្ឋាន ដែលជាសិទ្ធិរស់រានមានជីវិត ។ យើងសង្ឃឹមថាអង្គការសហប្រជាជាតិនិងសហគមន៍អន្តរជាតិអាចជួយប្រជាជនកម្ពុជាក្នុងការរកឲ្យឃើញការពិតស្តីអំពីសម័យកាលនោះ និងនាំយកនូវជនទាំងឡាយណាដែលមានការទទួលខុសត្រូវមកកាន់តុលាការដើម្បីវិនិច្ឆ័យទោសតាមច្បាប់ ។ មានតែតាមវិធីនេះទេ ទើបសោកនាដកម្មនេះអាចត្រូវបានបញ្ចប់ដោយពេញលេញ និងគ្មានថ្ងៃកើតសាជាថ្មីឡើងវិញបាន» ។

ក្រោយមក សំបុត្រនេះត្រូវបានលើកយកមកនិយាយនៅក្នុងកិច្ចពិភាក្សារវាងអគ្គការសហប្រជាជាតិនិងរដ្ឋាភិបាលកម្ពុជាស្តីអំពីបញ្ហាខ្មែរក្រហម ។ នៅពេលទៅដល់ទីក្រុងញូវយ៉ក សំបុត្រនេះត្រូវបានផ្សព្វផ្សាយដល់គ្រប់សមាជិកនៃក្រុមប្រឹក្សាសន្តិសុខ ប៉ុន្តែវាក្លាយទៅជាមានបញ្ហាចម្រូងចម្រាសទៅវិញ ។ គណៈប្រតិភូចិនបញ្ជាក់ច្បាស់ថាខ្លួនមិនចង់លើកយកប្រធានបទនេះដាក់ក្នុងរបៀបវារៈនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សាសន្តិសុខឡើយ ។ ខ្ញុំបានជួបជាមួយនឹងការិយាល័យទទួលបន្ទុកផ្នែកច្បាប់នៅលេខាធិការដ្ឋាន ហើយផ្តល់យោបល់ថា សុំឲ្យមានការរៀបចំដំណោះស្រាយផងចុះ ។ ការឆ្លើយតបដំបូងពីរដ្ឋដែលជាសមាជិកធំៗ និងមកពីលេខាធិការដ្ឋាន មិនស្ថិតនៅក្នុងលក្ខណៈអបអរទេ ហើយមានការច្របូកច្របល់ទៀតផង ។ ស្ថានការណ៍នេះប្រហែលមកពីកត្តានយោបាយមួយ ។ នៅដើមខែកក្កដា ភាពតានតឹងរវាងគណបក្សទាំងពីរនៃរដ្ឋាភិបាលចម្រុះនៅក្រុងភ្នំពេញនិងកងកម្លាំងប្រដាប់អាវុធរបស់ភាគីទាំងពីរក៏បានផ្ទុះឡើងជាការប្រឈមមុខខាងយោធា ។ កម្លាំងដែលមានភក្តីភាពជាមួយគណបក្សប្រជាជនបានចាប់ផ្តើមដកអាវុធពីភាគីម្ខាងទៀត ។ សម្តេចនាយករដ្ឋមន្ត្រីទីពីរបានទទួលជ័យជម្នះក្រោយពីធ្វើរដ្ឋប្រហារដោយគ្មានឈ្មញរាមក ។ សម្តេចក្រុមព្រះនរោត្តម រណឫទ្ធិ ដែលទើបតែចាកចេញពីប្រទេសកម្ពុជា ត្រូវបានសម្តេចនាយករដ្ឋមន្ត្រីទីពីរប្រកាសថាបានចុះចេញពីតំណែង ។ ទីស្នាក់ការគណបក្សហ៊្វុនស៊ិនប៉ិចត្រូវបានរំលោភ ហើយរាល់ឯកសារទាំងឡាយត្រូវបានរឹបអូសយក ។ បក្សប្រឆាំង "គណបក្សជាតិខ្មែរ" ដឹកនាំដោយអតីតរដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ សម រង្ស៊ី ក៏ទទួលរងអំពើដូចគ្នានេះដែរ ។ សភាជាតិត្រូវបានបិទទ្វារជាបណ្តោះអាសន្ន ប៉ុន្តែគ្មានវិទ្យុនិងទូរទស្សន៍របស់គណបក្សប្រជាជនណាមួយត្រូវបានបិទទ្វាររឹបអូសឡើយ ។

នៅអំឡុងខែកក្កដានិងខែសីហា អគ្គការសហប្រជាជាតិបានទទួលរបាយការណ៍ស៊ើបអង្កេតជាច្រើនទៅលើមន្ត្រីយោធារបស់គណបក្សហ៊្វុនស៊ិនប៉ិចដែលត្រូវបានសម្លាប់ជាខ្សែសង្វាក់ ។

ការដោះសារមួយក្នុងចំណោមការដោះសារជាច្រើនដែលនាំដល់ការបង្ក្រាបនេះគឺថា សម្តេចក្រុមព្រះបានធ្វើការទាក់ទងជាសម្ងាត់ជាមួយនឹងមេដឹកនាំខ្មែរក្រហម ហើយថាព្រះអង្គបាននាំទាហានខ្មែរក្រហមជាច្រើននាក់ចូលមកក្នុងទីក្រុងភ្នំពេញ (តាមពិតមានអ្នកចុះចូលមួយចំនួនក្នុងចំណោមកងកម្លាំងរបស់ភាគីទាំងពីរនៅក្នុងទីក្រុងភ្នំពេញ ហើយគ្មានការបង្ហាញឲ្យឃើញច្បាស់ថាគណបក្សហ៊្វុនស៊ិនប៉ិចបាននាំចំនួនដ៏ច្រើននេះចូលមកឡើយ) ។

នៅពេលនោះដែរ ការបែកបាក់នៅក្នុងចលនាខ្មែរក្រហមក៏ចេះតែជ្រៅទៅៗ ។ នៅខែមិថុនា សុន សេន អតីតឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការការពារជាតិព្រមទាំងក្រុមគ្រួសារត្រូវបានធ្វើឃាតតាមបញ្ជាពី ប៉ុល ពត ។ ជាការច្បាស់ណាស់ថា មេដឹកនាំខ្មែរក្រហមដែលនៅសល់ក៏បែកខ្ញែករត់គេចខ្លួនក្នុងចលនាតស៊ូផ្ទៃក្នុងដ៏ជូរចត់ ។ បងទី១ខ្លួនឯងត្រូវបានតុលាការប្រជាជននៅជិតព្រំដែនថៃកាត់ទោសនៅចុងខែកក្កដា ហើយដាក់ឲ្យជាប់ទោសអស់មួយជីវិត ។ ការចុះចូលនឹងមានបន្តទៅទៀត ហើយមានការភ័យខ្លាចថាបញ្ហានេះនឹងធ្វើកាន់តែធ្វើឲ្យមានភាពតានតឹងថែមទៀតរវាងគណបក្សធំៗទាំងពីរ ។

តើវិនាសកម្មទាំងនេះមានផលប៉ះពាល់យ៉ាងដូចម្តេចខ្លះចំពោះកិច្ចពិភាក្សាដែលងាយនឹងប្រេះស្រាំជាមួយនឹងអគ្គការសហប្រជាជាតិ ស្តីអំពីកិច្ចសហប្រតិបត្តិការក្នុងការនាំយកមេដឹកនាំខ្មែរក្រហមមកជំនុំជម្រះក្តី? តើសំណើចុះថ្ងៃទី២១ ខែមិថុនា នៅតែមានការគាំទ្រពីសំណាក់គណបក្សទាំងពីរឬយ៉ាងណា?

## មហាសន្និបាតអគ្គការសហប្រជាជាតិឆ្នាំ១៩៩៧

នៅដើមខែកញ្ញា ខ្ញុំបានជួបប្រជុំជាមួយសម្តេច ហ៊ុន សែន ។ ជំនួបនេះផ្តោតសំខាន់ទៅលើអនុស្សារណៈដែលខ្ញុំទើបតែបានដាក់ជូនរដ្ឋាភិបាលស្តីអំពីការសម្លាប់ក្រោយព្រឹត្តិការណ៍៥-៦កក្កដា ។ ទោះបីជាមានការប្រឈមមុខដាក់ស្តែងទៅលើប្រធានបទនេះក៏ដោយ ក៏សម្តេច ហ៊ុន សែន បានគូសបញ្ជាក់ថា លិខិតចុះថ្ងៃទី២១ ខែមិថុនា គឺនៅតែមានសុពលភាពនៅឡើយទេ ។ ការបញ្ជាក់នេះដូចគ្នាទៅនឹងមេដឹកនាំគណបក្សប្រជាជនកម្ពុជាដទៃទៀត ដែលខ្ញុំបានជួបដែរ ដូចជាសម្តេច ជា ស៊ីម ប្រធានគណបក្ស

ប្រជាជននិងជាប្រធានសភាជាតិ និងឯកឧត្តម ស ខេង ជាឧបនាយករដ្ឋមន្ត្រីនិងសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

ព្រះមហាក្សត្រសម្តេចព្រះ នរោត្តម សីហនុ ទ្រង់បានផ្តល់ការគាំទ្រយ៉ាងពេញទំហឹងដល់កិច្ចខិតខំប្រឹងប្រែងស្តីពីបញ្ហាខ្មែរក្រហម ដែលបានបញ្ជាក់ច្បាស់នៅក្នុងរបាយការណ៍មហាសន្និបាត ដោយទ្រង់មានព្រះបន្ទូលជម្រាបដល់ខ្ញុំថា បើមិនមានការអនុវត្តលើគំនិតផ្តួចផ្តើមនេះទេ នឹងគ្មានថ្ងៃបញ្ចប់ភាពរួចទោសនៅក្នុងប្រទេសកម្ពុជាឡើយ ។ ព្រះអង្គបានមានបន្ទូលបន្ថែមទៀតថា ទ្រង់ផ្ទាល់ក៏មានបំណងចង់ឲ្យមានកោះហៅព្រះអង្គឲ្យទៅបំភ្លឺអំពីទំនាក់ទំនងរបស់ព្រះអង្គជាមួយនឹងរបបខ្មែរក្រហមដែរ ។ «នេះជាភារកិច្ចរបស់ខ្ញុំ» ព្រះអង្គមានព្រះបន្ទូល ។

ក្រោយមកនៅខែកញ្ញា ខ្ញុំបានចូលគាល់សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ និងមេដឹកនាំប្រឆាំងក្រោយពីព្រឹត្តិការណ៍ថ្ងៃ៥ - ៦ កក្កដា មួយចំនួនទៀត នៅសណ្ឋាគារមួយនៅទីក្រុងញូវយ៉ក ។ មេដឹកនាំទាំងនេះធ្វើដំណើរទៅដល់ទីក្រុងញូវយ៉កដើម្បីបង្ហាញករណីរបស់ខ្លួនចំពោះសហគមន៍អន្តរជាតិ និងដើម្បីពិភាក្សាបញ្ចុះបញ្ចូលមហាសន្និបាតអង្គការសហប្រជាជាតិ សុំឲ្យចេញសេចក្តីសម្រេចបញ្ជាក់ថាសម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ត្រូវបានទទួលស្គាល់ជាតំណាងស្របច្បាប់របស់រដ្ឋាភិបាលកម្ពុជា ឬក៏ថាប្រទេសកម្ពុជាគួរតែត្រូវបានដកកៅអីពីអង្គការសហប្រជាជាតិ (សំណើក្រោយនេះបានក្លាយជាសេចក្តីសម្រេច) ។ មេដឹកនាំគណបក្សជាតិខ្មែរ សម រង្ស៊ី និងគណបក្សប្រជាធិបតេយ្យសេរីនិយមព្រះពុទ្ធសាសនាដឹកនាំដោយសម្តេច សឺន សាន ក៏មានវត្តមានក្នុងឱកាសនោះដែរ ។ ដោយយោងទៅតាមកិច្ចប្រជុំថ្មីៗជាមួយនឹងព្រះមហាក្សត្រ ខ្ញុំបានសុំឲ្យមានការធានាថា ការវិវត្តផ្នែកនយោបាយនឹងមិនធ្វើឲ្យមានការផ្លាស់ប្តូរជំហរគាំទ្រដល់សំបុត្រចុះថ្ងៃទី២១ ខែមិថុនា នោះទេ ។ ក្រោយពីស្ងាត់មួយសន្ទុះមក សម្តេចក្រុមព្រះក៏សាកសួរមតិពីអ្នកនយោបាយផ្សេងៗទៀតដែលមានវត្តមាននៅក្នុងបន្ទប់ ។ ម្នាក់ៗសម្តែងការយល់ព្រម ហើយសម្តេចក្រុមព្រះក៏ធ្វើជាសេចក្តីសង្ខេបចំពោះការយល់ព្រមជាឯកច្ឆ័ន្ទនេះ ។

ជាការគាប់ជួនដ៏ចម្លែកនិងជាប្រវត្តិសាស្ត្រ បញ្ហាដែលគួរតែបែកបាក់កាន់តែជ្រៅបែរជាក្លាយមកជាបញ្ហាតែមួយគត់ដែលមានកម្លាំងនយោបាយទាំងអស់យល់ព្រម ។ នៅលើមូលដ្ឋាននេះ ខ្ញុំបានជំរុញឲ្យមហាសន្និបាតអង្គការសហប្រជាជាតិឆ្លើយតបជាវិជ្ជមាននិងដោយសប្បុរសចំពោះសំណើសុំជំនួយរបស់ប្រទេសកម្ពុជា ។

តើដំណើរប្រព្រឹត្តទៅយ៉ាងដូចម្តេច? ជាការច្បាស់ណាស់ថា នេះជាដំណាក់កាលដែលមិនទាន់អាចនិយាយបានអំពីរឿងគំរូណាមួយឡើយ ទោះជាតុលាការពិសេសមួយមានលក្ខណៈប្រហាក់ប្រហែលនឹងតុលាការយូហ្គោស្លាវីនៅទីក្រុងឡាអេក៏ដោយ ។ ចាំបាច់ត្រូវមានជំហានមធ្យមមួយសិនដើម្បីពិភាក្សាឲ្យបានត្រឹមត្រូវនូវសារជាតិពិតនិងវិសាលភាពនៃឧក្រិដ្ឋកម្ម លក្ខណៈភ័ស្តុតាងច្បាប់អ្វីដែលត្រូវយកមកអនុវត្ត និងដំណើរការជម្រះក្តីដ៏សមរម្យបំផុត ។ ក្នុងពេលនេះជាការច្បាស់ទៅហើយថា ការពិភាក្សាស៊ីជម្រៅអំពីទំនាក់ទំនងរវាងទិដ្ឋភាពក្នុងស្រុកនិងអន្តរជាតិគឺជារឿងសំខាន់ ។

ក្នុងករណីអតីតយូហ្គោស្លាវី គណៈកម្មាធិការជំនាញត្រូវបានជ្រើសតាំងឲ្យប្រមូលនិងវាយតម្លៃភ័ស្តុតាងមុនពេលបង្កើតតុលាការ ។ គណៈកម្មាធិការប្រហាក់ប្រហែលគ្នានេះត្រូវបានបង្កើតនៅក្នុងករណីរ៉្វាន់ដា ដែលមានភារកិច្ចផ្តល់អនុសាសន៍ទៅលើមធ្យោបាយជាច្រើនក្នុងការសម្រេចការទទួលខុសត្រូវតាមច្បាប់ ។ នៅក្នុងករណីខ្មែរក្រហម ច្បាស់ជាមានការខុសប្លែកបន្តិចហើយ គឺត្រូវសង្កត់ធ្ងន់ទៅលើការឲ្យយោបល់យ៉ាងណាឲ្យបានដំណើរការជម្រះក្តីដ៏ល្អបំផុត ។ ពាក្យថា «គណៈកម្មការ» គួរតែត្រូវបញ្ចៀស ដើម្បីកុំឲ្យមានការនិយាយអំពីការយកគំរូរបស់អតីតយូហ្គោស្លាវីមកប្រើ ។ នៅជំហានទីមួយ ខ្ញុំបានស្នើមហាសន្និបាតអង្គការសហប្រជាជាតិ(មិនមែនក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិទេ) ថា អគ្គលេខាធិការអង្គការសហប្រជាជាតិគួរមានសិទ្ធិជ្រើសតាំងអ្នកជំនាញការដើម្បីឲ្យមកវាយតម្លៃភ័ស្តុតាងដែលមានស្រាប់ ស្តីពីការទទួលខុសត្រូវចំពោះការរំលោភផ្នែកសិទ្ធិមនុស្សរបស់ខ្មែរក្រហមនិងដើម្បីស្នើឲ្យមានវិធានការថែមទៀត ។

ខាងក្រោមនេះជាវិធីដែលចំណុចនេះត្រូវបានបំប្លែងនៅក្នុងសេចក្តីសម្រេចរបស់មហាសន្និបាតចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីអំពីកម្ពុជា (៥២/១៣៥)÷

"បំណងប្រាថ្នាប្រវត្តិសាស្ត្រខ្លោចផ្សារបស់កម្ពុជា តម្រូវឲ្យមានវិធានការពិសេសក្នុងការធានាការការពារសិទ្ធិមនុស្សរបស់ប្រជាជនគ្រប់រូបនៅក្នុងប្រទេសកម្ពុជា និងមិនឲ្យនយោបាយនិងការប្រព្រឹត្តកាលពីអតីតកាលវិលត្រឡប់សាជាថ្មីដូចដែលបានចែងនៅក្នុងកិច្ចព្រមព្រៀងចុះហត្ថលេខានៅទីក្រុងប៉ារីសឆ្នាំ១៩៩១÷

◆◆◆ "យល់ព្រមចំពោះយោបល់របស់លោកតំណាងពិសេសដែលថា ការរំលោភដ៏ធ្ងន់ធ្ងរផ្នែកសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជានៅក្នុងប្រវត្តិសាស្ត្រថ្មីៗនេះត្រូវបានប្រព្រឹត្តឡើងដោយខ្មែរក្រហម ហើយថា ឧក្រិដ្ឋកម្មរបស់ខ្មែរក្រហម រួមទាំងការចាប់និងការសម្លាប់ចំណាប់ខ្មាំងផង បានបន្តរហូតមកដល់បច្ចុប្បន្ន និងកត់សម្គាល់ទាំងការព្រួយបារម្ភថាគ្មានមេដឹកនាំខ្មែរក្រហមណាម្នាក់ត្រូវបាននាំយកមកកាន់តុលាការដើម្បីកាត់សេចក្តីអំពីបទឧក្រិដ្ឋរបស់ខ្លួនឡើយ ។

ស្នើលោកអគ្គលេខាធិការពិនិត្យសំណើរបស់អាជ្ញាធរកម្ពុជាសុំជំនួយទាក់ទងនឹងការរំលោភដ៏ធ្ងន់ធ្ងរកាលពីអតីតកាលទៅលើច្បាប់កម្ពុជា រួមទាំងលទ្ធភាពក្នុងការជ្រើសតាំងដោយលោកអគ្គលេខាធិការចំពោះក្រុមអ្នកជំនាញការ ឲ្យមកវាយតម្លៃភ័ស្តុតាងដែលមានស្រាប់ ហើយស្នើវិធានការថែមទៀតដែលជាមធ្យោបាយក្នុងការនាំមកការបង្រួបបង្រួមជាតិ ការពង្រឹងលទ្ធិប្រជាធិបតេយ្យ និងដោះស្រាយបញ្ហានៃការទទួលខុសត្រូវជាបុគ្គល" ។

នៅក្នុងខែមករា ឆ្នាំ១៩៩៨ ស្នងការជាន់ខ្ពស់របស់អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស អ្នកស្រី ម៉ារី រ៉ូប៊ីនសុន បានមកធ្វើទស្សនកិច្ចនៅកម្ពុជា ។ អ្នកស្រីបានពិភាក្សាទៅលើសេចក្តីសម្រេចរបស់មហាសន្និបាតជាមួយនឹងតំណាងរដ្ឋាភិបាល ហើយគូសបញ្ជាក់ថា សហគមន៍អន្តរជាតិបានឆ្លើយតបជាវិជ្ជមានចំពោះសំណើសុំជំនួយរបស់ប្រទេសកម្ពុជា ក្នុងការដោះស្រាយការរំលោភទូទៅដែលត្រូវបានប្រព្រឹត្តឡើងនៅក្នុងរបបខ្មែរក្រហមចាប់ពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ ។ រដ្ឋាភិបាលបានស្វាគមន៍ចំពោះសំណើជ្រើសតាំងក្រុមអ្នកជំនាញការឲ្យមកវាយតម្លៃភ័ស្តុតាងដែលមានស្រាប់និងស្នើឲ្យមានវិធានការថែមទៀត ។

ការរៀបចំយ៉ាងជាក់លាក់នៅក្នុងសេចក្តីចម្រេចរបស់មហាសន្និបាតក៏ត្រូវបានបញ្ចូលនៅក្នុងនៅក្នុងសេចក្តីសម្រេចស្តីអំពីបញ្ហាកម្ពុជាអនុម័តដោយគណៈកម្មការទទួលបន្ទុកផ្នែកសិទ្ធិមនុស្សនាថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៩៨ ។

## ការគាំទ្រសាជាថ្មី

មរណភាពរបស់ ប៉ុល ពត នៅថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៩៨ គឺជាការរំឭកថា "ជិតហួសពេលហើយ" ។ មេដឹកនាំខ្មែរក្រហមដទៃទៀតមានវ័យកាន់តែចាស់ ហើយប្រហែលជាមានបញ្ហាសុខភាពទៀតផង ។

ក្រោយពីមានរបាយការណ៍ស្តីអំពី "ការកាត់ទោស" ប៉ុល ពត នៅជិតអន្លង់វែងនាខែកក្កដា ឆ្នាំ១៩៩៧ រដ្ឋាភិបាលសហរដ្ឋអាមេរិកបានធ្វើការលើកគម្រោងចាប់ ប៉ុល ពត នៅតាមព្រំដែនថៃ-កម្ពុជា និងនាំខ្លួន ប៉ុល ពត មកកាន់ប្រទេសទីបីដើម្បីវិនិច្ឆ័យទោស ។ រដ្ឋាភិបាលថៃត្រូវបាននិយាយយោងថាបានយល់ព្រមធ្វើកិច្ចសហប្រតិបត្តិការជាមួយនឹងផែនការនេះ ទោះបីជាតំណាងប្រទេសថៃនិយាយជាមួយខ្ញុំផ្សេងគ្នាបន្តិចក៏ដោយ ។ ខ្ញុំក៏ត្រូវបានជម្រាបដែរថា ក្នុងចំណោមប្រទេសកាណាដា ដាណឺម៉ាក ស៊ុយអែដ និងអ៊ីស្រាអែល ត្រូវបានទាក់ទងដោយតំណាងរដ្ឋាភិបាលសហរដ្ឋអាមេរិក ឲ្យធ្វើជាម្ចាស់ផ្ទះរៀបចំដំណើរការកាត់សេចក្តីនេះ ។ អង្គការសហប្រជាជាតិមិនត្រូវបានជម្រាបជាផ្លូវការស្តីអំពីសកម្មភាពការទូតនេះឡើយ ហើយខ្ញុំផ្ទាល់បានរិះគន់ចំពោះរបៀបនៃការយល់ព្រមលើកគម្រោងការនេះ ។ នៅចុងបញ្ចប់គ្មានប្រទេសណាមួយត្រូវបានរៀបចំឲ្យធ្វើជាម្ចាស់ផ្ទះសម្រាប់ការជំនុំជម្រះនេះទេ ។

នៅក្នុងខែមេសា ពោលគឺ២សប្តាហ៍បន្ទាប់ពី ប៉ុល ពត បាត់បង់ជីវិត គណៈប្រតិភូសហរដ្ឋអាមេរិកនៅឯអង្គការសហប្រជាជាតិ

បានផ្សព្វផ្សាយសេចក្តីព្រាងនូវសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខ ដែលប្រសិនបើជាត្រូវបានអនុម័តអាចបង្កើតបានជាតុលាការពិសេសមួយនៅប្រទេសហូល្លង់ ដោយយកគំរូតាមតុលាការនៅអតីតប្រទេសយូហ្គោស្លាវី ។ ប្រទេសនេះគឺចិនបានស្តែងបង្ហាញភាពអវិជ្ជមាន ហើយមានសេចក្តីរាយការណ៍ថា ទាំងរុស្ស៊ីនិងបារាំងក៏មានបញ្ហាជាមួយនឹងការផ្តើមគំនិតរបស់សហរដ្ឋអាមេរិកដែរ ។

នៅអំឡុងបេសកកម្មរបស់ខ្ញុំក្នុងប្រទេសកម្ពុជានៅខែមេសា-ឧសភា ឆ្នាំ១៩៩៨ ខ្ញុំបានពិភាក្សាបញ្ហាតុលាការម្តងទៀតយ៉ាងលម្អិតជាមួយសម្តេច ហ៊ុន សែន ដែលបញ្ជាក់ថា សម្តេចនៅមានជំហរគាំទ្រដល់សំណើក្នុងលិខិតចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ១៩៩៧ ដដែល ។ សម្តេច ហ៊ុន សែន មានប្រសាសន៍ថា ជាការសំខាន់ណាស់ដែលនៅចុងបញ្ចប់ខ្មែរក្រហមត្រូវបាននាំមកកាន់តុលាការដើម្បីកាត់ទោសនោះ ប៉ុន្តែសម្តេចមានអារម្មណ៍ថា សកម្មភាពថ្មីរបស់សហរដ្ឋអាមេរិកបានធ្វើឲ្យសភាពការណ៍មានលក្ខណៈស្មុគស្មាញ ។

នៅក្នុងកម្រិតមួយច្បាស់ជាងនេះទៅទៀត សម្តេច ហ៊ុន សែន បានមានប្រសាសន៍អំពីផែនការរបស់សម្តេចក្នុងការចាប់ខ្លួន“អ្នកទាំងបី” (ខ្ញុំយល់ថាសម្តេចនិយាយយោងដល់ នួន ជា ខៀវ សំផន និង តាម៉ុក) ដែលផែនការនេះត្រូវអាក់ខានទៅវិញដោយសារការផ្សាយជាសាធារណៈនាពេលថ្មីៗកន្លងទៅនេះ ។ ទាក់ទងនឹង អៀង សារី សម្តេចរំឭកសាជាថ្មីម្តងទៀតថា ក្រឹត្យលើកលែងទោសត្រូវបានបង្កើតឡើងក្នុងផ្លូវដែលមិនអាចការពារ អៀង សារី អំពីដំណើរការទាក់ទងនឹងអំពើប្រល័យពូជសាសន៍ ។ សម្តេចមានប្រសាសន៍ថា តាមពិតសម្តេចបានទាក់ទាញបញ្ចុះបញ្ចូលឲ្យ អៀង សារី មកបង្ហាញមុខប្រសិនបើមានការបង្កើតតុលាការអន្តរជាតិ ។

ក៏ប៉ុន្តែ សម្តេច ហ៊ុន សែន លើកឡើងនូវបញ្ហាពីរ ។ ទី១ ជាការប្រថុយគ្រោះថ្នាក់ក្នុងការធ្វើការពិភាក្សាជាសាធារណៈអំពីការនាំយកមេដឹកនាំខ្មែរក្រហមមកកាន់តុលាការដើម្បីជំនុំជម្រះក្តីដែលអាចរារាំងដល់ការចុះចូលផ្តាច់ខ្លួនរបស់ចលនាខ្មែរក្រហម ។ សម្តេចបញ្ជាក់ច្បាស់ថា សម្តេចកំពុងតែធ្វើការទៅលើក្រុមខ្មែរក្រហមដែលនៅសេសសល់ ដើម្បីបញ្ចុះបញ្ចូលឲ្យបោះបង់ការប្រយុទ្ធ ។ បញ្ហាមួយទៀតគឺការប្រថុយគ្រោះថ្នាក់ដែលថា ការពិភាក្សាជាសាធារណៈអំពីរឿងនេះអាចរំខានដល់យុទ្ធនាការបោះឆ្នោតឆ្នាំ១៩៩៨ (ដែលនឹងត្រូវចាប់ផ្តើមនៅចុងខែកក្កដា) ។ ខ្ញុំបានពន្យល់ថា ការវិភាគមួយជំហានម្តងៗទៅលើភ័ស្តុតាងនិងជម្រើសសម្រាប់ដំណើរការនេះនឹងត្រូវការពេលវេលា ហើយថា ប្រសិនបើដូច្នេះមែន សូម្បីតែសំណើមួយក៏មិនអាចចប់សព្វគ្រប់មុនសរទរដូវឈានមកដល់ដែរ ។

សម្តេច ហ៊ុន សែន មានប្រសាសន៍ទៀតថា សម្តេចនឹងស្វាគមន៍ចំពោះការមកដល់របស់ក្រុមអ្នកជំនាញការ ហើយមានបំណងចង់ជ្រើសតាំងជនជាតិកម្ពុជាមួយចំនួនឲ្យមកចរចាជាមួយនឹងក្រុមអ្នកជំនាញការនេះ ។ សម្តេចគូសបញ្ជាក់ថា ក្រុមអ្នកជំនាញការនេះមិនត្រូវបង្កើតទុកជាមុនដោយសេចក្តីសម្រេចណាមួយទេ ប៉ុន្តែតុលាការអាចនឹងត្រូវបានយកគំរូតាមតុលាការដែលមានស្រាប់នៅទីក្រុងឡាអេ ។ សម្តេចក៏មិនចង់ឲ្យមានការសម្រេចនៅពេលនេះដែរថាដំណើរការត្រូវធ្វើឡើងនៅកម្ពុជា ។ ទិដ្ឋភាពនេះនឹងអាចនៅជាចំហសិន ហើយនឹងត្រូវបានវិភាគដោយក្រុមអ្នកជំនាញការ មុនការទទួលយកសេចក្តីសម្រេចផ្សេងៗ ។

នៅទីបញ្ចប់សម្តេច ហ៊ុន សែន លើកឡើងម្តងទៀតនូវកិច្ចគាំទ្ររបស់សម្តេចចំពោះគំនិតដែលបង្កើតឡើងតាមរយៈសេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ ។ សម្តេចមានប្រសាសន៍ ដោយយោលតាមការឲ្យយោបល់របស់រដ្ឋាភិបាលសហរដ្ឋអាមេរិកនៅពេលនោះថា សម្តេចមិនគិតថាវាជាការចាំបាច់ដល់ថ្នាក់ត្រូវសរសេរសំបុត្រជាលើកទីពីរដែលមានសំណើតែមួយឡើយ ។ ជំហានបៀបនេះក៏ប្រហែលជាអាចបង្កជាបញ្ហាស្មុគស្មាញថាតើអ្នកណានឹងចុះហត្ថលេខាជាមួយនឹងសម្តេច ។ ភាពស្របច្បាប់របស់ឯកឧត្តម អ៊ឹង ហួត ក្នុងនាមជានាយករដ្ឋមន្ត្រីទីមួយ មិនត្រូវបានទទួលស្គាល់ជាទូទៅឡើយ ។ “ខ្ញុំសូមឲ្យលោក

នាំយកជំហររបស់ខ្ញុំទៅប្រាប់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ» ។ សម្តេច ហ៊ុន សែន ក៏រំឭកឡើងវិញថា សម្តេចសង្ឃឹមថា នៅក្នុងដំណាក់កាលនេះ បញ្ហាចំពោះមុខនឹងមិនទាន់លេចចេញជាសាធារណៈ ។

សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ដែលខ្ញុំបានជួបនៅទីក្រុងបាងកក មានព្រះបន្ទូលថា សំបុត្រខែមិថុនា ឆ្នាំ១៩៩៧ នៅតែមានសុពលភាពនៅឡើយទេ ហើយថាព្រះអង្គគាំទ្រយ៉ាងពេញលេញចំពោះសំណើនេះ ។ ព្រះអង្គមានព្រះបន្ទូលគាំទ្រយ៉ាងពេញទំហឹងដល់កិច្ចប្រឹងប្រែងរបស់យើង និងគំនិតនាំយកក្រុមអ្នកជំនាញការមកក្នុងប្រទេសកម្ពុជា ដើម្បីវាយតម្លៃលើភ័ស្តុតាងនិងដាក់ស្នើវិធានការផ្សេងៗថែមទៀត ។ សម្តេចក្រុមព្រះយល់ស្របថា ក្រុមអ្នកជំនាញការនឹងពិនិត្យទៅលើជម្រើសដែលអាចទៅរួច ប៉ុន្តែទ្រង់ផ្ទាល់មានអារម្មណ៍ថា ជម្រើសដ៏ល្អបំផុតគឺប្រហែលជាយកតាមគំរូតាមតុលាការនៅទីក្រុងឡាអេ ។ នៅក្នុងអំឡុងបេសកកម្មនេះ ខ្ញុំបានចូលគាល់ព្រះមហាក្សត្រម្តងទៀត ។ ព្រះអង្គទ្រង់ប្រទាននូវការគាំទ្រយ៉ាងកក់ក្តៅដល់គំនិតបង្កើតតុលាការនិងកិច្ចសហប្រតិបត្តិការជាលក្ខណៈអន្តរជាតិលើបញ្ហានេះ ។ «ត្រូវតែធ្វើរឿងនេះឲ្យបាន» នេះជាព្រះរាជឱង្ការរបស់ព្រះមហាក្សត្រ ។ ខ្ញុំបានពន្យល់អំពីដំណោះស្រាយមួយជំហានម្តងៗនិងចំណុចនៃការវិភាគល្អិតល្អន់ទៅលើសារជាតិនៃភ័ស្តុតាងដែលមានស្រាប់ ព្រមទាំងទម្រង់ផ្សេងៗដែលអាចចេញរួចសម្រាប់ដំណើរការទាំងមូល ។ ព្រះមហាក្សត្រទ្រង់បញ្ជាក់ថា ព្រះអង្គយល់ព្រមលើគំនិតនេះទាំងស្រុង ។

ខ្ញុំក៏បានលើកបញ្ហានេះដែរជាមួយនឹងឧបនាយករដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឯកឧត្តម ស ខេង និងអ្នកនយោបាយប្រឆាំងពីររូបទៀតគឺលោក សម រង្ស៊ី និង លោក សឺន ស៊ូប៊ែត៍ ។ ឥស្សរជនទាំងបីរូបបានផ្តល់នូវចម្លើយគាំទ្រច្បាស់លាស់ ហើយមានប្រសាសន៍ថាដំណើរការមួយចំនួនមានសារសំខាន់ណាស់ ។ ឯកឧត្តម ស ខេង មានប្រសាសន៍ថា លោកប្រឆាំងនឹងការលើកលែងទោសចំពោះ អៀង សារី ហើយសង្ឃឹមថា អៀង សារី នឹងត្រូវនាំយកមកកាន់តុលាការដើម្បីជំនុំជម្រះទោសមិនខានឡើយ ។

មានចំណុចមួយដែលមានការសង្កត់ធ្ងន់នៅក្នុងកិច្ចសន្ទនាជាច្រើនគឺថា ប្រជាជនកម្ពុជាចង់ក្លាយជាភាគីមួយពេញលេញនៅក្នុងការពិភាក្សានេះ ។ «ហើយម្យ៉ាងវិញទៀត នេះជាបញ្ហារបស់យើង» នេះជាសម្តីដែលតែងតែលេចឡើងជាញឹកញាប់ ។ លទ្ធភាពក្នុងការរៀបចំឲ្យមានតុលាការនៅក្នុងប្រទេសកម្ពុជា ដោយមានបុគ្គលិកអន្តរជាតិ (រួមទាំងចៅក្រមនិងព្រះរាជអាជ្ញា) ប៉ុន្តែដោយមានកិច្ចសហប្រតិបត្តិការជាមួយកម្ពុជា គឺជាជម្រើសយ៉ាងច្បាស់ដែលត្រូវលើកយកមកវិភាគ ។ បើមិនដូច្នេះទេ តំណាងរបស់កម្ពុជាជាទូទៅនឹងមានគំនិតទូលំទូលាយពេកនៅក្នុងការពិភាក្សារកដំណោះស្រាយ ។ គំនិតរបស់ក្រុមអ្នកជំនាញការនៅជំហានដំបូងហាក់ដូចជាបានទទួលការសរសើរជាទូទៅ ។

សម្តេច ហ៊ុន សែន បានមានប្រសាសន៍អំពី «សំណុំរឿង»ឧក្រិដ្ឋកម្មដែលគួរតែត្រូវបានដាក់បញ្ចូល ដូចជាការទម្លាក់គ្រាប់បែករបស់អាមេរិកាំងនៅដើមទសវត្សរ៍ឆ្នាំ១៩៧០ និងការឧបត្ថម្ភគាំទ្ររបស់ប្រទេសចិនចំពោះខ្មែរក្រហម ។ នេះជាផ្ទៃរឿងដែលសម្តេចនឹងលើកយកមកនិយាយនៅក្នុងកិច្ចពិភាក្សារបស់យើងនៅពេលខាងមុខ ហើយជួនកាលលើកយកមកនិយាយជាសាធារណៈទៀតផង ។ ទោះបីជាខ្ញុំនឹងមិនបដិសេធថាវាជារឿងនយោបាយក៏ដោយ ក៏ខ្ញុំត្រូវតែបញ្ជាក់ថា អំពើឃោរឃៅរបស់ខ្មែរក្រហមគឺមានលក្ខណៈផ្សេងពីបញ្ហានេះ ។ មិនតែប៉ុណ្ណោះ សំបុត្រដែលសម្តេច ហ៊ុន សែន បានចុះហត្ថលេខានៅក្នុងខែមិថុនា ឆ្នាំ១៩៩៧ គឺមានលក្ខណៈច្បាស់លាស់ទាំងអំពីពេលវេលានិងបទឧក្រិដ្ឋកម្មដែលនឹងត្រូវដោះស្រាយ ។ ការពង្រីកវិសាលភាពគឺជារបៀបមួយដែលនឹងមិននាំមកនូវលទ្ធផលចំពោះបញ្ហាទាំងមូលឡើយ ។

នៅចុងបញ្ចប់នៃការពិភាក្សាពិសេសនៅខែឧសភា ឆ្នាំ១៩៩៨ សម្តេច ហ៊ុន សែន ហាក់ដូចជាទាញសន្និដ្ឋានថា គួរតែកម្រិតអំឡុងពេលត្រឹមតែពីខែមេសា ឆ្នាំ១៩៧៥ ដល់ខែមករា ឆ្នាំ១៩៧៩ បានហើយ ។

## ក្រុមអ្នកជំនាញការ

ខណៈដែលសម្តេច ហ៊ុន សែន បានក្រសោបមេដឹកនាំដែលចុះចូលមួយរូប បានធ្វើឲ្យមានសម្តីចំអកឡកឡឺយពីសំណាក់អ្នក

នយោបាយប្រឆាំង នៅក្នុងអំឡុងពេលនៃយុទ្ធនាការបោះឆ្នោតនាខែមិថុនា-កក្កដា ឆ្នាំ១៩៩៨ ។ នៅពេលជាមួយគ្នានេះដែរ គណបក្សប្រជាជនចោទថា សម្ដេចក្រុមព្រះ នរោត្ដម រណឫទ្ធិ មានទំនាក់ទំនងខ្លះដែរជាមួយនឹងកម្លាំងខ្មែរក្រហមដែលនៅសេសសល់មួយចំនួនក្រោមបញ្ជារបស់ តាម៉ុក និង ខៀវ សំផន ។ ចំណុចនេះត្រូវបានលើកយកមកបរិយាយនៅក្នុងការឃោសនាគ្រោតគ្រាតរបស់គណបក្សនយោបាយៈ ទាំងសម្ដេចក្រុមព្រះ និងលោក សម រង្ស៊ី ត្រូវបានចោទថា មានការសហការគ្នាជាមួយនឹងខ្មែរក្រហម ។

អន្តរទូតនៅទីក្រុងភ្នំពេញមានការចាប់អារម្មណ៍យ៉ាងខ្លាំងលើបញ្ហាខ្មែរក្រហម ។ នៅក្នុងអំឡុងបេសកកម្មផ្សេងៗ ខ្ញុំបានជួបអ្នកទាំងនោះជាបុគ្គលឬជាក្រុម ដើម្បីផ្ដល់ព័ត៌មានដែលនិយាយតែអំពីកិច្ចប្រជុំរបស់ខ្ញុំតែប៉ុណ្ណោះ ។ មានពេលខ្លះខ្ញុំក៏ឈប់សំចតនៅទីក្រុងបាងកកមួយរយៈដើម្បីសន្និបព័ត៌មានដល់អគ្គរដ្ឋទូតនានាដែលចាំក្ដាប់សភាពការណ៍កម្ពុជានៅទីនោះ ។ តាំងពីការចាប់ផ្ដើមដំបូងមក ខ្ញុំបានទទួលផលប្រយោជន៍ពីការផ្លាស់ប្ដូរ(យោបល់)ជាមួយប្រទេសជប៉ុននិងប្រទេសផ្សេងៗទៀតនៅភូមិភាគអាស៊ីភាគអគ្នេយ៍ ។ នៅក្នុងខែឧសភា ឆ្នាំ១៩៩៨ ខ្ញុំបានដាក់ប្រធានបទនេះជូនជាផ្លូវការចំពោះប្រធាន "អាស៊ានត្រយកា"ដែលជារដ្ឋមន្ត្រីការបរទេសហ្វីលីពីន គឺលោក ស៊ីអាហ្សូន ។ លោកអនុរដ្ឋមន្ត្រីការបរទេសថៃ លោក សុខុំហាន ក៏សម្ដែងការអារម្មណ៍របស់លោកលើបញ្ហានេះដែរ ។

នៅក្នុងខែកក្កដា ឆ្នាំ១៩៩៨ លោកអគ្គលេខាធិការអង្គការសហប្រជាជាតិបានតែងតាំងក្រុមអ្នកជំនាញការមួយក្រុមដែលមាននិយាយនៅក្នុងសេចក្ដីសម្រេចរបស់មហាសន្និបាតឆ្នាំ១៩៩៧ ។ លោក នីនាន ស្ទីហ្វិន (មកពីប្រទេសអូស្ត្រាលី) លោករ៉ាជស៊ូម័រ ឡាឡា (មកពីប្រទេសម៉ូរីទី) លោកសាស្ត្រាចារ្យ ស្ទីវ រ៉ាត់ន័រ (មកពីសហរដ្ឋអាមេរិក) ត្រូវបានស្នើឲ្យៈ ក) វាយតម្លៃភ័ស្តុតាងដែលមានស្រាប់ក្នុងគោលបំណងធ្វើសេចក្ដីសម្រេចទៅលើសារជាតិនៃបទឧក្រិដ្ឋដែលត្រូវបានប្រព្រឹត្តឡើងដោយមេដឹកនាំខ្មែរក្រហមនៅក្នុងអំឡុងឆ្នាំ១៩៧៥-១៩៧៩ ខ) វាយតម្លៃក្រោយពីការពិគ្រោះយោបល់ជាមួយនឹងរដ្ឋាភិបាលនានាដែលពាក់ព័ន្ធ អំពីលទ្ធភាពក្នុងការនាំយកមេដឹកនាំខ្មែរក្រហមមកកាន់តុលាការដើម្បីជំនុំជម្រះទោស ការចាប់ខ្លួន ការឃុំខ្លួន និងបត្យាប័នឬដាក់ចូលក្នុងដែនសមត្ថកិច្ចព្រហ្មទណ្ឌដែលត្រូវបានបង្កើតរួចហើយ និង គ) ស្វែងរកជម្រើសនាំមេដឹកនាំខ្មែរក្រហមមកកាត់ក្ដីក្នុងដែនសមត្ថកិច្ចជាតិឬអន្តរជាតិ ។

ក្រុមអ្នកជំនាញការនេះបានជួបប្រជុំនៅទីក្រុងញូវយ៉កក្នុងខែសីហា ដើម្បីទទួលសេចក្ដីរាយការណ៍សង្ខេបពីខ្ញុំនិងអគ្គលេខាធិការដ្ឋាន ហើយដើម្បីពិភាក្សាជាមួយគណៈប្រតិភូអង្គការសហប្រជាជាតិ ។ ដោយសារមានភាពច្របូកច្របល់ផ្នែកនយោបាយនៅក្នុងប្រទេសកម្ពុជាក្រោយពីការបោះឆ្នោតក្នុងខែកក្កដា ខ្ញុំក៏បានសម្រេចចិត្តផ្អាកបេសកកម្មមកភ្នំពេញមួយរយៈ រហូតដល់ថ្ងៃទី១៤-២៨ ខែវិច្ឆិកា ទើបត្រឡប់មកកម្ពុជាសាជាថ្មី ។ ពេលនោះក្រុមអ្នកជំនាញការក៏ជួបជាមួយមន្ត្រីរដ្ឋាភិបាលតំណាងតុលាការ ក្រុមអង្គការក្រៅរដ្ឋាភិបាល អន្តរទូតនានា និងអ្នកជំនាញការមួយចំនួនទៀត ។ ក្រុមអ្នកជំនាញការបានមកធ្វើទស្សនកិច្ចនៅមជ្ឈមណ្ឌលឯកសារកម្ពុជា បណ្ណសារជាតិ និងសារមន្ទីរទួលស្លែង (អតីតសាលារៀននៅទីក្រុងភ្នំពេញដែលត្រូវបានខ្មែរក្រហមយកធ្វើជាកន្លែងសួរចម្លើយ ហើយយ៉ាងហោចណាស់មានមនុស្សប្រមាណមួយម៉ឺនប្រាំមួយពាន់អ្នកដែលត្រូវបាននាំមកសួរចម្លើយនិងក្រោយមកយកទៅសម្លាប់) ។ ក្រុមអ្នកជំនាញការទាំងបីរូបត្រូវបានអមដំណើរដោយតំណាងមួយរូបមកពីការិយាល័យទទួលបន្ទុកផ្នែកច្បាប់ក៏ពិតមែន តែក្រុមនេះធ្វើការរៀងៗខ្លួន ។ ដំបូន្មានរបស់ខ្ញុំចំពោះក្រុមទាំងនេះគឺស្នើឲ្យស្វែងរកដោយយកចិត្តទុកដាក់នូវលទ្ធភាពបង្កើត"សមាសភាពកម្ពុជា"ដ៏រឹងមាំក្នុងដំណើរការនេះ រួមបញ្ចូលទាំងជម្រើសបង្កើតតុលាការនៅក្នុងប្រទេសកម្ពុជាខ្លួនឯងផ្ទាល់ ។ ក្រុមអ្នកជំនាញការក៏ជួបគ្នាដោយឡែកម្ដងទៀតនៅខែមករា ហើយបានដាក់ជូនរបាយការណ៍របស់ខ្លួនដល់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិនៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ១៩៩៩ ។

ក្រុមអ្នកជំនាញការនេះទាញសេចក្ដីសន្និដ្ឋានថា ភ័ស្តុតាងដែលប្រមូលបានមកដល់ពេលនេះបង្ហាញថា ឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរ

ត្រូវបានប្រព្រឹត្តឡើងទាំងក្រោមច្បាប់អន្តរជាតិនិងច្បាប់ជាតិ ហើយថាមានភ័ស្តុតាងគ្រប់គ្រាន់ដើម្បីបញ្ជាក់អំពីដំណើរការនីតិវិធីជម្រះក្តីប្រឆាំងនឹងមេដឹកនាំខ្មែរក្រហមចំពោះបទឧក្រិដ្ឋដែលក្រុមមេដឹកនាំទាំងនោះបានប្រព្រឹត្ត មានដូចជា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្រ្គាម ការបង្ខំឲ្យធ្វើការងារដោយទារុណ ឧក្រិដ្ឋកម្មប្រឆាំងនឹងបុគ្គលដែលត្រូវបានការពារដោយច្បាប់អន្តរជាតិនិងឧក្រិដ្ឋកម្មមួយចំនួនទៀតក្រោមច្បាប់របស់ប្រទេសកម្ពុជា ។

អ្នកជំនាញការទាំងនេះបានរាយការណ៍ថា លទ្ធភាពក្នុងការចាប់ខ្លួនមេដឹកនាំខ្មែរក្រហមអាស្រ័យទៅលើសមត្ថភាព និងឆន្ទៈរបស់រដ្ឋាភិបាលក្នុងការចាប់ខ្លួនជនសង្ស័យនិងការធ្វើបត្យាប័ន ។ ចុងបញ្ចប់អ្នកជំនាញការបានសន្និដ្ឋានថា រដ្ឋាភិបាលកម្ពុជាមានសមត្ថភាពចាប់ខ្លួនមេដឹកនាំខ្មែរក្រហមបាននៅលើទឹកដីរបស់ខ្លួនកាន់កាប់ ដោយទីតាំងរបស់ខ្មែរក្រហមត្រូវបានស្គាល់ ហើយខ្មែរក្រហមមិនមានការការពារខ្លួនទៀតទេ ។ នៅក្នុងកិច្ចប្រជុំរបស់អ្នកជំនាញការនៅខែវិច្ឆិកា ឆ្នាំ១៩៩៨ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានសម្តែងសុឆន្ទៈ និងរៀបចំរួចជាស្រេចក្នុងការចាប់ខ្លួនបុគ្គលដែលត្រូវបានចោទប្រកាន់ដោយព្រះរាជអាជ្ញាឯករាជ្យរបស់តុលាការនេះ ។ រដ្ឋាភិបាលថៃក៏បានបញ្ចេញជំហរប្រកបដោយសុឆន្ទៈដូចគ្នានេះដែរ ។

ក្រុមអ្នកជំនាញការបានវិភាគទៅលើជម្រើសផ្លូវច្បាប់ ដើម្បីនាំយកមេដឹកនាំខ្មែរក្រហមមកជំនុំជម្រះទោស ។ ជម្រើសនេះមាន÷ ក) សាលាក្តីបង្កើតឡើងក្រោមច្បាប់កម្ពុជានៅក្នុងតុលាការក្នុងស្រុក ខ) សាលាក្តីបង្កើតឡើងដោយក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ឬមហាសន្និបាតអង្គការសហប្រជាជាតិក្នុងទម្រង់ជាតុលាការអន្តរជាតិពិសេសមួយ គ) ជម្រើសចម្រុះនៃតុលាការកម្ពុជាក្រោមការគ្រប់គ្រងរបស់អង្គការសហប្រជាជាតិ ឃ) តុលាការអន្តរជាតិបង្កើតឡើងដោយអនុសញ្ញាច្រើន និង ង) តុលាការនៅក្នុងប្រទេសទីបី ។

ដោយបានគិតពិចារណាអំពីជម្រើសនេះ ក្រុមអ្នកជំនាញការឲ្យយោបល់ថា ដើម្បីឆ្លើយតបទៅនឹងសំណើរបស់រដ្ឋាភិបាលកម្ពុជា អង្គការសហប្រជាជាតិគួរតែបង្កើតតុលាការអន្តរជាតិពិសេសមួយដើម្បីកាត់សេចក្តីកម្មាភិបាលខ្មែរក្រហមអំពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងអំពើប្រល័យពូជសាសន៍ ដែលត្រូវបានប្រព្រឹត្តឡើងនៅក្នុងអំឡុងពេលចាប់ពីថ្ងៃ១៧ មេសា ១៩៧៥ ដល់ថ្ងៃ៧ មករា ឆ្នាំ១៩៧៩ ។ ក្រុមអ្នកជំនាញការនេះឲ្យយោបល់ទៀតថាក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិគួរតែបង្កើតតុលាការ ឬបើក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិមិនបង្កើត គួរឲ្យអង្គមហាសន្និបាតអង្គការសហប្រជាជាតិបង្កើតក៏បានដែរ ។ ក្រុមអ្នកជំនាញការក៏បានស្នើទៀតថា ឲ្យព្រះរាជអាជ្ញានៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីនិងសម្រាប់ប្រទេសរ៉ាន់ដាមកធ្វើជាព្រះរាជអាជ្ញានៅក្នុងតុលាការថ្មីនេះ ដោយមានព្រះរាជអាជ្ញារងមានបន្ទុកទទួលខុសត្រូវដោយផ្ទាល់ចំពោះតុលាការនេះ ។

មិនតែប៉ុណ្ណោះ អ្នកជំនាញការក៏បានស្នើទៀតថា តុលាការរួមទាំងការិយាល័យរបស់ព្រះរាជអាជ្ញារង គួរតែត្រូវបានបង្កើតនៅក្នុងរដ្ឋមួយនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក ប៉ុន្តែមិននៅក្នុងប្រទេសកម្ពុជាទេ ហើយថា ព្រះរាជអាជ្ញាគួរតែបង្កើតការិយាល័យស៊ើបអង្កេតមួយនៅក្នុងប្រទេសកម្ពុជា ហើយអង្គការសហប្រជាជាតិ ដែលសហការជាមួយនឹងរដ្ឋាភិបាលកម្ពុជា គួរតែរៀបចំឲ្យមានការផ្សព្វផ្សាយដំណើរការជម្រះក្តីនៅក្នុងប្រទេសកម្ពុជាតាមរយៈវិទ្យុនិងទូរទស្សន៍ដោយគ្មានការគាបសង្កត់ ។

មានការឲ្យយោបល់មួយទៀតពីសំណាក់ក្រុមអ្នកជំនាញដែលថា ចំពោះជាគោលនយោបាយសម្រាប់ព្រះរាជអាជ្ញាវិញ ព្រះរាជអាជ្ញាកំណត់ការស៊ើបអង្កេតរបស់ខ្លួនចំពោះបុគ្គលទាំងឡាយដែលទទួលខុសត្រូវចំពោះការរំលោភដ៏ធ្ងន់ធ្ងរបំផុតទៅលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ ។ គោលការណ៍នេះនឹងរួមបញ្ចូលទាំងមេដឹកនាំជាន់ខ្ពស់ដែលមានការទទួលខុសត្រូវចំពោះការរំលោភក៏ដូចជាកម្មាភិបាលថ្នាក់ក្រោមៗដែលត្រូវបានចោទប្រកាន់ដោយផ្ទាល់នូវចំពោះមុខឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរបំផុតនេះ ។

ក្រុមអ្នកជំនាញការបានសង្កត់ធ្ងន់ថា ឈ្មោះរបស់មន្ត្រីរដ្ឋាភិបាលថ្នាក់លើ និងមន្ត្រីរបស់បក្សនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

អាចមិនស៊ីគ្នាជាមួយនឹងឈ្មោះមនុស្សដែលមានការទទួលខុសត្រូវខ្ពស់បំផុតចំពោះការរំលោភដ៏ធ្ងន់ធ្ងរទៅលើសិទ្ធិមនុស្ស ។ មេដឹកនាំរដ្ឋាភិបាលមួយចំនួនអាចត្រូវបានដកចេញពីការដឹងឮ និងការធ្វើសេចក្តីសម្រេចចិត្តផ្សេងៗ ហើយអ្នកដទៃទៀតដែលមិនមាននៅក្នុងបញ្ជីឈ្មោះថ្នាក់ដឹកនាំជាន់ខ្ពស់ អាចដើរតួយ៉ាងសំខាន់ក្នុងបញ្ហានេះ ។

ក្រុមអ្នកជំនាញការសរសេរថា នេះហាក់ដូចជាមានលក្ខណៈពិតទាក់ទងទៅនឹងមេដឹកនាំមួយចំនួននៅថ្នាក់ភូមិភាគ ក៏ដូចជាមន្ត្រីទទួលបន្ទុកខាងមន្ទីរធ្វើទារុណកម្មនិងសួរចម្លើយ ដូចជានៅទួលស្លែងជាដើម ។ ក្រុមអ្នកជំនាញបានឲ្យយោបល់ទៀតថា ព្រះរាជអាជ្ញាគួរតែធ្វើការសម្រេចចិត្តរបស់ខ្លួនដោយប្រុងប្រយ័ត្ន ទាក់ទងនឹងការស៊ើបអង្កេត ដីកាចោទប្រកាន់ និងការជំនុំជម្រះក្តី ដើម្បីគិតគូរអំពីទិសដៅពីរ ពោលគឺការដាក់ឲ្យបុគ្គលទទួលខុសត្រូវចំពោះមុខច្បាប់ និងការបង្រួបបង្រួមជាតិនៅក្នុងប្រទេសកម្ពុជា ។

យោបល់មួយទៀតថា អង្គការសហប្រជាជាតិដែលមានកិច្ចសហប្រតិបត្តិការជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជានិងអង្គការក្រៅរដ្ឋាភិបាល គួរជំរុញឲ្យដំណើរការឆ្លុះបញ្ចាំងនៅក្នុងចំណោមប្រជាជនកម្ពុជា ដើម្បីកំណត់អំពីលទ្ធភាពប៉ងប្រាថ្នា និងប្រសិនបើសមស្របអំពីគំរូយន្តការរៀបរាប់ការពិត ក្នុងគោលបំណងបង្ហាញអំពីរូបភាពរឹតតែពេញលេញថែមទៀតស្តីពីអំពើឃោរឃៅកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

## ប្រតិកម្មអវិជ្ជមានរបស់រដ្ឋាភិបាល

នៅក្នុងខណៈដែលក្រុមអ្នកជំនាញការកំពុងតែធ្វើការទៅលើអនុសាសន៍របស់ខ្លួន មានការចុះចូលថែមទៀតត្រូវបានប្រកាសឡើង ។ នៅចុងខែធ្នូ ឆ្នាំ១៩៩៨ សម្តេច ហ៊ុន សែន បានទទួលមេដឹកនាំខ្មែរក្រហមសំខាន់ៗពីររូបទៀតគឺ នួន ជា និង ខៀវ សំផន ក្នុងគេហដ្ឋានរបស់សម្តេចនៅជាយក្រុងភ្នំពេញ ។ អៀង សារី បានចូលរួមនៅក្នុងឱកាសនោះ ហើយមើលទៅហាក់ដូចជាធ្វើជាអន្តរការីយ៉ាងដូច្នេះដែរ ។ នៅក្នុងគំនិតជានិមិត្តរូប នេះគឺជាព្រឹត្តិការណ៍ដ៏សំខាន់នៅក្នុងប្រវត្តិសាស្ត្រទំនើបរបស់កម្ពុជា ។ ថ្វីបើគ្មានមន្ទិលសង្ស័យថាបុរសចំណាស់ទាំងពីររូបនេះបានចុះចាញ់និងចូលមកសម្តែងការគោរពរាប់អានយ៉ាងណាក៏ដោយ សម្តេច ហ៊ុន សែន ហាក់ប្រែក្លាយឱកាសនោះឲ្យទៅជាឱកាសបង្រួបបង្រួមជាតិនិងការអត់ឱនឲ្យគ្នាទៅវិញ ។

សម្តីរបស់សម្តេច ហ៊ុន សែន មានភាពចម្រូងចម្រាស និងថែមទាំងធ្វើឲ្យមន្ត្រីមួយចំនួនរបស់គណបក្សប្រជាជនមានការភ្ញាក់ផ្អើលទៀតផង ។ ន័យធៀបមួយដែលសម្តេចយកមកប្រើគឺ «ដល់ពេលដែលត្រូវជីកកប់អតីតកាលចោលហើយ» ។ នេះដូចជាខុសគ្នាជាមួយនឹងការបង្កើតតុលាការ និងគោលការណ៍យុត្តិធម៌ដែលសម្តេចធ្លាប់បានគាំទ្រ ។

នេះជាការផ្លាស់ប្តូរខាងផ្លូវចិត្តទេដឹង? ឬក៏មានការគិតគូរស៊ីសង្វៃថ្នូររួចហើយអំពីការចុះចូលទាំងនេះ?

ឥឡូវនេះ សម្តេច ហ៊ុន សែន បានសង្កត់ធ្ងន់ទៅលើសារសំខាន់នៃការបញ្ចប់សង្គ្រាម ដែលជាការអាចកើតមានផលប៉ះទង្គិចរវាងការជំនុំជម្រះក្តីនិងសន្តិភាព ។ នៅពេលដែលខ្ញុំបានជួបសម្តេចនៅចុងខែមករា ឆ្នាំ១៩៩៩ សម្តេចបានប្រគល់ជូនខ្ញុំនូវអនុស្សារណៈសម្រាប់ប្រគល់ជូនលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ដែលក្នុងនោះមានលើកបញ្ហាស្តីអំពីការថែរក្សាសន្តិភាពផងនិងស្វែងរកយុត្តិធម៌ផង ។ អនុស្សារណៈនេះក៏និយាយយោងទៅដល់លទ្ធភាពនៃសេចក្តីប៉ងប្រាថ្នាក្នុងការដោះស្រាយបញ្ហាឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តឡើងមុនឆ្នាំ១៩៧៥ និងក្រោយឆ្នាំ១៩៧៩ ។ គោលបំណងនៃអនុស្សារណៈនេះគឺមិនច្បាស់លាស់ឡើយសម្រាប់រូបខ្ញុំ ។ នៅពេលដែលខ្ញុំស្នើសុំឲ្យមានការស្រាយបំភ្លឺ សម្តេចមានប្រសាសន៍ថា ចំណុចទាំងនេះគ្រាន់តែជាផ្នែកបន្ថែមសម្រាប់ឲ្យក្រុមអ្នកជំនាញការគិតពិចារណា ប៉ុន្តែមិនគួរត្រូវបានយល់ឃើញថាជាជំហរផ្លាស់ប្តូរមួយឡើយ ហើយសំបុត្រចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ១៩៩៧ នៅតែមានសុពលភាពនៅឡើយទេ ។ ការសាកល្បងនេះនឹងមានប្រតិកម្មចំពោះរបាយការណ៍របស់ក្រុមអ្នកជំនាញការដែលត្រូវបានផ្ញើជូនចំពោះក្រុមបេសកកម្មកម្ពុជានៅអង្គការសហប្រជាជាតិនៅទីក្រុងញូវយ៉កនៅថ្ងៃទី២៣ ខែកុម្ភៈ ។ **(នៅមានត)**

**ថូម៉ាស់ ហាម៉ាប៊ឺក**

# ទីបញ្ចប់នៃបដិវត្តន៍

**(តចប់)** ប៉ុន្តែគួរឲ្យហួសចិត្តនិងស្មានមិនដល់ថា នៅពេលដែលការបែងចែកអំណាចកំពុងតែមានលក្ខណៈសំខាន់ក្នុងការបន្តឲ្យមានលក្ខខណ្ឌងាយស្រួលចុះចូលរបស់ចលនាខ្មែរក្រហម ក៏មានការអភិវឌ្ឍនិងការវិវត្តយ៉ាងខ្លាំងពេញទំហឹងនូវការបំបែកខ្លួននៅក្នុងជួររដ្ឋាភិបាលខ្លួនឯងតែម្តង ។ ភាពតានតឹងរវាងសម្តេចក្រុមព្រះនរោត្តម រណឫទ្ធិ និងសម្តេច ហ៊ុន សែន នៅដើមឆ្នាំ១៩៩៦បានធ្វើឲ្យអ្នកទាំងពីរទៅទាក់ទងខ្មែរក្រហម ពោលគឺអ្នកប្រឆាំងនឹងជនក្បាលរឹងមុននិងក្រោយការបះបោរនេះ ក្នុងគោលបំណងគាំទ្រតំណែងរបស់ខ្លួន និងធ្វើឲ្យតំណែងរបស់ដៃគូចម្រុះចុះខ្សោយ ។ ការប្រកួតប្រជែងបានផ្តល់ផលប្រយោជន៍ដល់សមាជិកខ្មែរក្រហមនិងបំផ្លាញចោលនូវចលនាខ្លួនឯងផ្ទាល់ ។ ភាគីនីមួយៗបានផ្តល់នូវលក្ខខណ្ឌគួរឲ្យទាក់ទាញ ដូចជាឲ្យបន្តគ្រប់គ្រងកងទ័ព ធនធានផ្សេងៗនិងទឹកដី ឱកាសផ្នែកហិរញ្ញវត្ថុ មុខតំណែងជាន់ខ្ពស់ក្នុងវិស័យយោធាឬស៊ីវិលទាំងអស់នេះមិនដែលនិយាយនៅក្នុងកិច្ចចរចាម្តងណាឡើយនៅក្នុងឆ្នាំ១៩៩៣-១៩៩៤ ។ ភាគីទាំងពីរដំណើរការចរចាតែរៀងៗខ្លួនដោយប្រើទំនាក់ទំនងដែលមានចរិតប្រវត្តិសាស្ត្រនិងផ្ទាល់ខ្លួនព្រមទាំងរកមុខតំណែងសម្រាប់អ្នកចុះចូលថ្មីៗទៀតផង ។ គណបក្សហ៊្វុនស៊ិនប៉ិចដែលបានរៀបចំខ្លួនចរចាជាមួយនឹងកម្ពុជាប្រជាធិបតេយ្យទាំងមូលព្រមទាំងមេបញ្ជាការម្នាក់ៗនោះបានទទួលផលប្រយោជន៍ច្រើនជាងមុន មកពីការទាក់ទាញផ្នែកនយោបាយនិងបទពិសោធន៍រួមគ្នាមុនឆ្នាំ១៩៩១ ។ ប៉ុន្តែសម្តេច ហ៊ុន សែន មានបំណងចង់បំបែកកម្ពុជាប្រជាធិបតេយ្យនិងនាំយកអ្នកចុះចូលឲ្យបានច្រើនតាមដែលអាចធ្វើទៅបាន ដោយខាងគណបក្សប្រជាជនអាចផ្តល់នូវលក្ខណៈច្រើនជាងនេះទៅទៀត ដូចជាការធានាសន្តិសុខ ទ្រព្យសម្បត្តិ មុខតំណែង និងសិទ្ធិទទួលបានការលើកលែងទោសដូចជាចំពោះមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យដែលអស់ឥទ្ធិពលចាប់តាំងពីឆ្នាំ១៩៧៩ ពោលគឺ អៀង សារី និង កែ ពក ។

**ឆ្នាំ១៩៩៦-៩៨: ក្រុមផ្តាច់ខ្លួនរបស់ចលនានេះ**

ដោយសារតែការវិវត្តន៍ទាំងអស់នេះហើយ ទើបនាំឲ្យមានការផ្តាច់ខ្លួនយ៉ាងច្រើនសន្ធឹកសន្ធាប់នៅក្នុងចំណោមខ្មែរក្រហម ។ នៅពាក់កណ្តាលឆ្នាំ១៩៩៦ ដោយភ័ន្តច្រឡំនឹងល្បិចកលរបស់ក្រុមក្បាលរឹងនឹងសង្គ្រាមមិនចេះចប់ និងមិនអាចឈ្នះបានកម្មាភិបាលថ្នាក់ដឹកនាំនៅភ្នំម៉ាឡៃនិងប៉ៃលិនបានទាត់ចោលទាំងការបញ្ជាឲ្យយកទ្រព្យសម្បត្តិទៅដាក់ក្រោមការកាន់កាប់រួមនិងទាំង សុន សេន ទៀតផង ដែលត្រូវបានចាត់តាំងនៅមូលដ្ឋានឲ្យជំរុញកម្មាភិបាលទាំងនេះ ។ ការបះបោរជាប្រវត្តិសាស្ត្របានចាប់ផ្តើមឡើងរវាងតំបន់ទាំងពីរនេះ ហើយដែលបានទាមទារឲ្យមាននយោបាយតាមបែបសេរីនិយមថែមទៀត លែងគស្ស៊ូប្តូរនឹង សុន សេន ហើយលែងស្ថិតនៅក្រោមបញ្ជារបស់ សុន សេន និងទាមទារអំណាចផ្នែកយោធា សេដ្ឋកិច្ច ដើម្បីក្រោកឈរឡើងប្រឆាំងនឹងថ្នាក់ដឹកនាំ ។ នៅពេល ប៉ុល ពត គាំទ្រ សុន សេន ហើយមិនគាំទ្រពួកខ្ទាមនោះការបះបោរបានប្រែក្លាយពីក្រុមប្រឆាំងនឹងបទបញ្ជានិងថ្នាក់ដឹកនាំមកជាក្រុមប្រឆាំងនឹងចលនាខ្លួនឯង ។

នៅពេលដែលការបះបោរជាប្រវត្តិសាស្ត្របានចាប់ផ្តើមនៅក្នុងតំបន់ដែលមានទំនាក់ទំនងជាមួយនឹង អៀង សារី ហើយដែលមានប្រតិកម្មចំពោះសកម្មភាពរបស់ សុន សេន ភាពរង្គោះរង្គើនានាបានរាលដាលយ៉ាងឆាប់រហ័សទៅដល់អង្គភាពដែលមានទំនាក់ទំនងជាយូរណាស់មកហើយជាមួយ ប៉ុល ពត នួន ជា និង តាម៉ុក រហូតនាំឲ្យមានការរត់ចោលជួរយ៉ាងច្រើននៅភាគខាងលិចនិងភាគនិរតីនៃប្រទេសកម្ពុជា (ទោះបីជាមួយក្រុមតូចចូលរួមជាមួយ តាម៉ុក ដែលត្រូវបានធ្វើឲ្យចុះញ៉មសាជាថ្មីនៅឆ្នាំ១៩៩៧ក៏ដោយ) ។ ដោយជួបប្រទះនូវសភាពការណ៍យោធាដ៏ស្រួចស្រាល់ និងផ្តល់នូវការទាក់ទាញដែលមានលក្ខណៈប្រកួតប្រជែងគ្នារវាងគណបក្សប្រជាជននិងគណបក្សហ៊្វុនស៊ិនប៉ិចបានធ្វើឲ្យខ្មែរក្រហមបែកខ្ញែកគ្នារតាត់រតាយអស់ ។ ក្នុងអំឡុងពេលនោះ ផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុ គំនុំផ្ទាល់ខ្លួន មហិច្ឆតា

ទំនាស់គ្នា និងទំនោរនយោបាយផ្សេងៗគ្នា បានបង្ហាញឲ្យឃើញថាមានសារសំខាន់ជាងមរតករួមដែលបានមកពីការតស៊ូដ៏យូរអង្វែងរបស់ខ្លួនទៅទៀត ។ កូនចៅខ្មែរក្រហមដែលចុងក្រោយចុះចូលជាមួយនឹងគណបក្សទាំងពីរ នៅក្នុងខណៈមានការបះបោរយ៉ាងធំនៅក្នុងខែសីហា ឆ្នាំ១៩៩៦ ដែលធ្វើនៅប៉ៃលិននិងម៉ាឡៃ បានរិះរកវិធីធ្វើឲ្យបក្សទាំងពីរក្រឡុកគ្នាទៅវិញទៅមកនិងការពារនូវស្វ័យភាពរបស់ខ្លួន ។ ចំពោះក្រុមក្បាលរឹងដែលនៅសេសសល់មួយចំនួនតូចនៅឆ្នាំ១៩៩៧ បានប្រមូលផ្តុំគ្នារស់នៅក្នុងខេត្តមួយចំនួននៅភាគខាងជើងភាគឦសាន និងមូលដ្ឋានសំខាន់ៗដែលត្រូវបានកាន់កាប់ស្ទើរតែទាំងស្រុងទៅហើយនោះ ។ ប៉ុន្តែកត្តាដូចគ្នាជាច្រើនបាននាំទៅដល់ការដួលរលំនៃចលនាកម្ពុជាប្រជាធិបតេយ្យនៅគ្រប់ទីកន្លែង និងបេះតែបន្តកម្មេចមូលដ្ឋានយុទ្ធសាស្ត្រចុងក្រោយមួយនេះ ។ ជាងនេះទៅទៀត ថ្នាក់ដឹកនាំដែលមិនបានបញ្ចូលឈាមថ្មី ត្រូវបានចាត់ទុកជា "ថ្នាក់ទីពីរ" ក្នុងចំណោមមេដឹកនាំនានាដែលចុះចូលមកខាងរដ្ឋាភិបាលត្រូវតែប្រឈមមុខនឹងបញ្ហាថាតើអ្នកណាជាអ្នកធ្វើឲ្យចលនាដ៏គ្រោះថ្នាក់បែបនេះ ធ្លាក់ចុះហើយត្រូវដោះស្រាយតាមនយោបាយយ៉ាងដូចម្តេចជាមួយនឹងផលវិបាកទាំងនេះក្នុងខណៈដែលជ័យជម្នះផ្នែកយោធាលែងអាចទៅរួចហើយនោះ ។




សុខភាពរបស់ ប៉ុល ពត ដែលធ្លាក់ក្នុងសភាពទ្រុឌទ្រោមក៏តម្រូវឲ្យមានដំណោះស្រាយជាបន្ទាន់ចំពោះបញ្ហាអ្នកឡើងជំនួសតំណែង ។ ភាពតានតឹងទាំងអស់នេះមានលក្ខណៈកាន់តែធ្ងន់ធ្ងរឡើង ដោយសារតែកាលពីដំបូងវិធានការដឹកនាំទាំងអស់ស្ថិតនៅតែមួយកន្លែង ។ ការបែងចែកទឹកដីទទួលខុសត្រូវកាលពីមុនបានបន្ធូរភាពតានតឹង ហើយឥឡូវនេះលែងមានទៀតហើយ ។ ពីមុន តាម៉ុក កាន់កាប់អន្លង់វែង ហើយ ប៉ុល ពត កាន់កាប់ចលនាទាំងមូល ឥឡូវចលនាទាំងមូលគឺនៅអន្លង់វែង ។

ដោយមានការជំរុញឲ្យឆ្លើយសំណួរដ៏សំខាន់ទាំងនេះដែលលើកឡើងដោយគណបក្សហ៊ុនសិនប៉ិចដែលទទូចហើយទទូចទៀតសូមឲ្យមានការចងសម្ព័ន្ធភាពចេញមុខច្បាស់លាស់នោះ ថ្នាក់ដឹកនាំជាន់ខ្ពស់ខ្មែរក្រហមត្រូវដួលរលំដោយភាពប្រទូសរ៉ាយ ។ ប៉ុល ពត បានទម្លាក់កំហុសទៅលើ សុន សេន (អ្នកទទួលការចាត់តាំងឲ្យជំនួស ប៉ុល ពត នៅឆ្នាំ១៩៨៥) និង នួន ជា (ជាបងទីពីរយូរអង្វែងណាស់មកហើយ) ថាជាអ្នកធ្វើឲ្យមានការរលំរលាយនៅភាគបស្ចិមប្រទេសដែលខ្លួនទទួលខុសត្រូវតាំងពីឆ្នាំ១៩៩៤មក ។ ប៉ុល ពត ក៏បានស្តីបន្ទោសដល់ តាម៉ុក ដែរ (ត្រូវបានឡើងឋានៈជាបងទី២ ក្នុងឆ្នាំ១៩៩៤និងបញ្ជូនមកភាគបស្ចិមជាប្រតិភូរបស់ ប៉ុល ពត នៅក្នុងខែកក្កដា ឆ្នាំ១៩៩៧) ថាមិនបានការពារឬបង្ក្រាបការបះបោរនេះ ។ ដោយមូលហេតុនេះហើយបានជា ប៉ុល ពត ឃុំខ្លួនអ្នកទាំងបីនៅក្នុងផ្ទះ ហើយចេញមុខចាត់ការបញ្ហាដោយខ្លួនឯងផ្ទាល់ ។ ប៉ុល ពត បាន

តែងតាំងអតីតកូនចៅរបស់ សុន សេន ពីរនាក់ ឈ្មោះ សារឿន និង សាន ឲ្យកាន់កងទ័ពទាំងមូល ជាជាងប្រើ តាម៉ុក និងកូនចៅពីរបីនាក់របស់ផងខ្លួន ។ ក្នុងខណៈនោះដែរ សម្តេច ហ៊ុន សែន បានបន្តធ្វើឲ្យ ប៉ុល ពត មានគំនិតសង្ស័យតទៅទៀតដោយផ្តល់នូវឋានៈក្នុងរដ្ឋាភិបាលដល់សាច់ញាតិព្រមទាំងបក្ខពួករបស់ សុន សេន និង តាម៉ុក ក្នុងគោលបំណងបង្កើតទំនាក់ទំនងជាមួយបុគ្គលណាម្នាក់ក្នុងចំណោមអ្នកទាំងបីនាក់នេះ ។

ដោយជឿជាក់ថា សុន សេន និង តា ម៉ុក កំពុងរៀបដើងព្រួលដើម្បីក្បត់នឹងខ្លួន (នៅពេលដែលខ្លួនសង្ស័យថាអ្នកទាំងនេះបានព្យាយាមក្បត់នៅឆ្នាំ១៩៧៨) ប៉ុល ពត ដែលកំពុងតែមានជំងឺដុនដាបនោះ បានបញ្ជាឲ្យមានការបោសសម្អាតជាលើកចុងក្រោយមួយ ដែលលទ្ធផលសម្រេចបានតែ សុន សេន ម្នាក់ប៉ុណ្ណោះ ហើយ តាម៉ុក ត្រូវបានរួចខ្លួន ។ ផ្ទុយមកវិញ តាម៉ុក និងកូនចៅទេដែលឆក់បានឱកាសកាន់កាប់នោះ ។ ប៉ុល ពត និងមេបញ្ជាការដែលគាត់ពេញចិត្តត្រូវបានចាប់ខ្លួន និងដកចេញពីអំណាចនយោបាយ ។ ប៉ុល ពត បានឃុំខ្លួន តាម៉ុក និង នួន ជា នៅក្នុងផ្ទះ ប៉ុន្តែឥឡូវរឿងនេះបានជះត្រឡប់មកខ្លួនឯងវិញ ។ ប៉ុល ពត បានដឹងអំពីរសជាតិដែលខ្លួនមានជាប់ទាក់ទងនឹងការបោសសម្អាតអ្នកដែលក្បត់នឹងមាគ៌ាបក្ស នៅពេលដែលរឿងរ៉ាវបានកើតឡើងមកលើខ្លួនផ្ទាល់ ។

## គ្មានផ្លូវចេញ

ការស្វែងរកផលចំណេញខាងនយោបាយ ដែលបានមកពីការចាប់ខ្លួន ប៉ុល ពត និងក្រុមខ្មែរក្រហមដែលនៅសេសសល់ បានបញ្ចប់កិច្ចចរចាជាមួយនឹងគណបក្សហ៊ុនស៊ិនប៉ិច ដើម្បីចូលរួមក្នុងរណសិរ្សរួបរួមជាតិ រួចហើយបញ្ចប់ភាពឯកោផ្នែកនយោបាយ ។

នៅពេលមានព្រឹត្តិការណ៍ក្នុងខែកក្កដា ឆ្នាំ១៩៩៧ តាម៉ុក និង នួន ជា គ្មានភ្ញាក់ផ្អើលទេ គឺបានសង្ឃឹមថា ហេតុការណ៍នេះមានចរិតដូចក្នុងខែមីនា ឆ្នាំ១៩៧០ អ៊ីចឹងដែរ ហើយថារណសិរ្សរួបរួមជាតិដែលសហការរួមគ្នាជាមួយអ្នករាជានិយមនឹងទទួលបានជំនួយពីអន្តរជាតិ ការគាំទ្រពីមហាជន និងផលប្រយោជន៍ផ្នែកយោធាជាមិនខាន ។ ប៉ុន្តែពិភពលោកបេះតែរំកិលខ្លួនទៅមុខ ។ សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ មិនមែនជាសម្តេចព្រះនរោត្តម សីហនុទេ ។ ក្រោយពីសង្គ្រាមអស់រយៈពេល៣០ឆ្នាំ មានប្រជាជនតែមួយចំនួនតូចប៉ុណ្ណោះដែលបោះបង់ផ្ទះសម្បែងមកកាន់អាវុធច្បាំងដើម្បីផលប្រយោជន៍នយោបាយ ។ ក្រោយពីព្រឹត្តិការណ៍ខែកក្កដា ក្តីសង្ឃឹមទាំងអស់ដែលថា នឹងបានចូលប្រឡូកក្នុងនយោបាយសាជាថ្មីសម្រាប់កម្ពុជាប្រជាធិបតេយ្យត្រូវបានបញ្ចប់ ។ ប៉ុន្តែដោយគ្មានជំនួយយោធានិងជម្រកលាក់ខ្លួននៅក្នុងប្រទេសថៃដែលបានជួយឲ្យចលនានេះចាកផុតពីការលំបាកក្នុងទសវត្សរ៍ឆ្នាំ១៩៨០ កម្ពុជាប្រជាធិបតេយ្យ(ក៏ដូចជាគណបក្សហ៊ុនស៊ិនប៉ិច)ក៏មានឱកាសផ្នែកយោធាដែរ ។ ដោយខាងចិនដកខ្លួនចេញទៅហើយនោះ ក្តីសង្ឃឹមចុងក្រោយគឺអាស្រ័យលើលោកខាងលិចវិញ ។ តាម៉ុក ជាឧក្រិដ្ឋជនដ៏សាហាវនិងអស់សង្ឃឹមនោះ បានព្យាយាមអ៊ុតសន្លឹកបៀចុងក្រោយរបស់ខ្លួន ប៉ុន្តែជាការគួរឲ្យចង់សើច គាត់ត្រូវបានចាប់ខ្លួន ។ មានតែការជម្រះក្តី ប៉ុល ពត និងការស្លាប់របស់ ប៉ុល ពត ប៉ុណ្ណោះ (ដូចដែល ប៉ុល ពត បានទាយទុកជាយូរណាស់មកហើយ) ទើបអាចបំភ្លឺចំពោះសំណួរដែលកប់ទុកជាយូរមកហើយថាតើនរណាជាអ្នកទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅអំឡុងឆ្នាំ១៩៧៥-១៩៧៨ ។ តាម៉ុក បានជោគជ័យក្នុងការកៀងគរសកម្មភាពលោកខាងលិច ប៉ុន្តែមិនមែនតាមផ្លូវអ្វីដែលគាត់បានគិតទុកជាមុន ។

នៅពេលដែលនាវាលិចជ្រៅទៅក្នុងទឹកជាងពេលណាៗទាំងអស់នោះ កណ្តុរចុងក្រោយ ពោលគឺ “ជនក្បត់”ចុងក្រោយកំពុងតែរត់ប្រាសអាយុចេញទាំងភ័យស្ងន់ស្លោ ។ ទោះជាមានភក្តីភាពដាច់ខាតចំពោះគំនិតបដិវត្តន៍របស់ខ្លួន ឬគ្មានផ្លូវចេញយ៉ាងណាក៏ដោយ ក៏ តាម៉ុក និង នួន ជា គ្មានឆ្លើយតបចំពោះស្ថានភាពលំបាកដែលខ្លួនត្រូវតែសម្រេចចិត្តធ្វើនោះឡើយ ពីព្រោះអ្នកទាំងនេះគ្មានគំនិតនយោបាយផ្សេងក្រៅពីគំនិតដែលខ្លួនបានដើរតាមអស់រយៈពេល៥០ឆ្នាំកន្លងទៅនោះទេ ។ នៅពេលគ្មាន ប៉ុល ពត ចលនាខ្មែរក្រហមបានរលំរលាយទៅដោយបន្សល់ទុកនូវទាហានចាស់ៗពីរបីនាក់នៅក្នុងព្រៃ ស្ថានីយ៍វិទ្យុគ្មានអ្នកស្តាប់ និងតំណែងដឹកនាំគ្មានអ្នកណាគ្រប់គ្រង ។ **ដេវីដ អាស្លី**

# ឆ្មបខ្មែរសម័យក្រហម

តារាបជាឈ្មោះភូមិមួយស្ថិតនៅក្នុងឃុំជាងទង ស្រុកត្រាំកក់ ខេត្តតាកែវ ។ ក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ខេត្តតាកែវស្ថិតនៅក្នុងភូមិភាគនិរតីដែលមាន តាម៉ុក ជាអ្នកដឹកនាំ ។ ភូមិភាគនេះមានការសម្លាប់យ៉ាងរង្គៀល ។ អ៊ីស្រី អ៊ុង វុធ ជាអតីតឆ្មបកម្មាភិបាលខ្មែរក្រហម បច្ចុប្បន្នអ៊ីស្រី អ៊ុង វុធ


អ៊ុង វុធ

មានអាយុ៦០ឆ្នាំ ជាកូនទី៣នៃត្រកូលកសិករកណ្តាល រស់នៅជាមួយប្តីជាមេភូមិតារាបនិងម្តាយក្មេក ។ គាត់គ្មានកូនម្នាក់ឡើយ ។ អ៊ីស្រីប្រកបមុខរបរធ្វើស្រែចម្ការ និងធ្វើជាឆ្មបបង្កើតទារកនៅតាមភូមិម្តងម្កាលនៅពេលដែលអ្នកភូមិត្រូវការគាត់ ។ អ៊ីស្រីគឺជាពេទ្យឆ្មបដ៏ស្ទាត់ជំនាញម្នាក់តាំងពីទសវត្សរ៍ឆ្នាំ ១៩៦០ មកម្ល៉េះ ។

អ៊ីស្រី អ៊ុង វុធ បានចូលធ្វើជាពេទ្យឆ្មបប្រហែលនៅក្នុងឆ្នាំ១៩៥២ ។ កាលនោះគាត់ទើបមានអាយុ១៦ឆ្នាំ ហើយបានរៀនត្រឹមតែថ្នាក់ទី៥(ចាស់) ។ អ៊ីស្រីបានបម្រើការនៅតាមមន្ទីរពេទ្យភ្នំពេញចំនួនបីកន្លែងអស់រយៈពេល២៥ឆ្នាំ ។ ពីដំបូងឡើយ អ៊ីស្រីបានធ្វើការនៅមន្ទីរពេទ្យកេតុមាលា អស់រយៈពេល៣ឆ្នាំ ព្យាបាលជំងឺនិងបង្កើតទារក ។ ក្រោយពីចេះបង្កើតទារកស្ទាត់ហើយអ៊ីស្រីត្រូវបានបញ្ជូនមកធ្វើការនៅមន្ទីរពេទ្យចិនបានចំនួន៧ឆ្នាំផ្នែកខាងកូនង៉ែតដដែល ។ នៅឆ្នាំ(១៩៥៨)អ៊ីស្រីត្រូវបានផ្លាស់មកធ្វើនៅពេទ្យរុស្ស៊ីបានចំនួន១៥ឆ្នាំ ។ អ៊ីស្រីមានប្រសាសន៍ថាៈ គាត់ចូលធ្វើពេទ្យមិនមែនប្រលងចូលទេ គឺចូលតាមខ្សែរយៈពេទ្យ ដួន ជឿន ហៅ តាប៉ែន ដែលបានយកគាត់ទៅធ្វើនៅមន្ទីរពេទ្យទាំងនោះ ដោយមូលហេតុថា ដួន ជឿន, ខៀវសំផន, ហូនឹម, ហ៊ូយន់ និងឪពុកគាត់ធ្លាប់មានទំនាក់ទំនងនឹងគ្នា ។ អ៊ីស្រីបានប្រាប់ឲ្យដឹងថា «កាលណឹងក៏មានប្រវត្តិឪពុកខ្ញុំគាត់ខាង ដួន ជឿន អ៊ីចឹងដែរ ខ្សែរយៈគាត់ពីមុនមកចាស់ៗ» ចំណែក ខៀវ សំផន «កាលណឹងអត់មានប្រពន្ធទេ មកដេកផ្ទះឪពុកខ្ញុំ ក្រែដែកកញ្ចាស់អែ មកលាក់ខ្លួននៅផ្ទះឪពុកខ្ញុំ២-៥យប់ដែរ (នៅផ្សារអូឫស្សី) ស្នាក់នៅបួនប្រាំថ្ងៃ ទើបរំដោះចេញ» ។

ដោយសភាពការណ៍ជ្រួលច្របល់នៅឆ្នាំ១៩៧០ មុនរដ្ឋប្រហារមួយខែ អ៊ីស្រីចាកចេញពីក្រុងភ្នំពេញមកជាមួយ ដួន ជឿន ជាមួយនិងបុគ្គលិកពេទ្យប្រហែលជាង៨០នាក់ បានរត់ចូលព្រៃតាមផ្លូវជាតិលេខ៣ឆ្ពោះទៅស្ទឹងឪរ៉ាល់ ខេត្តកំពង់ស្ពឺ (តំបន់១៣) តាមមុខសញ្ញាដែលបានកំណត់ទុក ។ អ៊ីស្រី បាននិយាយថា «កាលដែលចេញពីទីក្រុងគ្មានអារម្មណ៍ថាស្តាយទីក្រុងទេ ព្រោះត្រូវគេបំពាក់បំប៉នពេញហើយ» ។ «ដួន ជឿន បានឃោសនាណែនាំថា ចង់ទាមទារសិទ្ធសេរីភាព ដូចថាពីមុនមកធ្លាប់គេជិះជាន់អ៊ីចឹងគេឲ្យយើងទៅពេទ្យជនបទយកចិត្តទុកដាក់នៅជនបទ»...«សីហនុ អ៊ីហ្នឹងឥឡូវទៅព្រៃអស់ហើយ ហើយឥឡូវនេះគេចង់ទាមទារឲ្យប្រជាជនឆ្លងផុតពីការជិះជាន់» ។ ពេលទៅដល់ស្ទឹងឪរ៉ាល់ អ៊ីស្រីបានឃើញ តាម៉ុក និងខៀវសំផន ហូនឹម និង ហ៊ូយន់ នៅទីនោះ ។ តាម៉ុក, ខៀវ សំផន ធ្លាប់បានប្រជុំណែនាំបំផុសស្មារតីដល់បុគ្គលិកពេទ្យទាំងអស់ឲ្យខិតខំតស៊ូរំដោះប្រជាជនដែរ ។ អ៊ីស្រីបានធ្វើជាពេទ្យនៅកន្លែងវះកាត់នៅឪរ៉ាល់បានប្រហែលមួយខែ ទើបមានប្រជុំមូលបែងចែកបុគ្គលិកទៅតាមខេត្តនានា អ៊ីស្រីត្រូវបានចាត់តាំងឲ្យមកធ្វើនៅពេទ្យភាគ(ហៅពេទ្យ២២) ។ ប្រហែលជាឆ្នាំ១៩៧៣-១៩៧៤

ដោយសារនៅតំបន់១៣ខ្វះបុគ្គលិកពេទ្យ អ៊ឹស្រីត្រូវអង្គការស្នើគាត់ពី ដួន ជឿន ឲ្យទៅធ្វើពេទ្យឆ្មបនៅទីនោះ ។ ប៉ុន្តែមុននឹងបានចូលធ្វើការងារពេទ្យនៅតំបន់១៣ អ៊ឹស្រីត្រូវអង្គការដាក់លក្ខខណ្ឌយ៉ាងតឹងរ៉ឹង អំពីការធានាជីវិតរបស់ម្តាយទារក ។ អ៊ឹស្រីមានប្រសាសន៍ថា «គេកំហិតយើងខ្លាំងណាស់ បើអ្នកឯងបង្កើតកូនង៉ើត ហើយអ្នកឈឺពោះហ្នឹងសុខភាពល្អ ប៉ុន្តែអ្នកឯងបង្កើតមកម្តាយឬទារកនោះស្លាប់នៅលើដៃឆ្មប យកឆ្មបដាក់គុក» អ៊ឹស្រីបានប្រកែកវិញថា «ខ្ញុំធ្វើបានលុះត្រាតែខ្ញុំអត់ប្រើថ្នាំអាចម៍ទន្សាយទេ ខ្ញុំប្រើពីនាយ សេរ៉ូមក៏ប្រើពីនាយ ហ្នឹងបានខ្ញុំអាចធ្វើជូនបាន ដល់អ៊ីចឹងគេឲ្យប្រើ ដើម្បីគេយកយើងបង្រៀនអ្នកមកពីគ្រប់ឃុំ» ។ នៅមន្ទីរពេទ្យតំបន់១៣នេះ អ៊ឹស្រីមានតួនាទីជាប្រធានពេទ្យឆ្មបដើរបង្កើតកូនង៉ើតទាំងគ្រប់ភូមិឃុំ និងជាគ្រូពេទ្យដ៏ស្ទាត់ជំនាញម្នាក់សម្រាប់បុគ្គលិកថ្មីៗដែលបញ្ជូនមកពីភូមិឃុំ នៅក្នុងខេត្តតាកែវ ។ ប៉ុន្តែការបង្រៀននេះមិនមានទ្រឹស្តីទេ គឺអនុវត្តផ្ទាល់តែម្តង ។

អ៊ឹស្រីជាមនុស្សខ្មស្សរាហ៍ណាស់ គាត់ធ្វើគ្រប់បែបយ៉ាងដើម្បីយកចិត្តគណៈស្រុក-ឃុំនិងប្រធានភូមិ ។ អ៊ឹស្រីមិនត្រឹមតែជាឆ្មបនៅក្នុងមន្ទីរពេទ្យទេ អ៊ឹស្រីត្រូវធ្វើឆ្មបនៅតាមភូមិផ្សេងៗទៀត ។ គាត់តែងតែទទួលបាននូវការកោតសរសើរពីគណៈស្រុក-ឃុំអំពីស្នាដៃរបស់គាត់ ព្រោះតាំងពីចេះបង្កើតកូនង៉ើតមក គាត់មិនដែលធ្វើម្តាយរបស់ទារកឬទារកត្រូវបាត់បង់ជីវិតម្នាក់ឡើយ ។ អ៊ឹស្រីមានប្រសាសន៍ថា «គណៈស្រុក គណៈឃុំសរសើរខ្ញុំណាស់ ថាជាមនុស្សសកម្មការងារ» ។ ប៉ុន្តែអ៊ឹស្រីក៏ត្រូវបានទិតៀនច្រើនណាស់ដែរ ដូចជាពាក់អាវដៃវែងអង្គការថាខុសគោលការណ៍បដិវត្តន៍ អ៊ឹស្រីពាក់អាវដៃខ្លី ។

អ៊ឹស្រីបានរៀបការនៅឆ្នាំ១៩៧៧ ។ តាម៉ុក ជាអ្នករៀបចំឲ្យ ។ រឿងរៀបការនេះ អ៊ឹស្រីនិយាយទាំងសើចថាកាលណោះប្រកែកនឹងអង្គការពុំព្រមទទួលទេ មិនទាន់ចង់បាន ប៉ុន្តែអង្គការបានយកឡានកាត់ចិនមកដឹកគាត់ទៅមន្ទីរប្រាប់ថាទៅជប់លៀងនៅទីរួមខេត្ត(តាកែវ)ជាកន្លែងប្រជុំធំ ពេលទៅដល់ទើបដឹងថាអង្គការចាប់យកមករៀបការ ។ ពេលរៀបការហើយ អ៊ឹស្រីពុំបាននៅជាមួយគ្នាទេ អ៊ឹស្រីនិយាយថា «រៀបការហើយមិនទាន់ត្រូវគ្នាទេ យូរណាស់ ហើយអង្គការចេះតែធ្វើសតិអារម្មណ៍ជាមួយឲ្យព្រមព្រៀងស្រឡាញ់គ្នាទៅ» ។ ក្រោយមកអ៊ឹស្រីបានស្នើអង្គការទៅរៀនផ្នែកបច្ចេកទេសរបៀបយកទារកនៅពេទ្យ១៧មេសា នៅភ្នំពេញ(ពេទ្យរុស្ស៊ី)សម្រាប់រយៈពេល១ឆ្នាំ ប៉ុន្តែបានតែ៦ខែត្រូវគណៈតំបន់ហៅមកវិញ ធ្វើសតិអារម្មណ៍អំពីរឿងគ្រួសារ ដោយសារតាំងពីរៀបការរួចមិនដែលបានជួបមុខគ្នាសោះ ។ អ៊ឹស្រីបានប្រាប់ថាគាត់ព្រមដាក់ចិត្តស្រឡាញ់ប្តីរបស់គាត់នោះ គឺនៅពេលដែលអង្គការយកអ៊ឹស្រីមកដាក់នៅមន្ទីរឃុំឃាំងភ្នំសន្ទុងចុងឆ្នាំ១៩៧៧ ដោយបំភ័ន្តថាឲ្យមករៀនសូត្រ ហើយប្តីរបស់អ៊ឹស្រីត្រូវអង្គការយកទៅធ្វើជីវទស្សន៍ខ្ទង់ឯង១យប់ ដោយបានស្នើឲ្យប្តីរបស់អ៊ឹស្រីលែងអ៊ឹស្រីចោលរួចហើយថាអង្គការនឹងរៀបការប្រពន្ធឲ្យមួយទៀត ។ ពេលនោះប្តីរបស់អ៊ឹស្រីប្រកែកមិនព្រម សុខចិត្តវេចបង្វេចរួចឡើងកង់តាមមកជាប់នៅមន្ទីរឃុំឃាំងសន្ទុងដែរ(នៅកងខុសគ្នា) ។ អ៊ឹស្រីបានប្រាប់ដែរថា គាត់ជាប់ឃុំនៅភ្នំសន្ទុងនេះគឺមកពីអង្គការចោទថាឪពុកម្តាយរបស់គាត់ជាប់ពាក់ព័ន្ធខ្សែបដិវត្តក្បត់ពីមុន ហើយបងប្អូនដែលពាក់ព័ន្ធត្រូវចាប់ទាំងអស់ ។ អ៊ឹស្រីបន្តថា តាម៉ុក ជាអ្នករៀបការឲ្យគាត់ ហើយ តាម៉ុក ក៏ជាអ្នកចាប់ឪពុកម្តាយគាត់ទៅដាក់គុកដែរ ។ អ៊ឹស្រីដឹងថា ការសម្លាប់មនុស្សទាំងខ្សែៗគឺតាម៉ុកតែម្តង ។ តាម៉ុក ជា«មនុស្សសម្តីផ្អែម» ។ និយាយដល់ចំណុចនេះ អ៊ឹស្រីទឹកភ្នែករលីងរលោងនិយាយទាំងអួលដើមកថា «បងប្អូនខ្ញុំទាំងអស់ ស្លាប់ទាំងអស់ អត់មានពូជណាមួយ ១២នាក់ទាំងឪពុកម្តាយ...នៅតែខ្ញុំមួយណឹង» ។ បងប្អូនរបស់អ៊ឹស្រីតែសុទ្ធធ្វើពេទ្យដែរ អ៊ឹស្រីនៅចាំច្បាស់ថា អ្នកដែលចាប់អ៊ឹស្រីមកឈ្មោះ ខែម ។

អ៊ឹស្រីបានរៀបរាប់ហេតុការណ៍នៅសន្ទុងថាៈ នៅមន្ទីរសន្ទុងមានបង្កើតជាកងរយ និងកង...ភាគច្រើនអ្នកដែលចាប់មកច្រើនតែអ្នកចាស់ កងទ័ពមកទាំងកងៗ កងចល័ត ដោយសារមានជាប់ខ្សែក្បត់ ហើយនៅក្នុងមន្ទីរសន្ទុងមានគុកមួយទៀត គុកនោះសម្រាប់តែអ្នកទោសដែលមានកំហុសខ្លាំងនៅក្នុងសន្ទុងនោះទើបបានចូល ប្រសិនបើបានចូលគុកនោះហើយតែ៥-៧ថ្ងៃគឺត្រូវយកទៅសម្លាប់ហើយ ។ នៅជុំវិញរោងរបស់កងនីមួយៗ

សុទ្ធតែរណ្ដៅដែលកាប់ទុកជាស្រេច “មួយយប់ៗ ពួសួរតែយ៉ូយ ជួយផង តែពីរដងគឺបាត់ហើយ ព្រឹកឡើងមើលស្នាមហ្នឹងហើយ តែមិនមាននរណាម្នាក់ហ៊ាននិយាយទេ” ។ អ្នកទោសនៅទីនោះ គេឲ្យវៃថ្ម ប្រសិនបើនារី១៧មេសាវិញ ដង្ហើមលោតដ្ដិកៗ ឲ្យលើកដីមួយម៉ែត្រគូបក្នុងមួយថ្ងៃ....មិនធម្មតាទេ វេទនាណាស់ សល់តែឆ្អឹង បើស្លឹកគ្រប់វិញសល់តែធាង បេះជ្រលក់អំបិល បើគេដឹងគេវៃញាត់មាត់ ដូចនេះវេទនាណាស់ កូនកង្កែបយើងយកមកគាបអាំងដោយលួចលាក់ បើគេឃើញផ្សែងហុយៗទៅ ឃើញអ្នកអាំងហ្នឹង យកកូនកង្កែបឆៅញាត់មាត់” ។ ចំណែកខ្លួនអ៊ំស្រីវិញពីដំបូងខ្មែរក្រហមឲ្យធ្វើពលកម្មដាំដំណាំ បន្ទាប់មកឲ្យព្យាបាលជំងឺអ្នកទោសនៅក្នុងមន្ទីរឃុំឃាំងមិនឲ្យចេញមកក្រៅទេ ក្រោយមកបញ្ជូនឲ្យទៅច្រូតស្រូវ បោកស្រូវ ។ អ៊ំស្រីនិយាយថា “កាលណឹង ខ្ញុំមានបេះកាន់តម្បៀតណាបោកដៃ...វាថាបោកដៃបោកអីចឹងស្មើម៉ានហើយ តិចមួយតម្បៀតឥឡូវ” ។ “ខ្ញុំតវ៉ាជាមួយវាខ្លាំងណាស់ ខ្ញុំតាំងចិត្តហើយមុននឹងខ្ញុំងាប់ បងប្អូនខ្ញុំងាប់អស់ហើយ បើហ៊ានតែវាយខ្ញុំមួយតម្បៀត មួយដងវែកដាក់ចំកំភួនជើងទាល់តែដួល ខ្ញុំតាំងចិត្តអីចឹងម៉ង” ។ ក្រោយមកទៀតអ៊ំស្រីត្រូវខ្មែរក្រហមយកទៅពិសោធន៍ជាច្រើនកន្លែងឆ្អាលនឹងយកលេសចាប់កំហុស ។ អ៊ំស្រីបានមានប្រសាសន៍ថា គេឲ្យ “ខ្ញុំទៅលីនជាយក្រមាដែលនៅតាមកងមួយថ្ងៃឲ្យហើយក្រមា ១០០ បន្ទាប់មកទៀតដេរខោរឹតបែកឲ្យយុទ្ធជនឲ្យបាន១០០ ក្នុងមួយថ្ងៃ...ខ្ញុំលីនទាល់តែបានហ្នឹង ដើងបេសធានា...ខ្ញុំធ្វើទាល់តែបាន បើកាលណាមិនហើយគេធ្វើទោសយើង...ដល់ធ្វើអីខ្ញុំមិនបាន យកខ្ញុំទៅដាក់កន្លែងពេទ្យវិញ” ។ អ៊ំស្រីក៏ត្រូវបញ្ជូនមកពេទ្យសន្ទុងវិញបាន២-៣ខែវៀតណាមរំដោះ ។ កាលនោះអ៊ំស្រីបេះតែរត់ទៅជាមួយមេៗធ្លាក់ទៅដល់កោះកុងបានត្រឡប់មកក្រោយធ្វើដំណើរតាមច្រកពេជ្រនិល ចុងបញ្ចប់បានមកដល់ស្រុកកំណើតវិញ ។ អ៊ំស្រីនិយាយទៀតថា ការខិតខំបម្រើអង្គការបដិវត្តអស់ពីកម្លាំងកាយចិត្តរបស់គាត់ លទ្ធផលចុងក្រោយអង្គការបដិវត្តន៍បានផ្ដល់ឲ្យគាត់នូវរង្វាន់ចាស់ដៃ គឺបាត់បង់នូវគ្រួសារដ៏កក់ក្ដៅមួយដែលមានឪពុកម្ដាយបងប្អូន១០នាក់និងក្មួយម្នាក់ ឯខ្លួនគាត់ត្រូវជាប់ឃុំឃាំង ។ រឿងទាំងនេះហើយដែលធ្វើឲ្យអ៊ំស្រីចាំមិនភ្លេចហើយនិយាយថា “ខ្ញុំឆ្អែតចិត្តលែងយល់លែងពូអ៊ីទៀតហើយទោះជាមានអ្នកដឹកត្រចៀកឲ្យខ្ញុំទៅខាងណាៗខ្ញុំលែងទៀតហើយ ទោះអតីតខ្មែរក្រហមដែលនៅអន្លង់វែងហៅទៀតក៏មិនទៅដែរ” ។ អ៊ំស្រីបញ្ជាក់ប្រាប់ថា រឿងដែលអ៊ំស្រីឈឺចាប់បំផុតគឺការបាត់បង់សមាជិកគ្រួសារប៉ុណ្ណោះ ចំណែករឿងដែលថាខ្លាចប្រជាជនស្អប់នោះ គាត់មិនខ្លាចទេ ព្រោះគាត់ធ្វើល្អប្រជាជនស្រឡាញ់គាត់គ្រប់គ្នាទៅណាក៏អ្នកស្រុករាប់អានដែរ ។ បើនៅសន្ទុងវិញ នរណាក៏និយាយដែរថាដើមស្វាយខ្ទុរ... ដែលនៅដុះរហូតមកដល់បច្ចុប្បន្ននេះ “គឺកេរដំណែលរបស់ពេទ្យវុធ!!” ព្រោះអ៊ំស្រីជាអ្នកដាំ ។ **លី សុផល**

---

**(តមកពីទំព័រ៣៨)** “ហើយនិងច្បាប់ក្រុមប្រឹក្សាឆ្នាំ១៩៧៤នៃកតិកាសញ្ញាអឺរ៉ុប” ស្ដីអំពីបញ្ហាដូចគ្នានេះដែរ ។ ថ្វីបើប្រទេសមួយចំនួនតូចដែលប្រកាន់ខ្ជាប់នូវកតិកាសញ្ញាទាំងអស់នេះលើកឡើងថា ការលុបចោលនូវដែនអាជ្ញាយុកាលគឺនៅមិនទាន់ត្រូវបានទាមទារឲ្យមានជាទំនៀមទម្លាប់នៅឡើយ យ៉ាងណាក៏ដោយ ក៏ការអនុវត្តរបស់ប្រទេសនានាគាំទ្រដល់សំណើដែលថាការលុបចោលនូវដែនអាជ្ញាយុកាលនោះយ៉ាងហោចណាស់ក៏ត្រូវអនុញ្ញាតហើយថានឹងមិនប្រឆាំងនឹងបទដ្ឋានច្បាប់ ។

ចំពោះបញ្ហាច្បាប់ក្នុងស្រុក ប្រទេសនានាបានអនុម័តនូវស្ថានភាពខុសៗគ្នាស្ដីពីការពន្យារពេលឬលុបចោលនូវដែនអាជ្ញាយុកាលចំពោះឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តកាលពីអតីតកាល “រួមទាំងឧក្រិដ្ឋកម្មទាំងឡាយណាដែលដែនអាជ្ញាយុកាលបានផុតកំណត់រួចហើយ” រំលោភទៅលើគោលការណ៍ច្បាប់ក្នុងស្រុកស្ដីពីអប្រតិសកម្ម ។ សាលាវិនិច្ឆ័យនៅក្នុងប្រទេសបារាំង បានសម្រេចថាច្បាប់ឆ្នាំ១៩៦៤ របស់បារាំងដែលលុបចោលនូវដែនអាជ្ញាយុកាលចំពោះឧក្រិដ្ឋកម្មសង្គ្រាមប្រឆាំងនឹងមនុស្សជាតិអាចអនុវត្តដោយប្រតិកម្មអនុញ្ញាតឲ្យនាំ បាប៊ីយកមកកាត់ទោស ថ្វីបើដែនអាជ្ញាយុកាលសម្រាប់ឃាតកម្មបានផុតកំណត់មុនការអនុម័តច្បាប់ឆ្នាំ១៩៦៤ក៏ដោយ ។ ហេតុដូច្នេះបញ្ហានេះក៏អាចទទួលបានការគាំទ្រពីសំណាក់តុលាការកម្ពុជាដែរ ។

**អេលីហ្សាប៊ែត វ៉ាន់ស្វាក់**

## លោកនាយកជាទីគោរព

ខ្ញុំបាទបានទទួលនូវទស្សនាវដ្តី«ស្វែងរកការពិត» ជារៀងរាល់ខែ ដើម្បីចែកជូននិស្សិតអាននិងស្វែងយល់ ហើយក៏ដូចជារូបខ្ញុំផ្ទាល់ ។ ខ្ញុំបានទទួលនូវពុទ្ធិយ៉ាងច្រើនអំពីរបបដ៏ព្រៃផ្សៃមួយតាមរយៈទស្សនាវដ្តីនេះ ដែលបានបំផុសនូវឆន្ទៈរបស់ខ្ញុំឲ្យកាន់តែនៅចងចាំនូវរឿងរ៉ាវគួរឲ្យជូរចត់បំផុតមកលើប្រជារាស្ត្រខ្មែរ ដោយសារកំហឹងទាំងនេះបានជំរុញឲ្យខ្ញុំត្រូវតែចូលរួមចំណែកជាមួយលោកនាយក ។ ទោះបីជាខ្ញុំដឹងថានេះជាវិភាគទានដ៏តូចបំផុតសម្រាប់លោកក៏ដោយ ក៏នេះជាសន្តានចិត្តដ៏ស្មោះរបស់ខ្ញុំដើម្បីរួមចំណែក និងជាពន្លឺជូនដល់ការស្រាវជ្រាវរបស់ក្រុមលោក ។

ខ្ញុំជាអ្នកភូមិម្នាក់ដែលរស់នៅភូមិតារាម ឃុំត្បែង ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ។ កាលពីចូលឆ្នាំចិនកន្លងមកនេះខ្ញុំបានទៅលេងស្រុកកំណើត ខ្ញុំបានសាកសួរបងខ្ញុំខ្លះៗ អ្នកជិតខាងខ្លះ និងអ្វីដែលខ្ញុំធ្លាប់ឃ្វាលគោកាលពីតូច និងបានឃើញនឹងភ្នែកផ្ទាល់ ។ ខ្ញុំសូមជម្រាបជូនលោកនាយកថា នៅខាងជើងភូមិខ្ញុំប្រហែល២គីឡូម៉ែត្រមានវត្តមួយដែលត្រូវបាក់បែកខ្ទេចខ្ទី ដោយថានៅទីវត្តទាំងមូលកាលពីរបបវាលពិឃាតវត្តនោះមានឈ្មោះថា «វត្តស្រង៉ែ» ដែលស្ថិតនៅក្នុងភូមិស្រង៉ែ ឃុំត្បែង ស្រុកំពង់ស្វាយខេត្តកំពង់ធំ ។ តាមការសាកសួររបស់ខ្ញុំ ប្រជាជនដែលត្រូវសម្លាប់នៅទីនោះប្រហែលពី៨០០ទៅ១០០០នាក់ភាគច្រើនអ្នកទាំងនោះជាអ្នក១៧ មេសា មកភូមិភាគបូព៌ា និងប្រជាជនថ្មី ។ តាមការសាកសួរបានឲ្យដឹងថាមេមន្ទីរសន្តិសុខនេះឈ្មោះ សមមិត្ត សក់ដែលស្លាប់នៅចុងឆ្នាំ១៩៧៩ ដោយរដ្ឋអំណាចភូមិឃុំជាអ្នកកាត់ទោស ។ ប៉ុន្តែសព្វថ្ងៃនេះមានសមាជិកសន្តិសុខម្នាក់នៅរស់រាននៅឡើយ គឺនៅភូមិកកោះ ក្នុងស្រុកសន្ទុក ចំណែកឯអតីតប្រធានឃុំត្បែងនាសម័យប៉ុលពតនោះ សព្វថ្ងៃនេះគាត់រស់នៅភូមិជាមួយខ្ញុំនេះដែរ គាត់មានអាយុប្រហែល៩០ឆ្នាំ ហើយមានប្តីមានកូន ។

ជាអវសាននៃលិខិតនេះ ខ្ញុំសូមសុំអភ័យទោសពីលោកនាយកនូវពាក្យពេចន៍និងសូមជូនពរឲ្យលោកនាយកនិងសហការីរបស់លោកបានជោគជ័យនូវរាល់ការងារគ្រប់យ៉ាង ព្រមទាំងជួបតែនឹងពុទ្ធពរទាំងប្រាំប្រការកុំបីឃ្លាតឡើយ ។ **គី សុផល**





ដើម្បីឧបត្ថម្ភការបោះពុម្ពនិងចែកចាយដោយឥតគិតថ្លៃដល់មន្ទីរស្រុក និងឃុំ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា
ទស្សនាវដ្តីចំនួន១០០០ច្បាប់ជារៀងរាល់លេខនីងដាក់លក់តែនៅក្នុងរាជធានីភ្នំពេញប៉ុណ្ណោះ មួយច្បាប់ក្នុងតម្លៃ ៧០០០រៀល

មជ្ឈមណ្ឌលឯកសារកម្ពុជាអំពាវនាវដល់រដ្ឋាភិបាល មូលនិធិនានា និងសាធារណជនគ្រប់រូប សូមជួយឧបត្ថម្ភការបោះពុម្ពផ្សាយទស្សនាវដ្តីនេះទៅតាមលទ្ធភាពដែលអាចធ្វើបាន។ ពត៌មានបន្ថែមចំពោះការបោះពុម្ពផ្សាយទស្សនាវដ្តីស្វែងរកការពិត សូមមេត្តាទាក់ទងមកកាន់នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមទូរស័ព្ទលេខ (៨៥៥) ២៣ ២១១ ៨៧៥។ សូមអរគុណ!

The Documentation Center of Cambodia would like to appeal to governments, foundations and individuals for support of the publication of Searching for the Truth!. For contribution, please contact (855) 23 211 875 or By Email: dccam@bigpond.com.kh. Thank you.

A magazine of the Documentation Center of Cambodia: Searching for the Truth! Number 18, June 2001.
Funded by the Royal Ministry of Foreign Affairs, Oslo, Norway, Section for the Human Rights and Humanitarian Assistance; Canadian International Development Agency (CIDA) through the Civil Society Fund, the Swedish International Development Cooperation Agency(Sida); the Royal Danish Government and the Royal Netherlands Government, *The Hague*.